The Asia Foundation

# ការរៀនសូត្រពីការអនុវត្ត អភិបាលកិច្ចល្អ
# នៅថ្នាក់ ក្រុង ស្រុក និងឃុំ សង្កាត់



pact building local promise.

# ថ្ងៃទី១

# ប្លង់មេរៀនទី១

# ចំណងជើងមេរៀនៈ ការណែនាំពីវគ្គបណ្តុះបណ្តាល

**ពេលវេលាៈ ០៨ៈ៣០ ដល់ ០៩ៈ៣០ (១ម៉ោង)**

**គោលបំណងនៃមេរៀនៈ** នៅចុងបញ្ចប់មេរៀននេះអ្នកចូលរួមនឹងអាចៈ

១. ពន្យល់បានពីគោលបំណង និងលទ្ធផលរំពឹងទុករបស់គម្រោង

២. រៀបរាប់ពីគោលបំណងរបស់វគ្គបណ្តុះបណ្តាល ការបញ្ជាក់ពីលទ្ធផលរំពឹងទុករបស់អ្នកចូលរួមនិងមូលហេតុនៃការ បង្កើតឱ្យមានវគ្គបណ្តុះបណ្តាលនេះឡើង

៣. ធ្វើតេស្តសាកល្បងមុនវគ្គបណ្តុះបណ្តាល

**កំណត់ចំណាំរបស់អ្នកសម្របសម្រួល**

១. បញ្ជាក់ឱ្យបានច្បាស់លាស់ជាមួយអ្នកចូលរួមអំពីគោលបំណងជាក់លាក់ និងលទ្ធផលរំពឹងទុករបស់គម្រោង ស្តីពីការ រៀនសូត្រពីការអនុវត្តគម្រោងអភិបាលកិច្ចល្អនៅថ្នាក់ក្រុង ស្រុក ឃុំ និងសង្កាត់ ដោយមានការសហការ និងគាំទ្រ ពីការិយាល័យសម្របសម្រួលគម្រោងអភិបាលកិច្ចល្អរបស់ក្រសួងមហាផ្ទៃ (PCO)

២.បកស្រាយពីសារៈសំខាន់ និងគោលបំណងរបស់វគ្គបណ្តុះបណ្តាលដែលឆ្លើយតបនឹងគោលបំណងរបស់គម្រោង

៣.បញ្ជាក់ឱ្យបានច្បាស់ពីសេចក្តីរំពឹងទុក របស់អ្នកចូលរួមដែលឆ្លើយតបទៅនឹងវគ្គបណ្តុះបណ្តាលរយៈពេល៣ថ្ងៃនេះ

៤. ជួយឱ្យអ្នកចូលរួមបានយល់ដឹងពីវគ្គបណ្តុះបណ្តាល ស្តីពីការលើកកម្ពស់ការអនុវត្តអភិបាលកិច្ចល្អនៅថ្នាក់ក្រុង ស្រុក ឃុំ និងសង្កាត់ដែលមានមេរៀនចំនួន៣ជំពូកៈ

**ជំពូកទី១៖** មូលដ្ឋានគ្រឹះរបស់គណនេយ្យភាពសង្គម

**ជំពូកទី២៖** ការភ្ជាប់ទំនាក់ទំនងជាមួយប្រជាពលរដ្ឋ

**ជំពូកទី៣៖** ការទំនាក់ទំនងតាមរយៈគណនេយ្យភាពសង្គមដើម្បីប្រសិទ្ធភាពនៃភាពជាដៃគូ

៥.ប្រមូលតេស្តមុនវគ្គដែលបានបំពេញរួច និងទុកសម្រាប់ធ្វើសេចក្តីសង្ខេប ចំណែកតេស្តក្រោយវគ្គនឹងធ្វើនៅថ្ងៃទី៣

៦. អ្នកសម្របសម្រួលត្រូវដើរតាមប្លង់មេរៀនទាំងស្រុងសម្រាប់ក្រុមប្រឹក្សាថ្នាក់ស្រុក/ក្រុង តែសម្រាប់ក្រុមប្រឹក្សាឃុំ/សង្កាត់គឺគ្រាន់តែរំលឹកឡើងវិញបានហើយ ។

**លទ្ធផលរំពឹងទុកនៃមេរៀន**

ក. អ្នកចូលរួមអាចរៀបរាប់បានពីគោលបំណង និងលទ្ធផលរំពឹងទុកនៃគម្រោងទាំងមូល

ខ. អ្នកចូលរួមអាចរៀបរាប់ពីគោលបំណងរបស់វគ្គ ហើយឆ្លើយតបទៅនឹងការរំពឹងទុករបស់ខ្លួន

គ. កចូលរួមអាចរៀបរាប់ពីសារៈសំខាន់របស់វគ្គបណ្តុះបណ្តាលឆ្លើយតបទៅនឹងគោលបំណងរបស់គម្រោង

## សម្ភារឧបទេសសម្រាប់មេរៀនៈ

- ឯកសារចែកជូនៈ
  - បទបង្ហាញស្តីពីគោលបំណង និងលទ្ធផលរំពឹងទុករបស់គម្រោង និងកាលវិភាគនៃវគ្គបណ្តុះបណ្តាល
- ហ្វឹតសរសេរក្រដាស ក្រដាសផ្ទាំងធំ ស្កុត
- កុំព្យូទ័រយួរដៃ និងម៉ាស៊ីនបញ្ចាំងឯកសារ
- សឺមីសម្រាប់ដាក់ឯកសារអ្នកចូលរួម

## ឯកសារយោង

- ឯកសារគម្រោង

## របៀបសម្របសម្រួលមេរៀន

| ម៉ោង | សកម្មភាព និងវិធីសាស្ត្រ | សម្ភារ និងឯកសារចែកជូន |
|---|---|---|
| ៥ នាទី | សកម្មភាពទី១៖ ការស្វាគមន៍ដល់អ្នកចូលរួម<br>▪ ការស្វាគមន៍ពីអ្នកសម្របសម្រួលដល់អ្នកចូលរួមទាំងអស់ពីការចំណាយពេលវេលារបស់ពួកគាត់ដើម្បីមកចូលរួមបណ្តុះបណ្តាលនេះ និងសំណេះសំណាលពីសុខទុក្ខផ្សេងៗ ។ល។ | |
| ១០នាទី | សកម្មភាពទី២៖ **ការណែនាំខ្លួន**<br>ដើម្បីឱ្យវគ្គបណ្តុះបណ្តាលអាចដំណើរការទៅបានដោយរលូន និងប្រកបដោយភាពស្និតស្នាលអ្នកចូលរួមទាំងអស់ត្រូវចូលរួមចំណែកក្នុងការចែករំលែកគំនិតយោបល់ឱ្យគ្នាទៅវិញទៅមក ។ មុននឹងចាប់មេរៀន យើងគួរណែនាំឱ្យមានការស្គាល់គ្នាជាមុនសិន ។<br>▪ សូមឱ្យមានការបង្ហាញខ្លួនតាមលំដាប់ពីឈ្មោះ តួនាទី អង្គភាព ឬអញ្ជើញមកពីណា (បើអាចទៅរួចគួរចាប់ផ្តើមពី ក្រុមប្រឹក្សា គណៈអភិបាល បន្ទាប់មក អ្នកដែលពាក់ព័ន្ធដទៃទៀត) ។ | |
| ២០នាទី | សកម្មភាពទី៣៖ ព័ត៌មានគម្រោង និងវគ្គបណ្តុះបណ្តាល<br>**ការពិភាក្សាក្រុមធំ**<br>▪ បទបង្ហាញពីគោលបំណង និងលទ្ធផលរំពឹងទុករបស់គម្រោង | ▪ បទបង្ហាញ<br>▪ កាលវិភាគលើក្រដាសផ្ទាំងធំ |

| | | |
|---|---|---|
| | ▪ អ្នកចូលរួមសរសេរពីលទ្ធផលរំពឹងទុកម្នាក់មួយនៅលើក្រដាស់តូច<br>▪ ពន្យល់ពីគោលបំណងនៃវគ្គបណ្តុះបណ្តាលរយៈពេលចំនួន៣ថ្ងៃ និងផ្គូរផ្គង់ទៅនឹងការរំពឹងទុករបស់អ្នកចូលរួមដោយទុកឱកាសឱ្យអ្នកចូលរួម ២ ឬ ៣ នាក់ដើម្បីបញ្ជាក់ថាតើការរំពឹងទុករបស់គាត់បានឆ្លើយតបទៅនឹងបំណងរបស់វគ្គដែរឬទេ?<br>▪ បង្ហាញពីកាលវិភាគទាំង៣ថ្ងៃ និងឯកភាពលើពេលសម្រាក ចូល និងចេញ<br>▪ ការរៀបចំវិន័យសម្រាប់ថ្នាក់រៀនៈ ដើម្បីឱ្យវគ្គបណ្តុះបណ្តាលដំណើរការបានទៅដោយរលូនយើង គួរមាន វិន័យសម្រាប់ថ្នាក់<br>▪ អ្នកសម្របសម្រួលកត់ត្រារាល់យោបល់របស់អ្នកចូលរួមទាំងអស់ក្នុងការរៀបចំវិន័យសម្រាប់វគ្គបណ្តុះបណ្តាលរយៈពេល៣ថ្ងៃនេះទៅលើ ក្រដាសផ្ទាំងធំ ហើយត្រូវបិទនៅលើជញ្ជាំង | ▪ វិន័យសម្រាប់វគ្គបណ្តុះបណ្តាល<br>▪ ក្រដាសផ្ទាំងតូចៗ |
| ២០ នាទី | <u>សកម្មភាពទី៤៖</u>**ការធ្វើតេស្តមុនវគ្គៈ**<br>១.ចែកកំរងសំណួរតេស្តមុនវគ្គឱ្យអ្នកចូលរួមបំពេញ<br>២. ទុករយៈពេល២០នាទីសម្រាប់ការបំពេញសំណួរតេស្តមុនវគ្គនេះ | ▪ កំរងសំណួរតេស្តមុនវគ្គ |
| ០៥ នាទី | <u>សកម្មភាពទី៥៖</u>ការបូកសរុបមេរៀនទី១<br>បញ្ជាក់ឡើងវិញពីការយល់ដឹងរបស់អ្នកចូលរួមទៅលើគោលបំណង ជាក់លាក់របស់គម្រោងនិងគោលបំណងនៃវគ្គបណ្តុះបណ្តាលរយៈពេល៣ថ្ងៃនេះ។ | |

# ថ្ងៃទី១ មេរៀនទី១

# គោលបំណង និងលទ្ធផលរំពឹងទុករបស់គម្រោង

## ការរៀនសូត្រពីការអនុវត្ត អភិបាលកិច្ចល្អ នៅថ្នាក់ ក្រុង ស្រុក និងឃុំ សង្កាត់

សហការជាមួយការិយាល័យសម្របសម្រួលគម្រោង DFGG នៃក្រសួងមហាផ្ទៃ និងអង្គការផេកកម្ពុជា

# គោលដៅ

រួមចំណែកគាំទ្រដល់ការិយាល័យសម្របសម្រួលគម្រោង (PCO) ដើម្បីរៀនសូត្រតាមរយៈការភ្ជាប់ទំនាក់ទំនងជាមួយអភិបាលកិច្ចល្អនិងបង្កើនគណនេយ្យភាពសង្គមរបស់ក្រុង ស្រុក និងឃុំសង្កាត់។

# គោលបំណងទី១

- អភិវឌ្ឍសមត្ថភាព និងទំនុកចិត្តរបស់ប្រជាពលរដ្ឋ ក្រុមអង្គការសង្គមស៊ីវិលឱ្យសកម្មចូលរួមក្នុងការបញ្ចេញមតិយោបល់ពីសេចក្តីត្រូវការជាអាទិភាពរបស់ខ្លួននៅក្នុងសកម្មភាពអភិវឌ្ឍរបស់ក្រុង ស្រុក និងឃុំសង្កាត់

# គោលបំណងទី២

- លើកកម្ពស់ទំនាក់ទំនង និងភាពជាដៃគូឱ្យមានប្រសិទ្ធភាពរវាងក្រុមប្រឹក្សា ក្រុង ស្រុក ឃុំ សង្កាត់ និងប្រជាពលរដ្ឋដើម្បីបង្កើនតម្លាភាពគណ នេយ្យភាព និងសេវាកម្មដែលឆ្លើយតបទៅនឹងតម្រូវការ

# គោលបំណងទី៣

- គាំទ្រដល់ការិយាល័យសម្របសម្រួលគម្រោងអភិបាលកិច្ចល្អ DFGG ក្រសួងមហាផ្ទៃ ដើម្បី អប់រំផ្សព្វផ្សាយ និងរៀនសូត្រអំពីអភិបាលកិច្ចល្អ និងការអនុវត្តគណនេយ្យភាពសង្គមនៅក្នុងស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងទៀត

# សកម្មភាពចំបងៗ របស់គម្រោង

| កំរិត | សកម្មភាពជាក់លាក់ |
|---|---|
| ថ្នាក់ឃុំ សង្កាត់ | បណ្តុះបណ្តាល និងហ្វឹកហ្វឺនដល់ក្រុមប្រឹក្សាឃុំ សង្កាត់ អង្គការសង្គមស៊ីវិល ដើម្បីអនុវត្តៈ<br>• សកម្មភាពពិគ្រោះយោបល់មូលដ្ឋានដោយក្រុមប្រឹក្សាឃុំ សង្កាត់<br>• ដំណើរការកសាងផែនការ និងថវិកាដោយមានការចូលរួម<br>• កិច្ចប្រជុំប្រចាំខែរបស់ឃុំ សង្កាត់ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ |
| ថ្នាក់ក្រុង ស្រុក | បណ្តុះបណ្តាល និងហ្វឹកហ្វឺនក្រុមប្រឹក្សាក្រុង ស្រុក ប្រព័ន្ធផ្សព្វផ្សាយ<br>• លើកទឹកចិត្តឱ្យមានការចុះផ្ទាល់ទៅមូលដ្ឋានដើម្បីសង្កេតសកម្មភាពរបស់ប្រជាពលរដ្ឋ និងឃុំ សង្កាត់<br>• ដំណើរការកសាងផែនការ និងថវិកាដោយមានការចូលរួម<br>• ការប្រជុំប្រចាំខែរបស់ក្រុង ស្រុក វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ |

| កំរិត | សកម្មភាពជាក់លាក់ |
|---|---|
| ថ្នាក់ខេត្ត | សហការ និងធ្វើជាដៃគូដើម្បីគាំទ្រដល់ ក្រុង ស្រុក និងឃុំសង្កាត់<br>• លើកកំពស់ឱ្យមានការភ្ជាប់ទំនាក់ទំនាងជាមួយប្រជាពលរដ្ឋ<br>• ការផ្សព្វផ្សាយព័ត៌មានឱ្យបានទូលំទូលាយ<br>• បន្តលើកទឹកចិត្ត (ឱ្យហ៊ាន និងអាចនិយាយ ហើយចង់ចូលរួម) |
| ថ្នាក់ជាតិ | ផ្តល់ការគាំទ្របច្ចេកទេស ការគាំទ្រឱ្យមានការអភិវឌ្ឍសមត្ថភាព តាមដានត្រួតពិនិត្យ និងវាយតម្លៃ និងរៀបចំឯកសារពីបទពិសោធន៍ល្អៗ |

# លទ្ធផលរំពឹងទុករបស់គម្រោង

# លទ្ធផលរំពឹងទុកគោលបំណងទី១

១.១ លិខិតគាំទ្ររវាងអង្គការដៃគូ និងក្រុមប្រឹក្សាខេត្តដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ និងធ្វើឱ្យប្រសើរឡើងនូវការអនុវត្តអភិបាលកិច្ចល្អ គណនេយ្យភាពសង្គមនៅក្នុងក្រុង ស្រុក និងឃុំសង្កាត់គោលដៅ

១.២ រៀបចំ និងបណ្តុះបណ្តាលមេរៀនចំនួន៣ទៅក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធដទៃទៀត

# លទ្ធផលរំពឹងទុកគោលបំណងទី១

១.៣ បុគ្គលិកអង្គការដៃគូថ្នាក់ខេត្តបានទទួលចំណេះដឹង និងសមត្ថភាព ក្នុងការគាំទ្រដល់ក្រុមប្រឹក្សា ក្រុង ស្រុក ឃុំ និងសង្កាត់ក្នុងអំឡុងពេលអនុវត្តគម្រោង និងក្រោយពេលបញ្ចប់គម្រោង

១.៤ បង្កើនទំនុកចិត្ត និងការចូលរួមរបស់ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិលជាមួយសកម្មភាពអភិវឌ្ឍរបស់ក្រុង ស្រុក និងឃុំ សង្កាត់គោលដៅ

# លទ្ធផលរំពឹងទុកគោលបំណងទី២

២.១ក្រុមប្រឹក្សា ៣សង្កាត់ និង៦ឃុំ ក្នុង២ស្រុក១ក្រុងបានបង្កើនចំណេះដឹង និងសមត្ថភាពស្តីពីអភិបាលកិច្ចល្អ និងមូលដ្ឋានគ្រឹះនៃការអនុវត្ត គណនេយ្យភាពសង្គម និងបញ្ចូលទៅក្នុងសកម្មភាពអនុវត្តប្រចាំថ្ងៃ

២.២ ការអនុវត្តសកម្មភាពជាដៃគូ រវាងអង្គការសង្គមស៊ីវិលនិងក្រុង និងស្រុកគោលដៅដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ និងការអនុវត្ត គណនេយ្យភាពសង្គម

២.៣ ក្រុមប្រឹក្សា ៣សង្កាត់ និង៦ឃុំ ក្នុង២ស្រុក ១ក្រុងបានលើកកម្ពស់ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងសកម្មភាពធ្វើផែនការ និងថវិកា ក្នុងកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈដើម្បីដោះស្រាយបញ្ហាជាអាទិភាពរបស់ប្រជាពលរដ្ឋ និងសហគមន៍

# លទ្ធផលរំពឹងទុកគោលបំណងទី៣

៣.១ បានរៀបចំសេចក្តីព្រមព្រៀងតាមរយៈអនុស្សរណៈនៅថ្នាក់ជាតិដើម្បីលើកកម្ពស់ការរៀនសូត្រពីអភិបាលកិច្ចល្អ និងការអនុវត្តគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ

៣.២ ការិយាល័យសម្របសម្រួលគម្រោង DFGG នៃក្រសួងមហាផ្ទៃអាចទទួលបានចំណេះដឹងបន្ថែមពីការអនុវត្តអភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គមតាមរយៈការតាមដានការអនុវត្តគម្រោង និងសិក្ខាសាលាវាយតម្លៃឆ្លុះបញ្ចាំង

៣.៣ បទពិសោធន៍ល្អៗនៃការអនុវត្តត្រូវបានរៀបចំជាឯកសារដើម្បីជូនជាព័ត៌មានដល់ វេទិកាគណនេយ្យភាពសង្គម របស់គម្រោង DFGG នៃក្រសួងមហាផ្ទៃនិងស្ថាប័នរដ្ឋផ្សេងៗទៀត ។

# សំណួរ

# ការបំភ្លឺផ្សេងៗ

# ថ្ងៃទី១

# ប្លង់មេរៀនទី ២

## ចំណងជើងមេរៀនៈ ទស្សនទាននៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គម

**រយៈពេលៈ** (១០:00-១១:៣0) ៩0 នាទី

**គោលបំណងមេរៀនៈ** នៅចុងបញ្ចប់មេរៀននេះអ្នកចូលរួមនឹងអាចៈ

១.បកស្រាយបានពី**<u>អត្ថន័យ</u>** ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គម

២.ពន្យល់ពី**<u>មូលហេតុ</u>**នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គម

៣.រៀបរាប់ពី**<u>ក្របខណ្ឌច្បាប់គាំទ្រ</u>**ការអនុវត្តគណនេយ្យភាពសង្គមនៅកម្ពុជា

៤.កំណត់បានពី**<u>ទំនាក់ទំនងរ</u>**វាង អភិបាលកិច្ចល្អ គណនេយ្យភាពសង្គម និងការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យ និង

៥. កំណត់ពី**<u>ការប្រឈម</u>**នានាក្នុងការលើកកម្ពស់ (ការអនុវត្ត) អភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គម ។

**កំណត់ចំណាំរបស់អ្នកសម្របសម្រួល**

១.ជួយអោយអ្នកចូលរួមមើលឃើញកាន់តែច្បាស់ និងដឹងពីទំនាក់ទំនងរវាងអភិបាលកិច្ចល្អ ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យ និងគណនេយ្យភាពសង្គម

២.ជួយអោយអ្នកចូលរួមដឹងពីសកម្មភាព និងលទ្ធផលមួយចំនួនរបស់ក្រុមប្រឹក្សា ដែលរួមចំណែកលើកកម្ពស់ គណនេយ្យភាពសង្គម និងអភិបាលកិច្ចល្អដោយបកស្រាយពីសារៈសំខាន់នៃការចូលរួមផ្តល់ព័ត៌មានត្រឡប់ គណនេយ្យភាព តម្លាភាពពីសកម្មភាពទាំងនោះ (**វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ កិច្ចប្រជុំប្រចាំខែ ការផ្សព្វផ្សាយព័ត៌មានសាធារណៈ ចូលរួមក្នុងដំណើរការកសាងផែនការ និងថវិកា**)

៣.ជួយឱ្យអ្នកចូលរួមឆ្លុះបញ្ចាំងពីបញ្ហាប្រឈមនានាក្នុងការអនុវត្តសកម្មភាពខាងលើដោយក្រុមប្រឹក្សាថ្នាក់ ក្រោមជាតិក្នុងការលើកកម្ពស់គណនេយ្យភាពសង្គម ។

៤.អ្នកសម្របសម្រួលគួរយល់អោយបានច្បាស់ពីអត្ថន័យរបស់គោលការណ៍អភិបាលកិច្ចល្អទាំង ៨ ដែលបាន រៀបរាប់នៅក្នុងសៀវភៅ អភិបាលកិច្ចល្អ សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ខែវិច្ឆិកា ២00៥។

៥. អ្នកសម្របសម្រួលអានសន្ទានុក្រមនៃកម្មវិធីជាតិ១0ឆ្នាំ ទំព័រ១៦0

**លទ្ធផលរំពឹងទុកនៃមេរៀន**

ក. អ្នកចូលរួមនឹងយល់ពីអត្ថន័យ និងមូលហេតុនៃការអភិវឌ្ឍតាមបែបប្រជាធិតេយ្យ អភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គម

ខ. អ្នកចូលរួមកំណត់ពីក្របខណ្ឌច្បាប់ដែលលើកកម្ពស់អភិបាលកិច្ចល្អ និងការអនុវត្តគណនេយ្យភាពសង្គម

គ. អ្នកចូលរួមកំណត់បានពីទំនាក់ទំនងរវាង អភិបាលកិច្ចល្អ គណនេយ្យភាពសង្គម និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

ឃ. អ្នកចូលរួមយល់ដឹងបញ្ហាប្រឈមនានាក្នុងការអនុវត្តសកម្មភាព វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ កិច្ចប្រជុំប្រចាំខែ ការផ្សព្វផ្សាយព័ត៌មានសាធារណៈ ចូលរួមក្នុងដំណើរការកសាងផែនការ និងថវិកា

**សម្ភារឧបទេ្ទសសម្រាប់មេរៀន**

- ឯកសារចែកជូន
- បទបង្ហាញ
- ហ្វឺតសរសេរក្រដាស ក្រដាសផ្ទាំងធំ ស្កុត
- កុំព្យូទ័រយួរដៃ និងម៉ាស៊ីនបញ្ចាំងឯកសារ

**ឯកសារយោង**

- សៀវភៅអភិបាលកិច្ចល្អសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ខែវិច្ឆិកា ២០០៥
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ប្លង់មេរៀនគោលការណ៍សំខាន់ៗជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ខែមិថុនា ២០០៩
- ឯកសារបណ្តុះបណ្តាលសម្រាប់គ្រូ និងសិក្ខាកាមស្តីពីការលើកកម្ពស់ការយល់ដឹង និងភ្ជាប់ទំនាក់ទំនងសង្គមស៊ីវិលជាមួយកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (Pact/VBNK) វិច្ឆិកា ២០១០ (ទំព័រ២៥ ដល់ ៦១)
- សៀវភៅណែនាំសម្រាប់គ្រូ ស្តីពីគណនេយ្យសង្គម - ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅកម្ពុជា - អង្គការសីលការ ខែមិថុនា ឆ្នាំ ២០១០ (ម៉ូឌុលទី៣ ទំព័រ ១៧១ដល់២១៣)
- សន្ទានុក្រមនៃកម្មវិធីជាតិ១០ឆ្នាំ ទំព័រ១៦០

## របៀបសម្របសម្រួលមេរៀន

| រយៈពេល | សកម្មភាព និងវិធីសាស្ត្រ | សម្ភារៈ/ឯកសារចែក |
|---|---|---|
| ៥ នាទី | **<u>សកម្មភាពទី១</u> សេចក្តីណែនាំ និងគោលបំណងមេរៀន**<br>• អ្នកចូលរួមភាគច្រើនបានយល់ដឹងពីដំណើរការអនុវត្ត និងការរីកចំរើននៃអភិបាលកិច្ចល្អ និងវិមជ្ឈការនៅកម្ពុជា ហើយអាចដឹងខ្លះៗពីការអនុវត្តគណនេយ្យភាពសង្គមដោយសង្គមស៊ីវិល<br>• អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកឡើងថាអភិបាលកិច្ចល្អជាផ្នែកមួយយ៉ាងសំខាន់ក្នុងការជំរុញ និងគាំទ្រដំណើរការនៃការគ្រប់គ្រងប្រកបដោយនិរន្តរភាព និងមូលដ្ឋានគ្រឹះនៃការអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។ ទន្ទឹមនេះគណនេយ្យភាពសង្គមក៏មានតួនាទីសំខាន់ក្នុងការគាំទ្រ និងចូលរួមចំណែកដល់ដំណើរការការអនុវត្តអភិបាលកិច្ចល្អ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិផងដែរ ។ គណនេយ្យភាពសង្គមជាសកម្មភាពរបស់ប្រជាពលរដ្ឋក្នុងការទាមទារអោយអ្នកដឹកនាំ និងក្រុមប្រឹក្សាជាប់ឆ្នោតមានគណនេយ្យភាពចំពោះការសម្រេចចិត្ត និងការអនុវត្តរបស់ខ្លួន ។<br>• មេរៀននេះនឹងពិភាក្សាពីទស្សនទានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ អភិបាលកិច្ច និងគណនេយ្យភាពសង្គម ។<br>• បង្ហាញគោលបំណង - អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ពីគោលបំណងមេរៀនស្លាយទី២ | • ស្លាយបង្ហាញទី២<br>• ឯកសារចែក |
| ២០ នាទី | **<u>សកម្មភាពទី២</u> - អត្ថន័យការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ**<br>**ក-** តើយើងបានឮពាក្យការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាំងពីពេលណាមក? តើពាក្យនេះ មានអត្ថន័យដូចម្តេច? តើមានសកម្មភាពអ្វីខ្លះរបស់ក្រុមប្រឹក្សា ដែលបានអនុវត្តកន្លងមកឆ្លើយតបនឹងការអភិវឌ្ឍតាមបែបប្រជា ធិបតេយ្យ? ។ ដូចនេះយើងនឹងពិភាក្សា និងស្វែងយល់ទាំងអស់គ្នា ពីសំណួរទាំងនេះ ។<br>**ខ- ពិភាក្សាក្រុមតូច** | • ស្លាយទី៣-១៤<br>• ក្រដាស់ផ្ទាំងធំ<br>• ឯកសារចែក |

| | | |
|---|---|---|
| | • ចែកអ្នកចូលរួមជា៨ក្រុម ដោយក្រុមនីមួយៗមួយយកគោលការណ៍របស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យមកពិភាក្សា និងលើកសកម្មភាពដែលបានអនុវត្តកន្លងមកចំនួន២ដែលពាក់ព័ន្ធនឹងចំណុចទាំងនោះ ។ ក្រុមទី១ ភាពតំណាងជាសាធារណៈ ក្រុមទី២ ស្វ័យភាពរបស់មូលដ្ឋាន ក្រុមទី៣ ការពិគ្រោះយោបល់ និងការចូលរួម ក្រុមទី៤ ការឆ្លើយតប និងគណនេយ្យភាព ក្រុមទី៥ ការលើកកម្ពស់គុណភាពនៃជីវិតរស់នៅរបស់ប្រជាជននៅមូលដ្ឋាន ក្រុមទី៦ ការលើកស្ទួយសមធម៌ ក្រុមទី៧ តម្លាភាព និងសុចរិតភាព ក្រុមទី៨ វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច (មាត្រា១២ ទំព័រ២ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)<br>• បិទចម្លើយលើក្តារខៀន ហើយអ្នកសម្របសម្រួលសង្ខេបត្រួសៗចម្លើយក្រុមពិភាក្សា<br>• បទបង្ហាញពីគោលការណ៍ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងលើកសកម្មភាពដែលបានអនុវត្តដោយក្រុមប្រឹក្សាពីចម្លើយក្រុមពិភាក្សា និងហេតុអ្វីបានជាការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យមានសារៈសំខាន់? ស្លាយទី៣-១៤<br>• អ្នកសម្របសម្រួលបូកសរុបថា ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យមានគោលការណ៍ចំនួន ៨ ។ | |
| **២០ នាទី** | **<u>សកម្មភាពទី៣</u> - អត្ថន័យពាក្យអភិបាលកិច្ចល្អ និងគោលការណ៍អភិបាលកិច្ចល្អ**<br>១- ការបំផុសគំនិត (៥ នាទី)<br>• បង្ហាញសំណួរ តើអ្វីជាអភិបាលកិច្ចល្អ? អ្នកចូលរួម៣នាក់ឆ្លើយ<br>២- ការបង្ហាញក្រុមធំ (៥ នាទី)<br>• បង្ហាញ និងបកស្រាយពីអត្ថន័យ និងសារៈសំខាន់អភិបាលកិច្ចល្អ និងគោលការណ៍ទាំង៨ ដោយអ្នកចូលរួម និងសង្ខេបខ្លឹមសារដោយអ្នកសម្របសម្រួល (ស្លាយទី១៦-១៨)<br>• សំណួរ ឬយោបល់បន្ថែមពីអ្នកចូលរួម<br>៣- ពិភាក្សាក្រុមតូច (១០ នាទី)<br>• ចែកអ្នកចូលរួមជា៤ក្រុមតូច ដោយក្រុមនិមួយៗយកគោល | • ស្លាយ១៥-១៨<br>• ឯកសារចែក<br>• ក្រដាស់ផ្ទាំងធំ<br>• ហ្វឺត |

| | | |
|---|---|---|
| | ការណ៍មួយយកទៅឆ្លុះបញ្ចាំងពីការអនុវត្តកន្លងមក ។ ក្រុមទី១-ការចូលរួម ក្រុមទី២-តម្លាភាព ក្រុមទី៣-គណនេយ្យភាព ក្រុមទី៤-ការឆ្លើយតប<br>• សំណួរក្រុមពិភាក្សា តើក្រុមប្រឹក្សាបានអនុវត្តសកម្មភាពអ្វីខ្លះដែលឆ្លើយតបទៅនឹងគោលការណ៍អភិបាលកិច្ចល្អ? ដោយលើកសកម្មភាពជាក់ស្តែងដែលបានអនុវត្ត ឬសកម្មភាពដែលគ្រោងអនុវត្ត (ស្លាយទី១៨)<br>• តំណាងក្រុមនិមួយៗបង្ហាញសកម្មភាពសំខាន់ៗដែលបានអនុវត្ត ឬគ្រោងអនុវត្តចំនួន២<br>• អ្នកសម្របសម្រួលបង្ហាញចម្លើយ ស្លាយទី១៩ ដល់ ២៤ | |
| ២០ នាទី | <u>**សកម្មភាពទី៤**</u> - ***អត្ថន័យ*គណនេយ្យភាពសង្គម**<br>**ក- សេចក្តីផ្តើម**<br>យើងនឹងពិភាក្សាពីអត្ថន័យ មូលហេតុ និងសារៈសំខាន់នៃគណនេយ្យភាពសង្គមដែលបាន និងកំពុងអនុវត្តន៍ដោយរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលក្នុងការសម្របសម្រួលអោយប្រជាពលរដ្ឋចូលរួមរាល់សកម្មភាពអភិវឌ្ឍនៅក្នុងសង្គមកម្ពុជា ។<br>**ខ- ការបំផុសគំនិត *(១០ នាទី)***<br>• អនុញ្ញាតិអោយអ្នកចូលរួមបញ្ចេញយោបល់លើសំណួរ *(១)* តើធ្លាប់ឮពាក្យគណនេយ្យភាពសង្គមឬទេ*?* នៅពេលណា*?(២)* តើពាក្យគណនេយ្យភាពសង្គមមានន័យដូចម្តេច*?*<br>• អ្នកសម្របសម្រួលកត់ត្រាចម្លើយលើក្រដាស់ផ្ទាំងធំ<br>• អ្នកសម្របសម្រួលបូកសរុបដោយឆ្លុះបញ្ចាំងសកម្មភាពកន្លងមករបស់សហគមន៍ និងក្រុមប្រឹក្សារួម*ទាំង*អត្ថន័យរបស់គណនេយ្យភាពសង្គម *(ស្លាយទី២៦-២៧)*<br>**គ- ការបំផុសគំនិត - សារៈប្រយោជន៍គណនេយ្យភាពសង្គម *(៥នាទី)***<br>• អនុញ្ញាតិអោយអ្នកចូលរួមបញ្ចេញយោបល់ឆ្លើយតបសំណួរ តើការអនុវត្តគណនេយ្យភាពសង្គមផ្តល់អត្ថប្រយោជន៍អ្វីខ្លះដល់សហគមន៍?<br>• អ្នកសម្របសម្រួលកត់ត្រា និងបកស្រាយចំនុចលំអិតនៃ | • ស្លាយទី២៥-៣០<br>• ក្រដាស់ផ្ទាំងធំ<br>• ឯកសារចែក |

| | | |
|---|---|---|
| | អត្ថប្រយោជន៍គណនេយ្យភាពសង្គម-តើមានសកម្មភាពអ្វីខ្លះដែលបានអនុវត្តដែលឆ្លើយតបនឹង *(១)* លើកកម្ពស់អភិបាលកិច្ចល្អ *(២)* ការអភិវឌ្ឍប្រកបដោយប្រសិទ្ធិភាព *(៣)* ការពង្រឹងអំណាចដល់ប្រជាពលរដ្ឋ *(ស្លាយទី២៨ ដល់២៩)*<br>**ឃ- ពិភាក្សាក្រុមធំ *(៥ នាទី)***<br>• បង្ហាញពីក្របខ័ណ្ឌគតិយុត្តគាំទ្រដល់ការអនុវត្តគណនេយ្យភាពសង្គមនៅកម្ពុជា *(ស្លាយទី៣០ ដល់៣១)*<br>• សួរបញ្ជាក់អ្នកចូលរួម ថាតើមានចម្ងល់ និងយោបល់អ្វីបន្ថែម | |
| ១០ នាទី | **<u>សកម្មភាពទី៥</u> - ទំនាក់ទំនងរវាងអភិបាលកិច្ចល្អ គណនេយ្យភាពសង្គម និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ**<br>**ក- សេចក្តីផ្តើម**<br>យើងបានយល់ពីទស្សនទាន មូលហេតុ និងសកម្មភាពដែលពាក់ព័ន្ធក្នុងការអនុវត្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គម ។ ដូចនេះយើងនឹងបន្តពិភាក្សាថាតើអភិបាលកិច្ចល្អ គណនេយ្យភាពសង្គម និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យមានទំនាក់ទំនងគ្នាដូចម្តេច?<br>**ខ- ពិភាក្សាក្រុមធំ (៥ នាទី)**<br>• អនុញ្ញាតិអោយអ្នកចូលរួម ៣នាក់ឆ្លើយសំណួរ តើអភិបាលកិច្ចល្អ គណនេយ្យភាពសង្គម និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យមានទំនាក់ទំនងគ្នាដូចម្តេច?<br>• អ្នកសម្របសម្រួលកត់ត្រាចម្លើយ និងបកស្រាយលំអិតពីទំនាក់ទំនងរវាងអភិបាលកិច្ចល្អ គណនេយ្យភាពសង្គម និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដោយយោងតាមស្លាយ (៣៣)<br>• បន្តពិភាក្សា តើមានការប្រឈមអ្វីខ្លះក្នុងការអនុវត្តអភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គម?<br>• អនុញ្ញាតិឱ្យអ្នកចូលរួម២នាក់ឆ្លើយសំណួរ<br>• អ្នកសម្របសម្រួលបង្ហាញមេរៀន (៣៤-៣៦) | • ស្លាយបង្ហាញទី៣២-៣៦<br>• ក្រដាស់ផ្ទាំងធំ<br>• ឯកសារចែក |
| ៥នាទី | **<u>សកម្មភាពទី៦</u> - សេចក្តីសន្និដ្ឋាន**<br>១- យើងបានពិភាក្សាពីអត្ថន័យ និងរំលឹកពីសកម្មភាពដែលបាន | |

| | | |
|---|---|---|
| | អនុវត្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គម<br>២- យើងបានពិភាក្សាពីអត្ថប្រយោជន៍នៃអនុវត្តអភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គម ដែលចូលរួមចំណែកអភិបាល កិច្ចល្អនៅថ្នាក់ក្រោមជាតិ ពិសេសថ្នាក់ក្រុង ស្រុក និងឃុំ/សង្កាត់<br>៣- យើងបានពិភាក្សាពីក្របខណ្ឌគោលនយោបាល និងច្បាប់គាំទ្រការអនុវត្តគណនេយ្យភាពសង្គមនៅកម្ពុជា<br>៤- យើងបានពិភាក្សាពីទំនាក់ទំនងរវាងអភិបាលកិច្ចល្អការអភិវឌ្ឍតាមបែបប្រជាធិតេយ្យ និងគណនេយ្យភាពសង្គម *គឺទាមទារឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងសកម្មភាព និងការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាប្រកបដោយតម្លាភាព និងគណនេយ្យភាពក្នុងការអនុវត្តមុខងារ និងតួនាទីបម្រើប្រជាពលរដ្ឋក្នុងគោលបំណង ៖ ១. ពង្រឹងគុណភាពនៃការផ្តល់សេវា*<br>*២. ពង្រឹងអំណាចប្រជាពលរដ្ឋ ៣. កាត់បន្ថយភាពក្រីក្រ ។ល។*<br>៥- នៅមេរៀនបន្ទាប់ យើងនឹងបានដឹងពីប្រវត្តិ និងព្រឹត្តការណ៍ចំបងៗនៃដំណើរការអនុវត្តអភិបាលកិច្ចល្អ ការអភិឌ្ឍតាមបែបប្រជាធិបតេយ្យ និងគណនេយ្យភាពសង្គម និងឆ្លុះបញ្ចាំងពីការអនុវត្តរបស់ក្រុមប្រឹក្សាទាក់ទងនឹងព្រឹត្តិការណ៍ចំបងៗទាំងនោះ ។ | |

ថ្ងៃទី១ មេរៀនទី២

# ទស្សនទាន
# ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
# អភិបាលកិច្ចល្អ និង
# គណនេយ្យភាពសង្គម

# គោលបំណងមេរៀន

១. បកស្រាយបានពីអត្ថន័យនៃការអភិវឌ្ឍតាមបែបប្រជាធិតេយ្យ អភិបាល
កិច្ចល្អ និងគណនេយ្យភាពសង្គម

២.ពន្យល់ពីមូលហេតុនៃការអភិវឌ្ឍតាមបែបប្រជាធិតេយ្យ អភិបាលកិច្ចល្អ
និងគណនេយ្យភាពសង្គម

៣.រៀបរាប់ពីក្របខណ្ឌច្បាប់គាំទ្រការអនុវត្តគណនេយ្យភាពសង្គមនៅកម្ពុជា

៤.កំណត់បានពីទំនាក់ទំនងរវាង អភិបាលកិច្ចល្អ គណនេយ្យភាពសង្គម និង
ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

៥. កំណត់ពីការប្រឈមនានាក្នុងការលើកកម្ពស់ (ការអនុវត្ត) អភិបាលកិច្ច
ល្អ និងគណនេយ្យភាពសង្គម។

# ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

# សំណួរផ្ដើមមេរៀន

១. តើយើងបានឮពាក្យការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាំងពីពេលណាមក?

២. តើពាក្យនេះមានអត្ថន័យដូចម្ដេច? តើមានសកម្មភាពអ្វីខ្លះរបស់ក្រុមប្រឹក្សា ដែលបានអនុវត្តកន្លងមកឆ្លើយតបនឹងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ?

# តើអ្វីជាការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ?

គឺជាការអភិវឌ្ឍដែលដំណើរការដោយមានលក្ខណៈ ៖

១. ភាពជាតំណាងសាធារណៈ

២. ស្វ័យភាពរបស់មូលដ្ឋាន

៣. ការពិគ្រោះយោបល់ និងការចូលរួម

៤. ឆ្លើយតប និងគណនេយ្យភាព

៥. លើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន

៦. លើកស្ទួយសមធម៌

៧. តម្លាភាព និងសុចរិតភាព

៨. វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច

មាត្រា១២ ទំព័រទី២  ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្តក្រុង ស្រុក ខណ្ឌ

# ១. ភាពជាតំណាងសាធារណៈ

ក្រុមប្រឹក្សាត្រូវអនុវត្តការងារក្នុងនាម និងធ្វើជាតំណាងឱ្យប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

<u>សកម្មភាព</u>

ធ្វើសេចក្តីសម្រេចចិត្តអភិវឌ្ឍមូលដ្ឋាន

កសាងផែនការ និងថវិកា

ដឹកា និងសេចក្តីសម្រេច

ចូលរួមនៅក្នុងដំណើរការរៀបចំគោលនយោបាយ

# ២. ស្វ័យភាពរបស់មូលដ្ឋាន

ស្ថានភាពដែលក្រុមប្រឹក្សាអាចម្ចាស់ការចាត់ចែង គ្រប់គ្រងនូវកិច្ចការដែលបានប្រគល់ ឬផ្ទេរប្រតិភូកម្មឱ្យដោយច្បាប់នេះប្រកបដោយប្រសិទ្ធភាព ។

**សកម្មភាព**

ចុះអត្រានុកូលដ្ឋាន

ការចុះឈ្មោះបោះឆ្នោត

# ៣. ការពិគ្រោះយោបល់ និងការចូលរួម

ជាដំណើរការនៃការអនុវត្តការងារ និងការធ្វើសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា ដែលក្រុមប្រឹក្សាត្រូវ ៖

- ជួប និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅមូលដ្ឋាន
- លើកទឹកចិត្ត និងសម្របសម្រួលឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន នៅគ្រប់ផ្នែកទាំងអស់នៃអភិបាលកិច្ច ដើម្បីស្វែងយល់ និងឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋ ។

<u>**សកម្មភាព**</u>

ក្រុមប្រឹក្សាពិគ្រោះយោបល់ជាទៀងទាត់ពីបញ្ហា ក្ដីកង្វល់ និងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ កុមារ និងយុវជន

# ៤. ឆ្លើយតប និងគណនេយ្យភាព

ក្នុងនាមជាតំណាងប្រជាពលរដ្ឋនៅមូលដ្ឋាន ក្រុមប្រឹក្សាត្រូវឆ្លើយតប ចំពោះប្រជាពលរដ្ឋរបស់ខ្លួនក្នុងការធ្វើគោលនយោបាយ សេចក្តីសម្រេចចិត្ត សកម្មភាព និងការបំពេញការងាររបស់ខ្លួន ប្រកបដោយការទទួលខុសត្រូវនូវអ្វីដែលខ្លួនបានអនុវត្ត ។ ក្រុមប្រឹក្សាក៏ទទួលខុស ត្រូវផងដែរចំពោះរាជរដ្ឋាភិបាលក្នុងការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងច្បាប់នានា ។

<u>សកម្មភាព</u>

អនុវត្តគម្រោងអភិវឌ្ឍមូលដ្ឋាន

ចុះពិគ្រោះយោបល់តាមមូលដ្ឋាន

វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់



# ៥. លើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន

សំដៅទៅលើកិច្ចខិតខំប្រឹងប្រែងដើម្បី៖

- បង្កើត និងធ្វើឱ្យមាននិរន្តភាពនូវបរិយាកាសមួយប្រកបដោយសន្តិភាព សុវត្ថិភាព និងសុខុមាលភាព
- លើកកម្ពស់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច
- លើកកម្ពស់ផាសុកភាព និងគុណភាពជីវិតនៃប្រជាពលរដ្ឋក្នុងមូលដ្ឋាន

សកម្មភាព

ភូមិឃុំមានសុវត្ថិភាព៖ មិនមានអំពើហឹង្សា ការជួញដូរមនុស្ស និងពេស្យាចារ ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ អំពើចោរកម្ម

មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព

# ៦. លើកស្ទួយសមធម៌

ការគិតគូរ និងយកចិត្តទុកដាក់ ជាពិសេសទៅលើតម្រូវការខុសៗគ្នារបស់ស្ត្រី បុរស យុវជន និងកុមារព្រមទាំងតម្រូវការខុសៗគ្នារបស់ក្រុមជនងាយរងគ្រោះរាប់បញ្ចូលទាំងប្រជាពលរដ្ឋក្រីក្រ និងជនជាតិដើមភាគតិច។

<u>សកម្មភាព</u>

ការពិគ្រោះយោបល់ពីបញ្ហា ក្តីបារម្ភ និងតម្រូវការជាអាទិភាព ជាមួយក្រុមគោលដៅស្ត្រី បុរស យុវជន កុមារ ជនជាតិដើមភាគតិច និងប្រជាពលរដ្ឋក្រីក្រ

# ៧. តម្លាភាព និងសុចរិតភាព

គឺជាការចាត់ចែង និងគ្រប់គ្រងកិច្ចការនានា រាប់បញ្ចូលទាំងកិច្ចការ ហិរញ្ញវត្ថុ ដោយអនុលោមតាមបទដ្ឋានខ្ពស់បំផុតនៃសុចរិតភាព និងច្បាប់ក្នុងលក្ខណៈបើកចំហ ប្រកបដោយតម្លាភាព ភាពចូលរួម ភាពឆ្លើយតប ។

<u>សកម្មភាព</u>

ក្រុមប្រឹក្សាឃុំបិទផ្សាយជាសាធារណៈ និងទៀងទាត់នូវចំណូល ចំណាយ និងសេចក្តីសម្រេចចិត្តរបស់ខ្លួន



# ៨. វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច

គឺជាការប្រកាន់យកនូវវិធាននៃច្បាប់ព្រមទាំងការប្រឆាំង និងរាយការណ៍អំពីអំពើពុករលួយ និងការរំលោភអំណាច។

<u>សកម្មភាព</u>

១. គាំទ្រការអនុវត្តច្បាប់

២. គាំទ្រឱ្យមានតម្លាភាពនូវរាល់សកម្មភាពអភិវឌ្ឍក្នុងដែនសមត្ថកិច្ច

៣. ប្រកាសចំណូលចំណាយ និងសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សា

៤. ផ្សព្វផ្សាយច្បាប់ស្តីពីច្បាប់ប្រឆាំងអំពើពុករលួយ



# ហេតុអ្វីបានជាការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យមានសារៈសំខាន់?

១. ផ្តល់ឱកាសឱ្យប្រជាពលរដ្ឋគ្រប់រូបចូលរួមក្នុងការអភិវឌ្ឍមូលដ្ឋាន និងធ្វើឱ្យប្រសើរ ឡើងនូវការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងកាត់បន្ថយភាពក្រីក្រ ។

២. បង្កិតសេវាសាធារណៈឱ្យកាន់តែជិតប្រជាពលរដ្ឋ

៣. បង្កើតវប្បធម៌ប្រជាធិបតេយ្យ ដោយមានការចូលរួមពីប្រជាពលរដ្ឋ និងប្រកបដោយការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ

៤. កែលម្អការផ្តល់សេវាសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធ

៥. នាំមកនូវការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច

# អភិបាលកិច្ចល្អ

# តើអភិបាលកិច្ចល្អជាអ្វី?

ជាវិធីសាស្ត្រ ឬមធ្យោបាយ ដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីបម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ ដោយបំពេញបាននូវគោលការណ៍ចំនួន ៨។





វប្បធម៌ប្រជាធិបតេយ្យ
កែលម្អការផ្តល់សេវាសាធារណៈ និង
ហេដ្ឋារចនាសម្ព័ន្ធ
ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច
កាត់បន្ថយភាពក្រីក្រ
VBNK
Pact Cambodia
THE WORLD BANK
NCDD
ការចូលរួម
តម្លាភាព
ការឆ្លើយតប
សមធម៌
នីតិរដ្ឋ
ការឯកភាព
ប្រសិទ្ធភាព
និងប្រសិទ្ធផល
គណនេយ្យភាព

# ហេតុអ្វីបានជាអភិបាលកិច្ចល្អមានសារៈសំខាន់?

- លើកកម្ពស់ការឆ្លើយតបរបស់ស្ថាប័នរដ្ឋាភិបាលចំពោះតម្រូវការរបស់សហគមន៍
- លើកកម្ពស់គណនេយ្យភាពក្នុងការគ្រប់គ្រងចាត់ចែងធនធានសាធារណៈ
- បង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ
- លើកកម្ពស់ប្រសិទ្ធិភាពការផ្តល់សេវារបស់ស្ថាប័នសាធារណៈ (គុណភាព និងទំហំ)
- ប្រជាពលរដ្ឋពេញចិត្តចំពោះក្រុមប្រឹក្សាក្នុងការបំពេញតួនាទី និងមុខងារ ដើម្បីឆ្លើយតបបញ្ហា និងតម្រូវការរបស់ប្រជាពលរដ្ឋដោយមានការចូលរួម តម្លាភាព និងគណនេយ្យភាព ។
- គឺជាស្នូលនៃយុទ្ធសាស្រ្តចតុកោណ (ការអភិវឌ្ឍ) ដើម្បីបង្កើនគុណភាព និងប្រសិទ្ធិភាពក្នុងការផ្តល់សេវាសាធារណៈ
- កំណែទម្រង់សេវាសាធារណៈ ប្រសិទ្ធផល និងប្រសិទ្ធិភាពនៃការចំណាយ

# ពិភាក្សាក្រុមតូច

1. តើក្រុមប្រឹក្សាបានអនុវត្តសកម្មភាពអ្វីខ្លះ ដែលឆ្លើយតបទៅនឹងគោលការណ៍អភិបាលកិច្ចល្អ? លើកសកម្មភាពជាក់ស្តែងដែលបានអនុវត្ត ឬសកម្មភាពដែលគ្រោងអនុវត្ត
2. តំណាងក្រុមនីមួយៗបង្ហាញសកម្មភាពសំខាន់ៗដែលបានអនុវត្ត ឬគ្រោងអនុវត្តចំនួន២

ក្រុមទី១ - ការចូលរួម

ក្រុមទី២ - តម្លាភាព

ក្រុមទី៣ - គណនេយ្យភាព

ក្រុមទី៤ - ការឆ្លើយតប

# ការចូលរួម

ប្រជាពលរដ្ឋ អង្គការសហគមន៍មូលដ្ឋាន គណៈកម្មការអភិវឌ្ឍភូមិ បណ្តាញភូមិ និងសមាគមនានាគួរស្នើឱ្យចូលរួមអនុវត្តការងារជាមួយរដ្ឋបាលមូលដ្ឋាន ។ បុរស ស្ត្រី កុមារ យុវជន និងក្រុមមិនសូវមានតំណាងត្រូវមានសមត្ថភាព ដើម្បីសកម្មចូលរួមក្នុងសកម្មភាពរបស់ក្រុមប្រឹក្សា ហើយបញ្ចុះបញ្ចូលក្រុមប្រឹក្សាឱ្យទទួលយកតម្រូវការរបស់ខ្លួន



# ការចូលរួម (ត)

<u>សកម្មភាព</u>

១. ប្រជាពលរដ្ឋចូលរួមរាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំដើម្បីលើកពីបញ្ហា និងតម្រូវការរបស់ខ្លួនក្នុងកិច្ចប្រជុំរៀបចំផែនការ និងថវិការបស់ក្រុមប្រឹក្សា

២. ចូលរួមតាមដាន និងវាយតម្លៃការអនុវត្តសកម្មភាពគម្រោង

# តម្លាភាព

ប្រជាពលរដ្ឋមានលទ្ធភាពទទួលព័ត៌មានពីសេចក្តីសម្រេចចិត្ត មូលនិធិ ចំណូល ចំណាយ និងសកម្មភាពនានា របស់ក្រុមប្រឹក្សា



**សកម្មភាព**

១. ក្រុមប្រឹក្សាបិទផ្សាយជាសាធារណៈ និងទៀងទាត់នូវចំណូល ចំណាយ និងសេចក្តីសម្រេចចិត្តរបស់ខ្លួន

# គណនេយ្យភាព

ក្រុមប្រឹក្សាត្រូវយល់ពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន និងមានការឆ្លើយតប ហើយទទួលខុសត្រូវរាល់ទង្វើរបស់ខ្លួនចំពោះមុខប្រជាពលរដ្ឋ ។ ដូចគ្នាដែរ ប្រជាពលរដ្ឋក៏ត្រូវយល់ពីតួនាទី និងកាតព្វកិច្ចរបស់ខ្លួនចំពោះរដ្ឋាភិបាល

<u>សកម្មភាព</u> ក្រុមប្រឹក្សាពិគ្រោះយោបល់ជាទៀងទាត់ពីបញ្ហា ក្តីកង្វល់ និងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ កុមារ និងយុវជន

# ការឆ្លើយតប

ជាការព្យាយាម ខិតខំប្រឹងប្រែងរបស់ក្រុមប្រឹក្សា ដើម្បីបម្រើដល់ប្រជាពលរដ្ឋ ដោយស្មើភាព និងមិនរើសអើង នៅក្នុងពេលវេលាមួយដ៏សមហេតុផល ។

<u>សកម្មភាព</u> ក្រុមប្រឹក្សារៀបចំ និងអនុវត្តគម្រោងឆ្លើយតបអំពើហិង្សាក្នុងគ្រួសារ បន្ទាប់ពីការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋក្នុងឃុំទាំងមូល



# គណនេយ្យភាពសង្គម

# សំណួរបំផុសគំនិត

១. តើធ្លាប់ឮពាក្យគណនេយ្យភាពសង្គមឬទេ? នៅពេលណា?

២. តើពាក្យគណនេយ្យភាពមានន័យដូចម្តេច?

៣. តើពាក្យគណនេយ្យភាពសង្គមមានន័យដូចម្តេច?

# គណនេយ្យភាពសង្គម

ជាវិធីសាស្រ្តមួយឆ្ពោះទៅរកការកសាងគណនេយ្យភាព ដែលសំដៅលើការចូលរួមដ៏ខ្ជាប់ខ្ជួនរបស់ប្រជាពលរដ្ឋ មានដូចជាប្រជាពលរដ្ឋទូទៅ និងឬអង្គការសង្គមស៊ីវិល ដែលចូលរួមដោយផ្ទាល់ ឬប្រយោល ដើម្បីធ្វើឱ្យរដ្ឋាភិបាលមានគណនេយ្យភាពពិតប្រាកដ ។

# ហេតុអ្វីបានជាគណនេយ្យភាពសង្គមមានសារៈសំខាន់?

**គណនេយ្យភាពសង្គម**

- លើកកម្ពស់អភិបាលកិច្ចល្អ
- ការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព
- ការពង្រឹងអំណាចដល់ប្រជាពលរដ្ឋ

# សកម្មភាពគណនេយ្យភាពសង្គម

សកម្មភាពដែលរួមចំណែកលើកកម្ពស់គណនេយ្យភាពសង្គមគឺការចូលរួមរបស់ប្រជាពលរដ្ឋក្នុងសកម្មភាពខាងក្រោម៖

- ការចុះពិគ្រោះយោបល់មូលដ្ឋានដោយក្រុមប្រឹក្សាឃុំ សង្កាត់
- ដំណើរការកសាងផែនការ និងថវិកា
- កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា
- វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់
- ផ្សព្វផ្សាយព័ត៌មានសាធារណៈ

# ក្របខណ្ឌច្បាប់គាំទ្រការអនុវត្តគណនេយ្យភាពសង្គមនៅកម្ពុជា

១. រដ្ឋធម្មនុញ្ញ ១៩៩៣ - សិទ្ធិ សេរីភាព កាតព្វកិច្ច និងការចូលរួម

២. (១)ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ (២)ក្របខ័ណ្ឌយុទ្ធសាស្រ្តសម្រាប់ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ២០០៥-២០០៩ (៣)យុទ្ធសាស្រ្តចតុកោណ -ដំណាក់កាលទី១ និងទី២ (៤) ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ២០០៩ - ជំរុញការចូលរួម គណនេយ្យភាព ការឆ្លើយតប និងតម្លាភាព

# ក្របខណ្ឌច្បាប់គាំទ្រការអនុវត្តគណនេយ្យភាពសង្គមនៅកម្ពុជា (ត)

៣. កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩ - ជំរុញការចូលរួម ការបញ្ជ្រាបយេនឌ័រ និងគណនេយ្យភាព

# ពិភាក្សាក្រុមធំ

តើអភិបាលកិច្ចល្អ  គណនេយ្យភាពសង្គម និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យមានទំនាក់ទំនងគ្នាដូចម្តេច?

# ទំនាក់ទំនង អភិបាលកិច្ចល្អ គណនេយ្យភាពសង្គម និង ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

ទាមទារឱ្យមានការចូលរួមសកម្មពីប្រជាពលរដ្ឋក្នុងសកម្មភាព និង ការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាប្រកបដោយតម្លាភាព និង គណនេយ្យភាព ក្នុងការអនុវត្តមុខងារ និងតួនាទីបម្រើប្រជាពលរដ្ឋ ក្នុងគោលបំណង ៖

១. ពង្រឹងគុណភាពនៃការផ្តល់សេវា

២. ពង្រឹងអំណាចប្រជាពលរដ្ឋ

៣. កាត់បន្ថយភាពក្រីក្រ ។ល។

# ពិភាក្សាក្រុមធំ

តើមានការប្រឈមអ្វីខ្លះក្នុងការអនុវត្តអភិបាលកិច្ចល្អ និង
គណនេយ្យភាពសង្គម?

# ការប្រឈមនានាក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គម

- ខ្វះសមត្ថភាព និងការសម្របសម្រួលពីសង្គមស៊ីវិលក្នុងការចងក្រងក្រុមរបស់ប្រជាពលរដ្ឋដើម្បីអាចចូលរួមជាមួយក្រុមប្រឹក្សា
- ការចូលរួមរបស់ប្រជាពលរដ្ឋនៅមានកំរិត ឧ. ប្រជាពលរដ្ឋមិនចូលរួមកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់បើមិនមានលិខិតអញ្ជើញ
- ធនធាន (មនុស្ស សម្ភារៈ និងថវិកា)មានកំណត់សម្រាប់ក្រុមប្រឹក្សាបំពេញតួនាទី និងមុខងារបម្រើប្រជាពលរដ្ឋ (គណនេយ្យភាពចំពោះប្រជាពលរដ្ឋ)

# ការប្រឈមនានាក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គម (ត)

- ការយល់ដឹងរបស់ប្រជាពលរដ្ឋចំពោះកិច្ចការរបស់ក្រុមប្រឹក្សានៅមានកំរិត
- ប្រជាពលរដ្ឋមិនដឹងពីពេលវេលានៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ហើយរបៀបវារៈមួយចំនួនមិនសូវទាក់ទងនឹងបញ្ហាប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ
- ការផ្សព្វផ្សាយលើកទឹកចិត្ត និងផ្តល់ឱកាសឱ្យប្រជាពលរដ្ឋចូលរួមឱ្យបានទូលំទូលាយ
- ក្រុមប្រឹក្សាមិនសូវយល់ពីសារៈប្រយោជន៍នៃការចូលរួមរបស់ប្រជាពលរដ្ឋ

# ឯកសារចែក

# ថ្ងៃទី១

# មេរៀនទី ២

## ទស្សនទាននៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គម

## មាតិកា

1. អ្វីជាការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ? និងគោលការណ៍ទាំង៨
2. អ្វីជាអភិបាលកិច្ចល្អ? និងគោលការណ៍ទាំង៨
3. គណនេយ្យភាព និងគណនេយ្យភាពសង្គម
   ក- អ្វីជាគណនេយ្យភាពសង្គម?
   ខ- ហេតុអ្វីបានជាគណនេយ្យភាពសង្គមមានសារៈសំខាន់?
   គ- ក្របខណ្ឌច្បាប់គាំទ្រការអនុវត្តគណនេយ្យភាពសង្គមនៅកម្ពុជា
4. ទំនាក់ទំនងរវាង អភិបាលកិច្ចល្អ គណនេយ្យភាពសង្គម និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

## ១. ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ គឺជាការអភិវឌ្ឍដែលដំណើរការដោយមានលក្ខណៈដូចខាងក្រោម ៖

១. ភាពជាតំណាងសាធារណៈ

២. ស្វ័យភាពរបស់មូលដ្ឋាន

៣. ការពិគ្រោះយោបល់ និងការចូលរួម

៤. ឆ្លើយតប និងគណនេយ្យភាព

៥. លើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន

៦. លើកស្ទួយសមធម៌

៧. តម្លាភាព និងសុច្ចរិតភាព

៨. វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច

## ២. អភិបាលកិច្ចល្អ

អភិបាលកិច្ចល្អជាផ្នែកមួយយ៉ាងសំខាន់ ក្នុងការជំរុញ និងគាំទ្រដំណើរការនៃការគ្រប់គ្រងធនធានរបស់ស្ថាប័ន អង្គភាព និងការអភិវឌ្ឍមួយប្រកបដោយនិរន្តរភាព ។ដោយមើលឃើញពីសារៈសំខាន់នៃអភិបាលកិច្ចល្អ យើងបានរៀបចំ និងចងក្រងមេរៀននេះឡើង ដើម្បីស្វែងយល់ពីការអនុវត្តអភិបាលកិច្ចល្អ

នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រ ស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

តើអ្វីជាអភិបាលកិច្ចល្អ? ជាវិធីសាស្ត្រ ឬមធ្យោបាយដែលរដ្ឋ ស្ថាប័ន អង្គភាពប្រើប្រាស់ក្នុងការ គ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីបំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋដោយបំពេញ បានទូវគោលការណ៍ ចំនួន៨រួមមាន (១) **ការចូលរួម** (២) **នីតិរដ្ឋ** (៣) **តម្លាភាព** (៤) **ការព្រមព្រៀង ឯកភាពគ្នា** (៥) **សមធម៌** (៦) **ប្រសិទ្ធភាពខ្ពស់**(៧) **គណនេយ្យភាព** និង (៨) **ការឆ្លើយតប** ។

អភិបាលកិច្ចល្អ គឺជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ (ដំណាក់កាលទី១ និងដំណាក់កាលទី២) របស់រាជរដ្ឋាភិបាល ដែលត្រូវបានទទួលស្គាល់ជាបុរេលក្ខណៈសំខាន់បំផុតសម្រាប់ការអភិវឌ្ឍប្រកប ដោយ ចីរភាព មានសមធម៌ និងយុត្តិធម៌ ។ ដើម្បីសម្រេចបាននូវគោលបំណងនេះ រាជរដ្ឋាភិបាលបានផ្តោត ការយកចិត្តទុកដាក់ទៅលើការអនុវត្តប្រកបដោយប្រសិទ្ធភាពចំពោះផែនការអភិបាលកិច្ចរបស់ខ្លួន ដែល គ្របដណ្តប់ទៅលើកំណែទម្រង់លើវិស័យចំនួនបួនដែលមានការពាក់ព័ន្ធគ្នាទៅវិញទៅមករួមមាន

- ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ
- កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- កំណែទម្រង់រដ្ឋបាលសាធារណៈ (**រួមមានវិមជ្ឈការ និងវិសហមជ្ឈការ**) និង
- កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ

**ចំណាំ** :នៅក្នុងកំណែទម្រង់រដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាលចាត់ទុកថា**កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** មានសារៈសំខាន់ចំពោះការ កែលម្អគុណភាពនៃសេវាសាធារណៈ និង ការអភិវឌ្ឍមូលដ្ឋានដោយមានការចូលរួម។

## ៣. គណនេយ្យភាពសង្គម

### តើអ្វីទៅជាគណនេយ្យភាពសង្គម?

***គណនេយ្យភាពសង្គម បានឱ្យនិយមន័យថាជាវិធីសាស្ត្រមួយឆ្ពោះទៅរកការកសាងគណនេយ្យភាព ដែលសំដៅលើការចូលរួមដ៏ខ្ជាប់ខ្ជួនរបស់ប្រជាពលរដ្ឋ មានដូចជាពីប្រជាពលរដ្ឋធម្មតា និង/ឬ អង្គការសង្គមស៊ីវិលដែល ចូលរួមដោយផ្ទាល់ក្តី ដោយប្រយោលក្តី ដើម្បីឱ្យមានគណនេយ្យភាព ពិតប្រាកដពីរដ្ឋាភិបាល។***

***យន្តការគណនេយ្យភាពសង្គម អាចត្រូវបានផ្តួចផ្តើម និងគាំទ្រដោយភាគីរដ្ឋ ដោយភាគីប្រជាពលរដ្ឋ ឬកើតឡើងដោយទាំងពីរភាគី ប៉ុន្តែជាទូទៅគឺផុសចេញពីផ្នែកទាមទារ ហើយមានដំណើរការចេញពីថ្នាក់ក្រោមឡើងទៅលើ ។***

**គណនេយ្យភាពសង្គម** សំដៅដល់សកម្មភាព និងយន្តការជាច្រើនបែបយ៉ាង (លើសពីការបោះឆ្នោត) ដែលប្រជាពលរដ្ឋ សហគមន៍ អង្គការសង្គមស៊ីវិល និងប្រភពផ្សព្វផ្សាយឯករាជ្យនានា អាចប្រើដើម្បី ទាមទារពីមន្ត្រីសាធារណៈ និងអ្នកផ្តល់សេវាសាធារណៈឱ្យមានគណនេយ្យភាព ។ ការទាមទារទាំង នេះបានរួមបញ្ចូលទាំងសកម្មភាព របស់ប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់ និងសង្គមស៊ីវិល ដូចជាបាតុកម្ម សាធារណៈ ការតវ៉ា យុទ្ធនាការតស៊ូមតិ ការចុះកាសែត ពីលទ្ធផលស៊ើបអង្កេតព័ត៌មានរបស់អ្នកកាសែត និងបណ្តឹងផ្លូវច្បាប់ពីប្រយោជន៍សាធារណៈជាដើម ។ ប៉ុន្មានឆ្នាំចុងក្រោយនេះ អាស្រ័យមានការរីករាលដាល ក្នុងការប្រើប្រាស់ការប្រមូលទិន្នន័យដោយមានការចូលរួម និងឧបករណ៍វិភាគកាន់តែទូលំទូលាយ គួបផ្សំជាមួយ (ក្នុងបរិបទប្រទេសជាច្រើន) ការបើកចំហ និងទុកឱកាសរិតតែច្រើនឱ្យប្រជាពលរដ្ឋ ក៏ដូចជាការចូលរួមដ៏ខ្ជាប់ខ្ជួនរបស់សង្គមស៊ីវិលជាមួយរដ្ឋាភិបាល កត្តាទាំងអស់នេះបាននាំឱ្យមានការអនុវត្ត គណនេយ្យភាពសង្គមបែបជំនាន់ថ្មី ដែលសង្កត់ធ្ងន់លើមូលដ្ឋានមានភស្តុតាងរឹងមាំ និងលើអន្តរសកម្ម (សកម្មភាពទៅវិញទៅមក) ដោយផ្ទាល់ជាមួយដៃគូនានារបស់រដ្ឋាភិបាល ។ ឧទាហរណ៍វិធីសាស្ត្រថ្មី ទាំងនេះរួមមានដូចជា ការរៀបចំគោលនយោបាយសាធារណៈដោយមានការចូលរួម ការរៀបចំគម្រោង ថវិកាដោយមានការចូលរួម ការត្រួតពិនិត្យចំណាយសាធារណៈ ការពិនិត្យតាមដាន និងវាយតម្លៃលើការ ផ្តល់សេវាសាធារណៈដោយប្រជាពលរដ្ឋជាដើម ។

ទិដ្ឋភាពគន្លឹះមួយទៀតនៃយន្តការគណនេយ្យភាពសង្គម គឺការប្រើប្រាស់ការផ្តល់រង្វាន់ និងការដាក់ទណ្ឌកម្មទាំងផ្លូវការ និងទាំងមិនផ្លូវការដែលរួមទាំងសំពាធសង្កត់ពីសាធារណៈផងដែរ ។ យន្តការផ្តល់រង្វាន់ លើកទឹកចិត្ត រឺដាក់ទណ្ឌកម្មក្រៅផ្លូវការ អាស្រ័យលើការបង្កើតគំនាបជំរុញសាធារណៈ ឧទាហរណ៍តាមរយៈ សេចក្តីប្រកាសព័ត៌មាន (ព័ត៌មានវិជ្ជមាន រឺព័ត៌មានអវិជ្ជមាន) ការគ្របដណ្តប់របស់ប្រព័ន្ធផ្សព្វផ្សាយ ការបង្ហាញពីការគាំទ្រ ឬការតវ៉ាជាកិច្ចប្រជុំផ្ទាល់មុខរវាងប្រជាពលរដ្ឋ និងមន្ត្រីសាធារណៈ និងការធ្វើលិខិត បណ្តឹងតវ៉ាទៅអាជ្ញាធរជាដើម ។ល។ ឧទាហរណ៍ នៅពេលចាំបាច់ ក្រុមប្រជាពលរដ្ឋអាចតវ៉ាសុំឱ្យវិនិច្ឆ័យ សារជាថ្មីចំពោះរបៀបដាក់ទោសរបស់រដ្ឋ ឬការបង្ខំឱ្យមានការផ្លាស់ប្តូរ ដោយបង្ហាញនូវភស្តុតាងដល់ ភ្នាក់ងារត្រួតពិនិត្យអំពើពុករលួយ ការប្តឹងតវ៉ាទៅអ្នកស៊ើបអង្កេតមុខងារសាធារណៈរបស់រដ្ឋ ឬការ ធ្វើពាក្យបណ្តឹងទាមទារតាមរយៈប្រព័ន្ធតុលាការ ។ ជាញឹកញាយទោះជាយ៉ាងណា មធ្យោបាយទាំងនេះ មិនបានធ្វើទៅរួចឡើយ មិនបានផ្តល់ប្រសិទ្ធភាព ឬមិនគ្រប់គ្រាន់ឱ្យមានឥទ្ធិពលដល់ការផ្លាស់ប្តូរពិត ប្រាកដបានទេ ។ សំរាប់ករណីទាំងនេះ

សកម្មភាពរបស់ប្រជាពលរដ្ឋ អាចឱ្យយន្តការទាំងនេះ បង្ហាញ នូវភាពត្រឹមត្រូវឡើងវិញ ដោយបញ្ចុះបញ្ចូលឱ្យមានកំណែទម្រង់ (កែប្រព័ន្ធច្បាប់រដ្ឋបាលឬស្ថាប័ន) ឬក៏បង្កើនប្រសិទ្ធភាពតាមរយៈការចូលរួមរបស់សាធារណៈ ។ ជាថ្មីម្តងទៀត សកម្មភាពប្រភេទនេះអាចមាន សក្តានុពលខ្លាំង នាំដល់ការបង្កើតឱ្យមានយន្តការប្រតិបត្តិកូនកាត់ថ្មី (ឧទាហរណ៍ បង្កើតជាយន្តការផ្លូវការ តាមផ្នែក១) រួមបញ្ចូលទាំងគណកម្មាធិការឃ្លាំមើលរបស់ប្រជាពលរដ្ឋ វីយន្តការដោះស្រាយទំនាស់ (ដែលធ្វើ ឡើងតាមក៏រិតខុស១គ្នាជាផ្លូវការ និងតាមអាជ្ញាធរទទួលបន្ទុកផ្លូវច្បាប់) ។

## ៩. ហេតុអ្វីបានជាគណនេយ្យភាពសង្គមមានសារៈសំខាន់

មានការយល់ឃើញធំ១ ៣ ដែលបង្ហាញពីសារៈសំខាន់នៃគណនេយ្យភាពសង្គមគឺ **ធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ច បង្កើនប្រសិទ្ធភាពការអភិវឌ្ឍ និងការពង្រឹងអំណាចដល់ប្រជាពលរដ្ឋ** ។ ចំណុចនីមួយ១នឹងលើកមកពិភាក្សាដូចខាងក្រោម ។

ជាដំបូងបង្អស់ គឺបញ្ហា**អភិបាលកិច្ច** ។ គណនេយ្យភាពរបស់មន្រ្តីសាធារណៈជាចំណុចសំខាន់របស់រដ្ឋាភិបាលល្អមួយ និងតម្រូវការចំបងឱ្យលទ្ធិប្រជាធិប្បតេយ្យមានប្រសិទ្ធភាព ។ សព្វថ្ងៃនេះ នៅពេលមានការយល់ដឹងពីសិទ្ធិ និងការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋកំពុងកើនឡើង និងរីកដុះដាលនោះ ទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាលបានបញ្ចេញនូវលក្ខណៈមួយ ដោយអ្នកខ្លះបានហៅថាជា "វិបត្តិច្បាប់"(Gaventa, ២០០២) ឬតាមធម្មតាហៅថាជា "វិបត្តិរដ្ឋាភិបាល "(Paul ២០០២) ដោយប្រជាពលរដ្ឋបានសម្តែងចេញនូវការបាត់បង់ជំនឿរបស់គេជាមួយ នឹងរដ្ឋាភិបាល ដែលកើតចេញពី កង្វះខាតការឆ្លើយតប ការបិទបាំងអំពើពុករលួយ និទណ្ឌភាព និងការ ទទួលខុសត្រូវមិនល្អរបស់មន្រ្តី សាធារណៈ (មូលនិធិសុខមាលភាពទូទៅ ១៩៩៩ Narayan et al. ២០០០) ។ យន្តការគណនេយ្យភាព អនុញ្ញាតិឱ្យប្រជាពលរដ្ឋសាមញ្ញទទួលបានព័ត៌មានបានបញ្ចេញសំឡេងពីតម្រូវការរបស់គេ និងទាមទារឱ្យ មានគណនេយ្យភាពក្នុងការបោះឆ្នោត ។ ការធ្វើឱ្យមានគណនេយ្យភាពសង្គមកើតឡើង គឺត្រូវពង្រឹងឱ្យ ប្រជាពលរដ្ឋមានសមត្ថភាព ដើម្បីចូលរួមជាមួយនឹងមន្រ្តីការិយាធិបតេយ្យ និងអ្នកនយោបាយឱ្យផ្តល់ ព័ត៌មានថែមទៀត និងរៀបចំអនុវត្តការងារអោយបានត្រឹមត្រូវមានលក្ខណៈស្ថាបនា និងលក្ខណៈជាប្រព័ន្ធ ដើម្បីបង្កើនឱកាសឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន ។

បន្ទាប់មកគណនេយ្យភាពសង្គមអាចរួមចំណែកឱ្យមាន**ការបង្កើនប្រសិទ្ធភាពអភិវឌ្ឍន** ។ គេអាចសម្រេចបានតាមរយៈការធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាសាធារណៈ និងការរៀបចំគោលនយោបាយ ។ នៅក្នុងប្រទេសជាច្រើន ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ រដ្ឋាភិបាលមិនបានបញ្ជូនសេវាសំខាន់១ ទៅឱ្យប្រជាពលរដ្ឋរបស់ខ្លួនបានទេ ដោយសារតែមានបញ្ហាមួយចំនួនដូចជា ការប្រើធនធានមិនបាន ត្រឹមត្រូវ មានអំពើពុករលួយមានការលើកទឹកចិត្តខ្សោយឬខ្វះសំឡេងទាមទារពីប្រជាពលរដ្ឋ ។ រដ្ឋាភិបាលបានបង្កើតគោលនយោ-

បាយមានលក្ខណៈប្រុងប្រយ័ត្ន និងគ្មានតម្លាភាព ដែលផ្ទុយនឹងផលប្រយោជន៍ និងតម្រូវការជាអាទិភាពពិតប្រាកដរបស់ជនក្រីក្រ ។ បញ្ហាទាំងនេះត្រូវស្ថិតនៅអូសបន្លាយ ដោយសារតែក្រុមអ្នកដើរតួសំខាន់ ទាំងបីដែលស្ថិតនៅក្នុងចំណោម ▪ អ្នកធ្វើគោលនយោបាយសាធារណៈ និងអ្នកបង្កើតគោលនយោបាយផ្តល់សេវាបន្ត ▪ អ្នកផ្តល់សេវា និង ▪ ប្រជាពលរដ្ឋមានគោលដៅ និងវិធី លើកទឹកចិត្តខុសៗគ្នា រួមទាំងមិនបានទទួលព័ត៌មានគ្រប់គ្រាន់ និងការខ្វះការប្រាស្រ័យទាក់ទង ជាមួយគ្នាល្អ ។ តាមរយៈព័ត៌មាន និងការពង្រឹងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ ការជំរុញឱ្យមានការ ពិភាក្សា និងការប្រជុំរវាងក្រុមអ្នកដើរតួសំខាន់ទាំងបី និងការបង្កើតឱ្យមានវិធីលើកទឹកចិត្តចំពោះ ទង្វើប្រសើរណាមួយនោះ យន្តការគណនេយ្យភាពសង្គមអាចរីករាលដាលចំពោះការ ធ្វើឱ្យប្រសើរឡើងដល់ ប្រសិទ្ធភាពនៃការផ្តល់សេវា និងធ្វើការសម្រេចចិត្តលើកិច្ចការសាធារណៈកាន់តែមានតម្លាភាព មានការចូលរួម និងឆ្លើយតបតម្រូវការជនក្រីក្រ ។

ការផ្តួចផ្តើមគំនិតអនុវត្តគណនេយ្យភាពសង្គម **នឹងនាំឱ្យមានការផ្តល់អំណាច** ពិសេសដល់ ប្រជាពលរដ្ឋក្រីក្រ ។ ខណៈនេះគ្មាននិយមន័យណាមួយសំរាប់ពាក្យផ្តល់អំណាចទេ តាមន័យទូលាយពាក្យ នេះអាចយល់បានថា ជាការពង្រីកសេរីភាពនៃការជ្រើសរើស និងការបញ្ចេញសកម្មភាព ។ ការស្រាវជ្រាវ មួយបានបង្ហាញថា ការមិនសប្បាយចិត្តរបស់ជនក្រីក្រចំពោះរដ្ឋាភិបាល ទាក់ទងចំបងនឹងបញ្ហា ការឆ្លើយតប និងគណនេយ្យភាព ។ ជនក្រីក្របានរាយការណ៍ថា ស្ថាប័នរដ្ឋគឺ "មិនត្រឹមតែមិនឆ្លើយតបទេ ថែមទាំងមិនមានគណនេយ្យភាពចំពោះជនក្រីក្រថែមទៀត" ហើយ "គ្មានគណនេយ្យភាពចំពោះអ្នកណា ម្នាក់សោះ ឬមានគណនេយ្យជាមួយតែអ្នកមាន និងអ្នកមានអំណាចប៉ុណ្ណោះ" (Narayan et al. ២000 ទំព័រ ១៧២ និង ១៧៧) ។ យន្តការគណនេយ្យភាពសង្គមផ្តល់ឱ្យជាមធ្យោបាយមួយដើម្បីបង្កើន ការចូលរួមជាសំឡេងរបស់ក្រុមជនងាយរងគ្រោះ ។ សំឡេងរួមទាំងនេះបានពង្រឹងអំណាចដល់ជនក្រីក្រ និងបង្កើនឱកាសឆ្លើយតបតម្រូវការកាន់ច្រើនឡើងពីរដ្ឋ ។

## គ. ក្របខណ្ឌច្បាប់គាំទ្រការអនុវត្តគណនេយ្យភាពសង្គមនៅកម្ពុជា

1. រដ្ឋធម្មនុញ្ញ ១៩៩៣ - សិទ្ធិ សេរីភាព កាតព្វកិច្ច និងការចូលរួម
2. ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ (២)ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ២០០៥-២០០៩ (៣)យុទ្ធសាស្ត្រចតុកោណ -ដំណាក់កាលទី១ និងទី២ (៤) ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ២០០៩ - ជំរុញការចូលរួម គណនេយ្យភាព ការឆ្លើយតប និងតម្លាភាព
3. កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩ - ជំរុញការចូលរួម ការបញ្ជ្រាបយេនឌ័រ និងគណនេយ្យភាព

## ៤. ទំនាក់ទំនងរវាង អភិបាលកិច្ចល្អ គណនេយ្យភាពសង្គម និងការអភិវឌ្ឍតាមបែប

## ប្រជាធិបតេយ្យ

យន្តការគណនេយ្យភាពសង្គម មានតួនាទីសំខាន់ក្នុងការលើកម្ពស់អភិបាលកិច្ចល្អ និងធ្វើឱ្យលទ្ធិប្រជាធិបតេយ្យចាក់ឫសកាន់តែជ្រៅ ។ គណនេយ្យភាពសង្គមតំរូវអោយមានការចូលរួម យ៉ាងសកម្មពី ប្រជាពលរដ្ឋ ដើម្បីទាមទារឱ្យមានគណនេយ្យភាពពីអ្នកតំណាងដែលគេបោះឆ្នោតឱ្យ និងពីអ្នកដឹកនាំ របស់ពួកគេ ។ គណនេយ្យភាពសង្គមក៏អាចជាសក្តានុពលយ៉ាងខ្លាំង ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រ តាមរយៈ ការរៀបចំគោលនយោបាយដែលមានការគាំទ្រពីប្រជាពលរដ្ឋក្រីក្រ និងធ្វើឱ្យប្រសើរឡើងដល់ ការផ្តល់សេវា និងការផ្តល់អំណាច ។

គណនេយ្យភាពសង្គម ក៏ជាប់ទាក់ទងជាមួយនឹង**យេនឌ័រ**ផងដែរ ។ ស្ត្រីមិនមានតំណាងជាលក្ខណៈប្រព័ន្ធនៅគ្រប់កម្រិតស្ថាប័នរដ្ឋាភិបាលទេ ។ ស្ថានភាពនយោបាយបានធ្វើឱ្យសមត្ថភាពស្ត្រីចុះខ្សោយ ដែលធ្វើអោយស្ត្រីមិនអាចការពារផលប្រយោជន៍ និងការពារសិទ្ធខ្លួនបាន ។ ដោយសារតែយន្តការ គណនេយ្យភាពសង្គមធ្វើពីក្រោមឡើងលើ និងមានការគាំទ្រពីអ្នកផ្តល់(រដ្ឋាភិបាល) បានពង្រឹង សមត្ថភាពស្ត្រីឱ្យបញ្ចេញសំឡេងកាន់តែលឺ ។ ឧបករណ៍គណនេយ្យភាពមួយចំនួន (ដូចជាការរៀបចំថវិកា និងការត្រួតពិនិត្យតាមដាន និងវាយតម្លៃដែលមានស្ត្រីចូលរួម) ត្រូវបានរៀបចំឡើងឱ្យបញ្ចូល បញ្ហាយេនឌ័រ ។

ទស្សនទានគណនេយ្យភាពសង្គម ទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹង**ការចូលរួមរបស់ប្រជាពលរដ្ឋ** ។ ក្នុងករណីជាច្រើន ប្រជាពលរដ្ឋ សហគមន៍ និងអង្គការសង្គមស៊ីវិលមូលដ្ឋាន មិនត្រឹមតែចូលរួមក្នុង សកម្មភាពគណនេយ្យភាពសង្គមប៉ុណ្ណោះទេ ថែមទាំងផ្តើមគំនិតពិនិត្យមើលពួកគេផងដែរ ។ នៅពេល បច្ចេកទេសចូលរួមជាច្រើនផ្តោតលើសហគមន៍តូចៗ ឬកម្រិតតូចៗ យន្តការគណនេយ្យភាពសង្គម ពង្រីកឱកាសឱ្យមានការចូលរួមពីគ្រប់កម្រិតតូចៗផងដែរ ។

តាមរយៈការត្រួតពិនិត្យការអនុវត្តរបស់រដ្ឋាភិបាល ដើម្បីទាមទារនិងពង្រឹងឱ្យមាន**តម្លាភាព** ព្រមទាំងបង្ហាញឱ្យឃើញពីកំហុសឆ្គងរបស់រដ្ឋាភិបាលនោះ យន្តការគណនេយ្យភាពសង្គមជា ឧបករណ៍ដ៏ មានអំណាចសំរាប់ប្រយុទ្ធប្រឆាំងអំពើពុករលួយអំពើពុករលួយ ។ យន្តការគណនេយ្យភាពសង្គមបង្គ្រប់ ដោយ**ការកំណែទម្រង់វិស័យសាធារណៈ** ដោយបង្ហាញឱ្យភាគីទាមទារ (ប្រជាពលរដ្ឋ) ឃើញរូបភាពនៃផ្តល់ សេវារបស់រដ្ឋ ការត្រួតពិនិត្យ និងមានគណនេយ្យភាព ។ យន្តការគណនេយ្យភាពសង្គមបង្ហាញថាសារៈ ប្រយោជន៍ជាពិសេសសំរាប់បរិបទ**វិមជ្ឈការ** ដើម្បីជួយពង្រឹងទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល កម្រិតមូលដ្ឋាន និងជួយអាជ្ញាធរមូលដ្ឋាន និងអ្នកផ្តល់សេវាឱ្យកាន់តែមានការឆ្លើយតប និងកាន់តែមាន ប្រសិទ្ធភាព ។

សរុបសេចក្តីមកអភិបាលកិច្ចល្អ គណនេយ្យភាពសង្គម និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ មានទំនាក់ទំនងយ៉ាងជិតស្និត និងបំពេញឱ្យគ្នាទៅវិញទៅមក ដោយហេតុថាអភិបាលកិច្ចល្អ គណនេយ្យភាពសង្គម និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ទាមទារឱ្យមាន ការចូលរួមពីប្រជាពលរដ្ឋក្នុងសកម្មភាព និងការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាប្រកប ដោយតម្លាភាព និងគណនេយ្យភាព

ក្នុងការអនុវត្តមុខងារ និងតួនាទីបម្រើប្រជាពលរដ្ឋ ក្នុងគោលបំណង ៖

១. ពង្រឹងគុណភាពនៃការផ្ដល់សេវា

២. ពង្រឹងអំណាចប្រជាពលរដ្ឋ

៣. កាត់បន្ថយភាពក្រីក្រ ។ល។

# ថ្ងៃទី១

# ប្លង់មេរៀនទី ៣

**ចំណងជើងមេរៀនៈ បទពិសោធន៍ និងការអនុវត្តជាក់ស្តែងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា**

**ពេលវេលាៈ ០១ះ៤៥ ដល់ ០២ះ៤៥ (១ម៉ោង)**

**គោលបំណងមេរៀនៈ** នៅចុងបញ្ចប់មេរៀននេះ អ្នកចូលរួមនឹងអាច

១. រំលឹកពីព្រឹត្តិការណ៍សំខាន់ៗនៃដំណើរការលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ដែលរួមបញ្ចូលដំណើរការអនុវត្តគណនេយ្យភាពសង្គម ។

២. ឆ្លុះបញ្ចាំង ពីកិច្ចខិតខំប្រឹងប្រែងកន្លងមកក្នុងការលើកកម្ពស់ការអនុវត្តសកម្មភាពអភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គមនៅមូលដ្ឋាន ។

**កំណត់ចំណាំរបស់អ្នកសម្របសម្រួល**

នៅក្នុងមេរៀននេះ អ្នកសម្របសម្រួលមានគោលបំណងចំនួន៣ៈ

១. និយាយប្រាប់ពីព្រឹត្តិការណ៍សំខាន់ៗ អំពីការលទ្ធិប្រជាធិបតេយ្យ និងដំណើរការអនុវត្តសកម្មភាពអភិបាល កិច្ចល្អ និងគណនេយ្យភាពសង្គមនៅប្រទេសកម្ពុជា ។

២. ឆ្លុះបញ្ចាំងពីសមិទ្ធផលមួយចំនួនដែលរដ្ឋាភិបាល និងសង្គមស៊ីវិលសម្រេចបានចាប់តាំងពីឆ្នាំ ១៩៩៣

៣. ជួយអ្នកចូលរួមលើកឡើងនូវបទពិសោធន៍ជាក់ស្តែងដែលបានអនុវត្តកន្លងមកក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ និងដំណើរការអនុវត្តអភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គម

**លទ្ធផលរំពឹងទុកនៃមេរៀន**

ក) អ្នកចូលរួមនឹងបានស្វែងយល់ពីទិដ្ឋភាពទូទៅស្តីពីប្រវត្តិនៃការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា និងអាចចែករំលែកបទពិសោធន៍ឱ្យគ្នាទៅវិញទៅមក ។

ខ) អ្នកចូលរួមទទួលបានចំណេះដឹងកាន់តែប្រសើរឡើងស្តីពីវឌ្ឍនភាព នៃការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យ និងដំណើរការអនុវត្តអភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គមនៅកម្ពុជា ។

គ) អ្នកចូលរួមយល់ដឹងពីការផ្លាស់ប្តូរតួនាទី ភារកិច្ចរបស់អង្គការសង្គមស៊ីវិលរួមទាំងអង្គការមិនមែនរដ្ឋាភិបា លផងដែរ ។

## សម្ភារៈឧបទ្ទេសសម្រាប់មេរៀន

- ឯកសារចែកៈ ដំណើរការលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា
- ហ្វឹតសសេរក្រដាស ក្រដាស់ផ្ទាំងធំ ស្កុតក្រដាស
- ឯកសារបទបង្ហាញ

## ឯកសារយោង

- ឯកសារកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជំពូកទី១ ទំព័រ២-១៥
- ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ២០០៥-២០០៩ រាជរដ្ឋាភិបាលកម្ពុជា ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥
- សៀវភៅណែនាំសម្រាប់គ្រូស្តីពីគណនេយ្យភាពសង្គម - ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅកម្ពុជា - អង្គការសីលការ មិថុនា ២០១០

## របៀបសម្របសម្រួលមេរៀន

| រយៈពេល | សកម្មភាព និងវិធីសាស្ត្រ | សម្ភារៈ/ឯកសារចែក |
|---|---|---|
| ៥ នាទី | <u>សកម្មភាពទី១ - សេចក្តីផ្តើម និងគោលបំណងមេរៀន</u><br>• យើងបានពិភាក្សា និងយល់ពីអត្ថន័យ សារៈសំខាន់ និងភាពទាក់ទងគ្នានៃអភិបាលកិច្ចល្អ វិមជ្ឈការ និងគណនេយ្យភាពសង្គម<br>• អ្នកចូលរួមភាគច្រើនបានដឹងពីភាពរីកចំរើននៃដំណើរការអនុវត្តអភិបាលកិច្ចល្អ វិមជ្ឈការ និងគណនេយ្យភាពសង្គមនៅកម្ពុជា ។<br>• មេរៀននេះនឹងរៀបរាប់ពីប្រវត្តិសង្ខេបនៃដំណើរការលទ្ធិប្រជាធិបតេយ្យ និងគណនេយ្យភាពសង្គមនៅកម្ពុជា ។<br>• បង្ហាញគោលបំណងមេរៀន | ស្លាយទី២<br>ឯកសារចែក |

| | | |
|---|---|---|
| ២៥ នាទី | **សកម្មភាពទី២ - ការបំផុសគំនិតអំពីព្រឹត្តិការណ៍អនុវត្តលទ្ធិប្រជាធិបតេយ្យ (អភិបាលកិច្ចល្អ វិមជ្ឈការ និងសហវិមជ្ឈការ) និងគណនេយ្យភាពសង្គម**<br>• ចែកអ្នកចូលរួម៤ក្រុម ដើម្បីពិភាក្សាសំណួរដូចខាងក្រោម<br>១- តើមានព្រឹត្តិការណ៍សំខាន់ៗអ្វីខ្លះទាក់ទងនឹងដំណើរការអនុវត្ត (រីកចំរើន)នៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៣ មកដល់បច្ចុប្បន្ន?<br>២- តើអង្គការសង្គមស៊ីវិលបានចូលរួមធ្វើអ្វីខ្លះក្នុងដំណើរការអនុវត្តលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៣ មកដល់បច្ចុប្បន្ន?<br>៣- តើមានព្រឹត្តិការណ៍ ឬសកម្មភាពសំខាន់ៗអ្វីខ្លះទាក់ទងនឹងដំណើរការអនុវត្តគណនេយ្យភាពសង្គមដោយរដ្ឋាភិបាល?<br>៤- តើមានព្រឹត្តិការណ៍ ឬសកម្មភាពសំខាន់ៗអ្វីខ្លះ ទាក់ទងនឹងដំណើរការអនុវត្តគណនេយ្យភាពសង្គម ដោយអង្គការសង្គមស៊ីវិល?<br>• ក្រុមនិមួយៗកត់ត្រាចម្លើយក្នុងសៀវភៅ<br>• តំណាងក្រុមនីមួយៗបង្ហាចម្លើយ ។<br>• អ្នកសម្របសម្រួលកត់ត្រារាល់ចម្លើយលើក្រដាសផ្ទាំងធំ | ស្លាយទី៣ |
| ២៥ នាទី | **សកម្មភាពទី៣ - បទបង្ហាញ អំពីព្រឹត្តិការណ៍អនុវត្តលទ្ធិប្រជាធិបតេយ្យ (អភិបាលកិច្ចល្អ វិមជ្ឈការ និងសហវិមជ្ឈការ) និងគណនេយ្យភាពសង្គម**<br>• បទបង្ហាញ និងសួរបញ្ជាក់អ្នកចូលរួមថាតើមានព្រឹត្តិការណ៍ ឬសកម្មភាពទាំងនេះកើតឡើងមែនឬទេ?<br>១-បង្ហាញពីព្រឹត្តិការណ៍សំខាន់ៗនៃដំណើរការអភិវឌ្ឍលទ្ធិ | ស្លាយទី៤-៥ |

| | | |
|---|---|---|
| | ប្រជាធិបតេយ្យចាប់តាំងពីឆ្នាំ១៩៩៣មកដល់បច្ចុប្បន្ន<br>២-បង្ហាញពីសកម្មភាពចូលរួមចំណែករបស់អង្គការសង្គមស៊ីវិលក្នុងដំណើរការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យចាប់តាំងពី ឆ្នាំ១៩៩៣មកដល់បច្ចុប្បន្ន<br>៣-បង្ហាញព្រឹត្តិការណ៍សំខាន់ៗទាក់ទងនឹងដំណើរការអនុវត្តគណនេយ្យភាពសង្គមដោយរដ្ឋាភិបាល<br>៤-បង្ហាញសកម្មភាពសំខាន់ៗរបស់អង្គការសង្គមស៊ីវិលដែលចូលរួមចំណែកក្នុងដំណើរការអនុវត្តគណនេយ្យភាពសង្គម (<u>ស្លាយទី៦ដល់ទី៩</u>)<br>• សួរអ្នកចូលរួមបន្ទាប់ពីចប់បទបង្ហាញ តើនៅមានព្រឹត្តិការណ៍ ឬសកម្មភាពអ្វីខ្លះទៀតមិនបានលើកមកបង្ហាញ? | ស្លាយទី៦ដល់ទី៩ |
| ៥ នាទី | <u>**សកម្មភាពទី៤ - សេចក្តីសន្និដ្ឋានមេរៀន**</u><br>១- សង្ខេបព្រឹត្តិការណ៍សំខាន់ៗនៅក្នុងដំណើរការអនុវត្តលទ្ធិប្រជាធិបតេយ្យ (អភិបាលកិច្ចល្អ វិមជ្ឈការ និងសហវិមជ្ឈការ)នៅកម្ពុជា<br>២- សង្ខេបព្រឹត្តិការណ៍ឬសកម្មភាពសំខាន់ៗចូលរួមចំណែករបស់អង្គការសង្គមស៊ីវិលក្នុងដំណើរការអនុវត្តលទ្ធិប្រជាធិបតេយ្យ (អភិបាលកិច្ចល្អ វិមជ្ឈការ និងសហវិមជ្ឈការ)នៅកម្ពុជា<br>៣- សង្ខេបព្រឹត្តិការណ៍សំខាន់ៗទាក់ទងនឹងដំណើរការអនុវត្តគណនេយ្យភាពសង្គមដោយរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដែលចូលរួមចំណែកក្នុងដំណើរការអនុវត្តលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។<br>៤- ពន្យល់ថា ក្នុងរយៈពេលបណ្តុះបណ្តាលចំនួនបីថ្ងៃនេះ យើងនឹងបន្តពិភាក្សាឱ្យបានស៊ីជម្រៅពីឧបករណ៍ និងរបៀប | |

| | | |
|---|---|---|
| | អនុវត្តអភិបាលកិច្ចល្អ វិមជ្ឈការ និងគណនេយ្យភាពសង្គម និងការភ្ជាប់ទំនាក់ទំនងរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។ | |

ថ្ងៃទី១ មេរៀនទី៣

# បទពិសោធន៍ និងការអនុវត្តជាក់ស្តែង លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា

# គោលបំណងមេរៀន

១. រំលឹកពីព្រឹត្តិការណ៍សំខាន់ៗនៃដំណើរការលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ដែលរួមបញ្ចូលដំណើរការអនុវត្តគណនេយ្យភាពសង្គម ។

២. ឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងកន្លងមកក្នុងការលើកកម្ពស់ការអនុត្តសកម្មភាពអភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គមនៅមូលដ្ឋាន

# សំណួរបំផុសគំនិត

១. តើមានព្រឹត្តិការណ៍សំខាន់ៗអ្វីខ្លះទាក់ទងនឹងដំណើរការអនុវត្ត (ការរីកចំរើន) នៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៣ មកដល់បច្ចុប្បន្ន?

២. តើអង្គការសង្គមស៊ីវិលបានចូលរួមធ្វើអ្វីខ្លះក្នុងដំណើរការអនុវត្តលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៣ មកដល់បច្ចុប្បន្ន?

៣. តើមានព្រឹត្តិការណ៍ ឬសកម្មភាពសំខាន់ៗអ្វីខ្លះ ទាក់ទងនឹងដំណើរការអនុវត្តគណនេយ្យភាពសង្គមដោយរដ្ឋាភិបាល?

៤. តើមានព្រឹត្តិការណ៍ ឬសកម្មភាពសំខាន់ៗអ្វីខ្លះ ទាក់ទងនឹងដំណើរការអនុវត្តគណនេយ្យភាពសង្គម ដោយអង្គការសង្គមស៊ីវិល?

# ដំណើរការវិវឌ្ឍនៃលទ្ធិប្រជាធិបតេយ្យ

រដ្ឋធម្មនុញ្ញ ១៩៩៣
បោះឆ្នោតតំណាងរាស្ត្រ ១៩៩៣

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ លើកទី១

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១

ក្របខ័ណ្ឌយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

បោះឆ្នោត ព្រឹទ្ធសភា

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ និងច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ផែនការអភិវឌ្ឍ យុទ្ធសាស្ត្រជាតិ (២០០៩_២០១៣)

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

1993 | 2001 | 2002 | 2004-2008 | 2005 | 2008-2013 | 2009 | 2010

អនាគតនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

# ដំណើរការវិវឌ្ឍនៃលទ្ធិប្រជាធិបតេយ្យ



# ការអនុវត្តគណនេយ្យភាពសង្គមកន្លងមក

ក - ការបង្កើតយន្តការរបស់រដ្ឋាភិបាល

ខ - ការអនុវត្តន៏ឧបករណ៏គណនេយ្យសង្គមរបស់សង្គមស៊ីវិល

# ការអនុវត្តគណនេយ្យភាពសង្គមកន្លងមក(ត)

**ក - ការខិតខំប្រឹងប្រែង និងការបង្កើតយន្តការរបស់រដ្ឋាភិបាល**

- ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- ក្រុមប្រឹក្សាសម្របសម្រួលទំនាស់ដីធ្លី
- ក្រុមប្រឹក្សាអាជ្ញាកណ្តាល-ក្រសួងការងារ
- ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ
- ប្រអប់គណនេយ្យភាព
- គម្រោងអភិបាលកិច្ចល្អរបស់ក្រសួងមហាផ្ទៃ (DFGG)
- ក្រុមការងារគណនេយ្យភាពថ្នាក់ជាតិ
- ក្រុមការងារគណនេយ្យភាពថ្នាក់ខេត្ត-រាជធានី
- គណៈកម្មាធិការស្ត្រីកុមាររបស់ឃុំ/សង្កាត់

# ការអនុវត្តគណនេយ្យភាពសង្គមកន្លងមក (ត)

## ២ - ការអនុវត្តន៍គណនេយ្យភាពរបស់សង្គមស៊ីវិល

- លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការកសាងផែនការ និងថវិកា ការប្រជុំប្រចាំខែ វេទិកាសាធារណៈ របស់ឃុំ សង្កាត់ (កម្មវិធីល្អ)
- ការផ្សព្វផ្សាយសាធារណៈនូវចំណូលចំណាយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ត្រួតពិនិត្យការគ្រប់គ្រង ថវិការបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដោយគណៈកម្មការគ្រប់គ្រងគម្រោងរបស់ឃុំដែលមានសមាសភាពសហគមន៍
- ការត្រួតពិនិត្យតាមដាន និងផ្តល់យោបល់ត្រឡប់របស់ប្រជាពលរដ្ឋទៅលើគុណភាព តម្លាភាពនៃការផ្តល់សេវាសាធារណៈ (គាំទ្រដោយគម្រោងDFGG របស់ក្រសួងមហាផ្ទៃ អនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាល)

# ការអនុវត្តគណនេយ្យសង្គមកន្លងមក (ត)

## ២ - ការអនុវត្តន៍គណនេយ្យភាពរបស់សង្គមស៊ីវិល

- ការឃ្លាំមើលសាធារណៈ របាយការណ៍ស្តីពីការកំណត់ ចំណាត់ថ្នាក់ដោយប្រជាពលរដ្ឋចំពោះការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំសង្កាត់អនុវត្តដោយ អង្គការមិនមែនរដ្ឋាភិបាល (NGOs)
- ការសិក្សាស្ទង់មតិរបស់ប្រជាពលរដ្ឋដោយ កម្មវិធីល្អ និង GIZ/SPACE
- ដំណើរការទទួលព័ត៌មានត្រឡប់តាមរយៈការិយាល័យប្រជាពលរដ្ឋនៃគម្រោងច្រកចេញចូលតែមួយ

# ឯកសារចែក

# មេរៀនទី៣ថ្ងៃទី១

## ១-លំហូរពេលវេលានៃដំណើរការលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា

- **១៩៩៣ :** រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា បានអនុម័តនៅ ថ្ងៃទី ២៤ កញ្ញា ១៩៩៣ ។

  - **មាត្រា ៥១ ( ប្រជាធិបតេយ្យសេរី អធិបតេយ្យភាព អំណាច)**

  ១. ព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស ។

  ២. ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។

  ៣. អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួន តាមរយៈរដ្ឋសភា ព្រឹទ្ធសភា រដ្ឋាភិបាល និងសាលាជំរះក្តី ។

  ៤. អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

- **១៩៩៣ : ការបោះឆ្នោតសភាជាតិ** ត្រូវធ្វើឡើងរៀងរាល់៥ឆ្នាំម្តង ដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ។ ការបោះឆ្នោតត្រូវបានប្រព្រឹត្តឡើងនៅក្នុងឆ្នាំ១៩៩៨ ឆ្នាំ២០០០ និងពេលថ្មីៗបំផុតក្នុងឆ្នាំ២០០៨ ។ ការបោះឆ្នោតសភាជាតិ លើកបន្ទាប់នឹងត្រូវប្រព្រឹត្តទៅ នៅក្នុងឆ្នាំ ២០១៣ ។

- **២០០១ :** រាជរដ្ឋាភិបាលកម្ពុជា **បានចាប់ផ្តើមអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ លើកដំបូងនៅថ្នាក់ឃុំ សង្កាត់** ។

- **២០០១ :** ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតឃុំ សង្កាត់ ត្រូវបានអនុម័ត ។

- **១៩ មីនា ២០០១ : ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។** រាជរដ្ឋាភិបាលកម្ពុជា បាន ចាប់ផ្តើមអនុវត្ត គោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ របស់ខ្លួននៅថ្នាក់ឃុំសង្កាត់ ។

- **២០០២ : ប្រជាពលរដ្ឋបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា នៅក្នុងឃុំ សង្កាត់ចំនួន ១៦២១ នៅទូទាំង ប្រទេស ។** ការបោះឆ្នោតឃុំ សង្កាត់ លើកទីពីរ ត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ ២០០៧ ។

- **២០០២ : ការបោះឆ្នោតក្រុមប្រឹក្សាឃុំ លើកដំបូង ។** ការបោះឆ្នោតក្រុមប្រឹក្សាឃុំ ត្រូវធ្វើឡើងរៀងរាល់៥ឆ្នាំ ម្តង ។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ លើកទីពីរ ត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ **២០០៧** ។

- **២០០៤-២០០៨ : យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ។** អភិបាលកិច្ចល្អ គឺជាសមាសធាតុស្នូល នៅក្នុងយុទ្ធសាស្ត្រចតុកោណ ។
  - *យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាផ្តោតលើ :* ការប្រឆាំងអំពើពុករលួយ កំណែទម្រង់ច្បាប់ និងតុលាការ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់កងកំលាំង ប្រដាប់អាវុធ ។
  - នៅក្នុងកំណែទម្រង់រដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាលទទួលស្គាល់ថា *វិមជ្ឈការ* គឺជារឿង សំខាន់ដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យ និងវិស័យទាំងអស់ សំដៅលើកកម្ពស់គុណភាពនៃការ ផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដោយមានការចូលរួម (ទំព័រទី៨) ។

- **១៧ មិថុនា ២០០៥ : ក្របខ័ណ្ឌយុទ្ធសាស្ត្រ ស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** គឺជាឯកសារ គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលណែនាំពីដំណើរការនៃកំណែទម្រង់អភិបាលកិច្ច នៅថ្នាក់ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ។

- **១៧ មិថុនា ២០០៥ :** ក្រោយការបោះឆ្នោតជាសកលជ្រើសរើសតាំងតំណាងរាស្ត្រនីតិកាលទី២ នាថ្ងៃទី២៦ កក្កដា ១៩៩៨ វិបត្តិនយោបាយផ្ទៃក្នុងមួយបានកើតឡើង ។ ដើម្បីដោះស្រាយវិបត្តិនេះ កិច្ចប្រជុំកំពូលរវាង ថ្នាក់ដឹកនាំជាន់ខ្ពស់នៃគណបក្សនយោបាយទាំងពីរ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិចបាន ប្រារព្ធឡើងពីថ្ងៃទី១២-១៣ វិច្ឆិកា ឆ្នាំ ១៩៩៨ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តមសីហនុ ។ តាមរយៈលទ្ធផលនៃកិច្ចប្រជុំនេះ ស្ថាប័នព្រឹទ្ធសភាត្រូវបានបង្កើតឡើង ដែលមាន សមាជិកចំនួន ៦១ រូប ហើយបានបើកប្រជុំនីតិកាលទី១ លើកទី១ ថ្ងៃទី២៥ មីនា ១៩៩៩ ។ ព្រឹទ្ធសភានីតិកាល ទី១ បានបើកសម័យប្រជុំលើកទី១ ថ្ងៃទី ២៥ មីនា ១៩៩៩ ។ ព្រឹទ្ធសភានីតិកាលទី២ កើតឡើងដោយការបោះ ឆ្នោតជាអសកល នាថ្ងៃអាទិត្យទី២២ មករា ២០០៦ ដោយមានអាណត្តិ ៦ឆ្នាំ ។

- **២០០៦ :** ច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ បានកែប្រែ ។

- **២០០៦-២០១០ : ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ** - ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ក៏បានចាត់ទុកថា **កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** គឺជាមធ្យោបាយមួយដើម្បីបង្កើន និងធ្វើឱ្យប្រសើរឡើងនូវការផ្តល់ សេវាសាធារណៈ និងការពង្រឹងការអភិវឌ្ឍមូលដ្ឋាន (ទំព័រទី ៣៨) ។

- **២២ ឧសភា ២០០៨ :** ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

- **២៦ កញ្ញា ២០០៨ :** យុទ្ធសាស្ត្រចតុកោណដំណាក់កាលទីពីរ របស់រាជរដ្ឋាភិបាលកម្ពុជា ។

- **២០០៨-២០១៣ :** យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ដើម្បីសម្រេចឱ្យបាននូវអភិបាលកិច្ចល្អ យុទ្ធសាស្ត្រចតុកោណបានប្តេជ្ញាដើម្បីឱ្យរាជរដ្ឋាភិបាល ផ្តោតលើកំណែទម្រង់ចំនួនបួន គឺ ការប្រឆាំងអំពើ ពុករលួយ កំណែទម្រង់ច្បាប់ និងតុលាការ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់កងកំលាំងប្រដាប់ អាវុធ ។ រាជរដ្ឋាភិបាលបានចាត់ទុក ការធ្វើវិមជ្ឈការគឺជារឿងសំខាន់ ដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យ និង វិស័យទាំងអស់ សំដៅលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដោយមាន ការចូលរួម ។

- **២៨ ឧសភា ២០១០ :** កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជារបៀប វារៈរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់រយៈពេល១០ឆ្នាំខាងមុខ ។ កម្មវិធីនេះ ត្រូវបានបង្កើតឡើងដើម្បី សម្រេចឱ្យបាននូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

## ២. លំហូរពេលវេលាស្របគ្នា ស្តីពីសង្គមស៊ីវិល និងអង្គការសង្គមស៊ីវិល

**បរិបទប្រទេសកម្ពុជា : ប្រវត្តិដើម និងការវិវត្តន៍នៃសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល នៅក្នុងប្រទេសកម្ពុជា និងតួនាទីរបស់ខ្លួន ក្នុងដំណើរការអភិវឌ្ឍន៍ប្រទេសជាតិ ។**

- ១៩៥៤-១៩៧០ : បន្ទាប់ពីបានឯករាជ្យពីអាណានិគមបារាំង បើទោះបីជាមានវត្តមាននៃសង្គមស៊ីវិលនៅក្នុង រូបភាពជាច្រើនក្តី គេក៏ពុំមានភស្តុតាងណាមួយបញ្ជាក់ពីការផ្លាស់ប្តូរនៃអង្គការមិនមែនរដ្ឋាភិបាលដែលបានបង្កើត ឡើងនៅក្នុងស្រុកឡើយ ។

- ១៩៧០-១៩៧៥ : នៅក្នុងសង្គ្រាមសម័យ លន់ ណុល ការផ្តល់ជំនួយរបស់អង្គការមិនមែនរដ្ឋាបាលអន្តរជាតិ ដែលមានរូបភាពជាការសង្គ្រោះជនដែលទទួលរងគ្រោះពីសង្គ្រាម ត្រូវបានជំនួសមកវិញដោយការផ្តល់ជំនួយសម្រាប់ការអភិវឌ្ឍទ្វេភាគី ។
- ១៩៧៥-១៩៧៩ : អំឡុងរបបខ្មែរក្រហម គេពុំឃើញមានវត្តមាននៃតំណាងអន្តរជាតិនៅក្នុងប្រទេសកម្ពុជាទេ លើកលែងតែតំណាងមកពីប្រទេសចិន និងប្រទេសកូរ៉េខាងជើង ។
- ១៩៧៩-១៩៨២ : បន្ទាប់ពីទទួលបានសេរីភាពពីរបបខ្មែរក្រហមរួចមក មានបណ្តាអង្គការមិនមែនរដ្ឋាភិបាល អន្តរជាតិជាច្រើន បានផ្តួចផ្តើមនូវកម្មវិធីសង្គ្រោះបន្ទាន់ ដោយប្រតិបត្តិការទាំងនៅក្នុងប្រទេសកម្ពុជា និងនៅតាម បណ្តោយព្រំដែន ខ្មែរ-ថៃ ។
    - មានការអនុវត្តនីកម្មវិធីសង្គ្រោះបន្ទាន់ជាច្រើន ត្រូវបានគ្របដណ្តប់ស្ទើរតែគ្រប់វិស័យនៃសេដ្ឋកិច្ច និងសង្គមកិច្ច ដូចជាសុខាភិបាល ផលិតផលកសិកម្ម និងការដឹកជញ្ជូន ព្រមទាំងលើកទឹកចិត្តឱ្យមានកិច្ចសហការល្អ និងកិច្ចសហប្រតិបត្តិការរវាងភ្នាក់ងារអង្គការសហប្រជា ជាតិ កាកបាទក្រហមអន្តរជាតិ អង្គការមិនមែនរដ្ឋាបាល និងដៃគូរដ្ឋាភិបាលនានា ។
- ១៩៨២ : អង្គការសហប្រជាជាតិ បានប្រកាសថា ប្រទេសកម្ពុជាជាប្រទេសមានអាសន្ន និងប្រឆាំងទៅនឹងការ ផ្តល់ជំនួយដល់ប្រទេសនេះ (ជាផ្នែកមួយនៃប្លុកសង្គមនិយម) ដែលការប្រកាសនោះត្រូវពន្យាពេលដល់ឆ្នាំ ១៩៩១ បន្ទាប់ពីបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាព ។
- ក្នុងឆ្នាំ ១៩៨៦ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិនានា បានចាប់ផ្តើមយុទ្ធនាការតស៊ូមតិជាអន្តរជាតិ សំដៅធ្វើ ឱ្យមានការផ្លាស់ប្តូរនៃការដាក់គំនាបនៃគោលនយោបាយបច្ចឹមប្រទេស ពីការបោះបង់ និងការហាមឃាត់ការផ្តល់ ជំនួយដល់ប្រទេសកម្ពុជា ។
- ១៩៨៧ : ការផ្តល់ជំនួយទ្វេភាគី សម្រាប់ការសង្គ្រោះបន្ទាន់ ត្រូវបានផ្តល់តាមរយៈ UNICEF, WFP, UNHCR, និង ICRC ។ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិនានា ត្រូវបានបង្ខំចិត្តឱ្យផ្លាស់ប្តូរតួនាទីនៃ ការគាំទ្ររដ្ឋបាលថ្នាក់ជាតិ ដែលផ្ទុយពីភាពខ្លាំងរបស់ខ្លួន ក្នុងការធ្វើការនៅថ្នាក់មូលដ្ឋាន ។
- ១៩៨៨-១៩៩១ : ការបង្កើនជំនួយទ្វេភាគី សម្រាប់សកម្មភាពមនុស្សធម៌ត្រូវបានធ្វើឡើងតាមរយៈ អង្គការ មិនមែនរដ្ឋាភិបាលអន្តរជាតិ ដែលភាគច្រើនជាអង្គការដែលបានចេញពីព្រំដែនមកធ្វើការនៅក្នុងប្រទេសកម្ពុជា។ អង្គការទាំងនេះ បានពង្រីកវិសាលភាពគ្របដណ្តប់ការងាររបស់ខ្លួន

និងការបោះទីតាំងដោយផ្អែកលើកត្តា ភូមិសាស្ត្រ ក្នុងនោះរួមមានការផ្តល់វគ្គបណ្តុះបណ្តាលដល់ដៃគូអនុវត្តរបស់រដ្ឋាភិបាល ការធ្វើឱ្យមានការចូលរួមប្រកបដោយអត្ថន័យនៅក្នុងការកសាងផែនការ និងការអនុវត្តន៍កម្មវិធី ហើយបានចាប់ផ្តើមងាកទៅរកតួនាទីដែលធ្លាប់ធ្វើកន្លងមកជាមួយសហគមន៍មូលដ្ឋានវិញ ។ ម្ចាស់ជំនួយទ្វេភាគី និងពហុភាគី បានប្រើប្រាស់អង្គការ មិនមែនរដ្ឋាភិបាលអន្តរជាតិ ជំនួយឱ្យស្ថាប័នរបស់រដ្ឋាភិបាល ។ ស្របពេលជាមួយគ្នានេះដែរ បណ្តាសហគមន៍ អន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិនានា បានរួមចំណែកគាំទ្រដល់កិច្ចចចារសន្តិភាពកម្ពុជា ដោយទទួលបានលទ្ធផលស្តីពីការចុះហត្ថលេខាស្តីពីកិច្ចព្រមព្រៀងទីក្រុងបារីសក្នុងខែ តុលា ឆ្នាំ ១៩៩១ ។

- ១៩៩២-១៩៩៧ : អង្គការសហប្រជាជាតិ ានគ្រប់គ្រងការងារបោះឆ្នោតពហុបក្សដែលបានធ្វើឡើងក្នុងឆ្នាំ (១៩៩៣) ដោយទទួលបាននូវរដ្ឋាភិបាលចម្រុះ ការធ្វើសមាហរណកម្មប្រទេសកម្ពុជាឡើងវិញទៅក្នុងសហគមន៍ ពិភពលោក ។ ប្រជាពលរដ្ឋខ្មែរជាច្រើនបានវិលត្រឡប់ពីបរទេសមកកាន់មាតុភូមិរបស់ខ្លួន ។ អង្គការមិនមែន រដ្ឋាភិបាលក្នុងស្រុក បានលេចឡើងហើយរីកសាយយ៉ាងលឿន ដោយមានការគាំទ្រពីម្ចាស់ជំនួយ និងតម្រូវការដើម្បីអនុវត្តនូវរបៀបវារៈនានារបស់ម្ចាស់ជំនួយនីមួយៗ ។ ក្នុងអំឡុងពេលនោះ ការយល់ដឹងនៃសហគមន៍ម្ចាស់ជំនួយ ស្តីពីសង្គមស៊ីវិល មានន័យថាជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលទើបតែបង្កើតថ្មី ។
- ១៩៩៨-២០០៤ : រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទីពីរ ត្រូវបានបោះឆ្នោតជ្រើសរើស ហើយដោយមានការគាំទ្រពីសហគមន៍ម្ចាស់ជំនួនអន្តរជាតិផងនោះ បានធ្វើឱ្យរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើរបៀប វារៈកំណែទម្រង់លើវិស័យជាច្រើន ដូចជាកំណែទម្រង់សេដ្ឋកិច្ច ការរំសាយកងទ័ព កំណែទម្រង់រដ្ឋបាល និង កំណែទម្រង់វិស័យសង្គមកិច្ច ។

## ៣. ដំណើរការអនុវត្តគណនេយ្យភាពសង្គមនៅកម្ពុជា

នៅក្នុងឆ្នាំ២០០២ រដ្ឋាភិបាល និងទីភ្នាក់ងារផ្តល់ជំនួយបានប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីពង្រឹងគណនេយ្យភាព ជាពិសេសទាក់ទងទៅនឹងអភិបាលកិច្ចល្អ ការផ្តល់សេវាកម្មល្អប្រសើរ និងការធ្វើឱ្យប្រសើរ ឡើង នូវសមិទ្ធិផលសង្គមនានា។ រដ្ឋាភិបាល ទីភ្នាក់ងារផ្តល់ជំនួយ និងសង្គមស៊ីវិលទទួលស្គាល់ថា អភិបាលកិច្ចល្អមិនអាចសម្រេចផល និងមាននិរន្តរភាពបានទេ ប្រសិនបើគ្មានប្រព័ន្ធគណនេយ្យភាព ដែលអាចដំណើរការបាន ហើយប្រព័ន្ធនោះត្រូវតែឆ្លើយតបនឹងបរិបទ របស់ស្ថាប័ន អភិបាលកិច្ច និងវប្បធម៌របស់ប្រទេសកម្ពុជា ។

គណនេយ្យភាពសង្គម

គឺជាដំណើរការដែលប្រជាពលរដ្ឋចូលរួមក្នុងការវាយតម្លៃការអនុវត្តលើគោលនយោបាយសាធារណៈ និងធ្វើឱ្យមានឥទ្ធិពលដល់ដំណើរការ លទ្ធផល និងផលប៉ះពាល់នៃគោលនយោបាយទាំងនោះ ។

**ក. ការខិតខំប្រឹងប្រែង និងការបង្កើតយន្តការរបស់រដ្ឋាភិបាល**

- ក្រុមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- ក្រុមប្រឹក្សាសម្របសម្រួលទំនាស់ដីធ្លី
- ក្រុមប្រឹក្សាអាជ្ញារកណ្តាល-ក្រសួងការងារ
- ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ
- ប្រអប់គណនេយ្យភាព
- គម្រោងអភិបាលកិច្ចល្អរបស់ក្រសួងមហាផ្ទៃ (DFGG)
- ក្រុមការងារគណនេយ្យភាពថ្នាក់ជាតិ
- ក្រុមការងារគណនេយ្យភាពថ្នាក់ខេត្ត-រាជធានី
- គណៈកម្មាធិការស្ត្រីកុមាររបស់ឃុំ/សង្កាត់

**ខ - ការអនុវត្តន៍គណនេយ្យភាពរបស់សង្គមស៊ីវិល**

- លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការកសាងផែនការ និងថវិកា ការប្រជុំប្រចាំខែ វេទិកាសាធារណៈ របស់ឃុំ សង្កាត់ (កម្មវិធីល្អ)
- ការផ្សព្វផ្សាយសាធារណៈនូវចំណូលចំណាយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ត្រួតពិនិត្យការគ្រប់គ្រង ថវិការបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដោយគណៈកម្មការគ្រប់គ្រងគម្រោងរបស់ឃុំដែលមានសមាសភាពសហគមន៍
- ការត្រួតពិនិត្យតាមដាន និងផ្តល់យោបល់ត្រឡប់របស់ប្រជាពលរដ្ឋទៅលើគុណភាព តម្លាភាពនៃការ ផ្តល់សេវាសាធារណៈ (គាំទ្រដោយគម្រោង DFGGរបស់ក្រសួងមហាផ្ទៃ អនុវត្តដោយអង្គការមិន មែនរដ្ឋាភិបាល)
- ការឃ្លាំមើលសាធារណៈ របាយការណ៍ស្តីពីការកំណត់ចំណាត់ថ្នាក់ដោយប្រជាពលរដ្ឋចំពោះការអនុវត្ត ការងាររបស់ក្រុមប្រឹក្សាឃុំសង្កាត់អនុវត្តដោយអង្គការមិនមែនរដ្ឋភិបាល (NGOs)
- ការសិក្សាស្ទង់មតិរបស់ប្រជាពលរដ្ឋដោយ កម្មវិធីល្អ និង GIZ/SPACE
- ដំណើរការទទួលព័តិមានត្រឡប់តាមរយៈការិយាល័យប្រជាពលរដ្ឋនៃគម្រោងច្រកចេញចូលតែ១

# ឯកសារចែក

# មេរៀនទី៣ថ្ងៃទី១

## ១. លំហូរពេលវេលានៃដំណើរការលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា

- **១៩៩៣ :** រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា បានអនុម័តនៅ ថ្ងៃទី ២៤ កញ្ញា ១៩៩៣ ។
  - **មាត្រា ៥១ ( ប្រជាធិបតេយ្យសេរី អធិបតេយ្យភាព អំណាច)**

  ១. ព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស ។

  ២. ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។

  ៣. អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួន តាមរយៈរដ្ឋសភា ព្រឹទ្ធសភា រដ្ឋាភិបាល និងសាលាជំរះក្តី ។

  ៤. អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

- **១៩៩៣ : ការបោះឆ្នោតសភាជាតិ** ត្រូវធ្វើឡើងរៀងរាល់៥ឆ្នាំម្តង ដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ។ ការបោះឆ្នោតត្រូវបានប្រព្រឹត្តឡើងនៅក្នុងឆ្នាំ១៩៩៨ ឆ្នាំ២០០០ និងពេលថ្មីៗបំផុតក្នុងឆ្នាំ២០០៨ ។ ការបោះឆ្នោតសភាជាតិ លើកបន្ទាប់នឹងត្រូវប្រព្រឹត្តទៅ នៅក្នុងឆ្នាំ ២០១៣ ។

- **២០០១ :** រាជរដ្ឋាភិបាលកម្ពុជា **បានចាប់ផ្តើមអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ លើកដំបូងនៅថ្នាក់ឃុំ សង្កាត់** ។

- **២០០១ :** ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតឃុំ សង្កាត់ ត្រូវបានអនុម័ត ។

- **១៩ មីនា ២០០១ : ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។** រាជរដ្ឋាភិបាលកម្ពុជា បានចាប់ផ្តើមអនុវត្ត គោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ របស់ខ្លួននៅថ្នាក់ឃុំសង្កាត់ ។

- **២០០២ : ប្រជាពលរដ្ឋបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា នៅក្នុងឃុំ សង្កាត់ចំនួន ១៦២១ នៅទូទាំងប្រទេស ។** ការបោះឆ្នោតឃុំ សង្កាត់ លើកទីពីរ ត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ ២០០៧ ។

- **២០០២ : ការបោះឆ្នោតក្រុមប្រឹក្សាឃុំ លើកដំបូង ។** ការបោះឆ្នោតក្រុមប្រឹក្សាឃុំ ត្រូវធ្វើឡើងរៀងរាល់៥ឆ្នាំ ម្តង ។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ លើកទីពីរ ត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ **២០០៧** ។

- **២០០៤-២០០៨ : យុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ។** អភិបាលកិច្ចល្អ គឺជាសមាសធាតុស្នូល នៅក្នុងយុទ្ធសាស្រ្តចតុកោណ ។

  - *យុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាផ្តោតលើ :* ការប្រឆាំងអំពើពុករលួយ កំណែទម្រង់ច្បាប់ និងតុលាការ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់កងកំលាំង ប្រដាប់អាវុធ ។
  - នៅក្នុងកំណែទម្រង់រដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាលទទួលស្គាល់ថា *វិមជ្ឈការ* គឺជារឿង សំខាន់ដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យ និងវិស័យទាំងអស់ សំដៅលើកកម្ពស់គុណភាពនៃការ ផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដោយមានការចូលរួម (ទំព័រទី៨) ។

- **១៧ មិថុនា ២០០៥ : ក្របខ័ណ្ឌយុទ្ធសាស្រ្ត ស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** គឺជាឯកសារ គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលណែនាំពីដំណើរការនៃកំណែទម្រង់អភិបាលកិច្ច នៅថ្នាក់ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ។

- **១៧ មិថុនា ២០០៥ :** ក្រោយការបោះឆ្នោតជាសកលជ្រើសរើសតាំងតំណាងរាស្រ្តនីតិកាលទី២ នាថ្ងៃទី២៦ កក្កដា ១៩៩៨ វិបត្តិនយោបាយផ្ទៃក្នុងមួយបានកើតឡើង ។ ដើម្បីដោះស្រាយវិបត្តិនេះ កិច្ចប្រជុំកំពូលរវាង ថ្នាក់ដឹកនាំជាន់ខ្ពស់នៃគណបក្សនយោបាយទាំងពីរ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិចបាន ប្រារព្ធឡើងពីថ្ងៃទី១២-១៣ វិច្ឆិកា ឆ្នាំ ១៩៩៨ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តមសីហនុ ។ តាមរយៈលទ្ធផលនៃកិច្ចប្រជុំនេះ ស្ថាប័នព្រឹទ្ធសភាត្រូវបានបង្កើតឡើង ដែលមាន សមាជិកចំនួន ៦១ រូប ហើយបានបើកប្រជុំនីតិកាលទី១ លើកទី១ ថ្ងៃទី២៥ មីនា ១៩៩៩ ។ ព្រឹទ្ធសភានីតិកាល ទី១ បានបើកសម័យប្រជុំលើកទី១ ថ្ងៃទី ២៥ មីនា ១៩៩៩ ។ ព្រឹទ្ធសភានីតិកាលទី២ កើតឡើងដោយការបោះ ឆ្នោតជាអសកល នាថ្ងៃអាទិត្យទី២២ មករា ២០០៦ ដោយមានអាណត្តិ ៦ឆ្នាំ ។

- **២០០៦ :** ច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ បានកែប្រែ ។

- **២០០៦-២០១០ : ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ** - ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ក៏បានចាត់ទុកថា **កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** គឺជាមធ្យោបាយមួយដើម្បីបង្កើន និងធ្វើឱ្យប្រសើរឡើងនូវការផ្តល់ សេវាសាធារណៈ និងការពង្រឹងការអភិវឌ្ឍមូលដ្ឋាន (ទំព័រទី ៣៨) ។

- **២២ ឧសភា ២០០៨ :** ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

- **២៦ កញ្ញា ២០០៨ :** យុទ្ធសាស្ត្រចតុកោណដំណាក់កាលទីពីរ របស់រាជរដ្ឋាភិបាលកម្ពុជា ។

- **២០០៨-២០១៣ :** យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ដើម្បីសម្រេចឱ្យបាននូវអភិបាលកិច្ចល្អ យុទ្ធសាស្ត្រចតុកោណបានប្តេជ្ញាដើម្បីឱ្យរាជរដ្ឋាភិបាល ផ្តោតលើកំណែទម្រង់ចំនួនបួន គឺ ការប្រឆាំងអំពើ ពុករលួយ កំណែទម្រង់ច្បាប់ និងតុលាការ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់កងកំលាំងប្រដាប់ អាវុធ ។ រាជរដ្ឋាភិបាលបានចាត់ទុកការធ្វើវិមជ្ឈការគឺជារឿងសំខាន់ ដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យ និង វិស័យទាំងអស់ សំដៅលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដោយមាន ការចូលរួម ។

- **២៨ ឧសភា ២០១០ :** កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជារបៀប វារៈរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់រយៈពេល១០ឆ្នាំខាងមុខ ។ កម្មវិធីនេះ ត្រូវបានបង្កើតឡើងដើម្បី សម្រេចឱ្យបាននូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

## ២_ លំហូរពេលវេលាស្របគ្នា ស្តីពីសង្គមស៊ីវិល និងអង្គការសង្គមស៊ីវិល

**បរិបទប្រទេសកម្ពុជា : ប្រវត្តិដើម និងការវិវត្តន៍នៃសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល នៅក្នុងប្រទេសកម្ពុជា និងតួនាទីរបស់ខ្លួន ក្នុងដំណើរការអភិវឌ្ឍន៍ប្រទេសជាតិ ។**

- ១៩៥៤-១៩៧០ : បន្ទាប់ពីបានឯករាជ្យពីអាណានិគមបារាំង បើទោះបីជាមានវត្តមាននៃសង្គមស៊ីវិលនៅក្នុង រូបភាពជាច្រើនក្តី គេក៏ពុំមានភស្តុតាងណាមួយបញ្ជាក់ពីការផ្លាស់ប្តូរនៃអង្គការមិនមែនរដ្ឋាភិបាលដែលបានបង្កើត ឡើងនៅក្នុងស្រុកឡើយ។

- ១៩៧០-១៩៧៥ : នៅក្នុងសង្គ្រាមសម័យ លន់ ណុល ការផ្តល់ជំនួយរបស់អង្គការមិនមែនរដ្ឋាបាលអន្តរជាតិ ដែលមានរូបភាពជាការសង្គ្រោះជនដែលទទួលរងគ្រោះពីសង្គ្រាម ត្រូវបានជំនួសមកវិញដោយការផ្តល់ជំនួយសម្រាប់ការអភិវឌ្ឍទ្វេភាគី ។
- ១៩៧៥-១៩៧៩ : អំឡុងរបបខ្មែរក្រហម គេពុំឃើញមានវត្តមាននៃតំណាងអន្តរជាតិនៅក្នុងប្រទេសកម្ពុជាទេ លើកលែងតែតំណាងមកពីប្រទេសចិន និងប្រទេសកូរ៉េខាងជើង ។
- ១៩៧៩-១៩៨២ : បន្ទាប់ពីទទួលបានសេរីភាពពីរបបខ្មែរក្រហមរួចមក មានបណ្តាអង្គការមិនមែនរដ្ឋាភិបាល អន្តរជាតិជាច្រើន បានផ្តួចផ្តើមនូវកម្មវិធីសង្គ្រោះបន្ទាន់ ដោយប្រតិបត្តិការទាំងនៅក្នុងប្រទេសកម្ពុជា និងនៅតាម បណ្តោយព្រំដែន ខ្មែរ-ថៃ ។
    - មានការអនុវត្តន៍កម្មវិធីសង្គ្រោះបន្ទាន់ជាច្រើន ត្រូវបានគ្របដណ្តប់ស្ទើរតែគ្រប់វិស័យនៃ សេដ្ឋកិច្ច និងសង្គមកិច្ច ដូចជាសុខាភិបាល ផលិតផលកសិកម្ម និងការដឹកជញ្ជូន ព្រមទាំងលើកទឹកចិត្តឱ្យមានកិច្ចសហការល្អ និងកិច្ចសហប្រតិបត្តិការរវាងភ្នាក់ងារអង្គការសហប្រជា ជាតិ កាកបាទក្រហមអន្តរជាតិ អង្គការមិនមែនរដ្ឋាបាល និងដៃគូរដ្ឋាភិបាលនានា ។
- ១៩៨២ : អង្គការសហប្រជាជាតិ បានប្រកាសថា ប្រទេសកម្ពុជាជាប្រទេសមានអាសន្ន និងប្រឆាំងទៅនឹងការ ផ្តល់ជំនួយដល់ប្រទេសនេះ (ជាផ្នែកមួយនៃប្លុកសង្គមនិយម) ដែលការប្រកាសនោះត្រូវពន្យាពេលដល់ឆ្នាំ ១៩៩១ បន្ទាប់ពីបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាព ។
- ក្នុងឆ្នាំ ១៩៨៦ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិនានា បានចាប់ផ្តើមយុទ្ធនាការតស៊ូមតិជាអន្តរជាតិ សំដៅធ្វើ ឱ្យមានការផ្លាស់ប្តូរនៃការដាក់គំនាបនៃគោលនយោបាយបច្ចឹមប្រទេស ពីការបោះបង់ និងការហាមឃាត់ការផ្តល់ ជំនួយដល់ប្រទេសកម្ពុជា ។
- ១៩៨៧ : ការផ្តល់ជំនួយទ្វេភាគី សម្រាប់ការសង្គ្រោះបន្ទាន់ ត្រូវបានផ្តល់តាមរយៈ UNICEF, WFP, UNHCR, និង ICRC ។ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិនានា ត្រូវបានបង្ខំចិត្តឱ្យផ្លាស់ប្តូរតួនាទីនៃ ការគាំទ្ររដ្ឋបាលថ្នាក់ជាតិ ដែលផ្ទុយពីភាពខ្លាំងរបស់ខ្លួន ក្នុងការធ្វើការនៅថ្នាក់មូលដ្ឋាន ។
- ១៩៨៨-១៩៩១ : ការបង្កើនជំនួយទ្វេភាគី សម្រាប់សកម្មភាពមនុស្សធម៌ត្រូវបានធ្វើឡើងតាមរយៈ អង្គការ មិនមែនរដ្ឋាភិបាលអន្តរជាតិ ដែលភាគច្រើនជាអង្គការដែលបានចេញពីព្រំដែន មកធ្វើការនៅក្នុងប្រទេសកម្ពុជា។ អង្គការទាំងនេះ បានពង្រីកវិសាលភាពគ្របដណ្តប់ការងាររបស់ខ្លួន

និងការបោះទីតាំងដោយផ្អែកលើកត្តា ភូមិសាស្ត្រ ក្នុងនោះរួមមានការផ្តល់វគ្គបណ្តុះបណ្តាលដល់ដៃគូអនុវត្តរបស់រដ្ឋាភិបាល ការធ្វើឱ្យមានការចូលរួមប្រកបដោយអត្ថន័យនៅក្នុងការកសាងផែនការ និងការអនុវត្តន៍កម្មវិធី ហើយបានចាប់ផ្តើមងាកទៅរកតួនាទីដែលធ្លាប់ធ្វើកន្លងមកជាមួយសហគមន៍មូលដ្ឋានវិញ ។ ម្ចាស់ជំនួយទ្វេភាគី និងពហុភាគីបានប្រើប្រាស់អង្គការ មិនមែនរដ្ឋាភិបាលអន្តរជាតិ ជំនួយឱ្យស្ថាប័នរបស់រដ្ឋាភិបាល ។ ស្របពេលជាមួយគ្នានេះដែរ បណ្តាសហគមន៍ អន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិនានាបានរួមចំណែកគាំទ្រដល់កិច្ចចចារសន្តិភាពកម្ពុជា ដោយទទួលបានលទ្ធផលស្តីពីការចុះហត្ថលេខាស្តីពីកិច្ចព្រមព្រៀងទីក្រុងបារីសក្នុងខែ តុលា ឆ្នាំ ១៩៩១ ។

- ១៩៩២-១៩៩៧ : អង្គការសហប្រជាជាតិ ានគ្រប់គ្រងការងារបោះឆ្នោតពហុបក្សដែលបានធ្វើឡើងក្នុងឆ្នាំ (១៩៩៣) ដោយទទួលបាននូវរដ្ឋាភិបាលចម្រុះ ការធ្វើសមាហរណកម្មប្រទេសកម្ពុជាឡើងវិញទៅក្នុងសហគមន៍ ពិភពលោក ។ ប្រជាពលរដ្ឋខ្មែរជាច្រើនបានវិលត្រឡប់ពីបរទេសមកកាន់មាតុភូមិរបស់ខ្លួន ។ អង្គការមិនមែន រដ្ឋាភិបាលក្នុងស្រុក បានលេចឡើងហើយរីកសាយយ៉ាងលឿន ដោយមានការគាំទ្រពីម្ចាស់ជំនួយ និងតម្រូវការដើម្បីអនុវត្តនូវរបៀបវារៈនានារបស់ម្ចាស់ជំនួយនីមួយៗ ។ ក្នុងអំឡុងពេលនោះ ការយល់ដឹងនៃសហគមន៍ម្ចាស់ជំនួយ ស្តីពីសង្គមស៊ីវិល មានន័យថាជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលទើបតែបង្កើតថ្មី ។
- ១៩៩៨-២០០៤ : រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទីពីរ ត្រូវបានបោះឆ្នោតជ្រើសរើស ហើយដោយមានការគាំទ្រពីសហគមន៍ម្ចាស់ជំនួនអន្តរជាតិផងនោះ បានធ្វើឱ្យរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើរបៀប វារៈកំណែទម្រង់លើវិស័យជាច្រើន ដូចជា កំណែទម្រង់សេដ្ឋកិច្ច ការរំសាយកងទ័ព កំណែទម្រង់រដ្ឋបាល និង កំណែទម្រង់វិស័យសង្គមកិច្ច ។

## ៣-ដំណើរការអនុវត្តគណនេយ្យភាពសង្គមនៅកម្ពុជា

នៅក្នុងឆ្នាំ២០០២ រដ្ឋាភិបាល និងទីភ្នាក់ងារផ្តល់ជំនួយបានប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីពង្រឹងគណនេយ្យភាព ជាពិសេសទាក់ទងទៅនឹងអភិបាលកិច្ចល្អ ការផ្តល់សេវាកម្មល្អប្រសើរ និងការធ្វើឱ្យប្រសើរ ឡើង នូវសមិទ្ធិផលសង្គមនានា។ រដ្ឋាភិបាល ទីភ្នាក់ងារផ្តល់ជំនួយ និងសង្គមស៊ីវិលទទួលស្គាល់ថា អភិបាលកិច្ចល្អមិនអាចសម្រេចផល និងមាននិរន្តរភាពបានទេ ប្រសិនបើគ្មានប្រព័ន្ធគណនេយ្យភាព ដែលអាចដំណើរការបាន ហើយប្រព័ន្ធនោះត្រូវតែឆ្លើយតបនឹងបរិបទ របស់ស្ថាប័ន អភិបាលកិច្ច និងវប្បធម៌របស់ប្រទេសកម្ពុជា ។

គណនេយ្យភាពសង្គម

គឺជាដំណើរការដែលប្រជាពលរដ្ឋចូលរួមក្នុងការវាយតម្លៃការអនុវត្តលើគោលនយោបាយសាធារណៈ និងធ្វើឱ្យមានឥទ្ធិពលដល់ដំណើរការ លទ្ធផល និងផលប៉ះពាល់នៃគោលនយោបាយទាំងនោះ ។

**ក. ការខិតខំប្រឹងប្រែង និងការបង្កើតយន្តការរបស់រដ្ឋាភិបាល**

- ក្រុមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- ក្រុមប្រឹក្សាសម្របសម្រួលទំនាស់ដីធ្លី
- ក្រុមប្រឹក្សាអាជ្ញាកណ្ដាល-ក្រសួងការងារ
- ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ
- ប្រអប់គណនេយ្យភាព
- គម្រោងអភិបាលកិច្ចល្អរបស់ក្រសួងមហាផ្ទៃ (DFGG)
- ក្រុមការងារគណនេយ្យភាពថ្នាក់ជាតិ
- ក្រុមការងារគណនេយ្យភាពថ្នាក់ខេត្ត-រាជធានី
- គណៈកម្មាធិការស្ត្រីកុមាររបស់ឃុំ/សង្កាត់

**ខ - ការអនុវត្តន៍គណនេយ្យភាពរបស់សង្គមស៊ីវិល**

- លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការកសាងផែនការ និងថវិកា ការប្រជុំប្រចាំខែ វេទិកាសាធារណៈ របស់ឃុំ សង្កាត់ (កម្មវិធីល្អ)
- ការផ្សព្វផ្សាយសាធារណៈនូវចំណូលចំណាយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ត្រួតពិនិត្យការគ្រប់គ្រង ថវិការបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដោយគណៈកម្មការគ្រប់គ្រងគម្រោងរបស់ឃុំដែលមានសមាសភាពសហគមន៍
- ការត្រួតពិនិត្យតាមដាន និងផ្ដល់យោបល់ត្រឡប់របស់ប្រជាពលរដ្ឋទៅលើគុណភាព តម្លាភាពនៃការ ផ្ដល់សេវាសាធារណៈ (គាំទ្រដោយគម្រោង DFGGរបស់ក្រសួងមហាផ្ទៃ អនុវត្តដោយអង្គការមិន មែនរដ្ឋាភិបាល)
- ការឃ្លាំមើលសាធារណៈ របាយការណ៍ស្ដីពីការកំណត់ចំណាត់ថ្នាក់ដោយប្រជាពលរដ្ឋចំពោះការអនុវត្ត ការងាររបស់ក្រុមប្រឹក្សាឃុំសង្កាត់អនុវត្តដោយអង្គការមិនមែនរដ្ឋភិបាល (NGOs)
- ការសិក្សាស្ទង់មតិរបស់ប្រជាពលរដ្ឋដោយ កម្មវិធីល្អ និង GIZ/SPACE
- ដំណើរការទទួលព័ត៌មានត្រឡប់តាមរយៈការិយាល័យប្រជាពលរដ្ឋនៃគម្រោងច្រកចេញចូលតែ១

## ថ្ងៃទី១

## ប្លង់មេរៀនទី ៤

## ចំណងជើងមេរៀនៈ ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ និងខ្សែគណនេយ្យភាព

**ពេលវេលាៈ០២ៈ៥៥ ដល់ ០៣ៈ៥៥ (១ម៉ោង)**

**គោលបំណងមេរៀនៈ** នៅចុងបញ្ចប់មេរៀននេះ អ្នកចូលរួមនឹងអាច

១.បកស្រាយបានពីរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាក្រុង ស្រុក និងឃុំ សង្កាត់និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សានីមួយៗនិង គណៈអភិបាលនិងបានដឹងពីរចនាសម្ព័ន្ធ របស់ក្រុមប្រឹក្សាខេត្ត។

២.ពន្យល់ពីខ្សែគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់នីមួយៗ និងក្រុមប្រឹក្សាចំពោះប្រជាពលរដ្ឋ ។

### កំណត់ចំណាំរបស់អ្នកសម្របសម្រួល

នៅក្នុងមេរៀននេះ អ្នកសម្របសម្រួលគួរតែៈ

១.មេរៀនមានការទាក់ទងគ្នានៅក្នុងច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ដែលតម្រូវឱ្យអ្នកសម្របសម្រួលយល់ឱ្យបានច្បាស់ពីច្បាប់ទាំងស្រុង ដើម្បីត្រៀមបកស្រាយសំណួរដែលពាក់ព័ន្ធ

២.ដោយសារពេលវេលាខ្លី(៦០នាទី) អ្នកសម្របសម្រួលគួរប្រើពេលវេលាឱ្យបានល្អ ដោយសង្កត់ធ្ងន់លើប្រភេទក្រុមប្រឹក្សានីមួយៗ ជាក់ស្តែងនៅពេលសម្របសម្រួលវគ្គសម្រាប់ក្រុមប្រឹក្សាស្រុក អ្នកសម្របសម្រួលត្រូវផ្តោតឱ្យស៊ីជំរៅពីរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាស្រុក ។ នៅពេលសម្របសម្រួលវគ្គជាមួយក្រុមប្រឹក្សាឃុំសង្កាត់ត្រូវផ្តោតឱ្យស៊ីជំរៅពីរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំសង្កាត់

៣.អ្នកសម្របសម្រួលគួរលើកទឹកចិត្តឱ្យអ្នកចូលរួមអានច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបន្ថែម ដោយផ្តោតលើរចនាសម្ព័ន្ធតួនាទី ភារៈកិច្ចរបស់ក្រុមប្រឹក្សា និងគណៈអភិបាល ។ (សៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ និងសៀវភៅណែនាំលិខិតបទដ្ឋានគតិយុត្ត)?

៤. ក្រុមប្រឹក្សា និងគណៈអភិបាលអាចមានការយល់ដឹងពីរចនាសម្ព័ន្ធ តួនាទី និងភារៈកិច្ចរបស់ខ្លួនតែអ្នកចូលរួមមកពីអង្គការសង្គមស៊ីវិល អ្នកសារព័ត៌មាន និងតំណាងសហគមន៍មូលដ្ឋានអាចមានការយល់ដឹងមិនបានទូលំទូលាយដូច្នេះអ្នកសម្របសម្រួលគួរព្យាយាមយកចិត្តទុកដាក់ឱ្យមានការបញ្ជាក់ជាសំណួរឱ្យបានច្រើនពីអ្នកចូលរួមមកពីអង្គការសង្គមស៊ីវិល

៥.ដោយសារពេលវេលាមានរយៈខ្លីអ្នកសម្របសម្រួលមិនអាចបកស្រាយពីតួនាទី និងភារៈកិច្ចលំអិតរបស់គណៈអភិបាលដែលបានសរសេរនៅក្នុងគោលបំណង និងលទ្ធផលរំពឹងទុករបស់មេរៀន។ បុគ្គលិក

អង្គការដៃគូថ្នាក់ខេត្តដែលជាអ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាលនឹងបន្តបង្ហាត់បង្ហាញដល់អង្គការសង្គមស៊ីវិលបន្ថែមទៀត (សៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ) ។ ។

**លទ្ធផលរំពឹងទុកនៃមេរៀន**

១. អ្នកចូលរួមអាចគូសរចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាក្រុងស្រុក និងក្រុមប្រឹក្សាឃុំសង្កាត់និងដឹងពីរចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាខេត្ត ។

២. អ្នកចូលរួមអាចពិភាក្សាបានពីតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា និងគណៈអភិបាល ។

៣. អ្នកចូលរួមអាចពន្យល់ប្រាប់ពីខ្សែគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់នីមួយៗ និងក្រុមប្រឹក្សាចំពោះប្រជាពលរដ្ឋ ។

**សម្ភារឧបទ្ទេសម្រាប់មេរៀន**

- ឯកសារចែក: រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សា គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា និងគណៈអភិបាលព្រមទាំងខ្សែគណនេយ្យភាព
- ឯកសារបង្ហាញ
- ប៊ិចសរសេរក្រដាស ក្រដាសផ្ទាំងធំ ស្កុត
- កុំព្យូទ័រយួរដៃ និងម៉ាស៊ីនបញ្ចាំងឯកសារ

**ឯកសារយោង**

- ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ-ខ្សែគណនេយ្យភាពទាំងបួន (ជំពូកទី៤ ទំព័រទី២៤-២៦)
- ឯកសារបណ្តុះបណ្តាលសម្រាប់គ្រូនិងសិក្ខាកាមស្តីពីការលើកកម្ពស់ការយល់ដឹង និងភ្ជាប់ទំនាក់ទំនងសង្គមស៊ីវិលជាមួយកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (Pact VBNK វិច្ឆិកា២០១០)
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- លិខិតបទដ្ឋានគតិយុត្តសម្រាប់គាំទ្រដំណើរការកំណែទម្រង់
- សៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ

**របៀបសម្របសម្រួលមេរៀន**

| រយៈពេល | សកម្មភាព និងវិធីសាស្ត្រ | សម្ភារ/ឯកសារចែក |
|---|---|---|
| ៥ នាទី | **សកម្មភាពទី១- សេចក្តីផ្តើម និងគោលបំណងមេរៀន**<br>• តើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌប្រកាសឱ្យប្រើប្រាស់ពេលណា? (២២ ឧសភា ២០០៨)<br>• តើក្រុមប្រឹក្សាបោះឆ្នោតជ្រើសតាំងនៅពេលណារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ?(**ឧសភា ២០០៩**)<br>• តើការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌតាមរបៀបណា? ហើយនរណាជាអង្គបោះឆ្នោត? (**អសកល ដោយក្រុមប្រឹក្សាឃុំ សង្កាត់**)<br>• តើក្រុមប្រឹក្សាគណៈអភិបាលមានរចនាសម្ព័ន្ធដូចម្តេច? ហើយមានតួនាទី និងភារកិច្ចអ្វីខ្លះ?<br>• តើក្រុមប្រឹក្សាមានគណនេយ្យភាពចំពោះនរណា?<br>• ដូច្នេះមេរៀននេះនឹងលើកយកសំណួរទាំងប៉ុន្មានមកពិភាក្សា និងស្រាយបំភ្លឺ<br>• បង្ហាញគោលបំណងមេរៀន នៅស្លាយទី២ | ស្លាយទី២<br>ឯកសារចែក |
| ១០ នាទី | **សកម្មភាពទី២ - រចនាសម្ព័ន្ធក្រុមប្រឹក្សានីមួយៗ**<br><u>ក្រុមពិភាក្សាតូច</u><br>• ចែកអ្នកចូលរួមជា៤ក្រុម ដើម្បីគូររចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សា (១) ខេត្ត (២) ស្រុក (៣) ក្រុង (៤) ឃុំ សង្កាត់ នៅលើក្រដាសផ្ទាំងធំ<br>• បិទរចនាសម្ព័ន្ធដែលបានគូរនីមួយៗ រួចសួរថា តើរចនាសម្ព័ន្ធក្រុមប្រឹក្សានីមួយៗមានចំណុចកែលំអឬទេ?<br>• អនុញ្ញាតិឱ្យអ្នកចូលរួមមានយោបល់ទៅលើរចនាសម្ព័ន្ធដែលគួស<br>• បង្ហាញ និងបំភ្លឺរចនាសម្ព័ន្ធ (១)វគ្គសម្រាប់ស្រុក ក្រុង ត្រូវពិភាក្សាឱ្យបានស៊ីជំរៅរចនាសម្ព័ន្ធរបស់ស្រុក ក្រុង (២)វគ្គសម្រាប់ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវពិភាក្សាឱ្យបានស៊ីជម្រៅរចនាសម្ព័ន្ធរបស់ឃុំ សង្កាត់ | ស្លាយទី៣-៦ |
| ១០ នាទី | **សកម្មភាពទី៣- តួនាទីរបស់ក្រុមប្រឹក្សា**<br><u>ការបំផុសគំនិត</u> | ស្លាយទី៧-៨ |

| | | |
|---|---|---|
| | • អនុញ្ញាតិឱ្យអ្នកចូលរួមចំនួន ៣នាក់ឆ្លើយសំណួរតើក្រុមប្រឹក្សាមានតួនាទីអ្វីខ្លះ?<br>• បទបង្ហាញ (១)បើវគ្គសម្រាប់ស្រុក ក្រុង ត្រូវពិភាក្សាលំអិតលើតួនាទីរបស់ក្រុមប្រឹក្សាស្រុក ក្រុង (២)បើវគ្គសម្រាប់ ឃុំ សង្កាត់ត្រូវពិភាក្សាលំអិតលើតួនាទីរបស់ក្រុមប្រឹក្សា ឃុំសង្កាត់ | |
| ១០ នាទី | **សកម្មភាពទី៤- ភារកិច្ចរបស់ក្រុមប្រឹក្សា**<br>ពិភាក្សាក្រុមតូច<br>• សួរអ្នកចូលរួមថា តើក្រុមប្រឹក្សាមានភារកិច្ចអ្វីខ្លះ?<br>• បទបង្ហាញពីភារកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ ដោយសង្កត់ធ្ងន់លើភារកិច្ចរបស់ក្រុមប្រឹក្សាស្រុកក្រុង និងឃុំសង្កាត់<br>• សង្ខេបថា ក្រុមប្រឹក្សាមានភារកិច្ចបីចំបងៗគឺ (១) ការពិគ្រោះយោបល់ និងការផ្សព្វផ្សាយព័ត៌មាន (២) ការកសាងផែនការ **និងថវិកា** (៣) ការគ្រប់គ្រងហិរញ្ញវត្ថុ និងរៀបចំថវិកា<br>• ចែកអ្នកចូលរួមជា៣ក្រុម ដើម្បីពិភាក្សា តើកន្លងមកក្រុមប្រឹក្សាបានអនុវត្ត (ធ្វើសកម្មភាព)អ្វីខ្លះដែលឆ្លើយតបនឹងភារកិច្ចរបស់ខ្លួន? ហើយយកចម្លើយចំនួន២ ស្លាយទី៩-១៤<br>-ក្រុមទី១ ការពិគ្រោះយោបល់ និងការផ្សព្វផ្សាយព័ត៌មាន<br>-ក្រុមទី២ ការកសាងផែនការ<br>-ក្រុមទី៣ ការគ្រប់គ្រងហិរញ្ញវត្ថុ និងរៀបចំថវិកា<br>• សង្ខេបបទបង្ហាញដែលទាក់ទងការងារដែលក្រុមប្រឹក្សាបានអនុវត្ត<br>• បិទចម្លើយ<br>• សង្ខេបពីភារកិច្ចចំបងៗរបស់ក្រុមប្រឹក្សានីមួយៗ | ស្លាយទី៩-១៤ |
| ១០នាទី | **សកម្មភាពទី៥- គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា**<br>ពិភាក្សាក្រុមធំ និងបទបង្ហាញ<br>• តាមរយៈការបង្ហាញរចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សានីមួយៗ អ្នកចូលរួមបានដឹងពីគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា (១) គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស (២) គណៈកម្មាធិការលទ្ធកម្ម (៣) គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ | ស្លាយទី១៥-២៦ |

| | | |
|---|---|---|
| | • គណៈកម្មាធិការ របស់ក្រុមប្រឹក្សាឃុំ សង្កាត់? (១) គណៈកម្មាធិការគ្រប់គ្រងគម្រោង (២) គណៈកម្មការលទ្ធកម្ម (៣) គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ (៤) គណៈកម្មាធិការកសាងផែនការ និងថវិកា<br>• សួរថា តើតួនាទីចំបងរបស់គណៈកម្មាធិការនីមួយៗមានអ្វីខ្លះ? ឬតើគណៈកម្មាធិការនីមួយៗជួយអ្វីខ្លះដល់ក្រុមប្រឹក្សា?<br>• បទបង្ហាញពីតួនាទីរបស់គណៈកម្មាធិការនីមួយៗ និងសំណួរចំលើយ ស្លាយ១៥ដល់២៦ | |
| ១០ នាទី | **សកម្មភាពទី៦ - តួនាទី និងភារកិច្ចរបស់គណៈអភិបាល**<br>• នៅក្នុងរចនាសម្ព័ន្ធសាលាខេត្ត ក្រុង ស្រុកមានក្រុមប្រឹក្សា និងគណៈអភិបាល ហើយយើងបានពិភាក្សាពីតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សារួចហើយ ដូច្នេះយើងនឹងបន្តពិភាក្សាពីតួនាទី និងភារកិច្ចរបស់គណៈអភិបាលម្តងថាតើគណៈអភិបាលមានតួនាទី និងភារកិច្ចអ្វីខ្លះ?<br>• អនុញ្ញាតិឱ្យអ្នកចូលរួមឆ្លើយសំណួរ២នាក់<br>• អ្នកសម្របសម្រួលបង្ហាញដោយសង្ខេបពីតួនាទី និងភារកិច្ចរបស់គណៈអភិបាលនៅឯកសារ**ស្លាយ**ទី២៧-៣៨ | ស្លាយទី២៧-៣៨ |
| ១០នាទី | **សកម្មភាពទី៧- ខ្សែគណនេយ្យភាព**<br><u>ពិភាក្សាក្រុមធំ</u><br>• រំលឹកនិយមន័យគណនេយ្យភាពដែលបានពិភាក្សាក្នុង មេរៀនទី២ ទស្សនទានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ អភិបាលកិច្ច និងគណនេយ្យភាពសង្គម<br>• បង្ហាញរូបភាពស្លាយស្តីពីខ្សែគណនេយ្យភាព និងអនុញ្ញាតិឱ្យអ្នកចូលរួមចំនួន៤នាក់បកស្រាយ តាមសំណួរ (១) តើក្រុមប្រឹក្សាណាខ្លះមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាឃុំ សង្កាត់? ហេតុអ្វី? **ក្រុមប្រឹក្សាឃុំ សង្កាត់ជាតំណាងរបស់ប្រជាពលរដ្ឋ**<br>• (២) តើក្រុមប្រឹក្សាណាមួយមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ? ហេតុអ្វី?(គ្រប់ក្រុមប្រឹក្សា) **បោះឆ្នោតអសកល(ក្រុមប្រឹក្សាឃុំសង្កាត់បោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋ)** | ស្លាយទី៣៩-៤១ |

| | | |
|---|---|---|
| | • សង្ខេប និងបំភ្លឺបន្ថែម | |
| ៥ នាទី | **សកម្មភាពទី៨- សេចក្ដីសន្និដ្ឋាន**<br>១- បានគូរ និងអាចបកស្រាយបានពីរចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាប្រភេទនីមួយៗ<br>២- បានពិភាក្សា និងអាចប្រាប់បានពីតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាប្រភេទនីមួយៗ ពិសេសតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាក្រុង ស្រុក និងក្រុមប្រឹក្សាឃុំសង្កាត់ ដែលផ្ដោតលើភារកិច្ច (១) ការពិគ្រោះយោបល់ និងការផ្សព្វផ្សាយពត៌មាន (២) ការកសាងផែនការ និងថវិកា (៣) ការគ្រប់គ្រងហិរញ្ញវត្ថុ និងរៀបចំថវិកា<br>៣- បានពិភាក្សាពីគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា និងតួនាទីរបស់គណៈកម្មាធិការ<br>៤- បានពិភាក្សាដោយសង្ខេបពីតួនាទី និងភារកិច្ចរបស់គណៈអភិបាល<br>៥-បានពិភាក្សាពីខ្សែគណនេយ្យភាពរបស់ក្រុមប្រឹក្សាដែលក្រុមប្រឹក្សាគ្រប់ប្រភេទត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ | |

## ថ្ងៃទី១ មេរៀនទី៤

# ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ
# និង
# គណនេយ្យភាព

សហការជាមួយការិយាល័យសម្របសម្រួលគម្រោងនៃក្រសួងមហាផ្ទៃ និង អង្គការផែកកម្ពុជា

# គោលបំណងមេរៀន

១. បកស្រាយបានពីចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់៖

- ក្រុមប្រឹក្សាក្រុង ស្រុក និងឃុំ សង្កាត់ និងគណកម្មាធិការនានារបស់ក្រុមប្រឹក្សានិមួយៗ
- គណៈអភិបាលនិងបានដឹងពីរចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាខេត្ត

២. ពន្យល់ពីខ្សែគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់និមួយៗនិងក្រុមប្រឹក្សាចំពោះប្រជាពលរដ្ឋ។

# រចនាសម្ព័ន្ធសាលាខេត្ត




រចនាសម្ព័ន្ធសាលាក្រុង
ក្រុមប្រឹក្សា
គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
គណៈកម្មាធិការលទ្ធកម្ម
គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ
គណៈកម្មាធិការផ្សេងទៀត
ការិយាល័យជំនាញ
គណៈអភិបាល
នាយករដ្ឋបាល
ការិយាល័យ ផែនការ និងគាំទ្រសង្កាត់
ការងារផែនការ
អនុវត្តគម្រោង កម្មវិធីអភិវឌ្ឍ
សម្របសម្រួល ការគាំទ្រកិច្ចសហប្រតិបត្តិការ ការអភិវឌ្ឍ
ត្រួតពិនិត្យ វាយតម្លៃ
ការិយាល័យ រដ្ឋបាល និងហិរញ្ញវត្ថុ
ការងាររដ្ឋបាល សរុប និង បុគ្គលិក
ស្ថិតិប្រជាពលរដ្ឋ និងអត្រានុកូលដ្ឋាន
ព័ត៌មាន
ការងារហិរញ្ញវត្ថុ និងគ្រប់គ្រងទ្រព្យសម្បត្តិ
ការងារលទ្ធកម្ម
លេខាធិការក្រុមប្រឹក្សា
ការិយាល័យ អភិវឌ្ឍក្រុង
កិច្ចការអភិវឌ្ឍក្រុង
កិច្ចការនគរូបនីយកម្ម សំណង់ និង សុរិយោដី
ការងារសណ្តាប់ធ្នាប់សាធារណៈ ច្បាប់ និងសិទ្ធិមនុស្ស
ការងារសេដ្ឋកិច្ច
ការងារសង្គមកិច្ច


រចនាសម្ព័ន្ធសាលាស្រុក
ក្រុមប្រឹក្សា
គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
គណៈកម្មាធិការលទ្ធកម្ម
គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ
គណៈកម្មាធិការផ្សេងទៀត
ការិយាល័យជំនាញ
គណៈអភិបាល
នាយករដ្ឋបាល
ការិយាល័យ ផែនការ និង គាំទ្រឃុំ សង្កាត់
ការិយាល័យ រដ្ឋបាល និងហិរញ្ញវត្ថុ
ការិយាល័យ អន្តរវិស័យ
ការងារផែនការ និងវិនិយោគ
អនុវត្តគម្រោង និងកម្មវិធីអភិវឌ្ឍ
សម្របសម្រួល គាំទ្រគម្រោងឃុំ/សង្កាត់
ត្រួតពិនិត្យ វាយតម្លៃ
ការងាររដ្ឋបាល សរុប និង បុគ្គលិក
ស្ថិតិប្រជាពលរដ្ឋ និងអត្រានុកូលដ្ឋាន
ព័ត៌មាន
គ្រប់គ្រងទ្រព្យសម្បត្តិ
ការងារលទ្ធកម្ម
ចំណូល ចំណាយ និងគណនេយ្យ
លេខាធិការក្រុមប្រឹក្សា
ការងារដីធ្លី សំណង់
ការងារសណ្តាប់ធ្នាប់សាធារណៈ ច្បាប់ និងសិទ្ធិមនុស្ស
ការងារសេដ្ឋកិច្ច
ការងារសង្គមកិច្ច

# រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់

1. រដ្ឋបាលឃុំ សង្កាត់ ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់
2. ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ជាមេឃុំ ចៅសង្កាត់



តើក្រុមប្រឹក្សាមានតួនាទីអ្វីខ្លះ?

តើក្រុមប្រឹក្សាមានភារកិច្ចអ្វីខ្លះ?

# តួនាទីរបស់ក្រុមប្រឹក្សា

១. ចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើត ការជម្រុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

២. បំពេញមុខងារ ភារកិច្ច ដែលបានប្រគល់ និងធ្វើប្រតិភូកម្មតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

(ច្បាប់រៀបចំអង្គការមាត្រា ១២ និង២៩)

# ភារកិច្ចរបស់ក្រុមប្រឹក្សា

១. ការពិគ្រោះយោបល់ និងការផ្សព្វផ្សាយព័ត៌មាន

២. ការកសាងផែនការ

៣. ការគ្រប់គ្រងហិរញ្ញវត្ថុ និងការរៀបចំថវិកា

# ភារកិច្ចរបស់ក្រុមប្រឹក្សា (ត)

១. ការពិគ្រោះយោបល់ និងការផ្សព្វផ្សាយព័ត៌មាន

- រៀងរាល់ឆ្នាំត្រូវរៀបចំវេទិកាពិគ្រោះយោបល់ដោយមានការចូលរួមពីប្រជាពលរដ្ឋ
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំវេទិកាពិគ្រោះយោបល់ជាប្រចាំ
- វេទិកាពិគ្រោះយោបល់គឺជាយន្តការជម្រុញឱ្យមានតម្លាភាព គណនេយ្យភាព និងការចូលរួម
- ត្រូវពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋក្នុងការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍ

# ភារកិច្ចរបស់ក្រុមប្រឹក្សា (ត)

១. ការពិគ្រោះយោបល់ និងការផ្សព្វផ្សាយព័ត៌មាន

- ត្រូវបង្កលក្ខណៈងាយស្រួលដល់សាធារណជនក្នុងការទទួលបាន ព័ត៌មាន ដូចជា របាយការណ៍ របៀបវារៈប្រជុំ កំណត់ហេតុនៃកិច្ចប្រជុំ ដីកា លិខិតបទដ្ឋានគតិយុត្តនានា
- ត្រូវរៀបចំឱ្យមានក្តារព័ត៌មានសាធារណៈ
- របាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាត្រូវរៀបចំ និងផ្សព្វផ្សាយជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

# ភារកិច្ចរបស់ក្រុមប្រឹក្សា (ត)

២. ការកសាងផែនការ

- ត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំ ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ តាមរយៈការរៀបចំកម្មវិធីវិនិយោគពីរឆ្នាំរំកិលប្រចាំឆ្នាំ ។
- ផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគពីរឆ្នាំរំកិលត្រូវបញ្ចូលតម្រូវការរបស់ស្ត្រី បុរស យុវវ័យ កុមារ ក្រុមងាយរងគ្រោះ ជនជាតិដើមភាគតិច
- ត្រូវតាមដាន និងវាយតម្លៃជារៀងរាល់ឆ្នាំទៅលើការអនុវត្ត ផែនការអភិវឌ្ឍរបស់ខ្លួន ។

# ភារកិច្ចរបស់ក្រុមប្រឹក្សា (ត)

២. ការកសាងផែនការ (ត)

- ការរៀបចំផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគពាឆ្នាំរំកិលត្រូវ អនុវត្តតាមគោលការណ៍៖ ការចែកព័ត៌មាន តម្លាភាព ការចូលរួមពិគ្រោះយោបល់ ការឆ្លើយតបនឹងតម្រូវការ គណនេយ្យភាព ។ល។
- ត្រូវចាត់ចែងឱ្យមានការតាមដានពីវឌ្ឍនភាពនៃការអនុវត្តផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគពាឆ្នាំរំកិល ។

# ភារកិច្ចរបស់ក្រុមប្រឹក្សា (ត)

៣. ការគ្រប់គ្រងហិរញ្ញវត្ថុ និងការរៀបចំថវិកា

- ត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុឱ្យមានតម្លាភាព និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ ។
- ត្រូវរៀបចំ និងអនុម័តថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ។
- ត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុសាធារណៈដើម្បីជម្រុញដល់ការអភិវឌ្ឍ និងផ្តោតលើតម្រូវការជាមូលដ្ឋាន កាត់បន្ថយភាពក្រីក្រ និងឆ្លើយតបតម្រូវការរបស់ស្ត្រី បុរស យុវវ័យ និងកុមារ ក្រុមជនងាយរងគ្រោះ និងជនជាតិដើមភាគតិច ។

# គណៈកម្មាធិការនានារបស់

# ក្រុមប្រឹក្សានិងគណនេយ្យ

# គណៈកម្មាធិការរបស់ក្រុមប្រឹក្សា និងតួនាទី

១. គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

២. គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

៣. គណៈកម្មាធិការលទ្ធកម្ម

# តួនាទីរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

ផ្តល់យោបល់ អនុសាសន៍ដល់ក្រុមប្រឹក្សានិងគណៈអភិបាលលើ៖

- ការសម្របសម្រួលការងាររវាងក្រុមប្រឹក្សា (ប្រភេទនីមួយៗ) និងមន្ទីរការិយាល័យជំនាញ ។
- ការសម្របសម្រួលការចូលរួមរបស់អ្នកពាក់ព័ន្ធនៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគពាឆ្នាំរំកិល ។

# តួនាទីរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

- ចូលរួមក្នុងការកសាងចក្ខុវិស័យពាក់ព័ន្ធនឹងសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ ។
- ប្រមូល និងវិភាគព័ត៌មានដែលទាក់ទងនឹងយេនឌ័រ តម្រូវការស្ត្រី យុវវ័យ និងកុមារដើម្បីបញ្ចូលក្នុងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរបស់ក្រុមប្រឹក្សា។
- ç រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ខ្លួន ដើម្បីបញ្ចូលទៅក្នុងផែនការសកម្មភាព និងថវិការបស់ក្រុមប្រឹក្សា

# តួនាទីរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (ត)

- ចូលរួមក្នុងការរៀបចំតាក់តែង ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាទាក់ទងនឹងការលើកកម្ពស់ និងការឆ្លើយតបលើបញ្ហាសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ។
- ស្វែងរកការគាំទ្រ ដើម្បីលើកផែនការសកម្មភាពសម្រាប់ដោះស្រាយបញ្ហាពាក់ពន្ធ័នឹងសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ។

# តួនាទីរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (ត)

- សហការ និងផ្ដល់ការគាំទ្រដល់ គ.ក.ស.ក របស់ក្រុមប្រឹក្សាប្រភេទផ្សេងទៀតក្នុងការដោះស្រាយបញ្ហា សំណូមពរ ឬ សំណើនានា។
- លើកសំណើ និងផ្ដល់យោបល់ជូនក្រុមប្រឹក្សា ឬ គណៈអភិបាលអំពីវិធានការសមស្របនានា ដើម្បីជំរុញឱ្យមានការចូលរួមពីសមត្ថកិច្ចពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងការដោះស្រាយ និងទប់ស្កាត់នូវបញ្ហាពាក់ព័ន្ធនឹងកិច្ចការស្ត្រី យុវវ័យ និងកុមារ។
- ជំរុញការលើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងគោលនយោបាយនានាទាក់ទងនឹងសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារដល់សហគមន៍នានា។

# តួនាទីរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (ត)

- ជំរុញឱ្យមានការប្រមូលព័ត៌មានរបស់សហគមន៍អំពីអ្វីដែលបានកើតមានជាប្រចាំពាក់ព័ន្ធនឹងសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ និងមានវិធានការឆ្លើយតប ។
- ស្វែងរកការគាំទ្រដើម្បីជំរុញឱ្យស្ត្រីចូលរួមនៅក្នុងការធ្វើសេចក្ដីសម្រេចពាក់ពន្ធ័នឹងការងារអភិវឌ្ឍនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ។
- លើកយោបល់ និងផ្ដល់អនុសាសន៍អំពីការពង្រឹងទំនាក់ទំនង កិច្ចសហការ និងការសម្របសម្រួលរវាងក្រុមប្រឹក្សាប្រភេទផ្សេងទៀត មន្ទីរ អ្នកពាក់ព័ន្ធនានា ដើម្បីធានាថាសកម្មភាពទាំងឡាយត្រូវបានគាំទ្រដល់ស្ត្រី យុវវ័យ និងកុមារ ។

# តួនាទីរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (ត)

- ពិនិត្យមើលលើការអនុវត្តគោលនយោបាយសមភាពយេនឌ័រ និងស្ថានភាពរបស់ស្ត្រី យុវវ័យ និងកុមារ ។
- រាយការណ៍ជូនក្រុមប្រឹក្សាលើបញ្ហាដែលទាក់ទងនឹងសមភាពយេនឌ័រការបង្កើនសមត្ថភាពដល់ស្ត្រី និងបញ្ហារបស់យុវវ័យ និងកុមារ ។
- គាំទ្រគ្រប់កិច្ចខិតខំប្រឹងប្រែង ដើម្បីកៀរគរមូលនិធិសម្រាប់ការងារសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ។
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់ក្រុមប្រឹក្សា។

(ប្រក៤២៧៥ ប្រការ៧)

# តួនាទីរបស់គណៈកម្មាធិការលទ្ធកម្ម

ធានាឱ្យសកម្មភាពលទ្ធកម្មទាំងអស់របស់ក្រុមប្រឹក្សាប្រព្រឹត្តទៅ ដោយស្មោះត្រង់ បើកចំហ តម្លាភាព និងមិនលំអៀង ។

# គណៈកម្មាធិការរបស់ក្រុមប្រឹក្សា

# ឃុំ សង្កាត់

# និងតួនាទី

# គណៈកម្មាធិការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

១. គណៈកម្មាធិការគ្រប់គ្រងគម្រោង ជួយឃុំក្នុងការសិក្សាលទ្ធភាព គម្រោង រៀបចំគម្រោង និងអនុម័តគម្រោង និងតាមដានការអនុវត្តគម្រោង និងវាយតម្លៃគម្រោងមុនមេឃុំចេញអាណត្តិបើកប្រាក់ឱ្យ អ្នកទទួលការ ។

២. គណៈកម្មាធិការកសាងផែនការ និងថវិកា ជាជំនួយការឱ្យឃុំក្នុងការទទួលខុសត្រូវរៀបចំផែនការអភិវឌ្ឍ និងថវិកាប្រចាំឃុំ

៣. គណៈកម្មការលទ្ធកម្ម ជួយឃុំក្នុងការរៀបចំឯកសារដេញថ្លៃ ប្រកាសដេញថ្លៃ និងវាយតម្លៃលទ្ធផលនៃការដេញថ្លៃរាល់គម្រោង ហេដ្ឋារចនាសម្ព័ន្ធ សេវាកម្ម និងសម្ភារៈឧបករណ៍ និងធ្វើរបាយការណ៍អំពីលទ្ធផលនៃការដេញថ្លៃ ។

# គណៈកម្មាធិការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ (ត)

៤. គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ជំនួយការឱ្យឃុំក្នុងការប្រមូលរបាយការណ៍ និងរាយការណ៍ស្តីពីបញ្ហាស្ត្រី និងកុមារ

៥. គណៈកម្មាធិការដោះស្រាយទំនាស់ក្រៅប្រព័ន្ធ ជំនួយការឱ្យឃុំ និងចូលរួមសម្របសម្រួលទំនាស់

# តួនាទី ភារកិច្ចរបស់គណៈអភិបាល

# តួនាទី ភារកិច្ចរបស់គណៈអភិបាល

គណៈអភិបាល មានតួនាទីសំខាន់ៗដូចជា ៖

- គណៈអភិបាលត្រូវផ្តល់យោបល់ជូនក្រុមប្រឹក្សា រាយការណ៍ជូនក្រុមប្រឹក្សា និងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។
- គណៈអភិបាលត្រូវលើកសំណើទៅក្រុមប្រឹក្សាដើម្បីកំណត់អំពីយុទ្ធសាស្រ្ត និងរបៀបនៃការពិគ្រោះយោបល់លើបញ្ហាចាំបាច់ផ្សេងៗរួមទាំង ផែនការអភិវឌ្ឍ

(មាត្រា ១៥៥, ១៦៤ ច្បាប់រៀបចំអង្គការ អនក្រ ២១៦ មាត្រា ២៨.៨៥.១៤៦)

# តួនាទី ភារកិច្ចរបស់គណៈអភិបាល (ត)

- គណៈអភិបាល ត្រូវផ្តល់អនុសាសន៍ និងដាក់ជូនក្រុមប្រឹក្សាដើម្បីពិភាក្សាសម្រេចអំពី :

- ការបង្កើត និង រំសាយអង្គភាព
- ការរៀបចំតួនាទី ភារកិច្ច និង លក្ខខណ្ឌការងារបុគ្គលិក
- ការតែងតាំង ការដំឡើងឋានន្តរស័ក្តិ និងការបញ្ឈប់បុគ្គលិក

( ច្បាប់រៀបចំអង្គការ មាត្រា ១៦២, អនក្រ ២១៦ មាត្រា១៤៧ )

# តួនាទី ភារកិច្ចរបស់គណៈអភិបាល (ត)

- ការកំណត់លក្ខណៈសម្បត្តិនៃការជ្រើសរើស ការតែងតាំង ការកំណត់ ប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗទៀតនៃបុគ្គលិករបស់ក្រុមប្រឹក្សា

- ការកំណត់និតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់អង្គភាព និងបុគ្គលិក របស់ក្រុមប្រឹក្សា

- ការកំណត់យុទ្ធសាស្រ្តដើម្បីអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សានិងបុគ្គលិករបស់ខ្លួន។

(មាត្រា ១៦២ ច្បាប់រៀបចំអង្គការ អនក្រ២១៦ មាត្រា១៤៧)

# តួនាទី ភារកិច្ចរបស់គណៈអភិបាល (ត)

- គណៈអភិបាលរៀបចំរបាយការណ៍ប្រចាំឆ្នាំដាក់ជូនក្រុមប្រឹក្សា ពិនិត្យ និងអនុម័តដែលពាក់ព័ន្ធនឹង៖

  - O ដីកា និងសេចក្តីសម្រេចនានាដែលបានដាក់ចេញដោយក្រុមប្រឹក្សា និងសកម្មភាពលទ្ធផលនៃការអនុវត្ត។
  - O របាយការណ៍ហិរញ្ញវត្ថុ
  - O.......

(អនក្រ ២១៦ មាត្រា ២៩.៨៦.១៤៧)

# តួនាទី ភារកិច្ចរបស់គណៈអភិបាល (ត)

- ការវាយតំលៃអំពីការបំពេញការងាររបស់គណៈអភិបាលនិងបុគ្គលិក
- វិធានការចាំបាច់ដើម្បីលើកម្ពស់សមភាពយេនឌ័រ
- ការវាយតំលៃសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងស្រុក និងតម្រូវការគាំទ្រចំពោះឃុំ សង្កាត់ក្នុងស្រុក ។

( អនក្រ ២១៦ មាត្រា ២៩.៨៦.១៤៧ )

# តួនាទី ភារកិច្ចរបស់គណៈអភិបាល (ត)

- គណៈអភិបាលត្រូវផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សា ពីការបង្កើតគណៈកម្មាធិការ នានាតាមការចាំបាច់ដើម្បីជួយដល់ក្រុមប្រឹក្សាក្នុងការអនុវត្តការងារ
- គណៈអភិបាលមានតួនាទីគាំទ្រក្រុមប្រឹក្សានៅក្នុងការបំពេញមុខងារសិទ្ធិ អំណាច និង ភារកិច្ចរបស់ខ្លួន

( ច្បាប់រៀបចំអង្គការ មាត្រា១៦៨ .១៥៥ អនក្រ ២១៦ មាត្រា ២៩.៨៦.១៤៧ )

# តួនាទី ភារកិច្ចរបស់គណៈអភិបាល (ត)

- គណៈអភិបាល ត្រូវពិគ្រោះយោបល់ជាមួយគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដើម្បីធានាឱ្យផែនការសកម្មភាព និង ថវិការបស់ក្រសួង ស្ថាប័ន មន្ទីរ និងអង្គភាពរបស់រាជរដ្ឋាភិបាលត្រូវបានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគពាណ្ឆាំរំកិលប្រចាំឆ្នាំ ព្រមទាំងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

(មាត្រា ១៦៦ នៃច្បាប់រៀបចំអង្គការ)

# តួនាទី ភារកិច្ចរបស់គណៈអភិបាល (ត)

- គណៈអភិបាល រៀបចំសេចក្ដីព្រាង និងដាក់ជូនទៅក្រុមប្រឹក្សាដើម្បី ពិភាក្សា អនុម័តនូវ

  - ផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំ និង កម្មវិធីវិនិយោគពាឆ្នាំរំកិលប្រចាំឆ្នាំ

  - ក្របខណ្ឌចំណាយរយៈពេលមធ្យមរបស់ក្រុមប្រឹក្សា

  - របាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា

( មាត្រា ១៦៣ នៃច្បាប់រៀបចំអង្គការ អនក្រ ២១៦ មាត្រា ២៩.៨៦.១៤៧ )

# តួនាទី ភារកិច្ចរបស់គណៈអភិបាល (ត)

- គណៈអភិបាល ត្រូវគាំទ្រសមាជិកក្រុមប្រឹក្សា និងបុគ្គលិករបស់ក្រុមប្រឹក្សា ដើម្បីរាយការណ៍អំពីការរំលោភអំណាចនៅក្នុងដែនសមត្ថកិច្ចរបស់ ក្រុមប្រឹក្សា។
- គណៈអភិបាល ត្រូវជួយក្រុមប្រឹក្សាក្នុងការពិនិត្យមើលមុខងារ ភារកិច្ច និងធនធានដែលបានបែងចែក ឬបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

( ច្បាប់រៀបចំអង្គការមាត្រា ១៦៧ .១៥៦  អនក្រ២១៦ មាត្រា ៣០.៨៧.១៤៨ )

# តួនាទី ភារកិច្ចរបស់គណៈអភិបាល (ត)

- គណៈអភិបាលត្រូវរាយការណ៍ជូនក្រុមប្រឹក្សាអំពីការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា និងសកម្មភាពដែលបានអនុវត្តដោយគណៈអភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា។
- គណៈអភិបាល អាចស្នើសុំដាក់បញ្ចូលរបៀបវារៈសម្រាប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាបាន

(ច្បាប់រៀបចំអង្គការ មាត្រា, ១៥៩ គំរូបទបញ្ជាផ្ទៃក្នុង ប្រការ ៥ )

# តួនាទី ភារកិច្ចរបស់គណៈអភិបាល (ត)

- គណៈអភិបាល ត្រូវប្រជុំពិភាក្សាដើម្បីបែងចែកភារកិច្ចដល់អភិបាលនិងអភិបាលរង ហើយបន្ទាប់មកស្នើសុំការសំរេចពីក្រុមប្រឹក្សារបស់ខ្លួន។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីការបែងចែកភារកិច្ចនៅក្នុងចំណោមអភិបាល និងអភិបាលរង។

(អនក្រ ២១៦ មាត្រា ៣៣, ៩០, ១៩១, សណន លេខ០៣៤)

# ខ្សែគណនេយ្យភាព

# គណនេយ្យភាព

ក្រុមប្រឹក្សាត្រូវយល់ពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន និងមានការឆ្លើយតប ហើយទទួលខុសត្រូវរាល់ទង្វើរបស់ខ្លួនចំពោះមុខប្រជាពលរដ្ឋ ។ ដូចគ្នាដែរ ប្រជាពលរដ្ឋក៏ត្រូវយល់ពីតួនាទី និងកាតព្វកិច្ចរបស់ខ្លួនចំពោះរដ្ឋាភិបាល

<u>សកម្មភាព</u> ក្រុមប្រឹក្សាពិគ្រោះយោបល់ជាទៀងទាត់ពីបញ្ហា ក្ដីកង្វល់ និងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ កុមារ និងយុវជន

# ខ្សែគណនេយ្យភាពក្នុងកម្មវិធីជាតិ

| ខ្សែគណនេយ្យភាព | ការពិពណ៌នា |
|---|---|
| ១. គណនេយ្យភាពផ្ទៃក្នុង | សំដៅទៅលើគណនេយ្យភាពនៅក្នុងអង្គភាពចាត់តាំងមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនៅក្នុង រង្វង់រដ្ឋបាលមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| ២. គណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ | សំដៅទៅលើគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិឬរវាងអង្គភាពចាត់តាំងនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានប្រភេទដូចគ្នា ឬប្រភេទផ្សេងគ្នា។ |
| ៣. គណនេយ្យភាពអន្តររដ្ឋបាល | សំដៅទៅលើគណនេយ្យភាពរវាងក្រសួង ស្ថាប័ន មន្ទីរ ទីភ្នាក់ងារនានា របស់ក្រសួង ស្ថាប័ន ជាមួយនឹង រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| ៤. គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ | សំដៅទៅលើខ្សែគណនេយ្យភាព ផ្នែកនយោបាយរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋក្នុង ដែនសមត្ថកិច្ចរបស់ខ្លួន។ |

ផ្ទាំងសង្ខេបភាពទី ១១




ប្រភពឯកសារ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩

# ឯកសារចែក

# ថ្ងៃទី១

# មេរៀនទី ៤

## ចំណងជើងមេរៀន៖ ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ និងខ្សែគណនេយ្យភាព

## រចនាសម្ព័ន្ធនៃរដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់នីមួយៗមានរចនាសម្ព័ន្ធជាក់លាក់របស់ខ្លួន ដោយផ្អែកតាមបទបញ្ញត្តិ ដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

- ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិក៥, ៧, ៩ ឬ ១១នាក់ ផ្អែកតាម ទំហំរបស់តំបន់ និងចំនួនប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងឃុំ សង្កាត់។ ចំនួនជាក់ស្តែងនៃសមាជិក ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវ កំណត់ដោយអនុក្រឹត្យ។
- ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ មានប្រធានមួយរូប ដែលហៅថា ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាមេឃុំ ចៅសង្កាត់។
- ឃុំ សង្កាត់នីមួយៗមានមេឃុំ ចៅសង្កាត់ម្នាក់។ ស្ត្រី និងបុរសអាច ត្រូវបានជ្រើសរើសឱ្យ ធ្វើជាមេឃុំ ចៅសង្កាត់។
- មេឃុំ ចៅសង្កាត់មានជំនួយការ២រូប គឺជំទប់ទី១ ឬចៅសង្កាត់ រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២។
- ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិ ម្នាក់សម្រាប់ភូមិនីមួយៗក្នុងឃុំ សង្កាត់របស់ខ្លួន ដោយអនុវត្តតាម សេចក្តីណែនាំលេខ૦០៤ ស.ណ.ន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ របស់ក្រសួងមហាផ្ទៃ ស្តីពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការ មេភូមិ និងតួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ។ មេភូមិ គឺជាតំណាងឱ្យប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិ និងជាខ្សែរយៈចម្បងសម្រាប់តភ្ជាប់ទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់។ មេភូមិត្រូវ មានជំនួយការរបស់ខ្លួន០២រូប ម្នាក់ជាអនុប្រធានភូមិ និងម្នាក់ទៀតជាសមាជិកភូមិ។
- មេឃុំ ចៅសង្កាត់ អាចចាត់តាំងបង្កើតគណៈកម្មាធិការផ្តល់យោ បល់។ គណៈកម្មាធិការនេះមានសមាជិកយ៉ាងតិចជាង០៣នាក់ ដើម្បីផ្តល់យោបល់ និងជួយការងារដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និង មេឃុំ ចៅសង្កាត់អំពីបញ្ហាជាក់លាក់ណាមួយ។ សមាជិកគណៈ កម្មាធិការនេះអាចជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឬជាប្រជា ពលរដ្ឋផ្សេងទៀតដែលមានសិទ្ធិបោះឆ្នោត។

- ឃុំ សង្កាត់ នីមួយៗមាន**ស្មៀនមួយរូប**ដែលត្រូវបានតែងតាំង និង បម្រើការងារនៅក្នុងក្របខ័ណ្ឌរដ្ឋបាល ក្រសួងមហាផ្ទៃ។ ស្មៀនឃុំ សង្កាត់ទទួលខុសត្រូវចំពោះក្រុមប្រឹក្សាឃុំ សង្កាត់។ នៅក្នុងការបំពេញមុខងាររបស់ខ្លួន ស្មៀនឃុំ សង្កាត់ត្រូវតែអព្យាក្រឹត្យ និងមិនលម្អៀង ហើយប្រកាន់តំរិយាបទឱ្យបានស្មើៗគ្នាចំពោះប្រជាពលរដ្ឋ ទាំងអស់នៅក្នុងឃុំ សង្កាត់ សមាជិកក្រុមប្រឹក្សាគ្រប់រូបដោយមិន ប្រកាន់គណបក្សនយោបាយ និងគណៈកម្មាធិការនានា។




## ១. តួនាទីនិងការទទួលខុសត្រូវរបស់អ្នកដើរតួសំខាន់ៗ នៅក្នុងការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់

### ១.១. ប្រធានក្រុមប្រឹក្សាឃុំសង្កាត់

- ធ្វើជាអធិបតីនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា
- ធានាថាក្រុមប្រឹក្សាឃុំ សង្កាត់បានប្រជុំយ៉ាងហោចណាស់ម្តងក្នុងមួយខែ
- ធានាថា កិច្ចប្រជុំត្រូវបានធ្វើឡើងស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ ក្រុមប្រឹក្សាឃុំសង្កាត់។

### ១.២. សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

- ធានាថា ក្រុមប្រឹក្សាឃុំសង្កាត់ប្រើប្រាស់អំណាច តួនាទី និងមុខងារ ដូចមានចែងនៅក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ
- ចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំសង្កាត់
- ធ្វើសហប្រតិបត្តិការជាមួយនឹងប្រជាពលរដ្ឋ។

### ១.៣. មេឃុំ ចៅសង្កាត់

- ធានាថា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានអនុវត្ត

- រាយការណ៍អំពីការបំពេញការងារប្រចាំខែជូនក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្តល់យោបល់ និងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់លើការងារកសាង ផែនការ ការរៀបចំហិរញ្ញវត្ថុ និងការអនុវត្តអំណាច តួនាទី និងមុខ ងាររបស់ក្រុមប្រឹក្សាឃុំសង្កាត់
- បំពេញភារកិច្ចផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់ប្រគល់ឱ្យ
- ផ្ទេរសិទ្ធិដល់ជំទប់ ចៅសង្កាត់រងតាមឋានុក្រម នៅពេលខ្លួនអវត្តមាន។

## ១.៤. ជំទប់ទី១ ចៅសង្កាត់រងទី១

- ទទួលជួយមេឃុំ ចៅសង្កាត់លើការងារហិរញ្ញវត្ថុ និងសេដ្ឋកិច្ច
- មេឃុំ ចៅសង្កាត់ អាចប្រគល់ភារកិច្ចបន្ថែមទៀតដល់ជំទប់ទី១ ចៅ សង្កាត់រងទី១
- បំពេញការងារជាមេឃុំ ចៅសង្កាត់ស្តីទី ក្នុងករណីដែលមេឃុំ ចៅ សង្កាត់អវត្តមាន។

## ១.៥. ជំទប់ទី២ ចៅសង្កាត់រងទី២

- ជួយមេឃុំចៅសង្កាត់លើការងារផ្នែករដ្ឋបាល សេវាសង្គមកិច្ច សេវាសា ធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ
- មេឃុំ ចៅសង្កាត់ អាចប្រគល់ភារកិច្ចបន្ថែមទៀតដល់ជំទប់ទី២ ចៅ សង្កាត់រងទី២
- បំពេញការងារជាមេឃុំ ចៅសង្កាត់ស្តីទី ក្នុងករណីដែលមេឃុំ ចៅ សង្កាត់ និងជំទប់ទី១ ចៅសង្កាត់រងទី១ អវត្តមាន។

## ១.៦. គណៈកម្មាធិការនានា

- ផ្តល់យោបល់ និងជួយការងារជាក់លាក់ណាមួយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដូចជា ការកសាងផែនការ និងថវិកា
- រាយការណ៍អំពីការវិវត្តន៍ការងារប្រចាំខែរបស់ខ្លួន
- ផ្តល់យោបល់ពីវិធានការត្រូវអនុវត្ត ដែលពាក់ព័ន្ធទៅនឹងការងារ។

## ១.៧. ស្មៀនឃុំ សង្កាត់

ថ្វីត្បិតតែស្មៀនឃុំ សង្កាត់ជាបុគ្គលិកស្ថិតនៅក្នុងក្របខ័ណ្ឌរដ្ឋបាលរបស់ ក្រសួងមហាផ្ទៃក៏ពិតមែន ប៉ុន្តែក្នុងការអនុវត្តការងារ ស្មៀនឃុំ សង្កាត់ត្រូវស្ថិត នៅក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ស្មៀនឃុំ សង្កាត់ជាអ្នក :

- ជួយក្រុមប្រឹក្សា ក្នុងការបំពេញតួនាទី និងមុខងារស្របទៅតាម តម្រូវការផ្នែកច្បាប់
- បំពេញការងាររដ្ឋបាល
- ធានាថា សេចក្តីសម្រេច និងការអនុវត្តសេចក្តីសម្រេចរបស់ក្រុម ប្រឹក្សាឃុំសង្កាត់ ស្របទៅនឹង ល័ក្ខខ័ណ្ឌច្បាប់

- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំ និងការអនុវត្តកិច្ចប្រជុំ របស់ក្រុមប្រឹក្សា និង គណៈកម្មាធិការនានារបស់ឃុំសង្កាត់
- ចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ឬគណៈកម្មាធិការ លើកលែងតែបានទទួល ការអនុញ្ញាតឱ្យអវត្តមានជាមុន ពីក្រុម ប្រឹក្សាឃុំសង្កាត់ ឬមេឃុំ ចៅសង្កាត់
- ជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការរៀបចំឱ្យមានក្តារខៀនព័ត៌ មានមួយ ឬច្រើនកន្លែង ដើម្បីបិទផ្សាយសេចក្តីជូនដំណឹង សេចក្តី សម្រេច និងលិខិតបទដ្ឋានផ្សេងៗរបស់ក្រុមប្រឹក្សា ឃុំសង្កាត់ និង មេឃុំ ចៅសង្កាត់ សម្រាប់ឱ្យសាធារណជនទូទៅបានដឹងនូវព័ត៌មាន ទាំងនោះ ។

# ថ្ងៃទី១

# ប្លង់មេរៀនទី៥

# ចំណងជើងមេរៀនៈ សិទ្ធិ និងតួនាទីរបស់ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិលក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ

**ពេលវេលាៈ ០៣:៥៥ ដល់ ០៤:៥៥ (១ម៉ោង)**

**គោលបំណងនៃមេរៀនៈ** នៅចុងបញ្ចប់មេរៀននេះអ្នកចូលរួមនឹងអាចៈ

១. ពន្យល់ពីអត្ថន័យនៃពាក្យអង្គការសង្គមស៊ីវិល វិស័យឯកជន អ្នកសារព័ត៌មាន

២. ពន្យល់ពីសិទ្ធិ និងតួនាទី អង្គការសង្គមស៊ីវិល វិស័យឯកជន អ្នកសារព័ត៌មានក្នុងការកម្ពស់សកម្មភាពអភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គម

## កំណត់ចំណាំរបស់អ្នកសម្របសម្រួល

១. ពេលអ្នកចូលរួមយល់ពីតួនាទី និងសិទ្ធិទៅវិញទៅមកអាចៈ

- បង្កើនការធ្វើប្រាស្រ័យទាក់ទងលើកទឹកចិត្តឱ្យមានការចូលរួម និងអាចចងក្រងភាពជាដៃគូ
- មានការបើកចំហឱ្យមានការសហការអនុវត្តគម្រោង និងដោះស្រាយបញ្ហាសហគមន៍
- (តារាងតួនាទី និងភារកិច្ច របស់អ្នកដែលពាក់ព័ន្ធសំខាន់ក្នុងការចូលរួមលើកកម្ពស់អភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គមអាចយកទៅប្រើប្រាស់មេរៀនទី៣ថ្ងៃទី០៣)

## លទ្ធផលរំពឹងទុកនៃមេរៀន

ក. យល់ពីអត្ថន័យនៃពាក្យអង្គការសង្គមស៊ីវិល វិស័យឯកជន អ្នកសារព័ត៌មាន

ខ. អាចពន្យល់បានពីសិទ្ធ និងតួនាទី អង្គការសង្គមស៊ីវិល វិស័យឯកជន អ្នកសារព័ត៌មានក្នុងការចូលរួមសហការ និងលើកឡើង អំពីបញ្ហា ក្តីកង្វល់ និងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍក្រុង ស្រុក ឃុំ សង្កាត់

គ. អ្នកចូលរួមអាចកំណត់បានពីតួនាទីដែលស្របគ្នាក្នុងការបង្កើនភាពជាដៃគូលើកកម្ពស់សកម្មភាពអភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គម

## សម្ភារឧបទ្ទេសសម្រាប់មេរៀនៈ

- ឯកសារចែកជូនៈ
    - បទបង្ហាញអំពីគោលបំណងមេរៀន និងខ្លឹមសារមេរៀន

- ហ្វឺតសរសេរក្រដាស ក្រដាសផ្ទាំងធំ ស្កុត
- កុំព្យូទ័រយួរដៃ និងម៉ាស៊ីនបញ្ចាំងឯកសារ

**ឯកសារយោង**

- ឯកសារបណ្តុះបណ្តាលសម្រាប់គ្រូ និងសិក្ខាកាមស្តីពីការលើកកម្ពស់ការយល់ដឹង និងភ្ជាប់ទំនាក់ទំនងសង្គមស៊ីវិលជាមួយកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (Pact VBNK វិច្ឆិកា២០១០)
- ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៥១ ៥២ ៧៥ ៦៨ ៧៦
- បទបញ្ជាផ្ទៃក្នុងនៃកិច្ចប្រជុំក្រុមប្រឹក្សាប្រការ ២៥ និង៣៣

**របៀបសម្របសម្រួលមេរៀន**

| ម៉ោង | <u>សកម្មភាព និងវិធីសាស្ត្រ</u> | សម្ភារ និងឯកសារចែកជូន |
|---|---|---|
| ៥ នាទី | <u>សកម្មភាពទី១៖</u> រំលឹកមេរៀនឡើងវិញ:<br>▪ អ្នកសម្របសម្រួលចាប់ផ្តើមរំលឹកមេរៀនទី៤ឡើងវិញបន្តិចស្តីពីខ្សែគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ ស្តីពីតួនាទី និងភារកិច្ចស្របគ្នាមួយចំនួនរបស់អង្គការសង្គមស៊ីវិល និងក្រុមប្រឹក្សាហើយពួកគេអាចធ្វើការជាមួយគ្នាបានដោយរលូនដោយមានការឆ្លើយតបបានយ៉ាងប្រសើរក្នុងការសម្រេចការងារក្នុងភាពជាដៃគូ | |
| ៥នាទី | <u>សកម្មភាពទី២៖</u>គោលបំណងមេរៀន:<br>▪ អ្នកសម្របសម្រួលបង្ហាញពីគោលបំណងមេរៀនព្រមទាំងបញ្ជាក់ជាមួយអ្នកចូលរួមទាំងអស់ឱ្យបានច្បាស់មុននឹងចាប់ផ្តើមជំហានបន្ទាប់ | ▪ ស្លាយទី ២ |
| ១៥នាទី | <u>សកម្មភាពទី៣៖</u> អត្ថន័យនៃអង្គការសង្គមស៊ីវិល វិស័យឯកជន អ្នកសារព័ត៌មាន ការពិក្សាក្រុមធំ: ផ្តល់ឱកាសដល់អ្នកចូលរួម៤ទៅ៥ឆ្លើយនូវសំណួរដូចខាងក្រោម:<br>▪ តើអង្គការសង្គមស៊ីវិលមានន័យយ៉ាងដូចម្តេច?<br>▪ តើវិស័យឯកជនមានន័យយ៉ាងដូចម្តេច?<br>▪ តើអ្នកសារព័ត៌មានមានន័យយ៉ាងដូចម្តេច?<br>▪ អ្នកសម្របសម្រួលកត់ត្រាចម្លើយរបស់អ្នកចូលរួមទាំងអស់ទៅលើក្រដាស់ | ▪ ស្លាយទី ៣ដល់៥ |

| | | |
|---|---|---|
| | ផ្ទាំងធំបន្ទាប់មកអ្នកសម្របសម្រួលធ្វើការបង្ហាញស្លាយស្ដីពីអត្ថន័យទាំង៣ខាងលើដល់អ្នកចូលរួមព្រមទាំងផ្ដល់ឱកាសឱ្យអ្នកចូលរួមមានជា សំណួរចម្លើយដើម្បីបញ្ជាក់ទៅលើអត្ថន័យនីមួយៗ | |
| ២៥នាទី | <u>សកម្មភាពទី៤៖</u> សិទ្ធិ និងតួនាទី<br>▪ <u>បទបង្ហាញ:</u> (១០នាទី)មុនធ្វើបទបង្ហាញអ្នកសម្របសម្រួលធ្វើការបំផុសសំណួរដោយឱ្យអ្នកចូលរួមចំនួន៣ ទៅ៤នាក់ឆ្លើយនូវសំណួរ:<br>　▪ តើអង្គការសង្គមស៊ីវិល វិស័យឯកជន អ្នកសារព័ត៌មាន មានសិទ្ធិ និងតួនាទីអ្វីខ្លះក្នុងការចូលរួមលើកកម្ពស់អភិបាលកិច្ចល្អ និង គណនេយ្យភាពសង្គម?<br>▪ អ្នកសម្របសម្រួលកត់ត្រាចម្លើយរបស់អ្នកចូលរួមទាំងអស់ទៅលើក្រដាស់ផ្ទាំងធំបន្ទាប់មកអ្នកសម្របសម្រួលធ្វើការបង្ហាញស្លាយស្ដីពីតួនាទី និងភារកិច្ចរបស់អង្គការសង្គមស៊ីវិល វិស័យឯកជន អ្នកសារព័ត៌មាន<br>▪ <u>ការពិភាក្សាក្រុមតូច:</u> ចែកជា៣ទៅ៤តាមក្រុមដោយក្រុមនីមួយៗ មានពេល១៥នាទីក្នុងការ ពិភាក្សា ដោយផ្អែកទៅលើ<u>តារាងទី១</u>ដែលចែកជូន ហើយឆ្លើយនូវសំណួរៈតើអ្នកដែលពាក់ព័ន្ធ សំខាន់ៗមានតួនាទីអ្វីខ្លះក្នុងការលើកកម្ពស់អភិបាលកិច្ចល្អនិងគណនេយ្យភាពសង្គម?<br>▪ អ្នកសម្របសម្រួលធ្វើការបូកសរុបលទ្ធផលក្រុមពិភាក្សាលើតារាងទី០១<br>▪ អ្នកសម្របសម្រួលបញ្ជាក់ទៅលើលទ្ធផលក្រុមពិភាក្សានីមួយៗដើម្បីឱ្យមានការព្រមព្រៀងគ្នានៅលើតារាងតួនាទី និងភារកិច្ច | ▪ ស្លាយទី ៦ដល់១១<br>▪ តារាងទី០១ |
| ១០ នាទី | <u>សកម្មភាពទី៥៖</u> សំយោគមេរៀនឡើងវិញ<br>▪ អ្នកសម្របសម្រួលបញ្ជាក់ទៅលើខ្លឹមសារមេរៀនដែលបានរៀនរួចមកហើយ ដោយផ្ដោតទៅលើ សង្គមស៊ីវិល វិស័យឯកជន និងអ្នកសារព័ត៌មាន<br>▪ បញ្ជាក់ពីតារាងតួនាទីរបស់សិទ្ធិ និងតួនាទី អង្គការសង្គមស៊ីវិល វិស័យឯកជន អ្នកសារព័ត៌មាន<br>▪ រំលឹកតួនាទីដែលស្របគ្នាក្នុងការលើកកម្ពស់ភាពជាដៃគូសម្រាប់អភិបាលកិច្ចល្អ និងយកទៅប្រើនៅមេរៀនទី៣ថ្ងៃទី៣ ស្ដីពីការចូលរួមរបស់អង្គការសង្គមស៊ីវិលនិងអ្នកពាក់ព័ន្ធក្នុងដំណើរការកសាងផែនការ និងថវិការបស់ក្រុង ស្រុក និងឃុំ សង្កាត់។ | |

# ថ្ងៃទី១

# មេរៀនទី៥



## សិទ្ធិ និងតួនាទីរបស់ប្រជាពលរដ្ឋ អង្គការសង្គម ស៊ីវិល ក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ នៅថ្នាក់ក្រុង ស្រុក ឃុំ និងសង្កាត់

សហការជាមួយការិយាល័យសម្របសម្រួលគម្រោងនៃក្រសួងមហាផ្ទៃ និង អង្គការផេកកម្ពុជា

# ១-គោលបំណងមេរៀន

១. ពន្យល់ពីអត្ថន័យនៃពាក្យអង្គការសង្គមស៊ីវិល វិស័យឯកជន អ្នកសារព័ត៌មាន

២. ពន្យល់ពីសិទ្ធិ និងតួនាទី អង្គការសង្គមស៊ីវិល វិស័យឯកជន អ្នកសារព័ត៌មានក្នុងការលើកកម្ពស់សកម្មភាពអភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គម

# ២.អត្ថន័យ

## អង្គការសង្គមស៊ីវិល

គឺជាអង្គការមិនមែនរដ្ឋាភិបាល ឬ
សមាគមមូលដ្ឋាននានាដែលមិនរកប្រាក់
ចំណេញ ហើយបម្រើផលប្រយោជន៍ជាសា
ធារណៈ និងគុណតម្លៃ នៃសមាជិកខ្លួន

# អត្ថន័យ (ត)

## វិស័យឯកជន

ជាផ្នែកនៃសេដ្ឋកិច្ចដែលបង្កើតឡើងដោយបុគ្គល ឬជាក្រុមតាមទម្រង់ជាសហគ្រិនដើម្បីរកផលចំណេញ

# អត្ថន័យ (ត)

## អ្នកសារព័ត៌មាន



គឺជាអ្នកស្វែងរក ប្រមូល ដើម្បីចងក្រងនូវ
ព័ត៌មានពីហេតុការពិតតាមទម្រង់មួយដែលងាយ
យល់ងាយទទួលយកបាន ដើម្បីធ្វើការផ្សព្វផ្សាយ
តាមរយៈកាសែត ទស្សនាវដ្តី វិទ្យុ និងទូរទស្សន៍

# ៣.ការចូលរួមរបស់អង្គការសង្គមស៊ីវិល

ការចូលរួមក្នុងការផ្តល់យោបល់ត្រឡប់ពីក្តីកង្វល់ បញ្ហាជាអាទិភាព និងចូលរួមដោះស្រាយតាមរយៈសកម្មភាពខាងក្រោម៖

- សកម្មភាពពិគ្រោះយោបល់នៅមូលដ្ឋាន
- ដំណើរការកសាងផែនការ និងថវិការបស់ក្រុមប្រឹក្សា
- វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ជាសាធារណៈ
- កិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់

# ការចូលរួមរបស់អង្គការសង្គមស៊ីវិល(ត)

- ចូលរួមតាមដានការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដើម្បីឱ្យមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ
- ដំណើរការត្រួតពិនិត្យ និងវាយតម្លៃគម្រោងរបស់ក្រុមប្រឹក្សា
- ការផ្សព្វផ្សាយបន្តពីសកម្មភាពអភិវឌ្ឍរបស់ក្រុមប្រឹក្សា
- ចូលរួមប្រជុំពីការរៀបចំគោលនយោបាយថ្មីៗនៅក្រុង ស្រុក ឃុំសង្កាត់

# ៤.ការចូលរួមរបស់វិស័យឯកជន

- ចូលរួមក្នុងដំណើរការលទ្ធកម្មគម្រោងរបស់ក្រុមប្រឹក្សា
- ចូលរួមធ្វើជាដៃគូជាមួយក្រុមប្រឹក្សាក្នុងការផ្តល់សេវាកម្មឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាពខ្ពស់ដល់ប្រជាពលរដ្ឋ
- ចូលរួមគាំទ្រផ្នែកបច្ចេកទេស និងផ្តល់យោបល់ផ្សេងៗដល់ក្រុមប្រឹក្សា
- ចូលក្នុងដំណើរការពិគ្រោះយោបល់នៅមូលដ្ឋាន
- ចូលរួមយ៉ាងសកម្មក្នុងដំណើរការកសាងផែនការ និងថវិកា
- ចូលរួមក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ

# ៤.ការចូលរួមរបស់វិស័យឯកជន(ត)

- ចូលរួមក្នុងកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់
- អនុវត្តគម្រោងដែលដាក់ដេញថ្លៃដោយក្រុមប្រឹក្សា
- ចូលរួមក្នុងការអភិវឌ្ឍសមត្ថភាពអង្គការសង្គមស៊ីវិល និងក្រុមប្រឹក្សា

# ៥.ការចូលរួមរបស់អ្នកសារព័ត៌មាន

- ជាដៃគូផ្សព្វផ្សាយនូវសកម្មភាពអភិវឌ្ឍរបស់ក្រុមប្រឹក្សាដល់សហគមន៍ និងសាធារណៈជនទាំងឡាយ
- ចូលរួមផ្សព្វផ្សាយសេចក្ដីសម្រេច សមិទ្ធិផល និងការរីកចម្រើននានារបស់ក្រុមប្រឹក្សាដល់សហគមន៍
- ផ្សព្វផ្សាយពីកាលវិភាគនៃការពិគ្រោះយោបល់នៅមូលដ្ឋានជូនសាធារណៈជន
- ផ្សព្វផ្សាយពីដំណោះស្រាយផ្សេងៗរបស់ក្រុមប្រឹក្សាក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ជូនសាធារណៈជន

# ៥.ការចូលរួមរបស់អ្នកសារព័ត៌មាន(ត)

- ចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗដែលរៀបចំឡើងដោយអង្គការសង្គមស៊ីវិល និងក្រុមប្រឹក្សា
- ចូលរួមផ្សព្វផ្សាយផែនការ និងថវិកាដែលបានអនុម័តដល់ក្រុមប្រឹក្សាដល់សាធារណៈជន
- ចូលរួមផ្សព្វផ្សាយពីចំណូលចំណាយរបស់ក្រុមប្រឹក្សាដល់សហគមន៍

ច្បាប់រៀបចំអង្គការ មាត្រា ៤២ ៥១ ៧៦

# ថ្ងៃទី១

## ចំណងជើងមេរៀនៈ សិទ្ធិ និងតួនាទីរបស់ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិលក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ

### តារាងទី១÷ តើតួនាទី និងភារកិច្ច របស់អ្នកពាក់ព័ន្ធខាងក្រោមក្នុងការ លើកកម្ពស់សកម្មភាពអភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គមមានអ្វីខ្លះ?

| សកម្មភាព | អង្គការសង្គមស៊ីវិល | វិស័យឯកជន | អ្នកសារព័ត៌មាន |
|---|---|---|---|
| ▪ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ | ▪<br>▪ | ▪<br>▪ | ▪<br>▪ |
| ▪ ដំណើរការពិគ្រោះយោបល់មូលដ្ឋាន | ▪<br>▪ | ▪<br>▪ | ▪<br>▪ |
| ▪ ដំណើរការកសាងផែនការក្រុង ស្រុក ឃុំ សង្កាត់ | ▪<br>▪ | ▪<br>▪ | ▪<br>▪ |
| ▪ ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា | ▪<br>▪ | ▪<br>▪ | ▪<br>▪ |
| ▪ ការផ្សព្វផ្សាយព័តិមាន | ▪<br>▪ | ▪<br>▪ | ▪<br>▪ |

# ថ្ងៃទី១

# ឯកសារចែក

# មេរៀនទី៥

# សិទ្ធិ និងតួនាទីរបស់ប្រជាពលរដ្ឋ អង្គការសង្គម ស៊ីវិលក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ នៅថ្នាក់ក្រុង ស្រុក ឃុំ និងសង្កាត់

## ១.គោលបំណងមេរៀន

១. ពន្យល់ពីអត្ថន័យនៃពាក្យអង្គការសង្គមស៊ីវិល វិស័យឯកជន អ្នកសារព័ត៌មាន

២. ពន្យល់ពីសិទ្ធិ និងតួនាទី អង្គការសង្គមស៊ីវិល វិស័យឯកជន អ្នកសារព័ត៌មានក្នុងការលើកកម្ពស់សកម្មភាពអភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គម

## ២.អត្ថន័យ

- **អង្គការសង្គមស៊ីវិល**

គឺជាអង្គការមិនមែនរដ្ឋាភិបាល ឬ សមាគមមូលដ្ឋាននានាដែលមិនរកប្រាក់ចំណេញ ហើយបម្រើផលប្រយោជន៍ជាសាធារណៈ និងគុណតម្លៃនៃសមាជិកខ្លួន

- **វិស័យឯកជន**

ជាផ្នែកនៃសេដ្ឋកិច្ចដែលបង្កើតឡើងដោយបុគ្គល ឬជាក្រុមតាមទម្រង់ជាសហគ្រិនដើម្បីរកផលចំណេញ

- **អ្នកសារព័ត៌មាន**

គឺជាអ្នកស្វែងរក ប្រមូល ដើម្បីចងក្រងនូវព័ត៌មានពីហេតុការពិតតាមទម្រង់មួយដែលងាយយល់ទទួលយកបាន ដើម្បីធ្វើការផ្សព្វផ្សាយតាមរយៈកាសែត ទស្សនាវដ្តី វិទ្យុ និងទូរទស្សន៍

## ៣.ការចូលរួមរបស់អង្គការសង្គមស៊ីវិល

ការចូលរួមក្នុងការផ្តល់យោបល់ត្រឡប់ពីក្តីកង្វល់ បញ្ហាជាអាទិភាព និងចូលរួមដោះស្រាយតាមរយៈសកម្មភាពខាងក្រោម ៖

- សកម្មភាពពិគ្រោះយោបល់នៅមូលដ្ឋាន
- ដំណើរការកសាងផែនការ និងថវិការបស់ក្រុមប្រឹក្សា
- វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ជាសាធារណៈ
- កិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់
- ចូលរួមតាមដានការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដើម្បីឱ្យមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ
- ដំណើរការត្រួតពិនិត្យ និងវាយតម្លៃគម្រោងរបស់ក្រុមប្រឹក្សា
- ការផ្សព្វផ្សាយបន្តពីសកម្មភាពអភិវឌ្ឍរបស់ក្រុមប្រឹក្សា

- ចូលរួមប្រជុំពីការរៀបចំគោលនយោបាយថ្មីៗនៅក្រុង ស្រុក ឃុំសង្កាត់

**៤.ការចូលរួមរបស់វិស័យឯកជន**

- ចូលរួមក្នុងដំណើរការលទ្ធកម្មគម្រោងរបស់ក្រុមប្រឹក្សា
- ចូលរួមធ្វើជាដៃគូជាមួយក្រុមប្រឹក្សាក្នុងការផ្តល់សេវាកម្មឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាពខ្ពស់ដល់ប្រជាពលរដ្ឋ
- ចូលរួមគាំទ្រផ្នែកបច្ចេកទេស និងផ្តល់យោបល់ផ្សេងៗដល់ក្រុមប្រឹក្សា
- ចូលក្នុងដំណើរការពិគ្រោះយោបល់នៅមូលដ្ឋាន
- ចូលរួមយ៉ាងសកម្មក្នុងដំណើរការកសាងផែនការ និងថវិកា
- ចូលរួមក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ
- ចូលរួមក្នុងកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់
- អនុវត្តគម្រោងដែលដាក់ដេញថ្លៃដោយក្រុមប្រឹក្សា
- ចូលរួមក្នុងការអភិវឌ្ឍសមត្ថភាពអង្គការសង្គមស៊ីវិល និងក្រុមប្រឹក្សា

**៥តើមានការចូលរួមរបស់អ្នកសារព័ត៌.**

- ជាដៃគូផ្សព្វផ្សាយនូវសកម្មភាពអភិវឌ្ឍរបស់ក្រុមប្រឹក្សាដល់ សហគមន៍ និងសាធារណៈជនទាំងឡាយ
- ចូលរួមផ្សព្វផ្សាយសេចក្តីសម្រេច សមិទ្ធិផល និងការរីកចម្រើននានារបស់ក្រុមប្រឹក្សាដល់សហគមន៍
- ផ្សព្វផ្សាយពីកាលវិភាគនៃការពិគ្រោះយោបល់នៅមូលដ្ឋានជូនសាធារណៈជន
- ផ្សព្វផ្សាយពីដំណោះស្រាយផ្សេងៗរបស់ក្រុមប្រឹក្សាក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ជូនសាធារណៈជន
- ចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗដែលរៀបចំឡើងដោយអង្គការសង្គម ស៊ីវិល និងក្រុមប្រឹក្សា
- ចូលរួមផ្សព្វផ្សាយផែនការ និងថវិកាដែលបានអនុម័តដល់ក្រុមប្រឹក្សា ដល់សាធារណៈជន
- ចូលរួមផ្សព្វផ្សាយពីចំណូលចំណាយរបស់ក្រុមប្រឹក្សាដល់សហគមន៍

**ឯកសារយោង**

ច្បាប់រៀបចំអង្គការ មាត្រា ៤២ ៥១ ៧៦

# ថ្ងៃទី២

## ការភ្ជាប់ទំនាក់ទំនង រវាងក្រុមប្រឹក្សា ក្រុង ស្រុក ឃុំ សង្កាត់ និងប្រជាពលរដ្ឋ

# ថ្ងៃទី២

# ម្លង់មេរៀនទី១

## ចំណងជើងមេរៀន: ការភ្ជាប់ទំនាក់ទំនង រវាងក្រុមប្រឹក្សា ក្រុង ស្រុក ឃុំ សង្កាត់ និងប្រជាពលរដ្ឋ

**ពេលវេលា: ០៨:៣០ ដល់ ១០:០០ (១:៣០ម៉ោង)**

**គោលបំណងនៃមេរៀន:** នៅចុងបញ្ចប់មេរៀននេះអ្នកចូលរួមនឹងអាចៈ

១. ពន្យល់បានពីមូលហេតុនៃការភ្ជាប់ទំនាក់ទំនង ហើយតើត្រូវភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សា ក្រុង ស្រុក ឃុំ សង្កាត់ដោយរបៀបណា

២. ពិពណ៌នាពីសកម្មភាព ឬ ឱកាសសម្រាប់ភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាក្រុង ស្រុក ឃុំ និងសង្កាត់។

**កំណត់ចំណាំរបស់អ្នកសម្របសម្រួល**

១. អ្នកសម្របសម្រួលត្រូវបញ្ជាក់អំពីអត្ថន័យ និងមូលហេតុនៃការភ្ជាប់ទំនាក់ទំនងរវាងក្រុមប្រឹក្សា និងប្រជាពលរដ្ឋ។

២. អ្នកសម្របសម្រួលត្រូវបង្ហាញពីរបៀបនៃការចូលរួមរបស់អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋក្នុងសកម្មភាពអភិវឌ្ឍរបស់ ក្រុង ស្រុក ឃុំ សង្កាត់។

**លទ្ធផលរំពឹងទុកនៃមេរៀន**

ក. អ្នកចូលរួមអាចពន្យល់បានពីអត្ថន័យនៃការភ្ជាប់ទំនាក់ទំនង

ខ. អ្នកចូលរួមអាចរៀបរាប់ពីសកម្មភាពចំបងៗនៃការភ្ជាប់ទំនាក់ទំនងរវាងក្រុមប្រឹក្សាក្រុង ស្រុក ឃុំ និង សង្កាត់ និងប្រជាពលរដ្ឋ

គ. អ្នកចូលរួមទាំងអស់យល់ពីរបៀបនៃការចូលរួមរបស់ប្រជាពលរដ្ឋក្នុងសកម្មភាពអភិវឌ្ឍរបស់ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ និងសង្កាត់។

**សម្ភារឧបទេ្ទសសម្រាប់មេរៀន:**

- ឯកសារចែកជូនៈ
  - បទបង្ហាញអំពីគោលបំណងមេរៀន និងខ្លឹមសារមេរៀន
- ហ្វឺតសរសេរក្រដាស ក្រដាសផ្ទាំងធំ ស្កុត

- កុំព្យូទ័រយួរដៃ និងម៉ាស៊ីនបញ្ចាំងឯកសារ

**ឯកសារយោង**

- ឯកសារបណ្តុះបណ្តាលសម្រាប់គ្រូ និងសិក្ខាកាមស្តីពីការលើកកម្ពស់ការយល់ដឹង និងភ្ជាប់ទំនាក់ទំនង សង្គមស៊ីវិលជាមួយកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (Pact VBNK វិច្ឆិកា២០១០)
- បទបង្ហាញស្តីពីទស្សនទាននៃការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាខេត្ត ស្រុក (ផេកកម្ពុជា ឈ ចន្ទសុផល មីនា ២០១០)

**របៀបសម្របសម្រួលមេរៀន**

| ម៉ោង | <u>សកម្មភាព និងវិធីសាស្ត្រ</u> | សម្ភារ និងឯកសារចែកជូន |
|---|---|---|
| ៥ នាទី | <u>សកម្មភាពទី១៖</u> អ្នកសម្របសម្រួលរំឭកឡើងវិញបន្តិចពីមេរៀនទី៥ថ្ងៃទី១ស្តីពីសិទ្ធិ និងតួនាទីរបស់ប្រជាពលរដ្ឋក្នុងការលើកកម្ពស់អភិបាលកិច្ចល្អនៅថ្នាក់ ក្រុង ស្រុក ឃុំ និងសង្កាត់ព្រោះមេរៀននេះមានការជាប់ទាក់ទងគ្នា។ | |
| ១០នាទី | <u>សកម្មភាពទី២៖ គោលបំណងមេរៀនៈ</u><br>▪ អ្នកសម្របសម្រួលពន្យល់ដោយសង្ខេបពីគោលបំណងមេរៀនៈ<br>▪ ការបញ្ជាក់ផ្សេងៗពីអ្នកចូលរួមទៅលើគោលបំណងនៃមេរៀន | ▪ ស្លាយទី២ |
| ១០នាទី | <u>សកម្មភាពទី៣៖ និយមន័យនៃការភ្ជាប់ទំនាក់ទំនង</u><br>▪ ការពិភាក្សាក្រុមធំៈអ្នកសម្របសម្រួលសួរសំណួរទៅកាន់អ្នកចូលរួមទាំងអស់ថាៈ តើអ្វីទៅជាការភ្ជាប់ទំនាក់ទំនង?<br>ក. ផ្តល់ឱកាសឱ្យអ្នកចូលរួម២ទៅ៣**នាក់**ដើម្បីឆ្លើយសំណួរ<br>ខ. អ្នកសម្របសម្រួលកត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ<br>គ. អ្នកសម្របសម្រួលបង្ហាញស្លាយទី៣ | ▪ ក្រដាសផ្ទាំងធំ<br>▪ ស្លាយទី៣ |
| ១០នាទី | <u>សកម្មភាពទី៤៖ មូលហេតុនៃការភ្ជាប់ទំនាក់ទំនង</u><br>▪ អ្នកសម្របសម្រួលសួរសំណួរទៅកាន់អ្នកចូលរួមទាំងអស់ៈ ហេតុអ្វីបានជា ចាំបាច់ត្រូវមានការទំនាក់ទំនងរវាងក្រុមប្រឹក្សា | |

| | | |
|---|---|---|
| | និងប្រជាពលរដ្ឋ?(ចម្លើយ)<br>○ ការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាមានឥទ្ធិពលទៅលើផលប្រយោជន៍សហគមន៍ និងតម្រូវការជាអាទិភាពរបស់ពួកគេ។<br>○ ប្រជាពលរដ្ឋ និងក្រុមអង្គការសង្គមស៊ីវិលជាស្ពាន ឬ ជាភ្នែកសម្រាប់ជួយការងាររបស់ក្រុមប្រឹក្សាឱ្យអនុវត្តកាន់តែប្រសើរឡើង និងឆ្លើយតបទៅនឹងផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងតម្រូវការនានា<br>○ ជួយពង្រឹងលទ្ធិប្រជាធិបតេយ្យឱ្យមានប្រសិទ្ធភាព<br>▪ បទបង្ហាញស្លាយទី៤ | ▪ ស្លាយទី៤ |
| ១៥នាទី | <u>សកម្មភាពទី៥៖សកម្មភាពភ្ជាប់ទំនាក់ទំនង:</u><br>សំណួរបន្តទៅក្រុមធំ: តើមានសកម្មភាពអ្វីខ្លះដែលប្រជាពលរដ្ឋត្រូវចូលរួមភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សា ក្រុង ស្រុក ឃុំ និងសង្កាត់? ហើយចូលរួមនៅពេលណា?<br>▪ ផ្តល់ឱកាសឱ្យអ្នកចូលរួម២ ទៅ៣នាក់ឆ្លើយសំណួរ<br>▪ អ្នកសម្របសម្រួលកត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ<br>▪ អ្នកសម្របសម្រួលធ្វើបទបង្ហាញស្តីពីសកម្មភាពភ្ជាប់ទំនាក់ទំនងដោយស្រង់យកមាត្រាច្បាប់មកជាអំណះអំណាង (ច្បាប់រៀបចំអង្គការ មាត្រា ៣៤ និង៣៨ ៦៨ ៧៥ និង៧៦) | ▪ ស្លាយទី៥ ដល់ ១០ |
| ៣០នាទី | <u>សកម្មភាពទី៦៖ សកម្មភាពនៃការភ្ជាប់ទំនាក់ទំនង</u><br>▪ <u>ពិភាក្សាក្រុមតូច:</u><br>ចែកក្រុមពិភាក្សាជា៤ក្រុមដោយផ្អែកទៅលើអ្នកចូលរួមជាក់ស្តែង ដោយឆ្លើយនូវសំណួរដូចខាងក្រោម:<br>▪ តើមានវិធីសាស្ត្រអ្វីខ្លះដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋដោយសកម្ម? (ក្នុងការបញ្ចេញមតិយោបល់)?<br>ក្រុមទី១៖ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ<br>ក្រុមទី២៖ ការកសាងផែនការ និងថវិកា | |

| | | |
|---|---|---|
| | ក្រុមទី៣៖ កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា<br>ក្រុមទី៤៖ ការផ្សព្វផ្សាយព័ត៌មាន<br>▪ បិទលទ្ធផលក្រុមពិភាក្សា ហើយឱ្យក្រុមដទៃទៀតត្រួតពិនិត្យនិងមានសំណួរ<br>▪ លទ្ធផលក្រុមពិភាក្សានឹងរក្សាទុកទៅប្រើប្រាស់នៅក្នុងមេរៀនទី៤ស្ដីពីការរៀបចំផែនការ**សកម្មភាព**នៅថ្ងៃទី៣ | |
| ១០ នាទី | <u>សកម្មភាពទី៧៖</u> <u>សំយោគមេរៀនឡើងវិញ</u><br>▪ ការភ្ជាប់ទំនាក់ទំនងរបស់ប្រជាពលរដ្ឋនៅគ្រប់ដំណាក់កាលនៃសកម្មភាពអភិវឌ្ឍអាស្រ័យទៅលើច្បាប់ និងការតាំងចិត្តរបស់អ្នកអនុវត្ត<br>▪ ការបើកចិត្តឱ្យទូលាយដើម្បីស្ដាប់ ការផ្ដល់នូវគុណតម្លៃទៅវិញទៅមករវាងក្រុមប្រឹក្សា និងប្រជាពលរដ្ឋគឺជាការចាំបាច់ដើម្បីឱ្យសម្រេចនូវគោលដៅរួម<br>▪ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងមិនអាចទទួលបានជោគជ័យទេបើគ្មានការចូលរួមភ្ជាប់ទំនាក់ទំនងក្រុមប្រឹក្សា និងប្រជាពលរដ្ឋ | |

# ថ្ងៃទី២
# មេរៀនទី១

## ការភ្ជាប់ទំនាក់ទំនង រវាងក្រុមប្រឹក្សា ក្រុង ស្រុក ឃុំ សង្កាត់ និងប្រជាពលរដ្ឋ

សហការការិយាល័យសម្របសម្រួលគម្រោង DFGG ក្រសួងមហាផ្ទៃ អង្គការផេកកម្ពុជា

# ១.គោលបំណងមេរៀន

១. ពន្យល់បានពីមូលហេតុនៃការភ្ជាប់ទំនាក់ទំនង ហើយតើត្រូវភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សា ក្រុង ស្រុក ឃុំ សង្កាត់ដោយរបៀបណា

២. ពិពណ៌នាពីសកម្មភាព ឬ ឱកាសសម្រាប់ភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាក្រុង ស្រុក ឃុំ និងសង្កាត់។

# ២.និយមន័យ ការភ្ជាប់ទំនាក់ទំនង

ការភ្ជាប់ទំនាក់ទំនងក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យគឺៈ

ដំណើរការចូលរួមរបស់ប្រជាពលរដ្ឋ (អ្នកទទួលសេវា) ក្នុងសកម្មភាពអនុវត្ត និងពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាអំពីបញ្ហា ក្ដីកង្វល់ តម្រូវការជាអាទិភាព និងផ្ដល់ព័ត៌មានត្រឡប់ ជួយឱ្យក្រុមប្រឹក្សាអាចបំពេញមុខងារ និងភារកិច្ចប្រកបដោយតម្លាភាព គណនេយ្យភាព និងឆ្លើយតបខ្ពស់។

(ផេកកម្ពុជា មីនា ២០១២)

# ៣.មូលហេតុនៃការភ្ជាប់ទំនាក់ទំនង

- ដោយសារការធ្វើសេចក្តីសម្រេចចិត្តដោយក្រុមប្រឹក្សាក្រុង ស្រុក ឃុំ និងសង្កាត់ និងមានផលប៉ះពាល់ធំធេងទៅលើផលប្រយោជន៍ប្រជាពលរដ្ឋ និងសហគមន៍
- មានការផ្លាស់ប្តូរយោបល់រវាងក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ និងប្រជាពលរដ្ឋ មានសារៈសំខាន់ចំពោះប្រសិទ្ធភាពនៃដំណើរការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យ
- ការឆ្លើយតបប្រកបដោយប្រសិទ្ធិភាពរបស់ក្រុមប្រឹក្សាត្រូវផ្តល់ឱកាសដល់ប្រជាពលរដ្ឋចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត រួមទាំងការកសាងផែនការ ថវិកា ការត្រួតពិនិត្យ និងដំណើរការតាមដាន និងវាយតម្លៃ

# ៤.សកម្មភាពដើម្បីភ្ជាប់ទំនាក់ទំនង

- ប្រជាពលរដ្ឋអាចធ្វើការបញ្ចុះបញ្ចូលឱ្យមានការចាប់អារម្មណ៍ពីផលប្រយោជន៍របស់ខ្លួន និងតម្រូវការទូទៅរបស់សហគមន៍ ឬតម្រូវការពិសេសជនជាតិភាគតិច
- ប្រជាពលរដ្ឋអាចផ្តល់យោបល់ដើម្បីកែលម្អគោលនយោបាយនានា
- ប្រជាពលរដ្ឋអាចធ្វើការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីអនុវត្តកម្មវិធីនានា
- ប្រជាពលរដ្ឋអាចចូលរួមក្នុងការតាមដានសកម្មភាពដែលអនុវត្តដោយក្រុមប្រឹក្សាឬ អ្នកម៉ៅការដើម្បីធានាពីគុណភាព

# ៤.សកម្មភាពដើម្បីភ្ជាប់ទំនាក់ទំនង

- ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់ អំពីជម្រើសជាអាទិភាពដើម្បីធ្វើសេចក្តីសម្រេចចិត្តធានាបានការ អភិវឌ្ឍតាមបែបប្រជាធិតេយ្យក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ការរៀបចំការអនុវត្តផែនការអភិវឌ្ឍក្រុមប្រឹក្សាត្រូវពិគ្រោះយោបល់ជាមួយៈ
  - ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
  - ប្រភេទក្រុមប្រឹក្សាផ្សេងទៀតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
  - ក្រសួងស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល
  - អ្នកពាក់ព័ន្ធនានា (ច្បាប់រៀបចំអង្គការ មាត្រា ៣៤ និង៣៨)

# ៤.សកម្មភាពដើម្បីភ្ជាប់ទំនាក់ទំនង

- ក្រុមប្រឹក្សានីមួយៗត្រូវមានក្តារព័ត៌មានសាធារណៈ ឬ មធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងទៀតនៅក្នុងការិយាល័យកណ្តាលរបស់ខ្លួន និងនៅតាមទីកន្លែងនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតាមការចាំបាច់ ហើយទីកន្លែងទាំងនោះមានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋទទួលបាននូវព័ត៌មានជាសាធារណៈទាំងនោះ
- ក្រុមប្រឹក្សាត្រូវតាមដាន និងវាយតម្លៃជារៀងរាល់ឆ្នាំទៅលើការអនុវត្តផែនការ អភិវឌ្ឍរបស់ខ្លួនដោយលើកទឹកចិត្តឱ្យមានការចូលរួមពីប្រជាពលរដ្ឋ

# ៥.តើប្រជាពលរដ្ឋអាចចូលរួមនៅពេលណា

- ដំណើរការពិគ្រោះយោបល់នៅមូលដ្ឋានរបស់ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់
- កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់
- ដំណើរការកសាងផែនការ និងថវិការបស់ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ និងសង្កាត់
- វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់
- ដំណើរការតាមដាន វាយតម្លៃគម្រោងរបស់ក្រុមប្រឹក្សាក្រុង ស្រុកឃុំសង្កាត់
- សកម្មភាពអភិវឌ្ឍផ្សេងៗរបស់ក្រុង ស្រុក ឃុំ និងសង្កាត់

# ៦.តើប្រជាពលរដ្ឋចូលរួមដោយរបៀបណា?

- “មាត្រា ៦៨ ៧៥ និង៧៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានចែងថា កិច្ចប្រជុំ ឬព្រឹត្តិការណ៍នានារបស់ក្រុមប្រឹក្សាត្រូវផ្សព្វផ្សាយជាសាធារណៈស្តីពីកាលបរិច្ឆេទ និងទីកន្លែងនៃកិច្ចប្រជុំ” បង្ហាញឱ្យមានការចូលរួមពីប្រជាពលរដ្ឋ។
- ប្រជាពលរដ្ឋអាចជួយអភិវឌ្ឍ និងពង្រឹងឱ្យមានគណនេយ្យភាព និងយន្តការនៃការឆ្លើយតប
- ដើរតួជាតំណាងផ្សព្វផ្សាយព័ត៌មានបន្តទៅសហគមន៍របស់ខ្លួន និងប្រមូលព័ត៌មានត្រឡប់ជូនក្រុមប្រឹក្សា

# ៧. តើប្រជាពលរដ្ឋចូលរួមដោយរបៀបណា?

- ដៃគូជាមួយក្រុមប្រឹក្សាដើម្បីផ្តល់សេវាកម្មប្រកបដោយគុណភាពដល់សហគមន៍ (ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងអរូបវ័ន្ត)
- ជាដៃគូតំណាងសហគមន៍សហការជាមួយសមាគមក្រុមប្រឹក្សាឃុំសង្កាត់ថ្នាក់ខេត្តដើម្បីបង្កើនសមត្ថភាព និងជំនឿចិត្តរបស់ក្រុមប្រឹក្សាឃុំសង្កាត់ (គាំទ្រលើកឡើងពីការព្រួយបារម្ភរបស់សហគមន៍ក្នុងពេលប្រជុំជាមួយក្រុមប្រឹក្សាក្រុង ស្រុក ឃុំ និងសង្កាត់)

# សំណួរ

# ការបំភ្លឺផ្សេងៗ

# ថ្ងៃទី២

# មេរៀនទី ១

# ឯកសារចែក

## ចំណងជើងមេរៀន: ការភ្ជាប់ទំនាក់ទំនងរវាងក្រុមប្រឹក្សា ក្រុង ស្រុក ឃុំ សង្កាត់ និងប្រជាពលរដ្ឋ

**១.គោលបំណងនៃមេរៀន:** នៅចុងបញ្ចប់មេរៀននេះអ្នកចូលរួមនឹងអាចៈ

១. អ្នកចូលរួមអាចពន្យល់បានពីមូលហេតុនៃការភ្ជាប់ទំនាក់ទំនង ហើយតើត្រូវភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សា ក្រុង ស្រុក ឃុំ សង្កាត់នៅពេលណា

២. អ្នកចូលរួមអាចពិពណ៌នាបានយ៉ាងហោចណាស់ឱ្យបានឱកាសពីរផ្សេងគ្នារបស់ប្រជាពលរដ្ឋ ក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាក្រុង ស្រុក ឃុំ និងសង្កាត់បាន។

## ២. ហេតុអ្វីបានជាប្រជាពលរដ្ឋត្រូវភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សា

- ការធ្វើសេចក្តីសម្រេចចិត្តដោយក្រុមប្រឹក្សាក្រុងស្រុក ឃុំ និងសង្កាត់ និងមានផលប៉ះពាល់ធំធេងទៅលើផលប្រយោជន៍ប្រជាពលរដ្ឋ និងសហគមន៍
- មានការផ្លាស់ប្តូរយោបល់រវាងក្រុមប្រឹក្សាក្រុងស្រុក ឃុំ សង្កាត់ និងប្រជាពលរដ្ឋមានសារៈសំខាន់ចំពោះប្រសិទ្ធភាពនៃដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- ការឆ្លើយតបប្រកបដោយប្រសិទ្ធិភាពរបស់ក្រុមប្រឹក្សាត្រូវផ្តល់ឱកាសដល់ប្រជាពលរដ្ឋចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តរួមទាំងការកសាងផែនការថវិកាការត្រួតពិនិត្យ និងដំណើរការតាមដាន និងវាយតម្លៃ

## ៣.តើប្រជាពលរដ្ឋអាចចូលរួមធ្វើអ្វីខ្លះ?

- ប្រជាពលរដ្ឋអាចធ្វើការបញ្ចុះបញ្ចូលឱ្យមានការចាប់អារម្មណ៍ពីផលប្រយោជន៍របស់ខ្លួន និងតម្រូវការទូទៅរបស់សហគមន៍ ឬតម្រូវការពិសេសជនជាតិភាគតិច
- ប្រជាពលរដ្ឋអាចផ្តល់យោបល់ដើម្បីកែលម្អគោលនយោបាយនានា
- ប្រជាពលរដ្ឋអាចធ្វើការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីអនុវត្តកម្មវិធីនានា
- ប្រជាពលរដ្ឋអាចចូលរួមក្នុងការតាមដានសកម្មភាពដែលអនុវត្តដោយក្រុមប្រឹក្សា ឬអ្នកម៉ៅការដើម្បីធានាពីគុណភាព

- ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់អំពីជម្រើសជាអាទិភាព ដើម្បីធ្វើសេចក្តីសម្រេចចិត្តធានាបានការអភិវឌ្ឍតាមបែបប្រជាធិតេយ្យក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ការរៀបចំការអនុវត្តផែនការអភិវឌ្ឍក្រុមប្រឹក្សាត្រូវពិគ្រោះយោបល់ជាមួយៈ
- ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ប្រភេទក្រុមប្រឹក្សាផ្សេងទៀតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល
- អ្នកពាក់ព័ន្ធនានា (ច្បាប់រៀបចំអង្គការ មាត្រា ៣៤ និង៣៨)
- ក្រុមប្រឹក្សានីមួយៗត្រូវមានក្តារព័ត៌មានសាធារណៈឬមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងទៀតនៅក្នុងការិយាល័យកណ្តាលរបស់ខ្លួន និងនៅតាមទីកន្លែងនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតាមការចាំបាច់ហើយទីកន្លែងទាំងនោះមានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋទទួលបាននូវព័ត៌មានជាសាធារណៈទាំងនោះ
- ក្រុមប្រឹក្សាត្រូវតាមដាននិងវាយតម្លៃជារៀងរាល់ឆ្នាំទៅលើការអនុវត្តផែនការ អភិវឌ្ឍរបស់ខ្លួនដោយលើកទឹកចិត្តឱ្យមានការចូលរួមពីប្រជាពលរដ្ឋ

## ៤.តើប្រជាពលរដ្ឋអាចចូលរួមដោយរបៀបណា

- ដំណើរការពិគ្រោះយោបល់នៅមូលដ្ឋានរបស់ក្រុមប្រឹក្សាក្រុងស្រុក ឃុំ សង្កាត់
- កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាក្រុងស្រុក ឃុំ សង្កាត់
- ដំណើរការកសាងផែនការ និងថវិការបស់ក្រុមប្រឹក្សាក្រុងស្រុក ឃុំ និងសង្កាត់
- វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់
- ដំណើរការតាមដានវាយតម្លៃគម្រោងរបស់ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់
- សកម្មភាពអភិវឌ្ឍផ្សេងៗរបស់ក្រុងស្រុក ឃុំ និងសង្កាត់
- “មាត្រា៦៨៧៥ និង៧៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុកខណ្ឌបានចែងថា កិច្ចប្រជុំឬព្រឹត្តិការណ៍នានារបស់ក្រុមប្រឹក្សាត្រូវផ្សព្វផ្សាយជាសាធារណៈស្តីពីកាលបរិច្ឆេទនិងទីកន្លែងនៃកិច្ចប្រជុំ” បង្ហាញឱ្យមានការចូលរួមពីប្រជាពលរដ្ឋ។
- ប្រជាពលរដ្ឋអាចជួយអភិវឌ្ឍនិងពង្រឹងឱ្យមានគណនេយ្យភាព និងយន្តការនៃការឆ្លើយតប
- ដើរតួជាតំណាងផ្សព្វផ្សាយព័ត៌មានបន្តទៅសហគមន៍របស់ខ្លួន និងប្រមូលព័ត៌មានត្រឡប់ជូនក្រុមប្រឹកក្សា

## ៥.ការគាំទ្រដល់ប្រជាពលរដ្ឋនិងអង្គការសង្គមស៊ីវិល

- ដៃគូជាមួយក្រុមប្រឹក្សាដើម្បីផ្តល់សេវាកម្មប្រកបដោយគុណភាពដល់សហគមន៍ (ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនិងអរូបវ័ន្ត)
- ជាដៃគូតំណាងសហគមន៍សហការជាមួយសមាគមក្រុមប្រឹក្សាឃុំសង្កាត់ថ្នាក់ខេត្ត ដើម្បីបង្កើនសមត្ថភាពនិងជំនឿចិត្តរបស់ក្រុមប្រឹក្សាឃុំសង្កាត់ (គាំទ្រលើកឡើងពីការព្រួយបារម្ភរបស់សហគមន៍ក្នុងពេលប្រជុំជាមួយក្រុមប្រឹក្សាក្រុងស្រុក ឃុំ និងសង្កាត់)

# ថ្ងៃទី២

# ប្លង់មេរៀនទី២

## ចំណងជើងមេរៀនៈ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការពិគ្រោះយោបល់នៅមូលដ្ឋាន

**ពេលវេលាៈ ១០:៣០ ដល់ ១១:៣០ (១ម៉ោង)**

**គោលបំណងនៃមេរៀនៈ នៅចុងបញ្ចប់មេរៀននេះអ្នកចូលរួមអាចៈ**

១. បកស្រាយបាននូវអត្ថន័យ និងសារៈសំខាន់នៃការពិគ្រោះយោបល់នៅមូលដ្ឋាន
២. រៀបរាប់ពីដំណើរការរៀបចំ និងអនុវត្តដំណើរការពិគ្រោះយោបល់នៅមូលដ្ឋាន
៣. កំណត់ពីរបៀប និងពេលវេលាបន្ស៊ីលទ្ធផលនៃការពិគ្រោះយោបល់ ទៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់

## កំណត់ចំណាំរបស់អ្នកសម្របសម្រួល

១. បញ្ជាក់ឱ្យបានច្បាស់លាស់ជាមួយអ្នកចូលរួមអំពីគោលបំណងជាក់លាក់ និងលទ្ធផលរំពឹងទុកនៃមេរៀនផ្នែកនេះ ។
២. ប្រើប្រាស់វិធីសាស្ត្រយ៉ាងណាជួយឱ្យអ្នកចូលរួមបានយល់ពីៈ
- និយមន័យនៃការពិគ្រោះយោបល់នៅមូលដ្ឋាន
- សារៈសំខាន់នៃការពិគ្រោះយោបល់នៅមូលដ្ឋាន (លើកបទពិសោធន៍អំពីលទ្ធផលពិគ្រោះយោបល់មកឆ្លុះបញ្ចាំង ដើម្បីឱ្យអ្នកចូលរួមបានយល់)
- ដំណើរការនៃការចូលរួមនៅក្នុងការពិគ្រោះយោបល់នៅមូលដ្ឋានមានអ្វីខ្លះ?
- យល់បានពីគោលគំនិតសំខាន់ៗ នៃការចុះពិគ្រោះយោបល់នៅមូលដ្ឋាន
- ការបន្ស៊ីលទ្ធផលនៃការពិគ្រោះយោបល់ទៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់

៣. សូមបញ្ជាក់ថាក្រុមប្រឹក្សា ឃុំ សង្កាត់ មានបទពិសោធន៍ក្នុងការរៀបចំ និងអនុវត្តការពិគ្រោះយោបល់រួចហើយ ដូច្នេះនេះគ្រាន់តែជាការឆ្លុះបញ្ចាំងឡើងវិញ ដើម្បីពិនិត្យមើលអ្វីដែលមាន និងបន្ថែមចំណុចកែលម្អ
៤. អ្នកចូលរួម (ក្រុមប្រឹក្សាឃុំ សង្កាត់)នៅថ្នាក់ឃុំ សង្កាត់នឹងរៀបចំផែនការអនុវត្តសកម្មភាពពិគ្រោះយោបល់នៅថ្ងៃទី៣
៥. អ្នកចូលរួម (ក្រុមប្រឹក្សាក្រុង ស្រុក) នៅថ្នាក់ស្រុក នឹងចូលរួមគាំទ្រ និងសង្កេត ស្វែងយល់អំពីបញ្ហា ក្តីកង្វល់ តម្រូវការជាអាទិភាព និងយោបល់ត្រឡប់របស់ប្រជាពលរដ្ឋក្នុងដំណើរការអនុវត្តសកម្មភាពពិគ្រោះយោបល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**លទ្ធផលរំពឹងទុកនៃមេរៀន**

- អ្នកចូលរួមនឹងអាចបកស្រាយបាននូវអត្ថន័យ និងសារៈសំខាន់ ហើយអាចរៀបរាប់បានពីដំណើរការរៀបចំ និងអនុវត្តនៃការពិគ្រោះយោបល់នៅមូលដ្ឋាន
- អ្នកចូលរួមកំណត់ពីរបៀប និងពេលវេលា បន្សុីលទ្ធផលការពិគ្រោះយោបល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ទៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ ។

## សម្ភារឧបទ្ទេសសម្រាប់បង្រៀន

- ឯកសារមេរៀន ស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការពិគ្រោះយោបល់នៅមូលដ្ឋាន
  - ស្លាយ
  - ឯកសាចែក ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការពិគ្រោះយោបល់នៅមូលដ្ឋាន
- ហ្វឺតសរសេរ ក្រដាស ក្រដាសផ្ទាំងធំ ស្កុត
- កុំព្យូទ័រយួរដៃ និងម៉ាស៊ីនបញ្ចាំងឯកសារ

## ឯកសារយោង

- សៀវភៅជំនួយស្មារតីស្តីពីការពិគ្រោះយោបល់មូលដ្ឋាន ដោយក្រសួងមហាផ្ទៃ សម្ព័ន្ធភាពជាតិឃុំ សង្កាត់ និងអង្គការផែកកម្ពុជា
- អនុក្រិត្យលេខ ២១៩ ស្តីពីផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល មាត្រា១៣
- សេចក្តីណែនាំស្តីពីកម្មវិធីវិនិយោគឃុំ សង្កាត់ តារាង ១.១ ស្តីពីបញ្ហា មូលហេតុ និងដំណោះស្រាយ

## របៀបសម្របសម្រួលមេរៀន

| ម៉ោង | សកម្មភាព និងវិធីសាស្ត្រ | សម្ភារ និងឯកសារចែកជូន |
|---|---|---|
| ៥ នាទី | **សកម្មភាពទី១ :** សេចក្តីផ្តើម (សូមមើលស្លាយទីទី២) ។<br>• ការពិគ្រោះយោបល់នៅមូលដ្ឋាន គឺជាយន្តការដ៏មានសារៈសំខាន់មួយសម្រាប់ ផ្តល់ឱកាសឱ្យប្រជាពលរដ្ឋនៅតាមមូលដ្ឋានបានចូលរួមបញ្ចេញមតិយោបល់ ក្តីព្រួយបារម្ភ និងតម្រូវការជាក់លាក់របស់ខ្លួនដល់ក្រុមប្រឹក្សាឃុំសង្កាត់ និងផ្តល់ព័ត៌មានត្រឡប់ពីក្រុមប្រឹក្សាជូនដល់ប្រជាពលរដ្ឋវិញ។ ការពិគ្រោះយោបល់នៅមូលដ្ឋានបានរួមចំណែកធ្វើឱ្យមានទំនាក់ទំនងល្អរវាងក្រុមប្រឹក្សា និងប្រជា | |

| | | |
|---|---|---|
| | ពលរដ្ឋ (រួមទាំងក្រុមមិនសូវមានតំណាង) ឱ្យមានឱកាសបានជួបពិភាក្សាជាមួយគ្នាពីបញ្ហា តម្រូវការជាក់លាក់ និងជួយដល់ក្រុមប្រឹក្សាក្នុងការរៀបចំផែនការប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។ ដូច្នេះរៀននេះនឹងពិភាក្សាពីការពិគ្រោះយោបល់នៅមូលដ្ឋាន | |
| ៥នាទី | **<u>សកម្មភាពទី២ :</u> គោលបំណង និងការរំពឹងទុកនៃមេរៀន**<br>**បំផុសគំនិត និងបង្ហាញក្រុមធំ**<br>- អ្នកសម្របសម្រួលពន្យល់គោលបំណងនៃមេរៀន<br>- សួរអ្នកចូលរួមចំនួន២នាក់ ឱ្យផ្តល់យោបល់ពីការរំពឹងទុក តើអ្នកចង់ចេះអ្វីខ្លះពីមេរៀននេះ?<br>- កត់ត្រាចម្លើយអ្នកចូលរួម នៅលើក្រដាសផ្ទាំងធំ រួចបិទលើជញ្ជាំងម្ខាង ទុកសម្រាប់ផ្ទៀងផ្ទាត់នៅពេលបញ្ចប់មេរៀន។<br>- បង្ហាញស្លាយទី២ ការរំពឹងទុកនៃមេរៀន | 💻 ស្លាយទី២<br>🗐 ក្រដាសផ្ទាំងធំ<br>✎ ហ្វឺតកត់ត្រាចម្លើយ និងបង់ស្អិត |
| ៥នាទី | **<u>សកម្មភាពទី៣ :</u> និយមន័យ និងសារៈសំខាន់នៃការពិគ្រោះយោបល់នៅមូលដ្ឋាន**<br>**បំផុសគំនិត និងបង្ហាញក្រុមធំ**<br>- អ្នកសម្របសម្រួល សួរអ្នកចូលរួម ៣នាក់ ទី១ តើអ្វីទៅជាការពិគ្រោះយោបល់នៅមូលដ្ឋាន? ទី២ តើការពិគ្រោះយោបល់នៅមូលដ្ឋានមានសារៈសំខាន់អ្វីខ្លះ?<br>- កត់ត្រាចម្លើយអ្នកចូលរួម នៅលើក្រដាសផ្ទាំងធំ រួចបិទលើជញ្ជាំង<br>- បង្ហាញស្លាយទី៣-៥ ដោយសួរសំណួរលើចំណុចមួយចំនួន | 💻 ស្លាយទី៣ - ៥<br>🗐 ក្រដាសផ្ទាំងធំ<br>✎ ហ្វឺតកត់ត្រាចម្លើយ និងបង់ស្អិត |
| ៥នាទី | **<u>សកម្មភាពទី៤</u> : ដំណើរការនៃការពិគ្រោះយោបល់នៅមូលដ្ឋាន**<br>**បំផុសគំនិត និងបង្ហាញក្រុមធំ**<br>- អ្នកសម្របសម្រួល សួរទៅកាន់អ្នកចូលរួមចំនួន៣នាក់ តើដំណើរការនៃការពិគ្រោះយោបល់មានប៉ុន្មានដំណាក់កាល? តើមានអ្វីខ្លះ?<br>- កត់ត្រាចម្លើយលើក្រដាស | ស្លាយទី៦<br>🗐 ក្រដាសផ្ទាំងធំ<br>✎ ហ្វឺតកត់ត្រាចម្លើយ និងបង់ស្អិត |

| | | |
|---|---|---|
| | - បង្ហាញស្លាយទី៦ ដោយមានការសួរបញ្ជាក់ពីអ្នកចូលរួម ។ | |
| ៨ នាទី | <u>សកម្មភាពទី៥</u> : **ដំណាក់កាលទី១ :ការរៀបចំ និងផ្សព្វផ្សាយផែនការ ពិគ្រោះយោបល់**<br>**សំណួរបំផុស និងពិភាក្សាក្រុមធំ :**<br>- អ្នកសម្របសម្រួល សួរទៅកាន់អ្នកចូលរួមចំនួន ៣នាក់ សំណួរ៖<br>**១. តើក្រុមប្រឹក្សាប្រើប្រាស់វិធីសាស្ត្រអ្វី ក្នុងការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ? ហេតុអ្វី?** ឧទាហរណ៍៖ ការប្រជុំក្រុមធំ ឬក្រុមតូច ឬដើរតាមផ្ទះ ។ល។ មានលក្ខណៈសាមញ្ញ ស្និទ្ធស្នាល ដើម្បីកាត់បន្ថយការភ័យខ្លាច ។<br>**២. តើអ្នកណាខ្លះ ជាក្រុមអាទិភាព ដែលក្រុមប្រឹក្សាត្រូវជួប? ហេតុអ្វី?** ឧទាហរណ៍ “ជួបជាមួយស្ត្រី យុវជនបោះបង់ការសិក្សា ជនជាតិដើមភាគតិច ក្រុមផ្ទុកមេរោគអេដស៍ ។ល។” ស្វែងយល់ពីការលំបាក បញ្ហា តម្រូវការ និងយោបល់ត្រឡប់ ដើម្បីបង្កើនគុណភាពផ្តល់សេវា ។<br>**៣. តើគួរជ្រើសរើសទីកន្លែងណាដើម្បីងាយ ធ្វើការពិគ្រោះយោបល់?** ឧទាហរណ៍៖ ជួបនៅផ្ទះ ឬប្រមូលគ្នាជួបកន្លែងណាមួយជាក្រុមតូចៗ (សមាសភាព៨ ឬ១០នាក់ ឬអាចច្រើនជាងនេះ អាស្រ័យលើទម្រង់នៃការប្រជុំ ឬពិភាក្សា) ។<br>**៤. តើក្រុមពិភាក្សាគួរជ្រើសរើសពេលណា?** (ពេលណាដែលប្រជាពលរដ្ឋទំនេរពីការងារ ឬរកស៊ី ។<br>- កត់ត្រាចម្លើយអ្នកចូលរួមលើក្រដាសផ្ទាំងធំ<br>- បង្ហាញពីដំណើរការអនុវត្តដំណាក់កាលទី១ ស្លាយទី៧ ដោយមានការចូលរួមសួរបញ្ជាក់ពីអ្នកចូលរួម | ស្លាយទី៧<br>🗐 ក្រដាសផ្ទាំងធំ<br>🖉 ហ្វឺតកត់ត្រាចម្លើយ និងបង់ស្អិត |
| ៧ នាទី | <u>សកម្មភាពទី៦</u> : **ដំណាក់កាលទី២: អនុវត្តសកម្មភាពពិគ្រោះយោបល់ (កំឡុងពេល)**<br>**ពិភាក្សាក្រុមធំ**<br>• អនុញ្ញាតិឱ្យអ្នកចូលរួមចំនួន ៣នាក់ឆ្លើយសំណួរ៖ | ស្លាយទី៨<br>🗐 ក្រដាសផ្ទាំងធំ<br>🖉 ហ្វឺតកត់ត្រាចម្លើយ និងបង់ស្អិត |

| | | |
|---|---|---|
| | **១) ហេតុអ្វីក្រុមប្រឹក្សាត្រូវចុះពិគ្រោះយោបល់? តើចង់បានអ្វីពីការពិគ្រោះយោបល់?** ឧទាហរណ៍៖ ចង់ដឹងពីការលំបាក បញ្ហា ក្តីកង្វល់ តម្រូវការជាអាទិភាព និងយោបល់ត្រឡប់ ដើម្បីយកទៅពិភាក្សាក្នុងអង្គប្រជុំក្រុមប្រឹក្សារកដំណោះស្រាយ និងបន្សុីលទ្ធផលទៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់។<br>**២) តើក្រុមប្រឹក្សាគួរផ្តល់ព័ត៌មានអ្វីខ្លះទៅប្រជាពលរដ្ឋក្នុងពេលពិគ្រោះយោបល់?** ឧទាហរណ៍៖ អំពីចំណូលចំណាយ សេចក្តីសម្រេចចិត្ត ស្តីពីការអភិវឌ្ឍនានាក្នុងមូលដ្ឋាន ដំណោះស្រាយនានា និងប្រមូលយោបល់ត្រឡប់។<br>• កត់ត្រាចម្លើយអ្នកចូលរួមលើក្រដាសផ្ទាំងធំ<br>• បង្ហាញពីដំណើរការអនុវត្តដំណាក់កាលទី២ ស្លាយទី៨ ដោយមានការចូលរួមសួរបញ្ជាក់ពីអ្នកចូលរួម ។ | |
| ២០នាទី | <u>*សកម្មភាពទី៧*</u> : **ដំណាក់កាលទី៣ ការបន្សុីលទ្ធផលពិគ្រោះយោបល់ទៅក្នុងកម្មវិធី វិនិយោគឃុំ សង្កាត់ (ក្រោយពេល)**<br>**ពិភាក្សាក្រុមតូច**<br>- ចែកអ្នកចូលរួមជា ៣ក្រុមតូច (ពេល១០នាទី) ដោយក្រុមនីមួយៗឆ្លើយសំណួរដូចខាងក្រោម៖<br>- អ្នកសម្របសម្រួលប្រាប់ថា លទ្ធផលដែលប្រមូលបានពីការពិគ្រោះយោបល់នឹងយកទៅបន្សុីក្នុងកម្មវិធីវិនិយោគ<br>**១. តើក្រុមប្រឹក្សាគួរបន្សុីលទ្ធផលពិគ្រោះយោបល់ទៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់យ៉ាងដូចម្តេច? តើនៅពេលណា?**<br>*ប្រើតារាង១.១ ដើម្បីឱ្យដឹងថាបញ្ហាដែលប្រមូលបាន យកទៅដាក់នៅកន្លែងណានៃតារាង ១.១*<br>- បិទចម្លើយលើក្រដាសផ្ទាំងធំ លើជញ្ជាំងម្ខាងសម្រាប់ផ្ទៀងផ្ទាត់ និងយកទៅរៀបចំផែនការនៅពេលបញ្ចប់មេរៀនថ្ងៃទី៣។<br>- តំណាងក្រុមឡើងបង្ហាញ (៣នាទី/មួយក្រុម)<br>- អ្នកសម្របសម្រួលធ្វើការបូកសរុប និងបង្ហាញស្លាយ៩-១២ | ស្លាយទី៩-១២<br>🗐 ក្រដាសផ្ទាំងធំ<br>🖉 ហ្វឺតកត់ត្រាចម្លើយ និងបង់ស្អិត |

| | | |
|---|---|---|
| ៥ នាទី | **សកម្មភាពទី៨ : បូកសរុបមេរៀន**<br>អ្នកសម្របសម្រួលធ្វើការសង្ខេបមេរៀន ដោយការបញ្ជាក់ឡើងវិញពីការយល់ដឹង និងការរំពឹងទុករបស់អ្នកចូលរួម ដែលបានកត់ត្រាលើក្រដាសផ្ទាំងធំជាការស្រេច។ | 🗐 ក្រដាសផ្ទាំងធំ ដែលកត់ត្រាចម្លើយរបស់អ្នកចូលរួម |

# ថ្ងៃទី២

# មេរៀនទី២:

# ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការពិគ្រោះយោបល់នៅមូលដ្ឋាន

សហការការិយាល័យសម្របសម្រួលគម្រោង DFGG ក្រសួងមហាផ្ទៃ អង្គការផេកកម្ពុជា

# គោលបំណង និងការរំពឹងទុកនៃមេរៀន

១. បកស្រាយបាននូវអត្ថន័យ និង សារៈសំខាន់ការពិគ្រោះយោបល់

២. រៀបរាប់ពីដំណើរការរៀបចំ និង អនុវត្តការពិគ្រោះយោបល់

៣. កំណត់ពីរបៀប និងពេលវេលា បន្ស៊ីលទ្ធផលនៃការពិគ្រោះយោបល់ទៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់

**គោលបំណង**

**ការរំពឹងទុក?**

✓ អាចពន្យល់បាននូវអត្ថន័យ

✓ ពិពណ៌នាបានពីសារៈសំខាន់

✓ អាចរៀបរាប់បានពីដំណើររៀបចំ និងអនុវត្តនៃការពិគ្រោះយោបល់

✓ កំណត់ពីរបៀប និងពេលវេលា បន្ស៊ីលទ្ធផលទៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ ។

# តើការពិគ្រោះយោបល់នៅមូលដ្ឋានជាអ្វី?

ការពិគ្រោះយោបល់នៅមូលដ្ឋាន គឺជាដំណើរការនៃទំនាក់ទំនងជាប្រចាំរវាងក្រុមប្រឹក្សាជាមួយប្រជាពលរដ្ឋ ដើម្បីទទួលបានព័ត៌មាន និងគំនិតយោបល់ទៅវិញទៅមក។



# សារៈសំខាន់នៃការពិគ្រោះយោបល់នៅមូលដ្ឋាន

បង្កើនទំនុកចិត្ត ភាពជឿជាក់ និង
ទំនាក់ទំនងល្អ

ប្រមូលបញ្ហា តម្រូវការ និងកំណត់អាទិភាព
លើកឡើងដោយប្រជាពលរដ្ឋ

ប្រជាពលរដ្ឋដឹងអំពីសេចក្តីសម្រេចចិត្ត
ចំណូល និងចំណាយរបស់ឃុំ សង្កាត់

ប្រជាពលរដ្ឋចូលរួមក្នុងសកម្មភាព
អភិវឌ្ឍឃុំ សង្កាត់

លើកកម្ពស់អភិបាលកិច្ចល្អ និង
ប្រសិទ្ធភាពសេវាសង្គម

បន្សុីលទ្ធផលនៃការពិគ្រោះយោបល់ទៅ
ក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់

# សារៈសំខាន់នៃការពិគ្រោះយោបល់ (ត)



ក្រុមប្រឹក្សាឃុំ សង្កាត់ យល់កាន់តែច្បាស់ពីបញ្ហា និងតម្រូវការជាអាទិភាពរបស់សហគមន៍

ប្រជាពលរដ្ឋ បានទទួលពតិមានស្ដីពី ចំណូល ចំណាយ ថវិកាឃុំ សង្កាត់សេចក្ដីសម្រេចចិត្ត និងកិច្ចការផ្សេងៗ

លទ្ធផលដែលទទួលបានពីការពិគ្រោះយោបល់ នឹងពង្រឹងប្រសិទ្ធភាព នៃការរៀបចំផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគឃុំ សង្កាត់។

ប្រជាពលរដ្ឋប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការផ្ដល់ និងទទួលព័តិមាន។

# ៥. ដំណើរនៃការពិគ្រោះយោបល់នៅមូលដ្ឋាន

ដំណាក់កាលទី១
រៀបចំ និងផ្សព្វផ្សាយផែនការពិគ្រោះយោបល់

ដំណាក់កាលទី២
អនុវត្តសកម្មភាពពិគ្រោះយោបល់



ដំណាក់កាលទី៣
បញ្ចូលលទ្ធផលពិគ្រោះយោបល់ទៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់



# ដំណាក់កាលទី១
# រៀបចំ និងផ្សព្វផ្សាយផែនការការពិគ្រោះយោបល់

លក្ខណៈប្រជុំ ៖
- ✓ក្រុមធំ
- ✓ក្រុមតូច
- ✓ដើរតាមផ្ទះ

តើពេលណា?

ទីកន្លែង និង

ពេលវេលា

គួរជួបអ្នកណា
- ✓ស្ត្រីនៅផ្ទះ
- ✓យុវជនបោះបង់សាលា
- ✓ជនជាតិដើមភាគតិច
- ✓អ្នកផ្ទុកមេរោគអេដស៍
- ✓ជនពិការ
- ✓ចាស់ជរា

មធ្យោបាយ ៖
- ✓ ក្តារព័ត៌មានតាម ភូមិ និងឃុំ សង្កាត់
- ✓ មេភូមិ
- ✓ ស៊ីអឹមស៊ី
- ✓ ពិធីបុណ្យផ្សេងៗ

**ដំណាក់កាលទី២ អនុវត្តសកម្មភាពពិគ្រោះយោបល់**

១) ស្វែងយល់ និងចង់ដឹងពីបញ្ហា ក្ដីកង្វល់ តម្រូវការអាទិភាព និងយោបល់ត្រឡប់

២) ព័ត៌មានដែលត្រូវផ្ដល់
ចំណូល ចំណាយ សេចក្ដីសម្រេចចិត្តស្ដីពីការអភិវឌ្ឍនានាក្នុងមូលដ្ឋាន ដំណោះស្រាយនានា និងប្រមូលយោបល់ត្រឡប់ ។

៣) ប្រមូលបញ្ហា ក្ដីកង្វល់ តម្រូវការជាអាទិភាព និងយោបល់ត្រឡប់ បូកសរុបលទ្ធផលប្រមូលបានដាក់ក្នុងអង្គប្រជុំ និងបញ្ជីទៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់

# ដំណាក់កាលទី៣ ការបន្ស៊ីលទ្ធផលនៃការពិគ្រោះយោបល់នៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់



# តារាង ១.១ បញ្ហា តម្រូវការ និងដំណោះស្រាយ

| បញ្ហា | ទីតាំងនៃបញ្ហា | មូលហេតុនៃបញ្ហា | តម្រូវការ | ឧបសគ្គ | ដំណោះស្រាយ | យោបល់របស់ជនជាតិដើមភាគតិច |
|---|---|---|---|---|---|---|
| នៅក្នុងភូមិមានបញ្ហាលួសះ លិចផ្ទះប្រជាពលរដ្ឋ | | | | | | |
| យុវជនឈប់រៀនដោយសារជីវភាព | | | | | | |
| មានអំពើហឹង្សាដោយសារក្មេងទំនើង | | | | | | |

# ការពិគ្រោះយោបល់មូលដ្ឋានមានប្រសិទ្ធភាពត្រូវ៖

**គោរពដោយពេញលេញ** គំនិតយោបល់ប្រជាពលរដ្ឋដោយមិនប្រកាន់ឋានៈ ។

**ឱកាសស្មើគ្នា** ក្នុងការចូលរួមបញ្ចេញមតិយោបល់

**លើកទឹកចិត្តអោយមានការចូលរួម**បញ្ចេញមតិយោបល់ បញ្ហា និងតម្រូវការជាអាទិភាព ។

**ផ្តល់ព័ត៌មានត្រឹមត្រូវ** អំពីស្ថានភាពទូទៅនៃការអភិវឌ្ឍឃុំ សង្កាត់ចំណូលចំណាយថវិកា និងសេចក្តីសម្រេចចិត្ត ។

# ☝ **កំណត់ចំណាំ**

ការពិគ្រោះយោបល់នៅមូលដ្ឋានត្រូវមានការចូលរួមពីៈ

- ✓ ប្រជាពលរដ្ឋទាំងពីរភេទ ដោយមិនប្រកាន់និន្នាការនយោបាយ ឋានៈសង្គម
- ✓ ក្រុមមិនសូវមានតំណាងដូចជាៈ ចាស់ជារា និង កុមារកំព្រាគ្មានទីពឹង ស្ត្រីងាយរងគ្រោះ ក្រុមយុវជន អ្នកធ្វើចំណាកស្រុក អ្នកផ្ទុកមេរោគអេដស៍ អ្នកសេពគ្រឿងញៀន និង ជនជាតិដើមភាគតិច។
- ✓ គណៈកម្មការកៀរគរសហគមន៏
- ✓ អង្គការសហគមន៏មូលដ្ឋាន



# ថ្ងៃទី២
# មេរៀនទី ២
# ឯកសារចែក

### មេរៀនទី២: ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការពិគ្រោះយោបល់នៅមូលដ្ឋាន

## ១. សេចក្តីផ្តើម:

ការពិគ្រោះយោបល់នៅមូលដ្ឋាន គឺជាយន្តការដ៏មានសារៈសំខាន់មួយសម្រាប់ផ្តល់ឱកាសឱ្យប្រជាពលរដ្ឋនៅតាមមូលដ្ឋានបានចូលរួមបញ្ចេញមតិយោបល់ ក្តីព្រួយបារម្ភ និងតម្រូវការជាក់លាក់របស់ខ្លួនដល់ក្រុមប្រឹក្សាឃុំសង្កាត់ និងផ្តល់ព័ត៌មានត្រឡប់ពីក្រុមប្រឹក្សាជូនដល់ប្រជាពលរដ្ឋវិញ។ តាមរយៈការពិគ្រោះយោបល់នៅមូលដ្ឋាន បានរួមចំណែកធ្វើឱ្យមានទំនាក់ទំនងល្អរវាងក្រុមប្រឹក្សា និងប្រជាពលរដ្ឋ (រួមទាំងក្រុមមិនសូវមានតំណាង) កាន់តែមានភាពជិតស្និទ្ធ ដោយមានឱកាសបានជួបពិភាក្សាជាមួយគ្នាពីបញ្ហា តម្រូវការជាក់លាក់ និងជួយដល់ក្រុមប្រឹក្សាក្នុងការរៀបចំផែនការប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។

ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈក៏បានកំណត់ពីធាតុដ៏សំខាន់ខាងលើនេះដែរ។

## ២. គោលបំណង និងលទ្ធផលរំពឹងទុកនៃមេរៀន

- **គោលបំណងនៃមេរៀន** : រៀបចំឡើង ក្នុងគោលបំណងឱ្យអ្នកចូលរួមអាចៈ
  ១. បកស្រាយបាននូវអត្ថន័យ និងសារៈសំខាន់នៃការពិគ្រោះយោបល់នៅមូលដ្ឋាន
  ២. រៀបរាប់ពីដំណើរការរៀបចំ និងអនុវត្តដំណើរការពិគ្រោះយោបល់នៅមូលដ្ឋាន
  ៣. កំណត់ពីរបៀប និងពេលវេលាបន្សុីលទ្ធផលនៃការពិគ្រោះយោបល់ ទៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់

**លទ្ធផលរំពឹងទុកនៃមេរៀន**

- អ្នកចូលរួមនឹងអាចបកស្រាយបាននូវអត្ថន័យ និងសារៈសំខាន់ ហើយអាចរៀបរាប់បានពីដំណើរការរៀបចំ និងអនុវត្តនៃការពិគ្រោះយោបល់នៅមូលដ្ឋាន
- អ្នកចូលរួមកំណត់ពីរបៀប និងពេលវេលា បន្សុីលទ្ធផលការពិគ្រោះយោបល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ទៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ ។

## ៣. និយមន័យ និងសារៈសំខាន់នៃការពិគ្រោះយោបល់នៅមូលដ្ឋាន?

ការពិគ្រោះយោបល់នៅមូលដ្ឋាន គឺជាដំណើរការនៃទំនាក់ទំនងជាប្រចាំរវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមប្រឹក្សាស្រុក ជាមួយប្រជាពលរដ្ឋ ដើម្បីទទួលបានព័ត៌មាន និងគំនិតយោបល់ទៅវិញទៅមក។

### សារសំខាន់នៃការពិគ្រោះយោបល់នៅមូល ដ្ឋាន?

ការពិគ្រោះយោបល់នៅមូលដ្ឋាន បានផ្តល់នូវអត្ថប្រយោជន៍ជាវិជ្ជមានដល់ក្រុមប្រឹក្សាឃុំ សង្កាត់ សហគមន៍ និងប្រជាពលរដ្ឋដូចជា៖




- ប្រជាពលរដ្ឋមានឱកាសជួបក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានកាតព្វកិច្ចបំរើផលប្រយោជន៍របស់ខ្លួនដោយផ្ទាល់ និងលើកឡើងជាបញ្ហា និងតំរូវការជាអទិភាព។ បង្កើនទំនុកចិត្ត និងភាពជឿជាក់រវាងប្រជាពលរដ្ឋ និង ក្រុមប្រឹក្សាឃុំ សង្កាត់
- បង្កើនការចូលរួម របស់ប្រជាពលរដ្ឋ ក្នុងដំណើរការអភិវឌ្ឍន៍មូលដ្ឋានជាមួយ ក្រុមប្រឹក្សាឃុំ សង្កាត់

- ក្រុមប្រឹក្សាឃុំ សង្កាត់ យល់កាន់តែច្បាស់ពីបញ្ហា និងតំរូវការជាអទិភាពរបស់សហគមន៍ ជាពិសេសក្រុមមិនសូវមានតំណាងដូចជា៖ ស្ត្រីមេម៉ាយរងគ្រោះ យុវជនសេពគ្រឿងញៀន អ្នកផ្ទុកមេរោគអេដស៍ចាស់ជរា ជនពិការ ក្មេងកំព្រាគ្មានទីពឹង បងប្អូនខ្មែរឥស្លាម និងជនជាតិដើមភាគតិចជាដើម។
- ប្រជាពលរដ្ឋ បានទទួលពត៌មានអំពីការងនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់រួមមាន៖ចំនូលចំនាយថវិកាឃុំ ការសម្រេចចិត្ត និងកិច្ចការផ្សេងៗទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់បានអនុវត្ត បញ្ហាប្រឈមនានាពត៌មានពីថ្នាក់ជាតិ និងសុខុមាលភាពប្រជាពលរដ្ឋ (ច្បាប់ ចរាចរណ៍ណែនាំ សេចក្តីសំរេចជាដើម)។
- ក្រុមប្រឹក្សាឃុំ សង្កាត់ ប្រើប្រាស់ លទ្ធផលដែលទទួលបានពីលទ្ធផលនៃការពិគ្រោះយោបល់ ដើម្បីពង្រឹងប្រសិទ្ធភាព គុណភាព នៃការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់។
- ប្រជាពលរដ្ឋបានប្រើប្រាស់សិទ្ធរបស់ខ្លួន ក្នុងការផ្តល់ព័ត៌មាន និងតាមដានការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

## ៤. ដំណើរការនៃការពិគ្រោះយោបល់នៅមូល ដ្ឋាន

ដំណើរការពិគ្រោះយោបល់នៅមូលដ្ឋាន មានបីដំណាក់កាលគឺ៖




☞ **ដំណាក់កាលទី១ : រៀបចំ និងផ្សព្វផ្សាយផែនការពិគ្រោះយោបល់**

- ក្រុមប្រឹក្សាឃុំ សង្កាត់ រៀបចំ ការប្រជុំ ជាមួយអ្នកពាក់ព័ន្ធ នានាសម្រាប់ការពិគ្រោះយោបល់។
- នៅក្នុងការរៀបចំផែនការពិគ្រោះយោបល់ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវកំណត់៖
  - ក) សកម្មភាពសម្រាប់ការប្រជុំជាលក្ខណៈក្រុមធំតាមភូមិនីមួយៗ។
  - ខ) សកម្មភាពសម្រាប់ការប្រជុំតាមភូមិក្រុមតូចៗដូចជា៖ ក្រុមយុវជនគ្មានការងារធ្វើ (ជាញឹកញាប់តែងតែធ្វើចំណាកស្រុក) ក្រុមអ្នកនេសាទ ក្រុមអ្នកប្រើប្រាស់គ្រឿងញៀន ។

គ) សកម្មភាពសម្រាប់ការចុះជួបសំណេះសំណាលតាមផ្ទះជាមួយចាស់ជរា និង កុមារកំព្រាគ្មានទីពឹងអ្នកផ្ទុកមេរោគអេដស៍ ជនពិការ អ្នកប្រើប្រាស់គ្រឿងញៀន ស្ត្រីងាយរងគ្រោះ និង អ្នកប្រព្រឹត្តអំពើហឹង្សាក្នុងគ្រួសារជាដើម។

ឃ) បែងចែកអ្នកទទួលខុសត្រូវ

ង) កំណត់ទីកន្លែង និង ពេលវេលា សម្រាប់ការជួបប្រជុំ

- បិទផ្សាយព័ត៌មានស្ដីពីការពិគ្រោះយោបល់លើក្តារពត៌មាន នៅតាមឃុំ ភូមិ
- សហការជាមួយមេភូមិ គណៈកម្មការកៀរគរសហគមន៍ សហគមន៍មូលដ្ឋាន ក្នុងផ្សព្វផ្សាយព័ត៌មានផ្សេងៗ និងអំពីការពិគ្រោះយោបល់ នៅតាមផ្ទះតាមរយៈបុណ្យផ្សេងៗ

**រូបភាពសង្ខេបបង្ហាញអំពីដំណាក់កាលទី១**




**<u>កំណត់ចំណាំ</u>:** ការជួបប្រជុំជាមួយប្រជាពលរដ្ឋ នៅក្នុងតំបន់របស់ខ្លួនក្រុមប្រឹក្សាអាចប្រើប្រាស់វិធីសាស្ត្រពះខាងក្រោមគឺជា ការរៀបរាប់លំអិតអំពីលក្ខណៈប្រជុំជាលក្ខណ:៖

១) **ការប្រជុំក្រុមធំ** : គឺជាកការប្រជុំ ដែលមានការចូលរួមពីប្រជាពលរដ្ឋទូទៅក្នុងភូមិច្រើននាក់ ដែលអញ្ជើញដោយក្រុមប្រឹក្សាឃុំ សង្កាត់។

២) **ការប្រជុំក្រុមតូច** : គឺជាការប្រជុំ ដែលក្រុមប្រឹក្សាឃុំ សង្កាត់ រៀបចំតាមក្រុមគោលដៅជាក់លាក់ ដូចជា៖ ក្រុមងាយរងគ្រោះ ក្រុមយុវជន និងគ្រួសារដែលធ្វើចំណាកស្រុក ។ល។

៣) **ការចុះពិគ្រោះយោបល់តាមផ្ទះ** :គឺជាការប្រជុំមានលក្ខណៈសាមញ្ញជាងគេ ដើម្បីបង្កើនភាពជិតស្និទ្ធផងនិងជម្រាបជូនដំណឹងដល់ប្រជាពលរដ្ឋពីចំណូលចំណាយ ការសម្រេចចិត្តនិង សកម្មភាពអភិវឌ្ឍន៍ឃុំ សង្កាត់។ ការពិគ្រោះយោបល់តាមផ្ទះនេះ មានផលប្រយោជន៍យ៉ាងខ្លាំង ណាស់សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ និង

ក្រុមប្រឹក្សាស្រុក ព្រោះការធ្វើបែបអាចកាត់បន្ថយគម្លាតនៃការភ័យខ្លាច ហើយបង្កើនភាពស្និទ្ធស្នាល និងអាចចែករំលែកនូវកង្វល់ ឬបញ្ហានានាប្រៀបបាននឹងក្រុមគ្រួសារតែមួយ ។

☞ **ដំណាក់កាលទី២ : អនុវត្តសកម្មភាពពិគ្រោះយោបល់**

ការអនុវត្តសកម្មភាពពិគ្រោះយោបល់ គឺជាការប្រជុំពិនិត្យដើម្បីប្រមូល បញ្ហា ក្តីកង្វល់ តម្រូវការជាអាទិភាពហើយក្រុមប្រឹក្សាអាចដំណោះស្រាយភ្លាមៗ នូវអ្វីដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន ។ បន្ទាប់ពីប្រមូលបញ្ហា និងតម្រូវការអទិភាពនានាតាមរយៈការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើការប្រជុំដើម្បីពិនិត្យបញ្ហា តម្រូវការទាំងអស់នោះ និងស្វែងរកដំណោះស្រាយ ដោយមានការចូលរួមពីប្រធានភូមិ គណៈកម្មការកៀរគរសហគមន៍ អង្គការសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធដទៃទៀត ។ ក្នុងពេលប្រជុំនេះក្រុមប្រឹក្សាត្រូវយកចិត្តទុកដាក់ពិចារណាទៅលើបញ្ហាអទិភាពទាំងអស់ ដែលប្រមូលបាន បន្ទាប់មកត្រូវកំណត់ថា បញ្ហានីមួយៗត្រូវដោះស្រាយទៅតាមអាទិភាពនៃបញ្ហា ឬត្រូវយកទៅបន្សុីជាមួយនឹងកម្មវិធីវិនិយោគឃុំ សង្កាត់ប្រចាំឆ្នាំរបស់ខ្លួន ។

**រូបភាពសង្ខេបបង្ហាញអំពីដំណាក់កាលទី២**

**ដំណាក់កាលទី២ អនុវត្តសកម្មភាពពិគ្រោះយោបល់**

១) ស្វែងយល់ និងចង់ដឹងពីបញ្ហា ក្តីកង្វល់ តម្រូវការអាទិភាព និងយោបល់ត្រឡប់

២) ព័ត៌មានដែលត្រូវផ្តល់
ចំណូល ចំណាយ សេចក្តីសម្រេចចិត្តស្តីពីការអភិវឌ្ឍនានាក្នុងមូលដ្ឋាន
ដំណោះស្រាយនានា និងប្រមូលយោបល់ត្រឡប់ ។

៣) ប្រមូលបញ្ហា ក្តីកង្វល់ តម្រូវការជាអាទិភាព និងយោបល់ត្រឡប់
បូកសរុបលទ្ធផលប្រមូលបានដាក់ក្នុងអង្គប្រជុំ និងបន្សុីទៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់

☝ **ដំណាក់កាលទី៣ : ការបន្សុីលទ្ធផលនៃការពិគ្រោះយោបល់ទៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ និងក្រុមប្រឹក្សាស្រុក**

គឺជាដំណាក់កាលចុងក្រោយ ដែលក្រុមប្រឹក្សាត្រូវធ្វើសកម្មភាពដោយយកលទ្ធផលដែលប្រមូលបានក្នុងការជួបប្រជុំ និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋបញ្ចូលទៅក្នុងរបៀបវារៈនៃប្រជុំនានា និងបន្សុីលទ្ធផលនោះទៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ ឬក្រុមប្រឹក្សាស្រុកប្រចាំឆ្នាំ ។

**រូបភាពសង្ខេបបង្ហាញអំពីដំណាក់កាលទី៣**




ឧទាហរណ៍ :

- ក្នុងជំហានទី១ នៃដំណើរការរៀបចំកម្មវិធីវិនិយោគឃុំ សង្កាត់ប្រចាំឆ្នាំ គណៈកម្មាធិការកសាងផែនការ និងថវិកា (គ.ផ.ថ) ត្រូវធ្វើការប្រជុំនៅតាមភូមិ ដើម្បីធ្វើការឆ្លុះបញ្ចាំងបញ្ហា តម្រូវការ និងដំណោះស្រាយដែលបានលើកឡើងជាមួយនឹងប្រជាពលរដ្ឋដោយប្រើប្រាស់នូវតារាង ដែលក្រុមប្រឹក្សាឃុំ សង្កាត់រៀបចំ។
- ដើម្បីឱ្យបញ្ហា តម្រូវការ និងដំណោះស្រាយដែលបានលើកឡើងកាន់តែមានភាពពិតប្រាកដ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវយកលទ្ធផលដែលដាក់/រៀបចំក្នុងតារាងនៃការពិគ្រោះយោបល់មកធ្វើការផ្ទៀងផ្ទាត់ជាមួយតារាង នៃកម្មវិធីវិនិយោគឃុំ សង្កាត់។ ក្នុងការផ្ទៀងផ្ទាត់នេះ ក្រុមប្រឹក្សាឃុំ សង្កាត់បានពិនិត្យ និងដាក់បញ្ចូលបន្ថែមនូវបញ្ហា ឬតម្រូវការដែលខ្វះចន្លោះ

**គម្រូតារាង១.១**

| បញ្ហា | ទីតាំងនៃបញ្ហា | មូលហេតុនៃបញ្ហា | តម្រូវការ | ឧបសគ្គ | ដំណោះស្រាយ | យោបល់របស់ជនជាតិដើមភាគតិច |
|---|---|---|---|---|---|---|
| នៅក្នុងភូមិមានបញ្ហាលូស្ទះ លិចផ្ទះប្រជាពលរដ្ឋ | | | | | | |
| យុវជនឈប់រៀន ដោយសារជីវភាព | | | | | | |
| មានអំពើហិង្សា ដោយសារក្មេងទំនើង | | | | | | |

**កំណត់ចំណាំ :**

១) ការពិគ្រោះយោបល់មូលដ្ឋាន ដែលមានប្រសិទ្ធភាពត្រូវប្រកាន់នូវគោលគំនិតសំខាន់ៗមួយចំនួន៖



២) ការពិគ្រោះយោបល់នៅមូលដ្ឋានត្រូវមានការចូលរួមពីៈ

- ប្រជាពលរដ្ឋទាំងពីរភេទ ដោយមិនប្រកាន់និន្នាការនយោបាយ ឋានៈសង្គម
- ក្រុមមិនសូវមានតំណាងដូចជាៈ ចាស់ជរា និង កុមារកំព្រាគ្មានទីពឹង ស្ត្រីងាយរងគ្រោះ ក្រុមយុវជនអ្នកធ្វើចំណាកស្រុក អ្នកផ្ទុកមេរោគអេដស៍ អ្នកសេពគ្រឿងញៀន និង ជនជាតិដើមភាគតិច។
- គណៈកម្មការគៀងគរសហគមន៍
- អង្គការសគមន៍មូលដ្ឋាន

## ៧. សេចក្តីសន្និដ្ឋាន

ជារួមការពិគ្រោះយោបល់នៅមូលដ្ឋានត្រូវបានគេមើលឃើញថាជាមធ្យោបាយដ៏សំខាន់មួយ ដើម្បីផ្តល់ឱកាសដល់ប្រជាពលរដ្ឋ និងក្រុមមិនសូវមានតំណាងឱ្យពួកគេបានទទួលព័ត៌មាន លើកទឹកចិត្តដល់ភាពជាដៃគូ និងធ្វើឱ្យប្រសើរឡើងនូវតម្លាភាព និងគណនេយ្យភាព។

**“ដើម្បីនិរន្តភាព និងជោគជ័យក្នុងការងារក្រុមប្រឹក្សាគួររៀបចំឱ្យមានការជួបពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋរបស់ខ្លួនឱ្យបានញឹកញាប់”**

**--- ចប់ ---**



# ថ្ងៃទី២

# ប្លង់មេរៀនទី៣

## ចំណងជើងមេរៀនៈ ការចូលរួមរបស់ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល ក្នុងដំណើរការកសាងផែនការ និងថវិកា

**ពេលវេលាៈ ០១:៤០ ដល់ ០៣:០០ (១:២០ម៉ោង)**

**គោលបំណងនៃមេរៀនៈ** នៅចុងបញ្ចប់មេរៀននេះអ្នកចូលរួមនឹងអាចៈ

១. ពន្យល់បានពីដំណើរការកសាងផែនការ និងថវិការបស់ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់

២. ពន្យល់បានពីមូលហេតុ និងសារៈសំខាន់នៃការចូលរួមរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលក្នុងដំណើរការកសាងផែនការ និងថវិការបស់ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់

៣. កំណត់បានពីប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលជាជនបង្គោលដើម្បីចូលរួមក្នុងដំណើរការកសាងផែនការរបស់ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់។

## កំណត់ចំណាំរបស់អ្នកសម្របសម្រួល

១. នៅក្នុងមេរៀននេះអ្នកសម្របសម្រួលគួរពន្យល់ដោយសង្ខេបអំពីអ្វីទៅជាដំណើរការកសាងផែនការរបស់ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ និងសង្កាត់ បន្ទាប់មកពន្យល់ពីមូលហេតុ និងសារៈសំខាន់នៃការចូលរួមរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល និងការលើកទឹកចិត្តដល់ប្រជាពលរដ្ឋក្នុងការភ្ជាប់ទំនាក់ក្នុងជំហាននៃការកសាងផែនការ

២. សម្របសម្រួលដល់អ្នកចូលរួមទាំងអស់ដើម្បីឱ្យពួកគាត់កំណត់ឱ្យបានតើប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលណាខ្លះជាជនបង្គោលក្នុងការចូលរួមក្នុងដំណើរការកសាងផែនការ និងថវិការបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។

### លទ្ធផលរំពឹងទុកនៃមេរៀន

ក. អាចពន្យល់បានពីដំណើរការនៃការកសាងផែនការ និងថវិការបស់ក្រុមប្រឹក្សា

ខ. បកស្រាយបានពីសារៈសំខាន់នៃការចូលរួមរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលក្នុងដំណើរការកសាងផែនការ និងថវិការបស់ក្រុមប្រឹក្សា

គ. អាចកំណត់បានប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលជាជនបង្គោលក្នុងការចូលរួមក្នុងដំណើរការកសាងផែនការ និងថវិការបស់ក្រុមប្រឹក្សា

## សម្ភារឧបទេ្ទសសម្រាប់មេរៀនៈ

- ឯកសារចែកជូនៈ
  - បទបង្ហាញអំពីគោលបំណងមេរៀន និងខ្លឹមសារមេរៀន
- ហ្វឺតសរសេរក្រដាស ក្រដាសផ្ទាំងធំ ស្កុត
- កុំព្យូទ័រយួរដៃ និងម៉ាស៊ីនបញ្ចាំងឯកសារ

## ឯកសារយោង

- អនុក្រិត្យលេខ ២១៩ស្តីពីផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៩ និង១២
- សេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ គ.ជ.អ.ប កញ្ញា២០១០

## របៀបសម្របសម្រួលមេរៀន

| ម៉ោង | <u>សកម្មភាព និងវិធីសាស្រ្ត</u> | សម្ភារ និងឯកសារចែកជូន |
|---|---|---|
| ៥នាទី | <u>សកម្មភាពទី១៖ រំឭកមេរៀន</u><br>អ្នកសម្របសម្រួលផ្តើមរំឭកមេរៀនទី២ឡើងវិញបន្តិចស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងសកម្មភាពពិគ្រោះយោបល់នៅមូលដ្ឋាន។<br>▪ | |
| ៥នាទី | សកម្មភាព២៖ <u>គោលបំណងមេរៀន និងទិដ្ឋភាពទូទៅ៖</u><br>អ្នកសម្របសម្រួលបង្ហាញពីគោលបំណងមេរៀន និងធ្វើការបញ្ជាក់ផ្សេងៗទៅលើគោលបំណង បន្ទាប់មកបង្ហាញពីទិដ្ឋភាពទូទៅនៃដំណើរការនៃការរៀបចំផែនការ និងថវិការបស់ក្រុមប្រឹក្សា | ▪ ស្លាយទី១ដល់៤ |
| ១០នាទី | <u>សកម្មភាព៣៖ សារៈសំខាន់នៃការចូលរួមរបស់ប្រជាពលរដ្ឋ:</u><br><u>ការពិភាក្សាក្រុមធំ:</u> អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យអ្នកចូលរួម ២ទៅ៣នាក់ឆ្លើយសំណួរ ដូចខាងក្រោមៈ តើមូលហេតុអ្វីបានជាការចូលរួមរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលមានសារៈសំខាន់?<br>▪ អ្នកសម្របសម្រួលកត់ត្រាចម្លើយលើក្រដាសផ្ទាំងធំបន្ទាប់មកធ្វើការបង្ហាញស្លាយ | ▪ ស្លាយទី៥ដល់ទី៧ |

| | | |
|---|---|---|
| ២០នាទី | <u>សកម្មភាព៤៖ ដំណើរការកសាងផែនការ និងថវិកាក្រុង ស្រុក</u><br><u>ការពិភាក្សាក្រុមធំ</u><br>អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យអ្នកចូលរួមទាំងអស់២ទៅ៣នាក់ឆ្លើយសំណួរ ដូចខាងក្រោម៖<br>ក.តើអ្វីទៅជាដំណើរការកសាងផែនការ និងថវិការបស់ក្រុមប្រឹក្សាក្រុង ស្រុក? ហើយមានជំហានអ្វីខ្លះ?<br>▪ អ្នកសម្របសម្រួលកត់ត្រាចម្លើយទាំងអស់របស់អ្នកចូលរួមទៅក្នុងក្រដាសផ្ទាំងធំ<br>▪ បន្ទាប់មកអ្នកសម្របសម្រួលធ្វើបទបង្ហាញនៅលើស្លាយ | ▪ ស្លាយទី៨ដល់៣២ |
| ២០នាទី | <u>សកម្មភាព៥៖ ដំណើរការកសាងផែនការ និងថវិកាឃុំ សង្កាត់</u><br><u>ការពិភាក្សាក្រុមធំ:</u> អ្នកសម្រសម្រួលសួរសំណួរថាមានលោកលោកស្រីណាធ្លាប់មានបទពិសោធន៍ក្នុងការចូលរួមក្នុងដំណើរការកសាងផែនការ និងថវិកា របស់ឃុំ សង្កាត់ដែរឬទេ?<br>▪ អ្នកសម្រសម្រួលអញ្ជើញអ្នកចូលររួម២ឬ៣នាក់ដើម្បីចែករំលែកបទពិសោធន៍។<br>▪ អ្នកសម្របសម្រួលកត់ត្រាចម្លើយទៅ លើក្រដាសផ្ទាំងធំ<br>▪ អ្នកសម្របសម្រួលធ្វើបទបង្ហាញស្លាយ | ▪ ស្លាយទី៣៣ដល់៤៤ |
| ២០នាទី | <u>សកម្មភាព៦៖ ការកំណត់ជនបង្គោល</u><br>▪ ការពិភាក្សាជាក្រុម៖<br>ចែកក្រុមពិភាក្សា៣ទៅ៤ក្រុមដោយឱ្យអ្នកចូលរួមមកពីឃុំណាចូលទៅតាមឃុំនោះ។<br>▪ អ្នកសម្របសម្រួលពន្យល់ពីរបៀបនៃការបំពេញទម្រង់រួចហើយក្រុមពិភាក្សាមានពេល៥នាទីក្នុងការបំពេញលើទម្រង់ដែលចែកជូននោះ។<br>▪ ព្រមព្រៀងក្នុងការកំណត់ តើប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលណាខ្លះជាជនបង្គោលក្នុងការចូលរួមក្នុងសកម្មភាពរបស់ក្រុមប្រឹក្សាដូចជា:<br>• ដំណើរការកសាងផែនការ និងថវិកាក្រុង ស្រុក ឃុំ សង្កាត់<br>• ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា | ▪ ទម្រង់ទី១ |

| | | |
|---|---|---|
| | • ............................<br>▪ ក្រោយពីក្រុមពិភាក្សាបំពេញរួចអ្នកសម្របសម្រួលសូមឱ្យក្រុមនីមួយៗយកមកបិទលើក្តារ ខៀនរួចហើយស្នើរឱ្យក្រុមទាំងអស់ពិនិត្យមើលធ្វើការប្រៀបធៀបក្រែងក្រុមណាមួយនៅមានខ្វះចន្លោះមិនទាន់បានបំពេញ។<br>▪ អ្នកសម្របសម្រួលអញ្ជើញឱ្យពួកគាត់ត្រលប់ទៅកាន់កន្លែងដើមវិញ ហើយអ្នកសម្របសម្រួលធ្វើការសង្ខេបដោយបញ្ជាក់ថាមេរៀនទី៤លោកអ្នកនឹងបានរៀនសូត្របន្ថែមទៀតដំណើរការនៃការប្រារព្ធវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈនៅមេរៀនបន្ទាប់។ | |
| ១០នាទី | <u>សកម្មភាព៧</u>៖ សំយោគមេរៀនឡើងវិញ<br>សារៈសំខាន់នៃការចូលរួមរបស់ ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល និងជំហាននីមួយៗនៃដំណើរការ កសាងផែនការ និងថវិកា របស់ ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ព្រមទាំង បញ្ជាក់ឡើងវិញពីជនបង្គោលដែលត្រូវចូលរួមក្នុងសកម្មភាពអភិវឌ្ឍ ផ្សេងៗរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។ | |

# ថ្ងៃទី២
# មេរៀនទី៣

## ការចូលរួមរបស់ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល នៅក្នុងដំណើរការកសាងផែនការ និងថវិកា

## នៅថ្នាក់ស្រុក ឃុំ និងសង្កាត់

សហការជាមួយការិយាល័យសម្របសម្រួលគម្រោង DFGGនៃក្រសួងមហាផ្ទៃ និងអង្គការផេកកម្ពុជា

# ១-គោលបំណងមេរៀន

១. អ្នកចូលរួមអាចពន្យល់បានថាតើអ្វីទៅជាដំណើរការកសាងផែនការ និងថវិការបស់ក្រុមប្រឹក្សា។

២. អ្នកចូលរួមអាចពន្យល់បានពីមូលហេតុ និងសារៈសំខាន់នៃការចូលរួមរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលក្នុង ដំណើរការកសាងផែនការ និងថវិការបស់ក្រុមប្រឹក្សា

៣. កំណត់បានពីប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលជាជនបង្គោលដើម្បីចូលរួមក្នុងដំណើរការកសាងផែនការរបស់ក្រុមប្រឹក្សា

# ២-ទិដ្ឋភាពទូទៅនៃការកសាងផែនការ និងថវិកា

- ក្នុងឆ្នាំនីមួយៗនៃអាណត្តិរបស់ខ្លួន ក្រុមប្រឹក្សាត្រូវកសាងផែនការអភិវឌ្ឍដែលមានសុពលភាពរយៈពេលប្រាំឆ្នាំ និងរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល សម្រាប់ថ្នាក់រដ្ឋបាលខ្លួន។ កម្មវិធីវិយោគត្រូវធ្វើបច្ចុប្បន្នភាពរៀងរាល់ឆ្នាំ
| ស្ថិតក្នុងអន្តររដ្ឋបាលដែនដី | គម្រោង ឬសេវាដែលមានលក្ខណៈអន្តរឃុំ សង្កាត់ |

# ជំហានទី១ ៖ ការរៀបចំបញ្ជីគម្រោងអាទិភាពសម្រាប់កម្មវិធីវិនិយោគ

## ១.៣). ការគណនាអត្ថប្រយោជន៍គម្រោង

ដើម្បីគណនាអំពីអត្ថប្រយោជន៍របស់គម្រោង ក្រុមការងារកសាងផែនការត្រូវ៖

- គណនាពិន្ទុមធ្យមថ្នាក់ក្រុង ស្រុក ខណ្ឌ
- កំណត់ពិន្ទុបច្ចេកទេស
- គណនាពិន្ទុអត្ថប្រយោជន៍ និង
- គណនាអត្រាប្រសិទ្ធភាពតម្លៃ

# ជំហានទី១ ៖ ការរៀបចំបញ្ជីគម្រោងអាទិភាពសម្រាប់កម្មវិធីវិនិយោគ

## ១.៤). ការរៀបចំសេចក្តីព្រាងបញ្ជីសំណើគម្រោងរបស់ក្រុង ស្រុក ខណ្ឌ

ដើម្បីរៀបចំបញ្ជីសំណើគម្រោង ក្រុមការងារត្រូវ ៖

- បូកសរុបសំណើគម្រោង
- រៀបចំសេចក្តីព្រាងបញ្ជីសំណើគម្រោង (តារាង ១.៣) ដោយបញ្ចូលនូវ គម្រោងសម្រាប់ឆ្នាំទី១ ព្រមទាំងគម្រោងសម្រាប់ទី២ និងទី៣ផងដែរ ។

# ជំហានទី១ ÷ ការរៀបចំបញ្ជីគម្រោងអាទិភាពសម្រាប់កម្មវិធីវិនិយោគ

## ១.៤). ការរៀបចំសេចក្តីព្រាងបញ្ជីសំណើគម្រោងរបស់ក្រុង ស្រុក ខណ្ឌ

### តារាង១.៣ ៖ សេចក្តីព្រាងបញ្ជីសំណើគម្រោងរបស់ក្រុង ស្រុក ខណ្ឌ

| ល.រ | ឈ្មោះគម្រោង | ចូលរួមសម្រេចគោលបំណង | ទីតាំងគម្រោង | លទ្ធផលគ្រោង | ស្នើដោយ | រយៈពេលអនុវត្ត | អ្នកទទួលផល | | តម្លៃគម្រោង | អត្រាប្រសិទ្ធភាពតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | សរុប | ស្រី | | |
| ១. ផ្នែកសេដ្ឋកិច្ច | | | | | | | | | | |
| ១.១. កសិកម្ម | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | សរុបរង | | | | | | | | | |

សេចក្តីព្រាងបញ្ជីសំណើរ
គម្រោងរបស់ក្រុង ស្រុក

# ដំណាក់កាលទី១ ÷ ការរៀបចំបញ្ជីគម្រោងអាទិភាពសម្រាប់កម្មវិធីវិនិយោគ

## ១.៥. ប្រជុំពិនិត្យសេចក្តីព្រាងបញ្ជីសំណើគម្រោ

- ដើម្បីផ្តល់ឱកាសដល់គ្រប់អ្នកពាក់ព័ន្ធធ្វើការពិ ឯកភាពទៅលើសេចក្តីព្រាងបញ្ជីសំណើគម្រោង

- **សមាសភាពចូលរួម ÷**
  - ក្រុមការងារកសាងផែនការ
  - តំណាងក្រុមប្រឹក្សា
  - តំណាងគណៈអភិបាល
  - តំណាង គ.ស.ប
  - តំណាង គ.ក.ស.ក
  - តំណាងការិយាល័យ អង្គភាព ក្នុងក្រុង ស្រុក ខណ្ឌ
  - តំណាង ប្រឹក្សាឃុំ សង្កាត់
  - តំណា មាគមក្រុមប្រឹក្សា និង
  - អ្នក កព័ន្ធដទៃទៀតតាមការសម្រេចរបស់អភិបាលក្រុង ស្រុក ខណ្ឌ

មានដូចជាតំណាងប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយ អ្នកកាសែត ទូរទស្សន៍ ផ្សេងៗ ...

# ជំហានទី១ ៖ ការរៀបចំបញ្ជីគម្រោងអាទិភាពសម្រាប់កម្មវិធីវិនិយោគ

## ១.៥. ប្រជុំពិនិត្យសេចក្តីព្រាងបញ្ជីសំណើគម្រោង (ត)

- កិច្ចប្រជុំពិនិត្យសេចក្តីព្រាងបញ្ជីសំណើគម្រោងរបស់ក្រុង ស្រុក ខណ្ឌប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់អភិបាលក្រុង ស្រុក ខណ្ឌ និងប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។
- របៀបវារៈសំខាន់ៗនៃកិច្ចប្រជុំរួមមាន៖
  - ការបង្ហាញអំពីក្របខ័ណ្ឌអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ និង
  - តារាង១.៣. សេចក្តីព្រាងបញ្ជីសំណើគម្រោងរបស់ក្រុង ស្រុក ខណ្ឌ
- បន្ទាប់ពីអង្គប្រជុំបានពិនិត្យ ពិភាក្សា និងឯកភាពគ្នារួចមក ក្រុមការងារកសាងផែនការក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំ បញ្ជីគម្រោងអាទិភាពរបស់ក្រុង ស្រុក ខណ្ឌដោយប្រើប្រាស់តារាង១.៤

# ជំហានទី១ ÷ ការរៀបចំបញ្ជីគម្រោងអាទិភាពសម្រាប់កម្មវិធីវិនិយោគ

តារាង១.៤ បញ្ជីគម្រោងអាទិភាពរបស់ក្រុង ស្រុក ខណ្ឌ

| ល.រ | ឈ្មោះគម្រោង | ចូលរួមសម្រេចគោលបំណង | ទីតាំងគម្រោង | លទ្ធផលគ្រោង | ស្នើដោយ | រយៈពេលអនុវត្ត | អ្នកទទួលផល | | តម្លៃគម្រោង | អត្រាប្រសិទ្ធភាពតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | សរុប | ស្រី | | |
| ១.ផ្នែកសេដ្ឋកិច្ច | | | | | | | | | | |
| ១.១ កសិកម្ម | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ១.២.................. | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | សរុបរង | | | | | | |
| ២.ផ្នែកសង្គមកិច្ច | | | | | | | | | | |
| ២.១............................ | | | | | | | | | | |
| | | | | | | | | | | |

តម្រូវការជាអាទិភាព
របស់ប្រជាពលរដ្ឋចុង
ក្រោយត្រូវដាក់បញ្ចូល
ក្នុងតារាងនេះដើម្បីឱ្យ
ក្រុមប្រឹក្សាធ្វើវិនិយោគ

# ជំហានទី ២÷ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

ជំហានទី ១÷ ការរៀបចំបញ្ជីគម្រោងអាទិភាពសម្រាប់
កម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

ជំហានទី ២÷ ការរៀបចំសេចក្តីព្រាងកម្មវិធី
វិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

ជំហានទី ៣÷ ការអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិល
ក្រុង ស្រុក ខណ្ឌ

# ជំហានទី ២៖ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

២.៤. ដំណើការ

២.៤.១ ការរៀបចំខ្លឹមសារស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច

២.៤.២ ការរៀបចំគម្រោងនៃកម្មវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

២.៤.៣ ការប្រជុំពិនិត្យសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

២.៤.៤ ការរៀបចំសិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគក្រុង ស្រុក ខណ្ឌ

២.៤.៥ ការជ្រើសរើសគម្រោងសម្រាប់ប្រើប្រាស់ថវិកាវិនិយោគក្រុង ស្រុក ខណ្ឌ

២.៤.៦ ការរៀបចំបញ្ចប់សេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

២.៤.៧ ការពិនិត្យ ផ្តល់យោបល់របស់គណៈអភិបាលក្រុង ស្រុក ខណ្ឌលើសេចក្តីព្រាង

២.៤.៨ ការពិនិត្យ ផ្តល់យោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស។

# ជំហានទី ២៖ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

## ២.៤. ដំណើការ

### ២.៤.១. ការរៀបចំខ្លឹមសារស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច

- ដូចគ្នានឹងស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចក្នុងផែនការអភិវឌ្ឍន៍ដែរ

### ២.៤.២. ការរៀបចំគម្រោងនៃកម្មវិធីវិនិយោគ

- ការរៀបចំគម្រោងវិនិយោគបីឆ្នាំរំកិល
- ការរៀបចំមូលនិធិគាំទ្រទៅតាមប្រភព
- ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (បីឆ្នាំ)
- ការរៀបចំផែនការសកម្មភាពសម្រាប់ការអនុវត្តគម្រោងវិនិយោគឆ្នាំទី១

# ជំហានទី ២៖ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំ រំកិលក្រុង ស្រុក ខណ្ឌ

**តារាង២.១ ៖ គម្រោងវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ**

ក). គម្រោងវិនិយោគកំពុងដំណើរការ

| ល.រ | ឈ្មោះគម្រោង | ចូលរួមសម្រេចគោលបំណង | ទីតាំងគម្រោង | លទ្ធផលគ្រោង | ប្រភពថវិកា | អនុវត្តដោយ | រយៈពេលអនុវត្ត | អ្នកទទួលផល | | កម្រិតទុនវិនិយោគ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | សរុប | ស្រី | 2010 | 2011 | 2012 | សរុប |
| ១. ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | | | |
| ១.១. កសិកម្ម | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| សរុបរង | | | | | | | | | | | | | |

តារាងបង្ហាញពី សកម្មភាពគម្រោងកំពុងដំណើរការ និង សកម្មភាពគម្រោងដែលមានការសន្យាគាំទ្រ

ខ). គម្រោងវិនិយោគដែលមានការសន្យាគាំទ្រ

| ល.រ | ឈ្មោះគម្រោង | ចូលរួមសម្រេចគោលបំណង | ទីតាំងគម្រោង | លទ្ធផលគ្រោង | ប្រភពថវិកា | អនុវត្តដោយ | រយៈពេលអនុវត្ត | អ្នកទទួលផល | | កម្រិតទុនវិនិយោគ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | សរុប | ស្រី | 2010 | 2011 | 2012 | សរុប |
| ១. ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | | | |
| ១.១. កសិកម្ម | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| សរុបរង | | | | | | | | | | | | | |

# ជំហានទី ២÷ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

## ២.៤.២. ការរៀបចំគម្រោងនៃកម្មវិធីវិនិយោគ

គ). គម្រោងវិនិយោគអាទិភាពដែលមិនទាន់មានការសន្យាគាំទ្រ

| ល.រ | ឈ្មោះគម្រោង | ចូលរួមសម្រេចគោលបំណង | ទីតាំងគម្រោង | លទ្ធផលគ្រោង | ស្នើដោយ | រយៈពេលអនុវត្ត | អ្នកទទួលផល | | កម្រិតទុនវិនិយោគ | | | | អត្រាប្រសិទ្ធភាពតម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | សរុប | ស្រី | 2011 | 2012 | 2013 | សរុប | |
| ១. ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | | | |
| ១.១. កសិកម្ម | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | សរុបរង | | | | | | | | | | | |

> សកម្មភាពគម្រោងអាទិភាពដែលត្រូវធ្វើវិនិយោគហើយមិនមានការសន្យាគាំទ្រ

**បញ្ជាក់** ៖ បន្ទាប់ពីបំពេញផ្នែក “គ“ នេះហើយ ក្រុមការងារត្រូវបញ្ជូនផ្នែក “គ” នេះទៅក្រុមការងារកសាងផែនការរាជធានី ខេត្តដើម្បីបូកសរុបសម្រាប់រៀបចំសិក្ខាសាលា សមាហរណកម្មកម្មវិធីវិនិយោគរាជធានី ខេត្ត ។

# ជំហានទី ២៖ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

## ២.៤.២. ការរៀបចំគម្រោងនៃកម្មវិធីវិនិយោគ (ត)

**តារាង ២.២ ៖ មូលនិធិគាំទ្រតាមប្រភព**

| ល.រ | ប្រភពមូលនិធិ | ចំនួនមូលនិធិ | ចំនួនគម្រោង | ទីភ្នាក់ងារអនុវត្ត | | |
|---|---|---|---|---|---|---|
| | | | | អង្គភាពឬទីភ្នាក់ងារ | ចំនួនគម្រោង | តម្លៃ |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| សរុប | | | | | | |

ការរៀបចំមូលនិធិដែលគាំទ្រគម្រោងដែលត្រូវធ្វើវិនិយោគតាមប្រភព

# ជំហានទី ២៖ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំ រំកិលក្រុង ស្រុក ខណ្ឌ

## ២.៤.៣. ការរៀបចំសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគ

**ទម្រង់នៃសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង**

- សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិល
- អារម្ភកថា
- សេចក្តីផ្តើម
- ផែនទី

**ជំពូកទី១ ៖ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច**

១.១. សេចក្តីសង្ខេបទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច

១.២. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម

១.២.១. ស្ថានភាពសេដ្ឋកិច្ច

១.២.២. ស្ថានភាពសង្គមកិច្ច

១.២.៣. ស្ថានភាពនៃការប្រើប្រាស់ដីធ្លីនិងការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន

១.២.៤. ស្ថានភាពនៃការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

១.២.៥. ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

**ជំពូកទី២ ៖ គម្រោងនៃកម្មវិធីវិនិយោគបីឆ្នាំរំកិល**

២.១. គម្រោងវិនិយោគ

២.២. ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

២.៣. ផែនការសកម្មភាពសម្រាប់អនុវត្តគម្រោង

**ឧបសម្ព័ន្ធនានា**

# ជំហានទី ២៖ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ក្រុង ស្រុក ខណ្ឌ

**២.៤.៤. ការប្រជុំពិនិត្យសេចក្តីព្រាងកម្មវិធីវិនិយោគ**

**គោលបំណង ៖** ដើម្បីពិនិត្យ ផ្តល់យោបល់ និងឯកភាពលើសេចក្តីព្រាង

**អ្នកចូលរួម ៖**

- សមាជិកក្រុមការងារកសាងផែនការក្រុង ស្រុក ខណ្ឌ
- តំណាងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- តំណាងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុង ស្រុក ខណ្ឌ
- តំណាងគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រីនិងកុមារ
- តំណាងគណៈអភិបាលក្រុង ស្រុក ខណ្ឌ
- អង្គការសង្គមស៊ីវិល វិស័យឯកជន និង
- អ្នកពាក់ព័ន្ធផ្សេងទៀត

# ជំហានទី ២៖ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

**២.៤.៤. ការប្រជុំពិនិត្យសេចក្តីព្រាងកម្មវិធីវិនិយោគ**

**របៀបវារៈ**

- ការបង្ហាញសង្ខេបអំពីខ្លឹមសារស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច
- ការបង្ហាញតារាង ២.១ តារាង ២.២ និងតារាង២.៣
- ពិនិត្យ ពិភាក្សា ផ្តល់យោបល់ និងឯកភាព។

**បញ្ជាក់ ៖** បន្ទាប់ពីកិច្ចប្រជុំនេះ ក្រុមការងារកសាងផែនការ ត្រូវ ៖

- កែសម្រួលសេចក្តីព្រាង ដោយផ្អែកតាមការឯកភាពរបស់អង្គប្រជុំ
- ត្រៀមរៀបចំសម្រាប់ចូលរួមសិក្ខាសាលាសមាហរណកម្មនៃកម្មវិធីវិនិយោគរាជធានី ខេត្ត
- ត្រៀមរៀបចំសិក្ខាសាលាសមាហរណកម្មនៃកម្មវិធីវិនិយោគក្រុង ស្រុក ខណ្ឌ។

# ជំហានទី ២៖ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

**២.៤.៥. ការរៀបចំសិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគក្រុង ស្រុក ខណ្ឌ**

**ខ). អ្នកចូលរួម**

- តំណាងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- តំណាងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- តំណាងគណៈអភិបាលក្រុង ស្រុក ខណ្ឌ
- ក្រុមការងារកសាងផែនការក្រុង ស្រុក ខណ្ឌ
- ថ្នាក់ដឹកនាំមន្ទីរ អង្គភាព និងការិយាល័យនៅរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ
- តំណាងក្រុមប្រឹក្សាឃុំ សង្កាត់
- តំណាងសមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- តំណាងអង្គការសង្គមស៊ីវិល វិស័យឯកជន និង
- អ្នកពាក់ព័ន្ធផ្សេងទៀត ។

# ជំហានទី ២៖ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

**២.៤.៥. ការរៀបចំសិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគក្រុង ស្រុក ខណ្ឌ**

ដំណាក់កាល ៖

- ដំណាក់កាលមុនសិក្ខាសាលា
- ដំណាក់កាលសិក្ខាសាលា និង
- ដំណាក់កាលក្រោយសិក្ខាសាលា

# ជំហានទី ២៖ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

**២.៤.៥. ការរៀបចំសិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគក្រុង ស្រុក ខណ្ឌ**

**ដំណាក់កាលមុនសិក្ខាសាលា**

- រៀបចំលិខិតអញ្ជើញ និងរបៀបវារៈ
- តារាងបូកសរុបគម្រោងវិនិយោគឃុំ សង្កាត់ (តារាងម៉ាទ្រិច)។
- រៀបចំតារាង២.១ ផ្នែក “គ” នៃសេចក្តីព្រាងកម្មវិធីវិនិយោគក្រុងស្រុកខណ្ឌ
- លទ្ធផលសិក្ខាសាលាសមាហរណកម្មនៃកម្មវិធីវិនិយោគរាជធានីខេត្ត (គម្រោងវិនិយោគក្រុង ស្រុក ខណ្ឌ ដែលទទួលបានការគាំទ្រក្នុងសិក្ខាសាលាសមាហរណកម្មនៃកម្មវិធីវិនិយោគរាជធានី ខេត្ត)។
- ឯកសារពាក់ព័ន្ធផ្សេងទៀត។

# ជំហានទី ២÷ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

## ២.៤.៥. ការរៀបចំសិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគក្រុង ស្រុក ខណ្ឌ

**ដំណាក់កាលអំឡុងពេលសិក្ខាសាលា ៖**

- តំណាងក្រុង ស្រុក ខណ្ឌបង្ហាញអំពី ៖
  - តារាង២.១ ផ្នែក“គ” របស់ក្រុង ស្រុក ខណ្ឌ
  - លទ្ធផលសិក្ខាសាលាសមាហរណកម្មនៃកម្មវិធីវិនិយោគរាជធានី ខេត្ត
  - តារាងបូកសរុបគម្រោងវិនិយោគជាអាទិភាពរបស់ឃុំ សង្កាត់
- តំណាងឃុំ សង្កាត់បង្ហាញអំពីតារាង២.២ អំពីគម្រោងវិនិយោគជាអាទិភាពរបស់ឃុំ សង្កាត់ (តារាងរបស់ឃុំ សង្កាត់)
- ពិភាក្សា ផ្តល់ការគាំទ្រ និងចុះកិច្ចព្រមព្រៀងបណ្តោះអាសន្ន។

# ជំហានទី ២៖ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

## ២.៤.៦.ការជ្រើសរើសគម្រោងសម្រាប់ប្រើប្រាស់ថវិកាវិនិយោគក្រុង ស្រុក ខណ្ឌ

**ដំណាក់កាលក្រោយពេលសិក្ខាសាលា ៖**

- ពិនិត្យ និងកែសម្រួលតារាង២.១ ផ្នែក“ខ” និង “គ”
- សម្រេចជ្រើសរើសគម្រោងសម្រាប់ប្រើប្រាស់ថវិកាវិនិយោគក្រុង ស្រុក ខណ្ឌ ដោយ ៖
  - ដំបូងត្រូវធ្វើការជ្រើសរើសគម្រោងសម្រាប់ប្រើប្រាស់មូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌ ដោយផ្អែកលើអត្រាប្រសិទ្ធភាពតម្លៃខ្ពស់តាមវិស័យនីមួយៗ
  - បន្ទាប់មក ត្រូវជ្រើសរើសគម្រោងសម្រាប់ប្រើប្រាស់មូលនិធិគ្មានភ្ជាប់ល័ក្ខខ័ណ្ឌ ដោយផ្អែកលើអត្រាប្រសិទ្ធភាពតម្លៃខ្ពស់ និងចំណាត់ថ្នាក់វិស័យអាទិភាពខ្ពស់
  - បន្តជ្រើសរើសគម្រោងតាមលំដាប់លំដោយរហូតដល់អស់មូលនិធិវិនិយោគដែលមាន
- បូកសរុបគម្រោងកំពុងដំណើរការ និងគម្រោងមានការសន្យាគាំទ្រ(តារាង១.២ ខ)

# ជំហានទី ២៖ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

**២.៤.៧.រៀបចំបញ្ចប់សេចក្តីព្រាងកម្មវិធីវិនិយោគក្រុង ស្រុក ខណ្ឌ**

**ដំណាក់កាលក្រោយពេលសិក្ខាសាលា៖**

- បន្ទាប់មក ក្រុមការងារត្រូវពិនិត្យ និងកែសម្រួល៖
  - តារាង២.១ ៖គម្រោងវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ (ផ្នែក“ខ” “គ”)
  - តារាង២.២ ៖ គម្រោងគាំទ្រតាមប្រភពមូលនិធិ
  - ផែនការសកម្មភាពសម្រាប់អនុវត្តគម្រោងវិនិយោគក្រុងឆ្នាំទី១ដោយប្រើប្រាស់តារាង២.៤។
- រៀបចំបញ្ចប់សេចក្តីព្រាងកម្មវិធីវិនិយោគក្រុង ស្រុក ខណ្ឌ។

# ជំហានទី ២៖ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

## ២.៤.៧.រៀបចំបញ្ចប់សេចក្តីព្រាងកម្មវិធីវិនិយោគក្រុង ស្រុក ខណ្ឌ

**តារាង២.៤៖ ផែនការសកម្មភាពសម្រាប់អនុវត្តគម្រោងវិនិយោគក្រុង ស្រុក ខណ្ឌឆ្នាំទី១**

| ល.រ | ឈ្មោះគម្រោង | ទីតាំងគម្រោង | លទ្ធផលគ្រោង | | តម្លៃគម្រោង | ប្រភពថវិកា | អនុវត្តដោយ | កាលបរិច្ឆេទអនុវត្ត | | អ្នកទទួលផល | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឯកតា | ចំនួន | | | | ចាប់ផ្តើម | បញ្ចប់ | សរុប | ស្រី |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

# ជំហានទី ២៖ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

## ២.៤.៨. ការពិនិត្យ និងផ្តល់យោបល់របស់គណៈអភិបាល

- ក្រុមការងារដាក់សេចក្តីព្រាងនេះ ជូនគណៈអភិបាលពិនិត្យ និងផ្តល់យោបល់
- គណៈអភិបាលត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួនដើម្បីពិនិត្យ និងផ្តល់យោបល់
- ក្រុមការងារធ្វើការកែសម្រួលតាមយោបល់របស់គណៈអភិបាល

## ២.៤.៩. ការពិនិត្យ និងផ្តល់យោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

- គណៈអភិបាលបញ្ជូនសេចក្តីព្រាងទៅគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសពិនិត្យ និងផ្តល់យោបល់
- ក្រុមការងារកែសម្រួលបញ្ចប់សេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ រួចហើយត្រូវដាក់ជូនក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌពិនិត្យ និងអនុម័ត

# ជំហានទី ៣៖ ការអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

ជំហានទី ១៖ ការរៀបចំបញ្ជីគម្រោងអាទិភាពសម្រាប់
កម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

ជំហានទី ២៖ ការរៀបចំសេចក្ដីព្រាងកម្មវិធី
វិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

**ជំហានទី ៣៖ ការអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិល
ក្រុង ស្រុក ខណ្ឌ**

# ជំហានទី ៣៖ ការអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

សកម្មភាពសំខាន់ៗ ៖

៣-១ ការងារត្រៀមសម្រាប់ការប្រជុំអនុម័តសេចក្តីព្រាង

៣-២ ការងារក្នុងពេលប្រជុំអនុម័ត

៣-៣ ការងារក្រោយពេលអនុម័ត

# ដំណាក់កាលទី ៣៖ ការអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

## ៣-១ ការងារត្រៀមសម្រាប់ការប្រជុំអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគ

គណៈអភិបាលដោយមាននាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ និងក្រុមការងារកសាងផែនការរាជធានី ខេត្ត ជាសេនាធិការ ត្រូវ ៖

- ចាត់ចែងបញ្ជូនសេចក្តីព្រាងកម្មវិធីទៅក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- រៀបចំសេចក្តីថ្លែងហេតុ ព្រមទាំងត្រៀមរៀបចំឯកសារយោង ឬឯកសារពាក់ព័ន្ធនានាសម្រាប់បំភ្លឺក្នុងកិច្ចប្រជុំក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។ សេចក្តីថ្លែងហេតុនេះត្រូវបង្ហាញអំពី ៖
  - មូលដ្ឋានគតិយុត្ត ដែលតម្រូវឱ្យមានសម្រាប់ការកសាងកម្មវិធីវិនិយោគ
  - ទម្រង់របស់កម្មវិធីវិនិយោគ
  - ចំនួនគម្រោង និងថវិកានៃកម្មវិធីវិនិយោគតាមវិស័យ និងឆ្នាំនីមួយៗ ព្រមទាំង
  - ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម។

# ដំណាក់កាលទី ៣៖ ការអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

## ៣-២ ការងារក្នុងពេលប្រជុំអនុម័ត

- ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួន ដើម្បីពិនិត្យ និងអនុម័តិសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ ។ កិច្ចដំណើរការប្រជុំនេះ ត្រូវប្រព្រឹត្តទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។
- របៀបវារៈសំខាន់ៗ នៃកិច្ចប្រជុំនេះ រួមមាន៖

– សេចក្តីថ្លែងហេតុ ដោយអភិបាលក្រុង ស្រុក ខណ្ឌ

– បទបង្ហាញអំពីសេចក្តីព្រាងកម្មវិធីវិនិយោគដោយអភិបាលក្រុង ស្រុក ខណ្ឌ

– ការពិនិត្យ ពិភាក្សា និងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគ

## ដំណាក់កាលទី ៣៖ ការអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

### ៣.៣ ការងារក្រោយពេលពេលប្រជុំអនុម័ត

**ក). ការកែសម្រួលសេចក្តីព្រាង**

គណៈអភិបាលក្រុង ស្រុក ខណ្ឌ ធ្វើការកែសម្រួលសេចក្តីព្រាងកម្មវិធីវិនិយោគ ដោយផ្អែកតាម ការសម្រេចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ហើយដាក់ជូនអភិបាលក្រុង ស្រុក ខណ្ឌ នូវសេចក្តីព្រាង ដែលបានកែសម្រួលនេះ ដើម្បីពិនិត្យ ។

**ខ). សេចក្តីសម្រេចស្តីពីការដាក់ឲ្យប្រើប្រាស់កម្មវិធីវិនិយោគ**

បន្ទាប់ពីការអនុម័តរបស់ក្រុមប្រឹក្សា គណៈអភិបាលត្រូវរៀបចំសេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់កម្មវិធីវិនិយោគ និងដាក់ជូនប្រធានក្រុមប្រឹក្សាចុះហត្ថលេខា ។

# ជំហានទី ៣៖ ការអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

**៣.៣ ការងារក្រោយពេលពេលប្រជុំអនុម័ត**

**គ). ការបោះពុម្ព និងផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគ**

គណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវ ៖

- រៀបចំបោះពុម្ពសៀវភៅកម្មវិធីវិនិយោគ
- ធ្វើការបែងចែកផ្សព្វផ្សាយជាសាធារណៈ
- តម្កល់ទុកនៅសាលារាជធានី ខេត្ត មន្ទីរផែនការរាជធានី ខេត្ត និង
- ផ្ញើរជូនក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអ្នកពាក់ព័ន្ធ

**ឃ). ការអនុវត្តកម្មវិធីវិនិយោគក្រុង ស្រុក ខណ្ឌ**

បន្ទាប់ពីអនុម័តកម្មវិធីវិនិយោគ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការណែនាំឱ្យគណៈអភិបាលក្រុង ស្រុក ខណ្ឌឱ្យចាត់ចែងអនុវត្តកម្មវិធីនេះ ប្រកបដោយតម្លាភាព គណនេយ្យភាព ការចូលរួម និងប្រសិទ្ធភាពខ្ពស់។

# ជំហានទី ៣៖ ការអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

## ៣.៣ ការងារក្រោយពេលពេលប្រជុំអនុម័ត

### ខ)ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគ

ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវទទួលខុសត្រូវក្នុងការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃជារៀងរាល់ឆ្នាំ លើការអនុវត្តកម្មវិធីវិនិយោគ ដោយរាប់ទាំងផ្នែកនៃកម្មវិធីវិនិយោគ ដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់៖

- ក្រុមប្រឹក្សាប្រភេទរួមគ្នា
- ប្រភេទក្រុមប្រឹក្សាផ្សេងទៀត
- ក្រសួង ស្ថាប័ន អង្គភាពនានារបស់រដ្ឋាភិបាល
- អ្នកពាក់ព័ន្ធនានា។

# ជំហានទី ៣៖ ការអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

## ៣.៣ ការងារក្រោយពេលពេលប្រជុំអនុម័ត

ជាមួយគ្នានេះដែរ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌត្រូវចាត់ចែង រៀបចំយុទ្ធសាស្ត្រតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌដោយផ្តោតលើចំណុចសំខាន់ៗ ដូចខាងក្រោម៖

- ការរៀបចំផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ
- ការកំណត់សូចនាករសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ
- ការកំណត់អ្នកទទួលខុសត្រូវក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ
- ការកំណត់វិធីសាស្ត្រអ្នកចូលរួមក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

# ជំហានទី ៣៖ ការអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

## ៣.៣ ការងារក្រោយពេលពេលប្រជុំអនុម័ត

- នៅចុងឆ្នាំនីមួយៗ គណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំ និងដាក់ជូនរបាយការណ៍ប្រចាំឆ្នាំស្ដីពីការអនុវត្តកម្មវិធីវិនិយោគ ទៅក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌពិនិត្យ និងអនុម័ត ។
- ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវផ្ញើរជូនរបាយការណ៍ប្រចាំឆ្នាំស្ដីពីការអនុវត្តកម្មវិធីវិនិយោគនេះ ទៅគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ។
- ខ្លឹមសាររបាយការណ៍នេះរួមមាន វឌ្ឍនភាពការងារអនុវត្តក្នុងឆ្នាំកន្លងមក ទិសដៅការងារសម្រាប់អនុវត្តឆ្នាំខាងមុខ និងសេចក្ដីសន្និដ្ឋានរួម
- ក្នុងករណីចាំបាច់នៃការអនុវត្តកម្មវិធីវិនិយោគតាមឆ្នាំនីមួយៗ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អាចធ្វើការកែតម្រូវគម្រោងថវិកា និងផែនការសកម្មភាពសម្រាប់អនុវត្តកម្មវិធីវិនិយោគនេះ ផ្អែកតាមការស្នើសុំកែតម្រូវរបស់គណៈអភិបាលក្រុង ស្រុក ខណ្ឌ ។

# ៤.វដ្តនៃកម្មវិធីវិនិយោគប្រចាំឆ្នាំ



# ជំហានទី១.ការពិនិត្យបញ្ហា ឬ តម្រូវការជាមួយប្រជាពលរដ្ឋឡើងវិញ

## ក្រុមប្រឹក្សាឃុំសង្កាត់

- ប្រជុំថ្នាក់ឃុំធ្វើបច្ចុប្បន្នភាព និង ផ្សព្វផ្សាយកាលវិភាគពីការពិគ្រោះយោបល់ជូនប្រជាពលរដ្ឋ
- ផ្សព្វផ្សាយពីពេលវេលាត្រូវប្រជុំ
- តំណាងគ្រួសារចូលរួមយ៉ាងតិច៦០% និងស្ត្រីយ៉ាងតិច៣០%
- ប្រជុំពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ដើម្បីធ្វើសុពលភាពតារាង១.១

## សង្គមស៊ីវិល និងប្រជាពលរដ្ឋ

- ត្រៀមលក្ខណៈចូលរួមជាមួយក្រុមប្រឹក្សាឃុំ សង្កាត់
- លើកឡើងពីបញ្ហា តម្រូវការ ក្តីកង្វល់ និងតម្រូវការអាទិភាពផ្សេង
- ត្រៀមបញ្ជាក់ពីបញ្ហា តម្រូវការ ក្តីកង្វល់ និងតម្រូវការជាអាទិភាពបានដាក់បញ្ចូលក្នុងតារាង១.១ដែរឬទេ

# ជំហានទី១.ការពិនិត្យបញ្ហា ឬ តម្រូវការជាមួយប្រជាពលរដ្ឋឡើងវិញ

**តារាង១.១ : បញ្ហា មូលហេតុ និងដំណោះស្រាយ**

| បញ្ហា | ទីតាំងនៃបញ្ហា | មូលហេតុនៃបញ្ហា | តម្រូវការ | ឧបសគ្គ | ដំណោះស្រាយ | យោបល់របស់ជនជាតិដើមភាគតិច |
|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

លទ្ធផលពីការពិគ្រោះយោបល់
ដាក់នៅក្នុងតារាង ១.១

**បញ្ជាក់ :** កូឡោនទី៧នៃតារាង១.១ សម្រាប់តែឃុំ សង្កាត់ និងភូមិដែលមានជនជាតិដើមភាគតិចរស់នៅប៉ុណ្ណោះ។

# ជំហានទី២. ការរៀបចំគម្រោងវិនិយោគឃុំ សង្កាត់

## ក្រុមប្រឹក្សាឃុំសង្កាត់

- កំណត់គម្រោងជាអាទិភាពដែលត្រូវធ្វើវិនិយោគទៅបង្ហាញនៅក្នុង DIW ដើម្បីកៀរគររកធនធានពីប្រភពផ្សេងមកគាំទ្រគម្រោងរបស់ឃុំ សង្កាត់
- កំណត់គម្រោងវិនិយោគសម្រាប់បង្ហាញនៅDIW ហើយស្រង់គម្រោងអាទិភាពទាំងនោះទៅក្នុងតារាង២.២

## សង្គមស៊ីវិល និងប្រជាពលរដ្ឋ

- សំណើរឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ដាក់បញ្ហាទៅក្នុងតារាង ២.២
- សំណើរដល់ឃុំ សង្កាត់ឱ្យមានការរំលេចបញ្ហាជាអាទិភាពនៅក្នុងតារាង ១.១ ទៅក្នុងតារាង២.២
- សំណើរក្រុមប្រឹក្សាឃុំ និងសង្កាត់ឱ្យគាំទ្រដល់បញ្ហាជាអាទិភាពដែលបានលើកឡើងពេលពិគ្រោះយោបល់

# ជំហានទី២. ការរៀបចំគម្រោងវិនិយោគឃុំ សង្កាត់

តារាង២.១ : បញ្ជីគម្រោងវិនិយោគដែលបានស្នើឡើង

| ល.រ | ឈ្មោះគម្រោង | ប្រភេទ | ទីតាំង | លទ្ធផលគម្រោង | | តម្លៃប៉ាន់ស្មាន | អ្នកទទួលផល | |
|---|---|---|---|---|---|---|---|---|
| | | | | ចំនួន | ឯកតា | (ពាន់រៀល) | សរុប | ស្រី |
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 |
| ផ្នែកសេដ្ឋកិច្ច | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| ផ្នែកសង្គមកិច្ច | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| ផ្នែកធនធានធម្មជាតិ និងបរិស្ថាន | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| ផ្នែកយេនឌ័រ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

# ជំហានទី២. ការរៀបចំគម្រោងវិនិយោគឃុំ សង្កាត់

តារាងទី២.២ ៖ គម្រោងវិនិយោគជាអាទិភាពរបស់ឃុំ សង្កាត់ ............ ឆ្នាំ ......

| ល.រ | ឈ្មោះគម្រោង | ប្រភេទ | ទីតាំង | លទ្ធផលគ្រោង | | តម្លៃប៉ាន់ស្មាន (ពាន់រៀល) | អ្នកទទួលផល | |
|---|---|---|---|---|---|---|---|---|
| | | | | ចំនួន | ឯកតា | | សរុប | ស្រី |
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 |
| ផ្នែកសេដ្ឋកិច្ច | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| ផ្នែកសង្គមកិច្ច | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| ផ្នែកធនធានធម្មជាតិ និងបរិស្ថាន | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| ផ្នែកសេវារដ្ឋបាល និងសន្តិសុខ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| ផ្នែកយេនឌ័រ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

# ជំហានទី២. ការរៀបចំគម្រោងវិនិយោគឃុំ សង្កាត់

**តារាង២.៣ : លទ្ធផលនៃការអនុវត្តគម្រោងឆ្នាំ....... ឃុំ...........**

| ល.រ | ឈ្មោះគម្រោង | ផ្នែក | ទីតាំងអនុវត្ត | លទ្ធផល | | តម្លៃ | អ្នកទទួលផល | | ប្រភពអ្នកគាំទ្រ |
|---|---|---|---|---|---|---|---|---|---|
| | | | | ចំនួន | ឯកតា | | សរុប | ស្រី | |
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| ក). គម្រោង ឬសកម្មភាពដែលបានចុះកិច្ចព្រមព្រៀងបណ្តោះអាសន្ន និងបានអនុវត្តរួចជាស្ថាពរ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ខ). គម្រោង ឬសកម្មភាពបានចុះកិច្ចព្រមព្រៀងបណ្តោះអាសន្ន ដែលកំពុងអនុវត្ត | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| គ). គម្រោង ឬសកម្មភាពបានចុះកិច្ចព្រមព្រៀងបណ្តោះអាសន្ន ដែលមិនបានអនុវត្ត | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ឃ). គម្រោង ឬសកម្មភាពដែលបានគាំទ្រក្រោយសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ង). គម្រោង ឬសកម្មភាពដែលប្រើប្រាស់មូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

# ជំហានទី៣. សិក្ខាសាលាសមាហរណកម្មផែនការ ថ្នាក់ ស្រុក

**ក្រុមប្រឹក្សាឃុំសង្កាត់**

- ត្រៀមបង្ហាញគម្រោងជាអាទិភាពដែលលើកឡើងដោយប្រជាពលរដ្ឋ និងសង្គមស៊ីវិលនៅក្នុងសមាហរណកម្មផែនការដើម្បីរកប្រភពថវិកាគាំទ្រ
- ផ្សារភ្ជាប់ជាមួយមន្ទីរជំនាញ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងដៃគូអភិវឌ្ឍនានា

**សង្គមស៊ីវិល និងប្រជាពលរដ្ឋ**

- ចូលរួមស្វែងយល់ពីសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលលើកឡើងក្នុងសមាហរណកម្ម
- សំណើរឱ្យមានការពិចារណារលើបញ្ហាជាអាទិភាពរបស់សហគមន៍
- ចែករំលែកព័តិមានបន្តពីលទ្ធផលDIWជូនដល់សហគមន៍

# ជំហានទី៤. ការអនុម័តកម្មវិធីវិនិយោគឃុំ សង្កាត់

## ក្រុមប្រឹក្សាឃុំសង្កាត់

- ជ្រើសរើសវិធីសាស្ត្រក្នុងការកំណត់ជ្រើសគម្រោងដែលផ្តល់មូលនិធិគាំទ្រដោយថវិកាឃុំ សង្កាត់លើសកម្មភាពអាទិភាពដែលលើកឡើងដោយប្រជាពលរដ្ឋ
- ផ្សព្វផ្សាយគម្រោងដែលបានអនុម័តដល់ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល និងអ្នកដែលពាក់ព័ន្ធនានា

## សង្គមស៊ីវិល និងប្រជាពលរដ្ឋ

- ចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីស្តាប់ពីការអនុម័តផែនការវិនិយោគ
- ត្រៀមលើកជាសំណួរ ឬ សូមឱ្យមានការបំភ្លឺនូវរាល់ចំងល់របស់ហាគមន៍ក្នុងកិច្ចប្រជុំ
- ផ្សព្វផ្សាយព័តិមានជូនដល់សហគមន៍ និងអ្នកជិតខាងរបស់ខ្លួន

# ដំណាក់កាលទី៥. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្ត កម្មវិធីវិនិយោគឃុំ សង្កាត់

## ក្រុមប្រឹក្សាឃុំសង្កាត់

- បង្កើតគណៈកម្មការមួយដើម្បីវាយតម្លៃការអនុវត្តគម្រោងវិនិយោគប្រចាំឆ្នាំដោយមានតំណាងសហគមន៍ចូលរួមផង
- ក្រុមប្រឹក្សាឃុំ សង្កាត់ ពិនិត្យ និងអនុម័តរបាយការណ៍វាយតម្លៃ ហើយផ្សព្វផ្សាយរបាយការណ៍នេះជាសាធារណៈ

## សង្គមស៊ីវិល និងប្រជាពលរដ្ឋ

- ចូលរួមស្វែងយល់ និងតាមដានការអនុវត្តសកម្មភាពគម្រោងរបស់ក្រុមប្រឹក្សា និងផ្តល់ព័ត៌មានត្រឡប់ដើម្បីកែលម្អ
- ចូលរួមវាយតម្លៃគម្រោងក្នុងនាមតំណាងឱ្យសហគមន៍

# ៧. តើត្រូវលើកទឹកចិត្តប្រជាពលរដ្ឋយ៉ាងដូចម្តេចក្នុងការភ្ជាប់ទំនាក់ទំនងក្នុងដំណើរការកសាងផែនការ និងថវិកា

- ពង្រឹងបណ្តាញការងាររបស់អង្គការសង្គមស៊ីវិលរៀបចំកម្មវិធីការងាររបស់ខ្លួនឱ្យបានច្បាស់លាស់ និងបន្សុីកម្មវិធីការងារជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ
- អភិវឌ្ឍសមត្ថភាព និងទំនុកចិត្តរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលដើម្បីធ្វើជាស្ពានសម្រាប់ភ្ជាប់ទំនាក់ទំនងរវាងប្រជាពលរដ្ឋ អង្គាការសង្គមស៊ីវិល និងក្រុមប្រឹក្សា
- កសាងភាពជាដៃគូជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិដើម្បីផ្តល់សេវាកម្មដ៏មានគុណភាពជូនប្រជាពលរដ្ឋ

# ៧. តើត្រូវលើកទឹកចិត្តប្រជាពលរដ្ឋយ៉ាងដូចម្តេចក្នុងការភ្ជាប់ទំនាក់ទំនងក្នុងដំណើរការកសាងផែនការ និងថវិកា

- គាំទ្រក្នុងការពង្រឹងភាពជាដៃគូជាមួយសមាគក្រុមប្រឹក្សាខេត្តដើម្បីអភិវឌ្ឍសមត្ថភាព និងទំនុកចិត្ត និងការកសាងបណ្តាញផ្សេងៗដើម្បីផ្តល់ឱកាសឱ្យប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលលើកឡើងពីបញ្ហា និងតម្រូវការផ្សេងៗ

- គាំទ្រឱ្យមានយន្តការផ្សេងៗក្នុងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋជាមួយសកម្មភាពអភិវឌ្ឍរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ហើយប្រជាពលរដ្ឋអាចដឹងអំពីចំណូល ចំណាយ និងការសម្រេចចិត្តរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ

# ៧. តើត្រូវលើកទឹកចិត្តប្រជាពលរដ្ឋយ៉ាងដូចម្តេចក្នុងការភ្ជាប់ទំនាក់ទំនងក្នុងដំណើរការកសាងផែនការ និងថវិកា

- គាំទ្រដល់ក្រុមមិនសូវមានតំណាង ជនជាតិភាគតិច ប្រជាពលរដ្ឋក្រីក្រ ស្ត្រីមេម៉ាយ ។ល។ឱ្យសកម្មចូលរួមជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិដើម្បីលើកឡើងពីបញ្ហា និងតម្រូវការជាអាទិភាពរបស់ខ្លួន
- គាំទ្រដល់ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិលឱ្យមានការយកចិត្តទុកដាក់លើសមភាព និងសមធម៌យេនឌ័រ ។
- គាំទ្រដល់ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិលដើម្បីផ្តល់ជាយោបល់ដល់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិក្នុងការធ្វើឱ្យប្រសើរឡើងនូវគោលនយោបាយ សេចក្តីណែនាំ និងនីតិវិធីផ្សេងៗពិសេសយន្តការនៃការភ្ជាប់ទំនាក់ទំនង

# ៩. សំណួរ

ការបំភ្លឺផ្សេងៗ

# ថ្ងៃទី២

# ប្លង់មេរៀនទី៤

# ចំណងជើងមេរៀនៈ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ

**ពេលវេលាៈ ០៣:១០ ដល់ ០៤:១០ (១ម៉ោង)**

**គោលបំណងនៃមេរៀនៈ** នៅចុងបញ្ចប់មេរៀននេះអ្នកចូលរួមនឹងអាចៈ

១. អាចយល់ពីនិយមន័យ និងប្រភេទនៃការអនុវត្តវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ

២. អាចរៀបរាប់បានពីសារៈសំខាន់ និងមូលហេតុនៃការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ

៣. អ្នកចូលរួមទាំងអស់មានជំនាញក្នុងការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ ហើយអាចប្រើប្រាស់ចំណេះដឹងនេះក្នុងការអនុវត្តជាក់ស្តែងបាន

**កំណត់ចំណាំរបស់អ្នកសម្របសម្រួល**

១. បញ្ជាក់ជាមួយអ្នកចូលរួមឱ្យបានច្បាស់ពីនិយមន័យរបស់វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈព្រមទាំងប្រភេទនៃវេទិកាសាធារណៈ

២. ពន្យល់ដល់អ្នកចូលរួមពីការប្រារព្ធវេទិកាសាធារណៈត្រូវប្រព្រឹត្តទៅតាម៣ដំណាក់កាលធំៗ (មុនពេល អំឡុងពេល និងក្រោយពេល) ។

៣. នៅពេលបូកសរុបលទ្ធផលមេរៀនអ្នកសម្របសម្រួលព្យាយាមបកស្រាយពីទំនាក់ទំនងរវាងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធាណៈ និងគណនេយ្យភាពសង្គម

**លទ្ធផលរំពឹងទុកនៃមេរៀន**

ក. អ្នកចូលរួម អាចពន្យល់បានពីនិយមន័យ និងភាពខុសគ្នានៃប្រភេទវេទិកាផ្សព្វផ្សាយ ពិគ្រោះយោបល់

ខ. យល់ច្បាស់ពីដំណាក់កាលនីមួយៗ (មុនពេល អំឡុងពេល និងក្រោយពេល) នៃការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់

គ. អ្នកចូលរួមយល់ដឹងពីតួនាទី និងការទទួលខុសត្រូវ អ្នកសម្របសម្រួលក្នុងការប្រារព្ធវេទិកាផ្សព្វផ្សាយ និងពិគ្រោះ យោបល់សាធារណៈ

ឃ. យល់ច្បាស់ពីរបៀបនៃការកំណត់អ្នកដែលត្រូវចូលរួមក្នុងការប្រារព្ធវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់

## សម្ភារឧបទេ្ទសសម្រាប់មេរៀនៈ

- ឯកសារចែកជូនៈ
  - បទបង្ហាញពីនិយមន័យ ភាពខុសគ្នា និងដំណើរការនៃវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ
  - ឯកសារស្តីពី ដំណើរការនៃការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ (មុនពេល អំឡុងពេល និងក្រោយពេល)
- ហ្វឺតសរសេរក្រដាស ក្រដាសផ្ទាំងធំ ស្កុត
- កុំព្យូទ័រយួរដៃ និងម៉ាស៊ីនបញ្ចាំងឯកសារ

## ឯកសារយោងៈ

- សៀវភៅជំនួយស្មារតីស្តីពីវេទិកាសាធារណៈឃុំ សង្កាត់ Pact/LAAR កញ្ញាឆ្នាំ ២០១០
- សៀវភៅសម្រាប់គ្រូស្តីពី ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅកម្ពុជា សីលការ មិថុនា២០១០
- អនុក្រិត្យ២១៦ មាត្រា១២១ ស្តីពី វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ

## របៀបសម្របសម្រួលមេរៀន

| ម៉ោង | <u>សកម្មភាព និងវិធីសាស្ត្រ</u> | សម្ភារ និងឯកសារចែកជូន |
|---|---|---|
| ៥ នាទី | <u>សកម្មភាពទី-១</u>រំលឹកមេរៀន<br>▪ មុននឹងចាប់ផ្តើមមេរៀនស្តីពីវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ អ្នកសម្របសម្រួលរំឭកពីមេរៀនទី៣ ថ្ងៃទី០២ មេរៀន ទី៣ស្តីពីប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិលចូលរួមក្នុងដំណើរ ការកសាង ផែនការ និងថវិការបស់ ក្រុង ស្រុក ឃុំ សង្កាត់បន្តិចដើម្បីភ្ជាប់ពី ទំនាក់ទំនងគ្នានៅក្នុងមេរៀននេះ | |
| | <u>សកម្មភាពទី២</u>-គោលបំណង ***សេចក្តីផ្តើម*** និងលទ្ធផលរំពឹងទុក<br>▪ អ្នកសម្របសម្រួលធ្វើការបង្ហាញគោលបំណងមេរៀន សេចក្តីផ្តើម និងលទ្ធផលរំពឹងទុកដែលមាននៅក្នុងស្លាយបទបង្ហាញ តែមុននឹងបង្ហាញ អ្នកសម្របសម្រួលធ្វើការបកស្រាយបន្តិចអំពីអនុក្រិត្យ និងមាត្រាដែលបានចែងអំពីការប្រារព្ធវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ដូច ដែលបានរៀបរាប់ខាងក្រោមនេះ<br>▪ អ្នកសម្របសម្រួលបញ្ជាក់ជាមួយអ្នកចូលរួមថា អនុក្រិត្យលេខ២១៦ | ▪ ស្លាយ១ដល់៤ |

| | | |
|---|---|---|
| | មាត្រា ១២១ បានចែងថា ក្នុងអំឡុងខែមិថុនានៃឆ្នាំនីមួយៗក្រុមប្រឹក្សាក្រុង ស្រុកទាំង អស់ ត្រូវរៀបចំឱ្យមានវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ នៅតាមឃុំ សង្កាត់ក្នុងក្រុង ស្រុករបស់ខ្លួន។ វេទិផ្សព្វផ្សាយ និងពិគ្រោះ យោបល់នេះត្រូវរៀបចំ និងចូលរួមដោយក្រុមប្រឹក្សាក្រុង ស្រុក គណៈអភិបាល សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងក្រុង ស្រុក តំណាងសហគមន៍ ប្រជាពលរដ្ឋ ឬ អ្នកពាក់ព័ន្ធដទៃទៀតតាមការសម្រេចរបស់ក្រុមប្រឹក្សាក្រុង ស្រុក។ | |
| ១៥នាទី | <u>សកម្មភាពទី៣-</u>និយមន័យ **គោលបំណង ប្រភេទ និងសារៈសំខាន់នៃវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ**<br>១. អ្នកសម្របសម្រួលប្រើប្រាស់សំណួរបំផុសគំនិតដោយស្នើសុំឱ្យអ្នកចូលរួមផ្តល់ចម្លើយ៣ទៅ៤នាក់នូវសំណួរដូចខាងក្រោមៈ<br>ក. តើលោកអ្នកធ្លាប់ឮពាក្យថាវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈដែរឬទេ? តើមានន័យយ៉ាងដូចម្តេច?ហើយមានគោលបំណងអ្វីដែរ?<br>ខ. តាមការយល់ឃើញរបស់លោកអ្នក តើវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈមានប៉ុន្មាន ប្រភេទអ្វីខ្លះ?<br>គ. តើមានសារៈសំខាន់អ្វីចាំបាច់ត្រូវរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ?<br>▪ អ្នកសម្របសម្រួលកត់ត្រាចម្លើយអ្នកចូលរួមលើក្រដាសផ្ទាំងធំរួចបង្ហាញស្លាយដើម្បីបញ្ជាក់ពីចំនុចខ្វះខាតបន្ថែម។ | ▪ ស្លាយទី៥ដល់ ៩ |
| ១៥នាទី | <u>សកម្មភាពទី៤-</u> ដំណើរការរៀបចំ និងអនុវត្តវេទិកា<br>▪ ក្រុមពិភាក្សាៈអ្នកសម្របសម្រួលចែកក្រុមពិភាក្សាជាបួនក្រុមដោយឱ្យក្រុមនីមួយៗឆ្លើយនូវសំណួរដូចខាងក្រោមៈ<br>ក. កំណត់ឱ្យបានប្រធានបទមួយដែលជាបញ្ហាជាក់ស្តែងនៅក្នុង មូលដ្ឋានលោកអ្នក<br>ខ. តើអ្នកណាខ្លះដែលជាអ្នកពាក់ព័ន្ធក្នុងដំណើរការប្រារព្ធវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់នៅថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់?<br>គ. តើមុនពេល អំឡុងពេល និងក្រោយពេលវេទិកាផ្សព្វផ្សាយ និង | |

| | | |
|---|---|---|
| | ពិគ្រោះយោបល់នៅថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់អ្នកពាក់ព័ន្ធ ទាំងនោះត្រូវរៀបចំធ្វើអ្វីខ្លះ?<br>ឃ. ក្រុមទាំងអស់យកលទ្ធផលមកផ្ទឹមគ្នាដើម្បីឆ្លុះបញ្ចាំង | |
| ១៥នាទី | <u>សកម្មភាពទី៥-</u> បទបង្ហាញពីដំណើរការ (មុនពេល អំឡុងពេល ក្រោយពេល) និងសារៈសំខាន់នៃការចូលរួមរបស់អ្នកពាក់ព័ន្ធ<br>▪ អ្នកសម្របសម្រួលធ្វើបទបង្ហាញស្ដីពីដំណើរការនៃការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ **(មុនពេល អំឡុងពេល ក្រោយពេល)**<br>▪ ឆ្លុះបញ្ចាំងសកម្មភាពចំបង៧ទៅនឹងលទ្ធផលក្រុមពិភាក្សា<br>▪ សំណួរ និងចម្លើយពីអ្នកចូលរួម | ▪ ស្លាយ ១០ដល់២០ |
| ១០ នាទី | <u>សកម្មភាពទី៧-</u> បូកសរុបមេរៀនៈ<br>▪ សំយោគមេរៀនឡើងវិញ បញ្ជាក់ទៅលើតួនាទីរបស់អ្នកសម្រប សម្រួល និងការបែងចែកការទទួលខុសត្រូវនៅក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ<br>▪ រំលឹកបញ្ជាក់ពីសារៈសំខាន់នៃការចូលរួមរបស់អង្គការសង្គមស៊ីវិល និងអ្នកសារព័ត៌មាន<br>▪ បញ្ជាក់ពីទំនាក់ទំនងរវាងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ សាធារណៈទៅនឹងគណនេយ្យភាពសង្គម (មានវេទិការសាធារណៈ ››› បង្កើន អភិបាលកិច្ចល្អ ››› មានគណនេយ្យភាពសង្គម)<br>▪ រំលឹកទៅអ្នកចូលរួមថា អង្គការដៃគូថ្នាក់ខេត្តនឹងបង្ហាត់បង្ហាញបន្ថែមទៀតក្នុងដំណើរការអនុវត្តជាក់ស្ដែងនៅថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ | |

# ថ្ងៃទី២

# មេរៀនទី៤

## វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ

សហការការិយាល័យសម្របសម្រួលគម្រោង DFGG ក្រសួងមហាផ្ទៃ អង្គការផេក កម្ពុជា

# ១.គោលបំណងមេរៀន

១. អាចយល់ពីនិយមន័យ និងប្រភេទនៃការអនុវត្តវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ

២. អាចរៀបរាប់បានពីសារៈសំខាន់ និងមូលហេតុនៃការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ

៣. អ្នកចូលរួមទាំងអស់មានជំនាញក្នុងការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ ហើយអាចប្រើប្រាស់ ចំណេះដឹងនេះក្នុងការអនុវត្តជាក់ស្តែងបាន

# ២.សេចក្តីផ្តើម

- វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ ផ្តល់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនូវឱកាសដើម្បីធ្វើការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកជាមួយនឹងប្រជាពលរដ្ឋ សង្គមស៊ីវិល វិស័យឯកជន និងអ្នកជំនាញនានា ដើម្បីធ្វើការផ្លាស់ប្តូរព័ត៌មាន បទពិសោធន៍ និងផ្តល់ប្រឹក្សាអំពីអាទិភាពនៃការងារអភិវឌ្ឍនៅក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ គឺជាមធ្យោបាយដ៏ប្រសើរមួយដើម្បីជំរុញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានតម្លាភាព លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការដោះស្រាយបញ្ហានៅមូលដ្ឋាន និងគាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

# ២.សេចក្តីផ្តើម (ត)

- វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ គឺជាការជួបជុំ ឬការប្រមូលផ្តុំគ្នាជាលក្ខណៈផ្លូវការ ឬមិនផ្លូវការនៅថ្នាក់មូលដ្ឋាន សហគមន៍ដែលជាកន្លែងប្រជាពលរដ្ឋ និងមន្ត្រីសាធារណៈ មានឱកាសជួបគ្នា ដើម្បីផ្លាស់ប្តូរព័ត៌មាន និងមតិយោបល់ ឬលើកឡើងនូវកង្វល់នានាដែលពាក់ព័ន្ធទៅនិងការងារអភិវឌ្ឍ និងការងារថវិការបស់សហគមន៍នៅក្នុងមូលដ្ឋានខ្លួន។

# ៣.គោលបំណងវេទិកា

- ក្រុមប្រឹក្សាអាចរាយការណ៍អំពីសកម្មភាពរបស់ខ្លួននៅក្នុងឆ្នាំកន្លងមក និងបង្ហាញពីផែនការសម្រាប់ឆ្នាំខាងមុខ
- ពិភាក្សា និងប្រឹក្សាយោបល់ជាមួយអ្នកចូលរួមអំពីលទ្ធផល ការផ្តល់ព័ត៌មានត្រឡប់ដល់ក្រុមប្រឹក្សាអំពីការងារនៅក្នុងឆ្នាំកន្លងមក និងលើកជាសំណើសម្រាប់ឆ្នាំបន្ទាប់។
- អ្នកចូលរួមអាចចូលរួមនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេច ដែលក្នុងនោះសំណើ និងការព្រួយបារម្ភរបស់ប្រជាពលរដ្ឋត្រូវបានលើកយកមកពិចារណានៅក្នុងការសម្រេចចុងក្រោយរបស់ក្រុមប្រឹក្សា

# ៣.គោលបំណងវេទិកា (ត)

- ក្រុមប្រឹក្សាទទួលបានព័ត៌មានប្រសើរជាងមុនអំពីតម្រូវការរបស់ប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋយល់ដឹងកាន់តែច្បាស់អំពីការអភិវឌ្ឍនៅមូលដ្ឋាន។
- ជំរុញ និងលើកកម្ពស់ភាពជាដៃគូរវាងក្រុមប្រឹក្សា ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា ដើម្បីចូលរួមចំណែកក្នុងការបង្កើតនូវដំណោះស្រាយដែលផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋជាអតិបរិមា។

# ៤.និយមន័យវេទិកា

- វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ គឺជាការជួបជុំគ្នាជាសាធារណៈរវាងប្រជាពលរដ្ឋមន្ត្រីសាធារណៈ អង្គការសង្គមស៊ីវិល ផ្នែកឯកជន អ្នកសារព័ត៌មាន និងអ្នកដែលពាក់ព័ន្ធផ្សេងៗទៀតដើម្បីផ្លាស់ប្តូរគំនិតយោបល់រួមគ្នាដោះស្រាយបញ្ហាសហគមន៍ និងផ្សព្វផ្សាយព័ត៌មានពីចំណូលចំណាយ សកម្មភាពអភិវឌ្ឍនានា និងការសម្រេចចិត្តរបស់ក្រុមប្រឹក្សា

# ៥. ប្រភេទនៃវេទិកាសាធារណៈ

- វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ មាន៣ប្រភេទៈ
    ១. វេទិកាដោយបើកចំហ
    
    ២. វេទិកាមានការកំហិត
    
    ៣. វេទិកាដោយមិនបើកចំហ

# ៦.សារៈសំខាន់នៃវេទិកាសាធារណៈ




វេទិកាសាធារណៈឃុំ សង្កាត់ ផេកកម្ពុជា ទំព័រ ០៤

# ក្រុមពិភាក្សា

ក. កំណត់ឱ្យបានប្រធានបទមួយដែលជាបញ្ហាជាក់ស្តែងនៅក្នុង មូលដ្ឋានលោកអ្នក

ខ. តើអ្នកណាខ្លះដែលជាអ្នកពាក់ព័ន្ធក្នុងដំណើរការប្រារព្ធវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់នៅថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់?

គ. តើមុនពេល អំឡុងពេល និងក្រោយពេលវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នៅថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់អ្នកពាក់ព័ន្ធ ទាំងនោះត្រូវរៀបចំធ្វើអ្វីខ្លះ?

# ៧. ដំណើរការនៃវេទិកាសាធារណៈ

## ៧.១ មុនពេលរៀបចំវេទិកា

ដើម្បីឱ្យវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈប្រព្រឹត្តទៅបានដោយរលូន និងមានការចូលរួមដោយសកម្មពីប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិលវិស័យឯកជន និងអ្នកដែលពាក់ព័ន្ធផ្សេងទៀត ក្រុមប្រឹក្សា ក្រុង ស្រុក ឃុំ សង្កាត់គួរពិចារណានូវជំហានសំខាន់ៗមួយចំនួនដើម្បីប្រារព្ធវេទិកាប្រកបដោយជោគជ័យ និងមានប្រសិទ្ធភាព។

# ៧. ដំណើរការនៃវេទិកាសាធារណៈ (ត)

## ក. ការបង្កើតតារាងត្រួតពិនិត្យសកម្មភាពមុនដំណើរការវេទិកាៈ

| តារាងត្រួតពិនិត្យការរៀបចំវេទិកា | | | |
|---|---|---|---|
| លរ | សកម្មភាព/សម្ភារ | បាទ | ទេ |
| ១ | របៀបវារៈ និងកម្មវិធីវេទិកា | | |
| ៣ | បទបញ្ជាផ្ទៃក្នុង | | |
| ៤ | ប្រអប់ទទួលសំណួរ | | |
| ៥ | ក្រដាសផ្ទាំងធំ ក្រដាសពណ៌ | | |
| ៦ | ក្តាខៀនសម្រាប់ពិភាក្សាក្រុម | | |
| ៧ | សុន្ទរកថាបើក | | |
| ៨ | សុន្ទរកថាបូកសរុបលទ្ធផល | | |
| ៩ | បដានៃវេទិកា | | |
| ១០ | ហ្វូងអក្សរនៃវេទិកា | | |
| ១១ | រោង តុ កៅអី មេក្រូ | | |
| ១២ | ផ្កាគណៈអធិបតី | | |
| ១៣ | អញ្ជើញអ្នកចូលរួម | | |
| ១៤ | វាគ្មិនដែលត្រូវចូលរួម | | |
| ១៥ | អញ្ជើញប្រព័ន្ធផ្សព្វផ្សាយ | | |
| ១៦ | អ្នកគ្រប់គ្រងអាហារសម្រន់ | | |

# ៧. ដំណើរការនៃវេទិកាសាធារណៈ (ត)

ខ. ការរៀបចំសេចក្តីព្រាងរបៀបវារៈ

| គម្រូរបៀបវារៈវេទិកាពិគ្រោះយោបល់សាធារណៈរបស់ក្រុង ស្រុក ឃុំ សង្កាត់ |
|---|
| ១. ប្រកាសហេតុ និងគោលបំណងនៃវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ |
| ២. គោរពទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា |
| ៣. បទបញ្ចូសម្រាប់វេទិកា |
| ៤. មតិស្វាគមន៍របស់ប្រធានក្រុមប្រឹក្សា |
| ៥. ការណែនាំខ្លួនរបស់សមាជិកក្រុមប្រឹក្សានីមួយៗ |
| ៦. បទបង្ហាញតួនាទី និងមុខងាររបស់ក្រុមប្រឹក្សា និង គណៈអភិបាលក្នុងពេលបច្ចុប្បន្ន ដោយប្រធានក្រុម ប្រឹក្សា |
| ៧. ការធ្វើរបាយការណ៍ពីស្ថានភាពអភិវឌ្ឍរបស់ក្រុង ស្រុក ឃុំ សង្កាត់ |
| ៨. ស្ថានភាពថវិការបស់ក្រុមប្រឹក្សា ដោយ ប្រធានការិយាល័យរដ្ឋបាល និង ហិរញ្ញវត្ថុ (ក្រុង ស្រុក) |
| ៩. សំណួរ និងចម្លើយ |
| ១០. ចំណាប់អារម្មណ៍ និងសំណូមពររបស់អ្នកចូលរួម |
| ១១. បូកសរុបលទ្ធផលដែលបានពិភាក្សា ដោះស្រាយ និងព្រមព្រៀងលើបញ្ហាដែលត្រូវយកទៅដោះស្រាយ |
| ១២. ការបិទវេទិកា ផ្សព្វផ្សាយ និងពិគ្រោះយោបល់ដោយប្រធានក្រុមប្រឹក្សា |

# ៧. ដំណើរការនៃវេទិកាសាធារណៈ (ត)

## គ. ការកំណត់អ្នកចូលរួម

មនុស្សសំខាន់ៗដែលត្រូវចូលរួមក្នុងវេទិកាសាធារណៈ (មានតុល្យភាពបុរស ស្ត្រី)

- ក្រុមប្រឹក្សា ក្រុង ស្រុក ឃុំ សង្កាត់
- គណៈអភិបាល ក្រុង ស្រុក
- ក្រុមប្រឹក្សាឃុំ សង្កាត់
- ប៉ូលីស ប៉េអឹម
- ការិយាល័យជំនាញទាំងអស់ដែលពាក់ព័ន្ធនឹងប្រធានបទ
- អង្គការសង្គមស៊ីវិលទាំងអស់
- ប្រជាពលរដ្ឋ (រួមទាំងក្រុមយុវជន)
- តំណាងក្រុមសាសនា ផ្សេងៗ
- តំណាងគណៈកម្មាធិការ:( ឧ.មណ្ឌលសុខភាព តំណាងគណៈកម្មការមាតាបិតាសិស្ស គ្រូបង្រៀន)
- វិស័យឯកជន
- តំណាងប្រព័ន្ធផ្សព្វផ្សាយក្នុងមូលដ្ឋាន (ទូរទស្ស កាសែត ទស្សនាវដ្តីព្រឹត្តិប័ត្ត ។ល។)
- អ្នកពាក់ព័ន្ធផ្សេងទៀត (អាស្រ័យទៅតាមរបៀបវារៈ)

# ៧. ដំណើរការនៃវេទិកាសាធារណៈ (ត)

ឃ. ការកំណត់អ្នកសម្របសម្រួល វិធីសាស្ត្រ និងទីកន្លែង

- ប្រធានក្រុមប្រឹក្សា គឺជាអ្នកដឹកនាំវេទិកាផ្សព្វផ្សាយ និង ពិគ្រោះយោបល់
- សមាជិកក្រុមប្រឹក្សាដទៃទៀតក៏ជាអ្នកចូលរួមចំណែកក្នុងការសម្របសម្រួល
- នាយករដ្ឋបាលជាអ្នកចាត់ចែងក្នុងការរៀបចំ តាមការណែនាំរបស់ក្រុមប្រឹក្សា
- នាយករដ្ឋបាលជាអ្នករៀបចំសម្ភារៈជំនួយ ដូចជា ក្រដាសផ្ទាំងធំ ថវិការបៀបវារៈ (សម្រាប់ការសាកល្បងមានថវិកាគាំទ្រពីគម្រោង)

# ៧. ដំណើរការនៃវេទិកាសាធារណៈ (ត)

ឃ. ការកំណត់អ្នកសម្របសម្រួល វិធីសាស្ត្រ និងទីកន្លែង

- គណៈអភិបាលប្រជុំជាមួយប្រធានមន្ទីរ ការិយាល័យពាក់ព័ន្ធ ដើម្បីត្រៀមកត់ត្រាសំណួរ មតិយោបល់ និង ឆ្លើយនូវសំណួរ
- វិធីសាស្ត្រក្នុងការប្រើប្រាស់ត្រូវមានលក្ខណៈសមស្រប ហើយមានការចូលរួម
- ទីតាំងដែលមានលក្ខណៈសមស្រប ដូចជា វត្តអារាម សាលារៀន សួនច្បារ សាលាឃុំ សាលាបុណ្យ ។ល ។

# ៧. ដំណើរការនៃវេទិកាសាធារណៈ (ត)

**៧.២ អំឡុងពេលប្រារព្ធវេទិកា៖** អ្នកចាត់ចែងត្រូវត្រួតពិនិត្យមើលនូវចំណុចដូចជា៖

- ទីកន្លែងសម្រាប់គណៈអធិបតី និងអ្នកចូលរួមអង្គុយ
- បទបញ្ហាផ្ទៃក្នុងត្រូវដាក់ឱ្យងាយស្រួលដល់អ្នកចូលរួមមើលឃើញ
- ការដាក់ប្រអប់សំបុត្រសម្រាប់ការបញ្ចេញមតិយោបល់ ឬ សំណើផ្សេងៗ
- ប្រកាសចំណូលចំណាយ និងការសម្រេចចិត្តសំខាន់ៗជូនជាសាធារណៈ
- ផ្ដល់ពេលវេលាសមស្របសម្រាប់ឱ្យអ្នកចូលរួមបញ្ចេញមតិយោបល់
- បូកសរុបការព្រមព្រៀង និងដំណោះស្រាយសំខាន់ៗរវាងក្រុមប្រឹក្សា និងសាធារណៈ និងសកម្មភាពដែលត្រូវតាមដាន និងអនុវត្តបន្ត

# ៧.ដំណើរការនៃវេទិកាសាធារណៈ (ត)

**៧.៣ ក្រោយពេលប្រារព្ធវេទិកាៈ**

- នាយករដ្ឋបាល ឬ ស្មៀនឃុំជាអ្នកដាក់ជូនសេចក្តីសង្ខេបនៃវេទិកាទាំងមូលទៅជូនក្រុមប្រឹក្សាដើម្បីពិនិត្យ និងអនុម័ត
- គណៈអភិបាល ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួនត្រូវធ្វើការបូកសរុបវាយតម្លៃអំពីលទ្ធផលនៃវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់រយៈពេលយ៉ាងយូរបំផុត១៥ថ្ងៃបន្ទាប់
- ប្រធានក្រុមប្រឹក្សា ណែនាំឱ្យនាយករដ្ឋបាលផ្ញើរបាយការណ៍ ទៅឱ្យគ្រប់អ្នកចូលរួមសំខាន់ៗនៅក្នុងវេទិកា ប្រធានក្រុមប្រឹក្សា ធានាថារបាយការណ៍ចុងក្រោយនេះ នឹងត្រូវផ្ញើទៅឱ្យសមាជិកទាំងអស់របស់ក្រុមប្រឹក្សា។

# ៧. ដំណើរការនៃវេទិកាសាធារណៈ (ត)

## ៧.៣ ក្រោយពេលប្រារព្ធវេទិកា៖

- អភិបាលរងដែលទទួលបន្ទុកព័ត៌មាននឹងធានាយ៉ាងណាឱ្យមានការសង្ខេបលទ្ធផលព្រមព្រៀងពីវេទិកាដើម្បីធ្វើការផ្សព្វផ្សាយជាសាធារណៈដោយសហការជាមួយប្រព័ន្ធផ្សព្វផ្សាយនានា (ក្ដារព័ត៌មាន វិទ្យុ ទស្សនាវដ្ដី កាសែត ឃុំ ភូមិ និងតាមរយៈអង្គការសង្គមស៊ីវិល)
- ផ្ដល់ព័ត៌មានត្រឡប់នូវលទ្ធផល និងដំណោះស្រាយជូនសាធារណៈ និងអ្នកពាក់ព័ន្ធនូវពេលមានវេទិកាបន្ត និងតាមការប្រជុំរបស់ក្រុមប្រឹក្សា។

# ៨.សារៈសំខាន់នៃការចូលរួមរបស់អ្នកពាក់ព័ន្ធ

- យល់ដឹង មានទស្សនៈដូចគ្នា នឹងមានភាពជាម្ចាស់លើកិច្ចការទាំងឡាយ
- មានការឆ្លើយតបទៅនឹងតម្រូវការដែលលើកឡើងដោយសហគមន៍
- បានជួយដោះស្រាយបញ្ហាសហគមន៍
- បង្កើនទំនុកចិត្តនិងភាពជាដៃគូរវាងក្រុមប្រឹក្សា ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ
- ប្រជាពលរដ្ឋបានទទួលព័ត៌មានស្តីពីចំណូលចំណាយ និងការអភិវឌ្ឍរបស់ក្រុមប្រឹក្សា

# សំណួរ

## ការបំភ្លឺផ្សេងៗ

# ថ្ងៃទី២
# មេរៀនទី៤
# ឯកសារចែក
# ចំណងជើងមេរៀនៈ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ

## ១.សេចក្តីផ្តើម

វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់សាធារណៈ ផ្តល់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ នូវឱកាសដើម្បីធ្វើការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកជាមួយនឹងប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកជំនាញនានា ដើម្បីធ្វើការផ្លាស់ប្តូរព័ត៌មានបទពិសោធន៍ និងផ្តល់ប្រឹក្សាអំពីអាទិភាពនៃការងារអភិវឌ្ឍ នៅក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់។ រដ្ឋបាលថ្នាក់ក្រោមជាតិ មានឱកាសបង្ហាញពីគណនេយ្យភាព ផែនការអភិវឌ្ឍរបស់ខ្លួនដល់សាធារណជន។ ប្រជាពលរដ្ឋអាចពិភាក្សាអំពីការងារនៅមូលដ្ឋាន ដោយសម្តែងចេញនូវបំណងប្រាថ្នា ការព្រួយបារម្ភរបស់ខ្លួន និងលើកឡើងនូវអនុសាសន៍សម្រាប់កែលម្អ។ វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់សាធារណៈ គឺជាមធ្យោបាយដ៏ប្រសើរមួយដើម្បីជំរុញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យមានតម្លាភាព លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការដោះស្រាយបញ្ហានៅមូលដ្ឋាន និងគាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ គឺជាការជួបជុំ ឬការប្រមូលផ្តុំគ្នាជាលក្ខណៈផ្លូវការ ឬមិនផ្លូវការនៅថ្នាក់មូលដ្ឋាន សហគមន៍ ដែលជាកន្លែងប្រជាពលរដ្ឋ និងមន្ត្រីសាធារណៈមានឱកាសជួយគ្នាដើម្បីផ្លាស់ប្តូរព័ត៌មាន និងមតិយោបល់ ឬលើកឡើងនូវកង្វល់នានាដែលពាក់ព័ន្ធទៅនិងការងារអភិវឌ្ឍ និងការងារថវិការបស់សហគមន៍នៅក្នុងមូលដ្ឋានរបស់ខ្លួន។

## ២.គោលបំណងនៃការរៀបចំវេទិកា

- ក្រុមប្រឹក្សាបានរាយការណ៍អំពីសកម្មភាពរបស់ខ្លួននៅក្នុងឆ្នាំកន្លងមក និងបង្ហាញពីផែនការសម្រាប់ឆ្នាំខាងមុខ
- ក្រុមប្រឹក្សានិងអ្នកចូលរួមពិភាក្សា អំពីលទ្ធផលផ្តល់ព័ត៌មានត្រឡប់ដល់ក្រុមប្រឹក្សា អំពីការងារនៅក្នុងឆ្នាំកន្លងមក និងលើកជាសំណើសម្រាប់ឆ្នាំបន្ទាប់
- អ្នកចូលរួមអាចចូលរួមនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេច ដែលក្នុងនោះសំណើនិងការព្រួយបារម្ភរបស់ប្រជាពលរដ្ឋ ត្រូវបានលើកយកមកពិចារណា នៅក្នុងការសម្រេចចុងក្រោយរបស់ក្រុមប្រឹក្សា
- ក្រុមប្រឹក្សាទទួលបានព័ត៌មានប្រសើរជាងមុន អំពីតម្រូវការរបស់ប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋយល់ដឹងកាន់តែច្បាស់អំពីការអភិវឌ្ឍនៅមូលដ្ឋាន។

- វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់សាធារណៈ ជំរុញនិងលើកកម្ពស់ភាពជាដៃគូរវាងក្រុមប្រឹក្សាប្រជាពលរដ្ឋ និងអ្នកពាក់ពន្ធ័នានា។ វេទិកាទាំងនេះចូលរួមចំណែកក្នុងការបង្កើតនូវដំណោះស្រាយដែលផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋនិងសហគមន៍។

## ៣. និយមន័យ

វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ គឺជាការជួបជុំគ្នាជា សាធារណៈរវាងប្រជាពលរដ្ឋ មន្រ្តីសាធារណៈ អង្គការសង្គមស៊ីវិល ផ្នែកឯកជន អ្នកសារព័តិមាន និងអ្នកដែលពាក់ព័ន្ធផ្សេងៗទៀត ដើម្បីផ្លាស់ប្តូរគំនិតយោបល់រួមគ្នាដោះស្រាយបញ្ហាសហគមន៍ និងផ្សព្វផ្សាយព័តិមានពីចំណូល ចំណាយ សកម្មភាពអភិវឌ្ឍនានា និងការសម្រេចចិត្តរបស់ក្រុមប្រឹក្សា។

## ៤. ប្រភេទនៃវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់សាធារណៈ

វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់សាធារណៈចែកចេញជាបីប្រភេទៈ SILAKA training manual on SA (page 415)

<u>ប្រភេទទី១</u> វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់សាធារណៈបើកចំហៈ

ជាទីកន្លែងប្រមូលផ្តុំគ្នាក្នុងការបញ្ចេញមតិដោយសេរីឬសាធារណៈដែលមានលក្ខណៈប្រពៃណី ហើយកន្លែងទាំងនោះរួមមានឧទ្យានសាធារណៈឬតាមកាច់ជ្រុងវិថីនានា។

<u>ប្រភេទទី២</u> វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់សាធារណៈ មានការកំហិតឬតាមការកំណត់ទុកជាមុនៈ

គឺជាកន្លែងប្រមូលផ្តុំក្នុងការបញ្ចេញមតិ ឬការសំដែងសកម្មភាព មានការកំណត់ទុកជាមុនដែលជាទូទៅផ្តោតលើក្រុមឬប្រធានបទណាមួយជាក់លាក់។ ឧ. ទីកន្លែងនៃវេទិកាប្រភេទនេះជាទូទៅ អាចស្ថិតនៅក្នុងសាលប្រជុំសកលវិទ្យាល័យឬសាលមហោស្របរបស់សាលាក្រុង ។ល។

<u>ប្រភេទទី៣</u> វេទិកាមិនបើកចំហៈ

គឺជាកន្លែងដែលប្រមូលផ្តុំគ្នា តែជាទម្លាប់មិនបើកចំហឱ្យដល់សាធារណៈជន ក្នុងការសំដែងមតិដោយសេរីឬសាធារណៈឡើយ ហើយដែលទីកន្លែងទាំងនោះរួមមាន មន្ទីរឃុំឃាំងមូលដ្ឋានយោធា ឬស្ថាប័នសំខាន់ៗមួយចំនួនរបស់រដ្ឋាភិបាល។

## ៥. សារៈសំខាន់នៃការរៀបចំវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់សាធារណៈ




វេទិកាសាធារណៈឃុំសង្កាត់ផេកកម្ពុជាទំព័រ០៤

## ៦. ដំណើរការនៃការរៀបចំវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់សាធារណៈ(មុនពេលអំឡុងពេលក្រោយពេល)

### ៦.១មុនពេលរៀបចំវេទិកា

ដើម្បីឱ្យវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈប្រព្រឹត្តទៅបានដោយរលូន និងមានការចូលរួមដោយសកម្មពីប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកដែលពាក់ព័ន្ធផ្សេងទៀត ក្រុមប្រឹក្សា ក្រុង ស្រុក ឃុំ សង្កាត់ គួរពិចារណានូវជំហានសំខាន់ៗមួយចំនួន ដើម្បីប្រារព្ធវេទិកាប្រកបដោយជោគជ័យ និងមានប្រសិទ្ធភាព។

ដើម្បីឱ្យអង្គវេទិកាមួយប្រព្រឹត្តប្រកបដោយប្រសិទ្ធភាព ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ត្រូវកោះអញ្ជើញគណៈអភិបាល នាយករដ្ឋបាល ស្មៀន (សម្រាប់ក្រុងស្រុក) ដើម្បីចូលរួមកិច្ចប្រជុំរួមគ្នាក្នុងការរៀបចំវេទិកា ព្រមទាំងការកំណត់របៀបវារៈ និងប្រធានបទសម្រាប់ការប្រារព្ធវេទិកា។ ការកំណត់របៀបវារៈ និងប្រធានបទ ប្រធាន

ក្រុមប្រឹក្សា គួរពិចារណាថា តើបញ្ហាណាខ្លះដែលធ្វើឱ្យប្រជាពលរដ្ឋមានការព្រួយបារម្ភ ? ដូចជាៈស្ថានភាពសុខភាព ស្ថានភាពអប់រំការទទួលបានទឹកស្អាត ចំណូល ចំណាយ ។ល។ ក្រុមប្រឹក្សា អភិបាល និងនាយករដ្ឋបាល (ក្រុង ស្រុក) ស្មៀន ត្រូវឯកភាពគ្នាលើរបាយការណ៍ផ្សេងៗ អ្នកធ្វើបទបង្ហាញ កាលបរិច្ឆេទ ពេលវេលា ទីកន្លែង ។ល។ ប្រធានក្រុមប្រឹក្សាត្រូវពិចារណាលើពេលវេលា និងវិធីសាស្ត្រសម្របសម្រួលសម្រាប់រៀបចំវេទិកា តើត្រូវរៀបចំរយៈពេលកន្លះថ្ងៃ ឬ ពេញមួយថ្ងៃ។

**ក.បញ្ជីត្រួតពិនិត្យសកម្មភាពមុនដំណើរការវេទិកា**

ក្រុមប្រឹក្សាត្រូវរៀបចំបញ្ជីត្រួតពិនិត្យសកម្មភាពការងារឱ្យបានរួចរាល់មុននឹងដំណើរការវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ ដើម្បីធានាថាពេលដំណើរការវេទិកាសម្ភារឧបទ្ទេសមានគ្រប់គ្រាន់សម្រាប់គាំទ្រដំណើរការ ។

| **តារាងត្រួតពិនិត្យការរៀបចំវេទិកា** | | | |
|---|---|---|---|
| លរ | សកម្មភាព/សម្ភារ | បាទ | ទេ |
| ១ | របៀបវារៈ និងកម្មវិធីវេទិកា | | |
| ៣ | បទបញ្ជាផ្ទៃក្នុង | | |
| ៤ | ប្រអប់ទទួលសំណួរ | | |
| ៥ | ក្រដាសផ្ទាំងធំ ក្រដាសពណ៌ | | |
| ៦ | ក្តារខៀនសម្រាប់ពិភាក្សាក្រុម | | |
| ៧ | សុន្ទរកថាបើក | | |
| ៨ | សុន្ទរកថាបូកសរុបលទ្ធផល | | |
| ៩ | បដានៃវេទិកា | | |
| ១០ | ហ្វុងអក្សរនៃវេទិកា | | |
| ១១ | រោង តុ កៅអី មេក្រូ | | |
| ១២ | ផ្កាគណៈអធិបតី | | |
| ១៣ | អញ្ជើញអ្នកចូលរួម | | |
| ១៤ | វាគ្មិនដែលត្រូវចូលរួម | | |
| ១៥ | អញ្ជើញប្រព័ន្ធផ្សព្វផ្សាយ | | |
| ១៦ | អ្នកគ្រប់គ្រងអាហារសម្រន់ | | |

**ខ. ការបរៀបចំសេចក្តីព្រាងរបៀបវារៈ**

នាយករដ្ឋបាលស្មៀន គួររៀបចំសេចក្តីព្រាងរបៀបវារៈសម្រាប់វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ ផ្អែកទៅតាមអនុសាសន៍របស់ប្រធានក្រុមប្រឹក្សា និងអភិបាល។ នាយករដ្ឋបាល ត្រូវកំណត់អ្នកកាន់កម្មវិធី រយៈពេលសម្រាប់បទបង្ហាញនីមួយៗ និងរយៈពេលសម្រាប់ការពិភាក្សា។

**គម្រូរបៀបវារៈ វេទិកាពិគ្រោះយោបល់សាធារណៈរបស់ក្រុង ស្រុក ឃុំ សង្កាត់**

១. ប្រកាសហេតុ និងគោលបំណងនៃវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ
២. គោរពទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា
៣. បទបញ្ជាសម្រាប់វេទិកា
៤. មតិស្វាគមន៍របស់ប្រធានក្រុមប្រឹក្សា
៥. ការណែនាំខ្លួនរបស់សមាជិកក្រុមប្រឹក្សានីមួយៗ
៦. បទបង្ហាញតួនាទីនិងមុខងាររបស់ក្រុមប្រឹក្សានិងគណៈអភិបាលក្នុងពេលបច្ចុប្បន្នដោយប្រធានក្រុមប្រឹក្សា
៧. បទបញ្ជាសម្រាប់វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់
៨. ការធ្វើរបាយការណ៍ពីស្ថានភាពអភិវឌ្ឍរបស់ក្រុង ស្រុក ឃុំ សង្កាត់
៩. ស្ថានភាពចរិការរបស់ក្រុមប្រឹក្សាដោយប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ (ក្រុងស្រុក)
១០. សំណួរ និងចម្លើយ
១១. ចំណាប់អារម្មណ៍ និងសំណូមពររបស់អ្នកចូលរួម
១២. ការបិទវេទិកា ផ្សព្វផ្សាយ និងពិគ្រោះយោបល់ដោយប្រធានក្រុមប្រឹក្សា

**គ. ការកំណត់អ្នកចូលរួមៈ**

នាយករដ្ឋបាល ឬ ស្មៀន ជារៀបចំឈ្មោះដែលត្រូវអញ្ជើញចូលរួមក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈនៅថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់។

**មនុស្សសំខាន់ៗដែលត្រូវចូលរួមក្នុងវេទិកាសាធារណៈ**

- ក្រុមប្រឹក្សា ក្រុង ស្រុក ឃុំ សង្កាត់
- គណៈអភិបាល ក្រុង ស្រុក
- ក្រុមប្រឹក្សាឃុំសង្កាត់
- ប៉ូលីស ប៉េអឹម

- ការិយាល័យជំនាញទាំងអស់ដែលពាក់ព័ន្ធនឹងប្រធានបទ
- អង្គការសង្គមស៊ីវិល
- ប្រជាពលរដ្ឋ
- តំណាងក្រុមសាសនាផ្សេងៗ
- តំណាងគណៈកម្មការៈ (ឧ.មណ្ឌលសុខភាពតំណាងគណៈកម្មការមាតាបិតាសិស្សគ្រូបង្រៀន)
- វិស័យឯកជន
- តំណាងប្រព័ន្ធផ្សព្វផ្សាយក្នុងមូលដ្ឋាន (ទូរទស្សន៏ កាសែត ទស្សនាវដ្ដី ប្រតិប័ត្ត ។ល។)
- អ្នកពាក់ព័ន្ធផ្សេងទៀត (អាស្រ័យទៅតាមរបៀបវារៈ)

នាយករដ្ឋបាល ព្រាងលិខិតអញ្ជើញដោយមានបញ្ជាក់ពីកាលបរិច្ឆេទ និងទីកន្លែង**និង**ដាក់លិខិតអញ្ជើញ ជូនប្រធានក្រុមប្រឹក្សា ដើម្បីពិនិត្យនិងចុះហត្ថលេខា បន្ទាប់មកប្រធានក្រុមប្រឹក្សាពិនិត្យនិងចុះហត្ថលេខា លើលិខិតអញ្ជើញ ។ នាយករដ្ឋបាល ផ្ញើលិខិតអញ្ជើញដោយភ្ជាប់ជាមួយនឹងរបៀបវារៈ ទៅអ្នកចូលរួមនិងតំណាង ប្រព័ន្ធផ្សព្វផ្សាយ នៅក្នុងមូលដ្ឋាន ហើយនាយករដ្ឋបាលបិទផ្សាយរបៀបវារៈ និងលិខិតអញ្ជើញតាមរយៈក្ដារព័ត៌មាននានា។

**ឃ. ការកំណត់អ្នកសម្របសម្រួល វិធីសាស្ត្រ និងទីកន្លែង**

ប្រធានក្រុមប្រឹក្សាគឺជាអ្នកដឹកនាំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ ប៉ុន្តែដើម្បីផ្ដល់លទ្ធភាពឱ្យប្រធានក្រុមប្រឹក្សាផ្ដោតការយកចិត្តទុកដាក់លើបញ្ហាសំខាន់ៗ សមាជិកក្រុមប្រឹក្សាដទៃទៀត អាចចូលរួមជួយសម្របសម្រួលវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នេះបានផងដែរ។ ដំណើរការនៃការសម្របសម្រួលវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈនេះ ត្រូវធ្វើឡើងដោយភាពច្បាស់លាស់ និងមានលក្ខណៈសមស្របដែលមានលទ្ធភាពក្នុងការបង្កលក្ខណៈឱ្យមានការចូលរួមពីគ្រប់មជ្ឈដ្ឋានទាំងអស់ ពិសេសប្រជាពលរដ្ឋដែលចូលរួម។ ចំពោះវេទិកាថ្នាក់ក្រុង ស្រុក ត្រូវធ្វើឡើងនៅតាមឃុំ សង្កាត់របស់ខ្លួន និងឃុំ សង្កាត់ត្រូវធ្វើនៅតាមឃុំ សង្កាត់របស់ខ្លួន។

គណៈអភិបាលប្រជុំជាមួយប្រធានមន្ទីរការិយាល័យពាក់ព័ន្ធ ដើម្បីត្រៀមកត់ត្រាសំណួរមតិយោបល់និងឆ្លើយនូវសំណួរដែលពាក់ព័ន្ធនឹងជំនាញនៅក្នុងវេទិកាដែលនឹងរៀបចំឡើងនាពេលខាងមុខ។ នាយករដ្ឋបាលជាអ្នករៀបចំលើសម្ភារៈជំនួយដូចជាក្រដាសផ្ទាំងធំ។ ឧទាហរណ៍ៈរបៀបវារៈនិងថវិការបស់ក្រុមប្រឹក្សារបាយការណ៍ របស់គណៈអភិបាល និងបទបញ្ហាសម្រាប់វេទិកា។

ការជ្រើសរើសរកទីតាំងសម្រាប់ប្រារព្ធវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់ ត្រូវជ្រើសរើសរកទីតាំងដែលមានលក្ខណៈសមស្រប ហើយបង្កលក្ខណៈឱ្យគ្រប់អ្នកចូលរួម អាចចូលរួមបានដោយមានការបញ្ចេញមតិយោបល់បាន

គ្រប់ៗគ្នា។ ត្រូវធានាថាមានកន្លែងសមស្រប សម្រាប់ការពិភាក្សាក្រុមតូច។ ដើម្បីឱ្យមានអ្នកចូលរួមច្រើននិងមានឱកាសពិភាក្សាបានសកម្ម។ កន្លែងសមស្របមួយចំនួនទាំងនោះដូចជា (ឧ. សាលារៀន វត្តអារាម សាលាបុណ្យ សាលាឃុំ សង្កាត់ សួនសាធារណៈ ។ល។)

វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សាធារណៈ មិនត្រូវធ្វើក្នុងបរិវេណស្នាក់ការគណៈបក្សនយោបាយណាមួយឡើយ។

**៦.២ ក្នុងអំឡុងពេលប្រារព្ធវេទិកា:**

ដើម្បីឱ្យវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ប្រព្រឹត្តបានដោយរលូន អ្នកសម្របសម្រួលត្រូវយកចិត្តទុកដាក់ទៅលើបញ្ហាមួយចំនួនដូចជា:

- ទីកន្លែងអ្នកចូលរួមអង្គុយ
- ទីកន្លែងសម្រាប់គណៈអធិបតី
- បទបញ្ហាផ្ទៃក្នុងត្រូវដាក់ឱ្យងាយស្រួលដល់អ្នកចូលរួមមើលឃើញ
- ការដាក់ប្រអប់សំបុត្រសម្រាប់ការបញ្ចេញមតិយោបល់ ឬ សំណើផ្សេងៗ
- ការចងបដាផ្សេងៗត្រូវបែមុខឱ្យចំអ្នកអង្គុយ
- ក្បាលមេក្រូត្រូវរៀបចំមួយ ឬ ច្រើនសម្រាប់អ្នកចូលរួមបញ្ចេញមតិយោបល់

អ្នកសម្របសម្រួល ឬអ្នកកាន់កម្មវិធីត្រូវអនុវត្តទៅតាមរបៀបវារៈ ដែលបានកំណត់ជៀសវាងការធ្វើតាមការនឹកឃើញ (សូមមើលរបៀបវារៈគម្រូខាងលើ) អ្នកសម្របសម្រួលត្រូវប្រើប្រាស់វិធីសាស្ត្រណា ដែលសមស្របដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋ និងអ្នកដែលពាក់ព័ន្ធផ្សេងទៀត ហើយធានាថាពួកគាត់អាចមានលទ្ធភាពក្នុងការលើកឡើងពីភាពកង្វល់ និងតម្រូវការជាអទិភាពរបស់ខ្លួន ក្នុងអំឡុងពេលប្រារព្ធវេទិកាសាធារណៈ ជៀសវាងការមានការរំខានផ្សេងៗ ដែលធ្វើឱ្យអ្នកចូលរួមមិនហ៊ានក្នុងការបញ្ចេញមតិយោបល់។

**៦.៣. ក្រោយពេលវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់បញ្ចប់**

នាយករដ្ឋបាល ឬស្មៀនឃុំជាអ្នកដាក់ជូនសេចក្ដីសង្ខេបនៃវេទិកាទាំងមូល ជូនក្រុមប្រឹក្សាដើម្បីពិនិត្យនិងអនុម័ត។ គណៈអភិបាលក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ត្រូវធ្វើការបូកសរុបវាយតម្លៃអំពីលទ្ធផលនៃវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់រយៈពេលយ៉ាងយូរបំផុត១៥ថ្ងៃបន្ទាប់។ ក្នុងការបូកសរុបវាយតម្លៃនេះត្រូវលើកឡើងនូវគោលការណ៍ និងវិធានការដើម្បីលើកកម្ពស់ការឆ្លើយតប ទៅនិងតម្រូវការរបស់មូលដ្ឋានក្នុងក្របខ័ណ្ឌរដ្ឋបាលរបស់ខ្លួន។

ចំពោះកិច្ចការទាំងឡាយណាដែលពាក់ព័ន្ធ និងតួនាទីសមត្ថកិច្ចរបស់ក្រុមប្រឹក្សាប្រភេទផ្សេងទៀត ត្រូវពិគ្រោះពិភាក្សាជាមួយក្រុមប្រឹក្សាដែលពាក់ព័ន្ធទាំងនោះ ដើម្បីលើកឡើងពីគោលការណ៍ និងវិធានការក្នុងការដោះស្រាយតាមដែនសមត្ថកិច្ចរៀងៗខ្លួន។

ក្រុមប្រឹក្សានឹងធ្វើការសម្រេចអំពីចំណាត់ការបន្តបន្ទាប់ ចំពោះយោបល់ដែលបានលើកឡើងនៅក្នុងវេទិកា។ បន្ទាប់ពីមានការពិភាក្សាក្នុងក្រុមប្រឹក្សារួចហើយ មតិយោបល់ដែលមិនស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្រុមប្រឹក្សានឹងបញ្ជូនទៅកាន់ក្រសួង មន្ទីរ និងការិយាល័យពាក់ព័ន្ធ។

- ប្រធានក្រុមប្រឹក្សា ណែនាំឱ្យនាយករដ្ឋបាលធ្វើរបាយការណ៍ ទៅឱ្យគ្រប់អ្នកចូលរួមទាំងអស់នៅក្នុងវេទិកា ប្រធានក្រុមប្រឹក្សាធានាថារបាយការណ៍ចុងក្រោយនេះនឹងត្រូវផ្ញើទៅឱ្យសមាជិកទាំងអស់របស់ក្រុមប្រឹក្សា។
- អភិបាលរងដែលទទួលបន្ទុកព័ត៌មាននឹងធានាយ៉ាងណាឱ្យមានការសង្ខេបខ្លឹមសារសំខាន់ៗ ដើម្បីបិទផ្សាយលើក្តារព័ត៌មាន។
- អភិបាលរងដែលទទួលបន្ទុកព័ត៌មានត្រូវធានាឱ្យមានរបាយការណ៍ វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់ នៅការិយាល័យទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិរបស់សាលាខេត្ត ឬការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុរបស់សាលាក្រុង ស្រុក។
- អភិបាលរងទទួលបន្ទុកព័ត៌មានត្រូវធានាបែងចែករបាយការណ៍នេះ ដល់ប្រព័ន្ធផ្សព្វផ្សាយក្នុងមូលដ្ឋាន
- គណៈអភិបាលត្រូវធានាឱ្យមានការផ្ញើអនុសាសន៍របស់ក្រុមប្រឹក្សាទៅដល់មន្ទីរការិយាល័យពាក់ព័ន្ធ។

## ៧. សារៈសំខាន់នៃការចូលរួមរបស់អ្នកពាក់ព័ន្ធ

- យល់ដឹង មានទស្សនៈដូចគ្នា នឹងមានភាពជាម្ចាស់លើកិច្ចការទាំងឡាយ
- មានការឆ្លើយតបទៅនឹងតម្រូវការដែលលើកឡើងដោយសហគមន៍
- បានជួយដោះស្រាយបញ្ហាសហគមន៍
- បង្កើនទំនុកចិត្តនិងភាពជាដៃគូរវាងក្រុមប្រឹក្សា ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ
- ប្រជាពលរដ្ឋបានទទួលព័ត៌មានស្តីពីចំណូលចំណាយ និងការអភិវឌ្ឍរបស់ក្រុមប្រឹក្សា

<u>ឯកសារយោង:</u>

១. វេទិកាសាធារណៈឃុំសង្កាត់ផេកកម្ពុជា (ខែកញ្ញាឆ្នាំ២០១០)
២. សៀវភៅណែនាំសម្រាប់គ្រូស្តីពីគណៈភាពសង្គមតាមបែបប្រជាធិបតេយ្យអង្គការសីលការ (ខែមិនថុនាឆ្នាំ២០១០)
៣. អនុក្រិត២១៦មាត្រា១២១ស្តីពីការប្រារព្ធវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់ (ខែធ្នូឆ្នាំ២០០៩)
៤. អនុក្រិត២១៦មាត្រា១២១អ្នកដែលត្រូវចូលរួមក្នុងវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់ (ខែធ្នូឆ្នាំ២០០៩)

# ថ្ងៃទី២

# ម្លង់មេរៀនទី៥

# ចំណងជើងមេរៀនៈ លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចប្រជុំប្រចាំខែ

**ពេលវេលាៈ ០៤:១០ ដល់ ០៤:៥៥ (៤៥នាទី)**

**គោលបំណងនៃមេរៀនៈ** នៅចុងបញ្ចប់មេរៀននេះអ្នកចូលរួមអាចៈ

១. រៀបរាប់អំពី**<u>សារៈសំខាន់</u>**នៃកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្រុក ព្រមទាំងមូលហេតុនៃ**<u>ការចូលរួមរបស់ប្រជាពលរដ្ឋ</u>** ។

២. កំណត់ និងឯកភាពលើ**<u>វិធីសាស្ត្រ</u>** ក្នុងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និង ស្រុក។

៣. ឆ្លុះបញ្ចាំងពីដំណើរការរៀបចំ និងអនុវត្តកិច្ចប្រជុំកន្លងមក (ចំណុចល្អ និងចំណុចគួរកែលម្អ)

## កំណត់ចំណាំរបស់អ្នកសម្របសម្រួល

១. ក្រុមប្រឹក្សាឃុំ សង្កាត់បានរៀបចំ និងអនុវត្តកិច្ចប្រជុំច្រើន (ពីរអាណត្តិកន្លងមកហើយ) ដូច្នេះការងារនេះមិនមែនជាការងារថ្មីសម្រាប់គាត់ឡើយ ក៏ប៉ុន្តែជាការងារថ្មីសម្រាប់ក្រុមប្រឹក្សាក្រុង ស្រុក។

២. ការប្រឈមក្នុងការរៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ គឺមិនមាន ឬមិនសូវមានប្រជាពលរដ្ឋចូលរួម មួយវិញទៀតក្រុមប្រឹក្សាឃុំ សង្កាត់ មួយចំនួនមិនបានធ្វើការប្រជុំទៀងទាត់ឡើយ ។

៣. ប្រសិនបើមានពេលវេលាគ្រប់គ្រាន់ អ្នកសម្របសម្រួលគួរតែអនុវត្តសកម្មភាពទី៣បទពិសោធន៍កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ពិភាក្សាក្រុមតូច ដែលត្រូវការពេលវេលា ២០នាទី ។ លទ្ធផលក្រុមពិភាក្សាមានប្រយោជន៍សម្រាប់ជួយក្រុមប្រឹក្សាក្នុងការ កែលម្អការរៀបចំកិច្ចប្រជុំ និងជាជំនួយសម្រាប់អ្នកបង្ហាត់បង្ហាញ ។

## លទ្ធផលរំពឹងទុកនៃមេរៀន

អ្នកចូលរួម ៖

១. យល់អំពីសារៈសំខាន់នៃកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និង ស្រុក ព្រមទាំងមូលហេតុនៃការចូលរួមរបស់ប្រជាពលរដ្ឋ ។

២. ឯកភាពលើវិធីសាស្ត្រ ដើម្បីយកទៅអនុវត្តក្នុងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និង ស្រុក។

៣. មានឱកាសឆ្លុះបញ្ចាំងពីដំណើរការរៀបចំ និងអនុវត្តកិច្ចប្រជុំកន្លងមក (ចំណុចល្អ និងចំណុចគួរកែលម្អ)

## សម្ភារឧបទេ្ទសសម្រាប់បង្រៀន

- ឯកសារមេរៀន ស្តីពី លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចប្រជុំប្រចាំខែ
  - បទបង្ហាញ/ស្លាយ
  - ឯកសារចែក - លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចប្រជុំប្រចាំខែ
  - រូបភាពអប់រំ សេចក្តីណែនាំលេខ២៨៩ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩
- ហ្វឺតសរសេរក្រដាស ក្រដាសផ្ទាំងធំ ស្កុត
- កុំព្យូទ័រយួរដៃ និងម៉ាស៊ីនបញ្ចាំងឯកសារ/ស្លាយ

## ឯកសារយោង

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មាត្រា២១ (ទំព័រ១១៤) និង មាត្រា២១៣ (ទំព័រ១១៥)
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ **មាត្រា ៣១** (ទំព័រ៨)
- សេចក្តីណែនាំលេខ២៨៩ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩

## របៀបសម្របសម្រួលមេរៀន

| ម៉ោង | <u>សកម្មភាព និងវិធីសាស្ត្រ</u> | សម្ភារ និងឯកសារចែកជូន |
|---|---|---|
| ៥នាទី | **<u>សកម្មភាពទី១ :</u> សេចក្តីផ្តើម គោលបំណង និងការរំពឹងទុកនៃមេរៀន**<br>**<u>បទបង្ហាញ</u>**<br>• កិច្ចប្រជុំប្រចាំខែ គឺជាមធ្យោបាយមួយក្នុងការគាំទ្រដល់ដំណើរការអនុវត្តអភិបាលកិច្ចល្អ។ កិច្ចប្រជុំប្រចាំខែ បង្កើតឡើងដើម្បីផ្តល់ឱកាសសម្រាប់ការចូលរួមពីប្រជាពលរដ្ឋ និងតួអង្គពាក់ព័ន្ធនានាក្នុងការតាមដាន និងផ្តល់ព័ត៌មានត្រឡប់ទៅលើការអនុវត្តតួនាទី ភារៈកិច្ច និងមុខងាររបស់រដ្ឋបាលមូលដ្ឋាន ។ ដូច្នេះ មេរៀននេះនឹងពិភាក្សាពីៈ<br>១. តើហេតុអ្វីបានជាក្រុមប្រឹក្សាត្រូវរៀបចំកិច្ចប្រជុំប្រចាំខែ?<br>២. តើហេតុអ្វីត្រូវមានប្រជាពលរដ្ឋចូលរួមកិច្ចប្រជុំប្រចាំខែរបស់ | 💻 ស្លាយទី២-៣ |

| | | |
|---|---|---|
| | ក្រុមប្រឹក្សា?<br>៣. តើក្រុមប្រឹក្សាមានបញ្ហាប្រឈមអ្វីខ្លះក្នុងការរៀបចំ និងដំណើរការកិច្ចប្រជុំ ពិសេសការចូលរួមរបស់ប្រជាពលរដ្ឋ?<br>៤. តើក្រុមប្រឹក្សាមានវិធីសាស្ត្រអ្វីខ្លះក្នុងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា<br>• បង្ហាញគោលបំណងនៃមេរៀន និងលទ្ធផលរំពឹងទុក | |
| ១៥នាទី | **<u>សកម្មភាពទី២ :</u> សារៈសំខាន់នៃកិច្ចប្រជុំប្រចាំខែ និងការចូលរួមរបស់ប្រជាពលរដ្ឋ**<br>**<u>ការបំផុសគំនិត និងពិភាក្សាក្រុមធំ</u>**<br>- អ្នកសម្របសម្រួល សួរអ្នកចូលរួមចំនួន៣នាក់<br>១. តើក្រុមប្រឹក្សាបានទទួលផលប្រយោជន៍អ្វីខ្លះ ក្នុងការរៀបចំកិច្ចប្រជុំប្រចាំខែ? ស្លាយទី៤ដល់៩<br>២. តើប្រជាពលរដ្ឋបានទទួលផលអ្វីខ្លះ ក្នុងការចូលរួមកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្រុក? ស្លាយទី១០<br>- កត់ត្រាចម្លើយអ្នកចូលរួម នៅលើក្រដាសផ្ទាំងធំ រួចបិទលើជញ្ជាំង<br>- បង្ហាញស្លាយទី៤-១០ ដោយមានការសួរបញ្ជាក់ពីអ្នកចូលរួម | 💻 ស្លាយទី៤-១០<br>📄 ក្រដាសផ្ទាំងធំ កត់ត្រាចម្លើយ |
| ២០នាទី | **<u>សកម្មភាពទី៣ :</u> វិធីសាស្ត្រលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចប្រជុំប្រចាំខែ**<br>**ពិភាក្សាក្រុមតូច**<br>- ចែកជា ៤ក្រុមតូច ដើម្បីពិភាក្សាលើសំណួរ**<u>តើក្រុមប្រឹក្សាមានវិធីសាស្ត្រអ្វីខ្លះ ដើម្បីឱ្យប្រជាពលរដ្ឋចូលរួមក្នុងកិច្ចប្រជុំប្រចាំខែ?</u>** (មានពេល ១០នាទី)<br>- ក្រុមនីមួយៗ ជ្រើសយកចម្លើយចំនួន២ ដើម្បីប្រាប់ក្រុមធំ (តំណាងក្រុមពិភាក្សា)<br>- អ្នកសម្របសម្រួលកត់ត្រាចម្លើយលើក្រដាស់ផ្ទាំងធំ ហើយបិទលើជញ្ជាំង<br>- បង្ហាញស្លាយទី១១-១៦ | 💻 ស្លាយទី១១-១៦<br>📄 ក្រដាសផ្ទាំងធំ កត់ត្រាចម្លើយ |

| | | |
|---|---|---|
| | <u>**សកម្មភាពទី៤ :**</u> **បទពិសោធន៍កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ពិភាក្សាក្រុមធំ**<br>▪ អ្នកសម្របសម្រួលអញ្ជើញក្រុមប្រឹក្សា២ ឬ ៣នាក់ដើម្បីចែករំលែកបទពិសោធន៍<br>○ តើក្រុមប្រឹក្សាឃុំ សង្កាត់មានបញ្ហាប្រឈម និងជោគជ័យអ្វីខ្លះក្នុងការរៀបចំ និងអនុវត្តកិច្ចប្រជុំប្រចាំខែ? (ស្លាយ១៧)<br>▪ អ្នកសម្របសម្រួលកត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ និងបូកសរុប | 💻 ស្លាយទី១៧<br>🗐 ក្រដាសផ្ទាំងធំ កត់ត្រាចម្លើយ |
| ៥ នាទី | <u>**សកម្មភាពទី៥ :**</u> **បូកសរុបបញ្ចប់មេរៀន**<br>យើងបានពិភាក្សាពីៈ<br>• សារៈប្រយោជន៍នៃកិច្ចប្រជុំប្រចាំខែ និងការចូលរួមរបស់ប្រជាពលរដ្ឋ<br>• វិធីសាស្ត្រអ្វីខ្លះក្នុងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា | |

# ថ្ងៃទី២
# មេរៀនទី៥: លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចប្រជុំប្រចាំខែ

សហការការិយាល័យសម្របសម្រួលគម្រោងDFGG ក្រសួងមហាផ្ទៃ អង្គការផេក កម្ពុជា

# គោលបំណងនៃមេរៀន

១. រៀបរាប់អំពីសារៈសំខាន់នៃកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្រុក ព្រមទាំងមូលហេតុនៃការចូលរួមរបស់ប្រជាពលរដ្ឋ ។

២. កំណត់ និងឯកភាពលើវិធីសាស្រ្ត ក្នុងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និង ស្រុក។

៣. ឆ្លុះបញ្ចាំងពីដំណើរការរៀបចំ និងអនុវត្តកិច្ចប្រជុំកន្លងមក (ចំណុចល្អ និងចំណុចគួរកែលម្អ)

# លទ្ធផលរំពឹងទុកនៃមេរៀន

១. យល់អំពីអត្ថន័យ និងសារៈសំខាន់នៃកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុង ស្រុក ព្រមទាំងមូលហេតុនៃការចូលរួមរបស់ប្រជាពលរដ្ឋ ។

២. ឯកភាពលើវិធីសាស្ត្រ ដើម្បីយកទៅអនុវត្តក្នុងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និង ក្រុង ស្រុក។

៣. មានឱកាសឆ្លុះបញ្ចាំងពីដំណើរការរៀបចំ និងអនុវត្តកិច្ចប្រជុំកន្លងមក (ចំណុចល្អ និងចំណុចគួរកែលម្អ)

# មូលហេតុដែលក្រុមប្រឹក្សាត្រូវរៀបចំកិច្ចប្រជុំប្រចាំខែ

រាជរដ្ឋាភិបាលមើលឃើញថា ការចូលរួមរបស់ប្រជាពលរដ្ឋ គឺកត្តាដ៏សំខាន់ ដោយហេតុនេះហើយទើបរាជរដ្ឋាភិបានដាក់ចេញនូវយុទ្ធសាស្ត្រ គោលការណ៍ និងបង្កើតច្បាប់នានា ដើម្បីធានា និងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ដូចមានសេចក្ដីដកស្រង់ដូចខាងក្រោម៖

# សារៈសំខាន់នៃការចូលរួមកិច្ចប្រជុំប្រចាំខែ

រៀបចំឡើងដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការផ្តល់ព័ត៌មានត្រឡប់ជូនក្រុមប្រឹក្សា ហើយក៏ជាធាតុមួយដ៏សំខាន់ក្នុង ចំណោមធាតុសំខាន់ទាំង៤ (តម្លាភាព គណនេយ្យភាព ការឆ្លើយតប និងការចូលរួម)ដើម្បីលើកកម្ពស់អភិបាលកិច្ច និងគណនេយ្យភាពសង្គម

## ❑ មាត្រាសំខាន់ៗនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ :

- **មាត្រា ២១** (ទំព័រ១១៨) **:** ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើកិច្ចប្រជុំយ៉ាងតិចណាស់ចំនួនមួយដងក្នុងមួយខែ ។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវប្រជុំក្នុងសាលាឃុំ ឬសាលាសង្កាត់របស់ខ្លួន ឬក្នុងករណីចាំបាច់អធិបតីនៃអង្គប្រជុំអាចជ្រើសយកទីកន្លែងណាមួយក្នុងឃុំ សង្កាត់ របស់ខ្លួនដើម្បីប្រជុំ ។
- **មាត្រា ២៣** (ទំព័រ១១៩) **:** កិច្ចប្រជុំក្រុមប្រឹក្សាសង្កាត់ត្រូវធ្វើជាសាធារណៈនិងមានលក្ខណៈប្រជាធិបតេយ្យ ។ ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រជុំជាសម្ងាត់បាន ។

## ❒ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ :

- **មាត្រា ៣១** (ទំព័រ៨) : ក្រុមប្រឹក្សា ត្រូវបំពេញមុខងារ និងភារកិច្ច ដោយធ្វើសេចក្តីសម្រេចនៅក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្តីសម្រេចនោះត្រូវបានអនុវត្ត ។



“យើងចង់ឱ្យប្រជាពលរដ្ឋគ្រប់រូបចូលរួមក្នុងការអភិវឌ្ឍមូលដ្ឋាន។ យើងចង់លើកកម្ពស់ការគ្រប់គ្រង និងការផ្តល់សេវាប្រកបដោយគុណភាព ដើម្បីឆ្លើយតបតម្រូវការរបស់មូលដ្ឋាន និងឆ្ពោះទៅរកការកាត់បន្ថយភាពក្រីក្រ”

*(សុន្ទរកថារបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ២៨/០១/២០០៩)*

# អត្ថប្រយោជន៍ដែលក្រុមប្រឹក្សាទទួលបាន

**អត្ថប្រយោជន៍ក្រុមប្រឹក្សាទទួលបាន**

- កសាងភាពជឿជាក់ និងភាពជាដៃគូជាមួយប្រជាពលរដ្ឋ
- មានទំនាក់ទំនងល្អ ជាមួយប្រជាពលរដ្ឋ
- ជួយដោះស្រាយបញ្ហា និងក្ដីកង្វល់
- ជាឱកាសឆ្លើយតបសំណូររបស់ប្រជាពលរដ្ឋ
- ស្វែងយល់ពីបញ្ហា ក្ដីកង្វល់ និងតម្រូវការជាអាទិភាព
- ផ្សព្វផ្សាយព័ត៌មាន និងសេចក្ដីសម្រេចចិត្ត

# លើកកម្ពស់តម្លាភាព និងគណនេយ្យភាព

# អត្ថប្រយោជន៍ដែលប្រជាពលរដ្ឋនឹងទទួលបាន

ដឹងព័ត៌មានថ្មីៗ

បានកែលម្អគ្នា
ទៅវិញទៅមក

បង្ការជម្លោះ
ក្នុងសហគមន៍

អត្ថប្រយោជន៍
ប្រជាពលរដ្ឋ
ទទួលបាន

ចូលរួមក្នុងការ
រៀបចំផែនការ
និងថវិកា

ជាឱកាសលើក
និងដោះស្រាយ
បញ្ហា

ចូលរួមផ្ដល់
យោបល់ក្នុងការ
សម្រេចចិត្ត

ចែកជា ៤ក្រុមតូច

**តើក្រុមប្រឹក្សាមានវិធីសាស្ត្រអ្វីខ្លះ ដើម្បីឱ្យប្រជាពលរដ្ឋចូលរួមក្នុងកិច្ចប្រជុំប្រចាំខែ?**

(មានពេល ១0នាទី)

# វិធីសាស្ត្រលើកទឹកចិត្តប្រជាពលរដ្ឋចូលរួមក្នុងកិច្ចប្រជុំប្រចាំខែ

មុនពេលប្រជុំ

អំឡុងពេល ប្រជុំ

ក្រោយពេលប្រជុំ

## មុនពេលប្រជុំ

- ✓ កំណត់របៀបវារៈ ពេលវេលា និងទីកន្លែង
- ✓ ទទួលរបៀបវារៈពីប្រជាពលរដ្ឋ ឬតំណាងសហគម
- ✓ រៀបចំលិខិតអញ្ជើញអ្នកពាក់ព័ន្ធសំខាន់ៗ
- ✓ ផ្សព្វផ្សាយជាសាធារណៈនូវរបៀបវារៈ ទីកន្លែង ពេលវេលានៃកិច្ចប្រជុំប្រចាំខែ ឱ្យបានទូលំទូលាយដើម្បីឱ្យប្រជាពលរដ្ឋបានចូលរួម តាមមធ្យោបាយដូចខាងក្រោម៖

# មធ្យោបាយផ្សព្វផ្សាយ

- ✓ ចុះសួរសុខទុក្ខ និងពិគ្រោះយោបល់ជាក្រុមតូចតាមផ្ទះ
- ✓ ចុះផ្សព្វផ្សាយតាមភូមិមានលក្ខណៈក្រុមធំ និងកិច្ចប្រជុំពិគ្រោះយោបល់
- ✓ តាមរយៈវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់
- ✓ តាមពិធីបុណ្យផ្សេងៗ
- ✓ តាមរយៈមេភូមិ
- ✓ តាមរយៈគណៈកម្មការកៀរគរសហគមន៍
- ✓ តាមរយៈក្តារព័ត៌មានតាមភូមិ ឃុំ សង្កាត់ និងស្រុក ។ល។

# អំឡុងពេលប្រជុំ

- ✓ ក្រុមប្រឹក្សាអនុវត្តតាមបទបញ្ជាផ្ទៃក្នុងនៃកិច្ចប្រជុំ
- ✓ មានរបៀបវារៈ និងចាត់ចែងពេលវេលាឱ្យប្រជាពលរដ្ឋចូលរួមយោបល់
- ✓ ពិភាក្សាលើបញ្ហា ក្តីកង្វល់ តម្រូវការជាអាទិភាព ដំណោះស្រាយ
- ✓ ផ្តល់ឱកាសឱ្យតំណាងប្រជាពលរដ្ឋមានសំណួរ ឬផ្តល់មតិត្រឡប់

**ក្រោយពេលប្រជុំ**

- ✓ ផ្សព្វផ្សាយអំពីលទ្ធផល និងសេចក្តីសម្រេចរបស់កិច្ចប្រជុំប្រចាំខែជាសាធារណៈ
- ✓ អនុវត្ត និងតាមដានសេចក្តីសម្រេច
- ✓ ផ្តល់ព័ត៌មានត្រឡប់ពីការអនុវត្តសេចក្តីសម្រេចជាសាធារណៈ

## ការចែករំលែកបទពិសោធពីក្រុមប្រឹក្សា

**តើក្រុមប្រឹក្សាឃុំ សង្កាត់ មានបញ្ហា ប្រឈម និងជោគជ័យអ្វីខ្លះក្នុងការរៀបចំ និងអនុវត្តកិច្ចប្រជុំប្រចាំខែ?**

(មានពេល ១០នាទី)

**បទពិសោធន៏កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់**

# ថ្ងៃទី២

# ឯកសារចែក

# មេរៀនទី៥: លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចប្រជុំប្រចាំខែ

## ១. សេចក្ដីផ្ដើម:

ការប្រជុំប្រចាំខែ គឺជាមធ្យោបាយមួយក្នុងការគាំទ្រដល់ដំណើរការអនុវត្តអភិបាលកិច្ចល្អ។ ការប្រជុំប្រចាំខែ បង្កើតអាចផ្តល់ឱកាសសម្រាប់ការចូលរួមពីសំណាក់ប្រជាពលរដ្ឋ និងតួអង្គពាក់ព័ន្ធនានាក្នុងការតាមដាន និងផ្តល់ព័ត៌មានត្រឡប់ទៅលើការអនុវត្តតួនាទី ភារៈកិច្ច និងមុខងាររបស់រដ្ឋបាលមូលដ្ឋាន ។ កិច្ចប្រជុំប្រចាំខែមានសារៈសំខាន់ជាសារវន្ត និងផ្តល់ផលប្រយោជន៍យ៉ាងច្រើន ហើយបានបង្កើននូវទំនុកចិត្ត និងប្រសិទ្ធភាពនៃការសម្រេចចិត្ត ក៏ដូចជាការធ្វើឱ្យកាន់តែប្រសើរឡើងនូវគុណភាពនៃការផ្តល់សេវាសាធារណៈ និងកិច្ចអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន។

## ២. គោលបំណង និងលទ្ធផលរំពឹងទុកនៃមេរៀន:

### គោលបំណង

មេរៀននេះ រៀបចំឡើង ក្នុងគោលបំណងឱ្យអ្នកចូលរួមអាចៈ

- រៀបរាប់អំពីសារៈសំខាន់នៃកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្រុក ព្រមទាំងមូលហេតុនៃការចូលរួមរបស់ប្រជាពលរដ្ឋ ។
- កំណត់ និងឯកភាពលើវិធីសាស្ត្រ ក្នុងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និង ស្រុក ក្រុង។
- ឆ្លុះបញ្ចាំងពីដំណើរការរៀបចំ និងអនុវត្តកិច្ចប្រជុំកន្លងមក (ចំណុចល្អ និងចំណុចគួរកែលម្អ)

### លទ្ធផលរំពឹងទុក

អ្នកចូលរួម ៖

- យល់អំពីអត្ថន័យ និងសារៈសំខាន់នៃកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុង ស្រុក ព្រមទាំងមូលហេតុនៃការចូលរួមរបស់ប្រជាពលរដ្ឋ ។
- ឯកភាពលើវិធីសាស្ត្រ ដើម្បីយកទៅអនុវត្តក្នុងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និង ក្រុង ស្រុក។
- មានឱកាសឆ្លុះបញ្ចាំងពីដំណើរការរៀបចំ និងអនុវត្តកិច្ចប្រជុំកន្លងមក (ចំណុចល្អ និងចំណុចគួរកែលម្អ)

## ៣. មូលហេតុដែលក្រុមប្រឹក្សាត្រូវរៀបចំកិច្ចប្រជុំប្រចាំខែ

រាជរដ្ឋាភិបាលមើលឃើញថា ការចូលរួមរបស់ប្រជាពលរដ្ឋ គឺកត្តាដ៏សំខាន់ ដោយហេតុនេះហើយទើបរាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រ គោលការណ៍ និងបង្កើតច្បាប់នានា ដើម្បីធានា និងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ដូចមានសេចក្តីដកស្រង់ដូចខាងក្រោម៖

**មាត្រាសំខាន់ៗនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់** :

- **មាត្រា ២១** (ទំព័រ១១៤) **:** ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើកិច្ចប្រជុំយ៉ាងតិចណាស់ចំនួនមួយដងក្នុងមួយខែ ។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវប្រជុំក្នុងសាលាឃុំ ឬសាលាសង្កាត់របស់ខ្លួន ឬក្នុងករណីចាំបាច់អធិបតីនៃអង្គប្រជុំអាចជ្រើសយកទីកន្លែងណាមួយក្នុងឃុំ សង្កាត់ របស់ខ្លួនដើម្បីប្រជុំ ។
- **មាត្រា ២៣** (ទំព័រ១១៥) **:** កិច្ចប្រជុំក្រុមប្រឹក្សាសង្កាត់ ត្រូវធ្វើជាសាធារណៈនិងមានលក្ខណៈប្រជាធិបតេយ្យ ។ ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រជុំជាសម្ងាត់បាន ។

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**:



- **មាត្រា ២៩** (ទំព័រ៧) **:** ក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើត ការជម្រុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារភារកិច្ចដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្មតាមច្បាប់នេះ ឬដែលស្របតាមច្បាប់នេះ ។
- **មាត្រា ៣១** (ទំព័រ៨)**:** ក្រុមប្រឹក្សា ត្រូវបំពេញមុខងារ និងភារកិច្ច ដោយធ្វើសេចក្តីសម្រេចនៅក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្តីសម្រេចនោះត្រូវបានអនុវត្ត ។
- **មាត្រា៣៤** (ទំព័រ៨)**:** ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់អំពីជម្រើសអាទិភាព ដើម្បីធ្វើសេចក្តីសម្រេច ធានាបានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ ក្រុមប្រឹក្សាអាចធ្វើការសង្កេតលើករណីទាំងឡាយណា ដែលយល់ឃើញថាមានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង ព្រមទាំងអាចផ្សព្វផ្សាយលទ្ធផលនៃការធ្វើសង្កេតនោះ រួចហើយត្រូវផ្តល់គោលការណ៍ណែនាំអនុវត្តដល់គណៈអភិបាល ។

### សុន្ទរកថារបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ២៨/០៧/២០០៩

> **“យើងចង់ឱ្យប្រជាពលរដ្ឋគ្រប់រូបចូលរួមក្នុងការអភិវឌ្ឍមូលដ្ឋាន។ យើងចង់លើកកម្ពស់ការគ្រប់គ្រង និងការផ្តល់សេវាប្រកបដោយគុណភាព ដើម្បីឆ្លើយតបតម្រូវការរបស់មូលដ្ឋាន និងឆ្ពោះទៅរកការកាត់បន្ថយភាពក្រីក្រ”**

### អត្ថប្រយោជន៍ដែលក្រុមប្រឹក្សាទទួលបានក្នុងការអនុញ្ញាតិអោយប្រជាពលរដ្ឋចូលក្នុងកិច្ចប្រចាំខែ

ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចប្រជុំប្រចាំខែ នឹងផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់ក្រុមប្រឹក្សាដូចមានរៀបរាប់ក្នុងរូបភាពខាងក្រោម៖




## ៤. សារៈសំខាន់នៃការចូលរួមកិច្ចប្រជុំប្រចាំខែ

រៀបចំឡើងដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការផ្តល់ព័ត៌មានត្រឡប់ជូនក្រុមប្រឹក្សា ហើយក៏ជាធាតុមួយដ៏សំខាន់ក្នុង ចំណោមធាតុសំខាន់ទាំង៤ (តម្លាភាព គណនេយ្យភាព ការឆ្លើយតប និងការចូលរួម)ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គម។

## អត្ថប្រយោជន៍ដែលប្រជាពលរដ្ឋនឹងទទួលបានពីការចូលរួមក្នុងកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា

**អត្ថប្រយោជន៍ដែលប្រជាពលរដ្ឋនឹងទទួលបាន**




## ៥. វិធីសាស្ត្រលើកទឹកចិត្តប្រជាពលរដ្ឋចូលរួមក្នុងកិច្ចប្រជុំប្រចាំខែ

ខាងក្រោមនេះជា វិធីសាស្ត្រក្នុងការជួយបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា៖




### មុនពេលប្រជុំ

- កំណត់របៀបវារៈ ពេលវេលា និងទីកន្លែង
- ទទួលរបៀបវារៈពីប្រជាពលរដ្ឋ ឬតំណាងសហគម
- រៀបចំលិខិតអញ្ជើញអ្នកពាក់ព័ន្ធសំខាន់ៗ
- ផ្សព្វផ្សាយជាសារធារណៈនូវរបៀបវារៈ ទីកន្លែង ពេលវេលានៃកិច្ចប្រជុំប្រចាំខែ ឱ្យបានទូលំទូលាយ ដើម្បីឱ្យប្រជាពលរដ្ឋបានចូលរួម តាមមធ្យោបាយដូចខាងក្រោម៖

**មធ្យោបាយផ្សព្វផ្សាយ**

- ចុះសួរសុខទុក្ខ និងពិគ្រោះយោបល់ជាក្រុមតូចតាមផ្ទះ
- ចុះផ្សព្វផ្សាយតាមភូមិមានលក្ខណៈក្រុមធំ និងកិច្ចប្រជុំពិគ្រោះយោបល់
- តាមរយៈវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់
- តាមពិធីបុណ្យផ្សេងៗ
- តាមរយៈមេភូមិ
- តាមរយៈគណៈកម្មការកៀរគរសហគមន៍
- តាមរយៈក្តារព័ត៌មានតាមភូមិ ឃុំ សង្កាត់ និងស្រុក ។ល ។

**អំឡុងពេលប្រជុំ**

- ក្រុមប្រឹក្សាអនុវត្តតាមបទបញ្ជាផ្ទៃក្នុងនៃកិច្ចប្រជុំ
- មានរបៀបវារៈ និងចាត់ចែងពេលវេលាឱ្យប្រជាពលរដ្ឋចូលរួមយោបល់
- ពិភាក្សាលើបញ្ហា ក្តីកង្វល់ តម្រូវការជាអាទិភាព ដំណោះស្រាយ
- ផ្តល់ឱកាសឱ្យតំណាងប្រជាពលរដ្ឋមានសំណួរ ឬផ្តល់មតិត្រឡប់

**ក្រោយពេលប្រជុំ**

- ផ្សព្វផ្សាយអំពីលទ្ធផល និងសេចក្តីសម្រេចរបស់កិច្ចប្រជុំប្រចាំខែជាសាធារណៈ
- អនុវត្ត និងតាមដានសេចក្តីសម្រេច
- ផ្តល់ព័ត៌មានត្រឡប់ពីការអនុវត្តសេចក្តីសម្រេចជាសាធារណៈ

## ៦. សេចក្តីសន្និដ្ឋាន

ការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុង ស្រុក អាចបំពេញតួនាទីខ្លួនបានល្អ និងប្រកបដោយជោគជ័យ លុះណាមានប្រជាពលរដ្ឋបានចូលរួមផ្តល់ព័ត៌មានត្រឡប់តាមរយៈការប្រជុំប្រចាំខែឱ្យបានទូលំទូលាយ ព្រោះការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាកម្លាំងចលករដ៏សំខាន់ក្នុងការធ្វើឱ្យសម្រេចនូវគោលដៅរួម ។

**សកម្មភាពអភិវឌ្ឍមូលដ្ឋាន ការរួមចំណែកកាត់បន្ថយភាពក្រីក្រ មិនអាចទទួលបានជោគជ័យឡើយ**

**ប្រសិនបើគ្មានការចូលរួមរបស់ប្រជាពលរដ្ឋ !!!**

**---- ចប់ ----**

# ថ្ងៃទី៣

# ថ្ងៃទី៣

# ប្លង់មេរៀនទី១

# ចំណងជើងមេរៀន: ជំនាញទំនាក់ទំនង

**ពេលវេលា:** ០៨:១០ ដល់ ០៩:១០ (៦០នាទី)

**គោលបំណងនៃមេរៀន:** នៅចុងបញ្ចប់មេរៀននេះអ្នកចូលរួមអាចៈ

១. រៀបរាប់បានអំពីអត្ថន័យនៃជំនាញទំនាក់ទំនង

២. ពិពណ៌នាអំពីសារៈសំខាន់នៃជំនាញទំនាក់ទំនង

៣. ឆ្លុះបញ្ចាំងអំពីបទពិសោធន៍នៃជំនាញទំនាក់ទំនងរវាងក្រុមប្រឹក្សានិងក្រុមប្រឹក្សា និងក្រុមប្រឹក្សាជាមួយប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធ

៤. កំណត់បាន និងឯកភាពលើវិធីសាស្ត្រនៃការទំនាក់ទំនង ដើម្បីយកទៅអនុវត្ត។

## កំណត់ចំណាំរបស់អ្នកសម្របសម្រួល

១. បំផុសគំនិត និងពិភាក្សាក្រុមធំ **ដោយឆ្លុះបញ្ចាំង**អំពីគោលបំណង និងលទ្ធផលរំពឹងទុកនៃមេរៀន

២. បំផុសគំនិតតាមរយៈការសួរសំណួរ និងពិភាក្សាក្រុមធំ ដើម្បីជួយឱ្យអ្នកចូលរួមបានយល់ដឹងៈ

- តើការទំនាក់ទំនងមានន័យដូចម្តេច?
- តើការទំនាក់ទំនងជួយអ្វីខ្លះដល់ក្រុមប្រឹក្សាក្នុងការបំពេញការងារ?

## លទ្ធផលរំពឹងទុកនៃមេរៀន

អ្នកចូលរួមៈ

១. យល់ និងរៀបរាប់បានអំពីអត្ថន័យនៃជំនាញទំនាក់ទំនង

២. ពិពណ៌នាបានអំពីសារសំខាន់នៃជំនាញទំនាក់ទំនង

៣. បានរៀនសូត្រ និងដឹងពីចំណុចល្អ និងចំណុចគួរកែលម្អអំពីបទពិសោធន៍នៃជំនាញទំនាក់ទំនងរវាងក្រុមប្រឹក្សានិងក្រុមប្រឹក្សា និងក្រុមប្រឹក្សាជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ (ប្រព័ន្ធផ្សព្វផ្សាយ អង្គការសហគមន៍មូលដ្ឋាន)

៤. កំណត់បាន និងឯកភាពលើវិធីសាស្ត្រនៃជំនាញទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមប្រឹក្សាស្រុក

ហើយក្រុមប្រឹក្សាឃុំ សង្កាត់ ជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ (ប្រព័ន្ធផ្សព្វផ្សាយ អង្គការសហគមន៍មូលដ្ឋាន)

## សម្ភារឧបទ្ទេសសម្រាប់បង្រៀន:

- ឯកសារមេរៀន ស្តីពីជំនាញទំនាក់ទំនង
  - បទបង្ហាញស្លាយ
  - ឯកសារចែក
- ហ្វឺតសរសេរក្រដាស ក្រដាសផ្ទាំងធំ ស្កុត
- កុំព្យូទ័រយួរដៃ និងម៉ាស៊ីនបញ្ចាំងឯកសារស្លាយ

## ឯកសារយោង:

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (មាត្រា៩១ និង៩២ - ទំព័រ១៦)
- ឯកសារបណ្តុះបណ្តាលសម្រាប់គ្រូ និងសិក្ខាកាម ស្តីពី**ការ**លើកកម្ពស់ការយល់ដឹង និងភ្ជាប់ទំនាក់ទំនងសង្គមស៊ីវិលជាមួយកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (ទំព័រ២៤០)

## របៀបសម្របសម្រួលមេរៀន:

| ម៉ោង | សកម្មភាព និងវិធីសាស្ត្រ | សម្ភារ និងឯកសារចែកជូន |
|---|---|---|
| **៥** នាទី | <u>សកម្មភាពទី១</u> : សេចក្តីផ្តើម<br>អនុញ្ញាតិឱ្យអ្នកចូលរួមដឹកនាំលេងល្បែងបង្កើនថាមពល | ស្លាយ**ទី ២** |
| ៥នាទី | <u>សកម្មភាពទី២</u> : គោលបំណង និងលទ្ធផលរំពឹងទុកនៃមេរៀន<br>សំណួរបំផុសគំនិត និងពិភាក្សាក្រុមធំ<br>- បង្ហាញស្លាយទី**៣** ឆ្លុះបញ្ចាំងអំពីគោលបំណងមេរៀន<br>- សួរសំណួរអ្នកចូលរួមចំនួន ២នាក់ (ដោយសារពេលវេលាតិច) អំពីការរំពឹងទុក ហើយកត់ត្រាចម្លើយអ្នកចូលរួម នៅលើក្រដាសផ្ទាំងធំ រួចបិទលើជញ្ជាំងម្ខាងសម្រាប់ផ្ទៀងផ្ទាត់នៅពេលបញ្ចប់មេរៀន | 💻 ស្លាយ**ទី៣**<br>📄 ក្រដាសផ្ទាំងធំ<br>✎ ហ្វឺតកត់ត្រាចម្លើយ និងបង់ស្អិត |

| | | |
|---|---|---|
| | - បង្ហាញស្លាយដែលត្រៀមទុក អំពី**លទ្ធផល**រំពឹងទុក | |
| ៥នាទី | <u>សកម្មភាពទី៣ :</u> និយមន័យនៃជំនាញទំនាក់ទំនង<br>សំណួរបំផុសគំនិត និងពិភាក្សាក្រុមធំ<br>- អ្នកសម្របសម្រួលសួរថា តើជំនាញទំនាក់ទំនងមានន័យដូចម្តេច?<br>- កត់ត្រាចម្លើយអ្នកចូលរួម នៅលើក្រដាសផ្ទាំងធំ រួចបិទលើជញ្ជាំង<br>- បង្ហាញស្លាយ**ទី៤** ហើយធ្វើការពន្យល់បន្ថែម | 💻 ស្លាយ**ទី៤**<br>📄 ក្រដាសផ្ទាំងធំ<br>🖊 ហ្វឺតកត់ត្រាចម្លើយ និងបង់ស្ទិត |
| ៥នាទី | <u>សកម្មភាពទី៤:</u> សារៈសំខាន់នៃជំនាញទំនាក់ទំនង<br>សំណួរបំផុសគំនិត និងពិភាក្សាក្រុមធំ<br>- តើជំនាញទំនាក់ទំនងជួយអ្វីខ្លះដល់ក្រុមប្រឹក្សាក្នុងការបំពេញការងារ?<br>- កត់ត្រាចម្លើយអ្នកចូលរួម នៅលើក្រដាសផ្ទាំងធំ រួចបិទលើជញ្ជាំង<br>- បង្ហាញ ស្លាយ**ទី៥ដល់៩** ហើយធ្វើការពន្យល់បន្ថែម | 💻 ស្លាយ**ទី៥ដល់៩**<br>📄 ក្រដាសផ្ទាំងធំ<br>🖊 ហ្វឺតកត់ត្រាចម្លើយ និងបង់ស្ទិត |
| ៥នាទី | សកម្មភាពទី៥ : វិធីសាស្ត្រនៃជំនាញទំនាក់ទំនង<br>បទបង្ហាញ និងពិភាក្សាក្រុមធំ<br>- អ្នកសម្របសម្រួលធ្វើបទបង្ហាញស្តីពីវិធីសាស្ត្រជំនាញទំនាក់ទំនង ដើម្បី ផ្តល់ជាគំនិត និងឆ្លុះបញ្ចាំងដោយលើកឧទាហរណ៍ជាក់ស្តែង ដល់អ្នកចូលរួមមុននឹងចែកក្រុមតូចពិភាក្សា | 💻 ស្លាយ**១០ដល់១១** |
| ១៥នាទី | <u>សកម្មភាពទី៦ :</u> ឆ្លុះបញ្ចាំងអំពីបទពិសោធន៍នៃជំនាញទំនាក់ទំនង (ចំណុចល្អ និងចំណុចកែលម្អ)<br>ពិភាក្សាក្រុមធំ តើកន្លងមកក្រុមប្រឹក្សាមានបញ្ហាប្រឈម និងភាពងាយស្រួលអ្វីខ្លះ ក្នុងការទំនាក់ទំនងរវាងក្រុមប្រឹក្សា និងក្រុមប្រឹក្សា? (ក្រុមប្រឹក្សាឃុំសង្កាត់ និងក្រុមប្រឹក្សាស្រុក ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ)<br>▪ អ្នកសម្របសម្រួលកត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ<br>▪ ធ្វើការឆ្លុះបញ្ចាំងចម្លើយរបស់អ្នកចូលរួម | 💻 ស្លាយ១២<br>📄 ក្រដាសផ្ទាំងធំ<br>🖊 ហ្វឺតកត់ត្រាចម្លើយ និងបង់ស្ទិត |
| ១៥ នាទី | <u>សកម្មភាពទី៧:</u> កំណត់វិធីសាស្ត្រជំនាញទំនាក់ទំនង (ពេលខាងមុខ)<br>ពិភាក្សាក្រុមតូច : ចែកជា ៤ក្រុម (ក្រុមនីមួយៗមានពេល១០នាទី)<br>- ក្រុមទី១ និងក្រុមទី២ ពិភាក្សាសំណួរ ដើម្បីឱ្យការអនុវត្តសកម្មភាព | 💻 ស្លាយ **១៣ដល់១៥**<br>📄 ក្រដាសផ្ទាំងធំ |

| | | |
|---|---|---|
| | ខាងក្រោមនៃគម្រោងយើងបានជោគជ័យ តើក្រុមប្រឹក្សាត្រូវប្រើប្រាស់វិធីសាស្ត្រណាខ្លះ ដើម្បីឱ្យជំនាញទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំសង្កាត់ និងក្រុមប្រឹក្សាស្រុកមានប្រសិទ្ធភាព?<br>▪ វេទិកាផ្សព្វផ្សាយព័ត៌មាន និងពិគ្រោះយោបល់<br>▪ កិច្ចប្រជុំប្រចាំខែ<br>▪ ដំណើរការរៀបចំផែនការថវិកាថ្នាក់<br>▪ ការផ្សព្វផ្សាយព័ត៌មានសាធារណៈ<br>- ក្រុមទី៣ និងក្រុមទី៤ ពិភាក្សាសំណួរ ដើម្បីឱ្យការអនុវត្តសកម្មភាពគម្រោងបានជោគជ័យ តើក្រុមប្រឹក្សាត្រូវប្រើប្រាស់វិធីសាស្ត្រណាខ្លះ ដើម្បីឱ្យការទំនាក់ទំនងមានប្រសិទ្ធភាពជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ (ប្រព័ន្ធផ្សព្វផ្សាយ អង្គការដៃគូ អង្គការសហគមន៍មូលដ្ឋាន)<br>▪ វេទិកាផ្សព្វផ្សាយព័ត៌មាន និងពិគ្រោះយោបល់<br>▪ កិច្ចប្រជុំប្រចាំខែ<br>▪ ដំណើរការរៀបចំផែនការថវិកាថ្នាក់<br>▪ ការផ្សព្វផ្សាយព័ត៌មានសាធារណៈ<br>- អ្នកសម្របសម្រួលបូកសរុបលទ្ធផលពិភាក្សា | សម្រាប់ក្រុមពិភាក្សា<br>✎ ហ្វឺត និងបង់ស្អិត |
| **៥នាទី** | <u>សកម្មភាពទី៨ :</u> បូកសរុបបញ្ចប់មេរៀន<br>- អ្នកសម្របសម្រួលផ្ទៀងផ្ទាត់លទ្ធផលរំពឹងទុករបស់អ្នកចូលរួមដែលបានកត់ត្រាលើក្រដាសផ្ទាំងធំបិទលើជញ្ជាំង<br>- សូមការព្រមព្រៀងជាបឋមលើសេចក្តីព្រាងនៃវិធីសាស្ត្រទំនាក់ទំនងតាមក្រុង ស្រុក ឃុំ សង្កាត់ គោលដៅ ហើយសំណូមពរសូមឱ្យអ្នកចូលរួមជាក្រុមប្រឹក្សា អង្គការសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយសម្រេចពេលវេលាជាក់លាក់ ដើម្បីពិភាក្សាបន្ត និងអនុម័ត ៕ | ▤ ក្រដាសផ្ទាំងធំដែលកត់ត្រាចម្លើយរបស់អ្នកចូលរួម |

# ថ្ងៃទី៣
# មេរៀនទី១:
# ជំនាញទំនាក់ទំនង



សហការការិយាល័យសម្របសម្រួលគម្រោង DFGG ក្រសួងមហាផ្ទៃ អង្គការផេក កម្ពុជា

# ១.សេចក្ដីផ្ដើម

ការជ្រើសរើសមធ្យោបាយ វិធីសាស្ត្រ
ទំនាក់ទំនងត្រឹមត្រូវនឹងជួយឱ្យការងារ
ក្រុមប្រឹក្សាទទួលបានតែភាពជោគជ័យ
និងប្រសិទ្ធផល ។

# ២. គោលបំណង និងការរំពឹងទុកនៃមេរៀន

## គោលបំណង

១. រៀបរាប់បានអំពីអត្ថន័យនៃជំនាញទំនាក់ទំនង

២. ពិពណ៌នាអំពីសារៈសំខាន់នៃជំនាញទំនាក់ទំនងដ៏មានប្រសិទ្ធភាព

៣. រៀបរាប់ពីដំណើរជំនាញទំនាក់ទំនងកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សា

៤. កំណត់តួនាទី និងការទទួលខុសត្រូវអ្នកសម្របសម្រួលក្នុងកិច្ចប្រជុំ

## ការរំពឹងទុក

១. យល់ និងរៀបរាប់បានអំពីអត្ថន័យនៃជំនាញទំនាក់ទំនង

២. អាចពិពណ៌នាបានអំពីសារៈសំខាន់នៃជំនាញទំនាក់ទំនងដ៏មានប្រសិទ្ធភាព

៣. ដឹង និងយល់ពីដំណើរការ និងវិធីសាស្ត្រសម្របសម្រួលកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សា

៤. ដឹង និងយល់អំពីតួនាទី និងការទទួលខុសត្រូវអ្នកសម្របសម្រួលក្នុងកិច្ចប្រជុំ

# ៣. និយមន័យនៃការទំនាក់ទំនង

ការទំនាក់ទំនង គឺជាសកម្មភាព ឬដំណើរការនៃការប្រាស្រ័យទាក់ទង ឬការផ្លាស់ប្តូរមតិយោបល់នៅក្នុងកិច្ចប្រជុំប្រចាំខែ វេទិកាផ្សព្វផ្សាយព័ត៌មាននិងការពិគ្រោះយោបល់ ដំណើរការរៀបចំផែនការថវិកា និងការផ្សព្វផ្សាយព័ត៌មានសាធារណៈ ដែលការទំនាក់ទំនងនេះនឹងជួយក្រុមប្រឹក្សាក្នុងកសាងបាននូវភាពជាដៃគូដ៏យូរអង្វែង

# ៤. សារៈសំខាន់នៃការទំនាក់ទំនង

ការទំនាក់ទំនងគឺជាកត្តាសំខាន់ ហេតុដូច្នេះហើយទើបរាជរដ្ឋាភិបានបង្កើតឱ្យមានគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីបង្ហាញពីសារៈសំខាន់នៃការផ្សព្វផ្សាយ និងមធ្យោបាយ ផ្តល់ព័ត៌មានជាសាធារណៈដល់ប្រជាពលរដ្ឋ ដូចមានរៀបរាប់ខាងក្រោម ៖



# ៤. សារៈសំខាន់នៃការទំនាក់ទំនង (ត)

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
  - **មាត្រា ៥១ (ទំព័រ១៥ - ១៦):** ក្រុមប្រឹក្សាត្រូវបង្កលក្ខណៈងាយស្រួលដល់សាធារណជនក្នុងការជូនព័ត៌មានជាសាធារណៈអំពីរបាយការណ៍ របៀបវារៈប្រជុំ កំណត់ហេតុប្រជុំ ដីកា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសទាំងអស់ដែលពាក់ព័ន្ធ និងឯកសារដទៃទៀតរបស់ក្រុមប្រឹក្សា។
  - **មាត្រា ៥២ (ទំព័រ១៦):** ក្រុមប្រឹក្សាត្រូវមានក្តារព័ត៌មានជាសាធារណៈ ឬមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងទៀតនៅការិយាល័យកណ្តាលរបស់ខ្លួន និងនៅតាមទីកន្លែងនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតាមការចាំបាច់ ហើយទីកន្លែងទាំងនោះមានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋទទួលបានព័ត៌មានជាសាធារណៈទាំងនោះ។

# ៤. សារៈសំខាន់នៃការទំនាក់ទំនង (ត)

- **អនុក្រឹត្យ ស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក លេខ២១៦ អនក្រ.បក មាត្រា១៧២:**

- រដ្ឋបាលក្រុង ស្រុក ត្រូវរៀបចំឱ្យមានក្តារព័ត៌មានសាធារណៈនៅមុខសាលាក្រុង ស្រុក ដែលសាធារណជនអាចពិនិត្យមើលបានដោយងាយស្រួល ។
- ក្តារព័ត៌មានសាធារណៈនេះ ត្រូវបានសរសេរ ឬបានបិទផ្សាយសេចក្តីជូនដំណឹងជាផ្លូវការដល់សាធារណជន ។
- ការសរសេរនិងបិទផ្សាយព័ត៌មានខាងលើនេះ ត្រូវរក្សាទុកឱ្យបានយ៉ាងតិចដប់ (១០) ថ្ងៃ ។
- ក្រៅពីក្តារព័ត៌មានសាធារណៈនៅមុខសាលាក្រុង ស្រុក ក្រុមប្រឹក្សាក្រុង ស្រុកត្រូវរៀបចំឱ្យមានក្តារព័ត៌មានសាធារណៈនៅទីសាធារណៈសមស្រប ដើម្បីបិទផ្សាយព័ត៌មានជូនសាធារណជន ។
- ក្រៅពីការរៀបចំឱ្យមានក្តារព័ត៌មានសាធារណៈ ក្រុមប្រឹក្សាខេត្តត្រូវស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងៗទៀត ដើម្បីជូនដំណឹងអំពីកិច្ចការនានានៃរដ្ឋបាលរបស់ខ្លួនដល់ប្រជាពលរដ្ឋ ។

# ៤. សារៈសំខាន់នៃការទំនាក់ទំនង (ត)

- សម្រេចនូវគោលបំណង និងគោលដៅអភិវឌ្ឍន៍
- លើកកម្ពស់អភិបាលកិច្ចល្អ គឺតម្លាភាព និងគណនេយ្យភាព
- បង្កើនការចូលរួម និងជំនឿទុកចិត្ត
- ជួយលើកទឹកចិត្តប្រជាពលរដ្ឋ អង្គការដៃគូ អង្គការសហគមន៍មូលដ្ឋាន ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកពាក់ព័ន្ធសំខាន់ដទៃទៀតមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួន
- អនុញ្ញាតឱ្យប្រជាពលរដ្ឋ អង្គការដៃគូ អង្គការសហគមន៍មូលដ្ឋាន ប្រព័ន្ធផ្សព្វផ្សាយបាន៖
    - ចូលរួមក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចទាំងនោះ

# ៤.    សារៈសំខាន់នៃការទំនាក់ទំនង (ត)



- រួមចំណែកធ្វើអ្វីមួយដែលពាក់ព័ន្ធទៅនឹងផលប៉ះពាល់ចំពោះផលប្រយោជន៍របស់ពួកគេ។
- ដឹង និងយល់ពីដំណើរការនៃការប្រតិបត្តិគម្រោងរបស់ក្រុមប្រឹក្សា
- កាត់បន្ថយគម្លាតនូវភាពយល់ច្រឡំនានា
- ចំណេញពេលវេលា
- ថវិកាបម្រុងតាមតម្រូវការជាអាទិភាព
- កែលម្អគ្នាទៅវិញទៅមក ក្នុងន័យស្ថាបនា ។ល។

# ៥. វិធីសាស្ត្រនៃការទំនាក់ទំនង

តើក្រុមប្រឹក្សាគួរប្រើវិធីសាស្ត្រអ្វីខ្លះ ដើម្បីកសាងទំនាក់ទំនងដ៏យូរអង្វែងមួយ ជាមួយប្រជាពលរដ្ឋ អង្គការដៃគូ អង្គការសហគមន៍មូលដ្ឋាន ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកពាក់ព័ន្ធដទៃទៀតបាន?

# ៥. វិធីសាស្ត្រនៃការទំនាក់ទំនង

មានវិធីសាស្ត្រសំខាន់៤ ដែលលើកយកពិភាក្សារួមមាន

- ✓ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់
- ✓ កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមប្រឹក្សាស្រុក
- ✓ ដំណើរការរៀបចំផែនការថវិកាថ្នាក់
- ✓ ការផ្សព្វផ្សាយព័ត៌មានសាធារណៈ



# ឆ្លុះបញ្ចាំងអំពីបទពិសោធន៍ទំនាក់ទំនង
# ពិភាក្សាក្រុមធំ

តើកន្លងមកក្រុមប្រឹក្សាមានបញ្ហាប្រឈម និងភាពងាយស្រួលអ្វីខ្លះក្នុងការទំនាក់ទំនងជាមួយក្រុមប្រឹក្សា និងក្រុមប្រឹក្សា និងប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ?

# ឆ្លុះបញ្ចាំងអំពីបទពិសោធន៍ទំនាក់ទំនង
# ពិភាក្សាក្រុមតូច (ចែកជា៤ក្រុម - ១០នាទី)

ក្រុមទី១ និងទី២ ពិភាក្សាសំណួរ:

តើក្រុមប្រឹក្សាត្រូវប្រើប្រាស់វិធីសាស្រ្តណាខ្លះ ដើម្បីឱ្យជំនាញទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមប្រឹក្សាស្រុកមានប្រសិទ្ធភាព?

ក្រុមទី៣ និងទី៤ ពិភាក្សាសំណួរ:

តើក្រុមប្រឹក្សាត្រូវប្រើប្រាស់វិធីសាស្រ្តណាខ្លះ ដើម្បីឱ្យការទំនាក់ទំនងមានប្រសិទ្ធភាពជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ ?

# ហេតុអ្វី? ក៏ព្រោះតែ

- ✓ **វេទិកាផ្សព្វផ្សាយព័ត៌មាន និងពិគ្រោះយោបល់ :** គឺជាដំណើរការនៃជំនាញទំនាក់ទំនងជាប្រចាំរវាងក្រុមប្រឹក្សាជាមួយប្រជាពលរដ្ឋ ដើម្បីទទួលបានព័ត៌មាន និងគំនិតយោបល់ទៅវិញទៅមក។
- ✓ **កិច្ចប្រជុំប្រចាំខែ :** រៀបចំឡើងដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ហើយក៏ជាធាតុមួយដ៏សំខាន់ក្នុង ចំណោមធាតុសំខាន់ទាំង៤ (តម្លាភាព គណនេយ្យភាព ការឆ្លើយតប និងការចូលរួម) នៃគោលការណ៍អភិបាលកិច្ចល្អ ដែលជាស្នូលនៃយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

៥. វិធីសាស្រ្តនៃជំនាញទំនាក់ទំនង

# ហេតុអ្វី? ក៏ព្រោះតែ

- ✓ **ដំណើរការរៀបចំផែនការថវិកាថ្នាក់ :** ដើម្បីឱ្យប្រជាពលរដ្ឋ អង្គការដៃគូ អង្គការសហគមន៍មូលដ្ឋាន ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកពាក់ព័ន្ធដទៃទៀតបានយល់អំពីដំណើរការនៃការរៀបចំថវិកាថ្នាក់ឃុំ សង្កាត់ ឬស្រុក និងត្រៀមលក្ខណៈចូលរួម
- ✓ **ការផ្សព្វផ្សាយព័ត៌មានសាធារណៈ :** ដើម្បីឱ្យ ប្រជាពលរដ្ឋ អង្គការដៃគូ អង្គការសហគមន៍មូលដ្ឋាន ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកពាក់ព័ន្ធដទៃទៀតបានយល់អំពីផែនការសកម្មភាពពិគ្រោះយោបល់ និងត្រៀមលក្ខណៈចូលរួម

៥. វិធីសាស្ត្រនៃជំនាញទំនាក់ទំនង

# កំនត់ចំណាំ :

១) សារព័ត៌មាននៃការទំនាក់ទំនងត្រូវកំណត់ច្បាស់លាស់

២) លំហូរនៃព័ត៌មានដែលទំនាក់ទំនងត្រូវកើតមានទាំងសងខាង

៣) ចែករំលែកព័ត៌មានដោយគ្មានការលាក់លៀមទៅគ្រប់អ្នកពាក់ព័ន្ធ

៤) ធានានូវនិរន្តភាព មានន័យថាដំណើរការនេះមានសារៈប្រយោជន៍ ហើយយកទៅប្រើជារៀងរហូត !

# ការចែករំលែកលទ្ធផលនៃការពិភាក្សា!!



# សំណួរ ?

# បូកសរុបបញ្ចប់មេរៀន !



# ថ្ងៃទី៣

# ឯកសារចែក

# មេរៀនទី១: ជំនាញទំនាក់ទំនង

## ១. សេចក្ដីផ្ដើម:

ជំនាញទំនាក់ទំនង គឺសំដៅទៅលើការប្រាស្រ័យទាក់ទងរវាងគ្នានិងគ្នា តាមរយៈមធ្យោបាយជាច្រើនដូចជា៖ ការផ្ដល់ព័ត៌មាន កិច្ចប្រជុំ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់។ ការទំនាក់ទំនងល្អ បានជួយកាត់បន្ថយគម្លាតយល់ដឹង ឬយល់ ច្រឡំរវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមប្រឹក្សាស្រុក រវាងក្រុមប្រឹក្សា ជាមួយប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល អង្គការសហគមន៍មូលដ្ឋាន និងប្រព័ន្ធផ្សព្វផ្សាយ។ នៅពេលដែលបណ្ដាញទំនាក់ទំនងត្រូវបានពង្រីក កាន់តែស្មុគស្មាញ ហេតុដូច្នេះហើយជំនាញទំនាក់ទំនងមានសារៈសំខាន់ជួយឱ្យក្រុមប្រឹក្សាបំពេញការងារដោយជោគជ័យ និងរលូន។

## ២. គោលបំណង និងលទ្ធផលរំពឹងទុកនៃមេរៀន:

### គោលបំណង

នៅចុងបញ្ចប់នៃមេរៀនអ្នកចូលរួមអាច៖

១. រៀបរាប់បានអំពីអត្ថន័យនៃការទំនាក់ទំនង

២. ពិពិណនាអំពីសារៈសំខាន់នៃការទំនាក់ទំនងដ៏មានប្រសិទ្ធភាព

៣. រៀបរាប់ពីដំណើរការទំនាក់ទំនងកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សា

៤. កំណត់តួនាទី និងការទទួលខុសត្រូវអ្នកទំនាក់ទំនងល្អក្នុងកិច្ចប្រជុំ

### លទ្ធផលរំពឹងទុក

អ្នកចូលរួម៖

១. យល់ និងរៀបរាប់បានអំពីអត្ថន័យនៃការការទំនាក់ទំនង

២. អាចពិពណនាបានអំពីសារៈសំខាន់នៃការទំនាក់ទំនងដ៏មានប្រសិទ្ធភាព

៣. ដឹង និងយល់ពីដំណើរការ និងវិធីសាស្ត្រទំនាក់ទំនងកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សា

៤. ដឹង និងយល់អំពីតួនាទី និងការទទួលខុសត្រូវទំនាក់ទំនងល្អក្នុងកិច្ចប្រជុំ

## ៣. និយមន័យនៃការទំនាក់ទំនង

ការទំនាក់ទំនង គឺជាសកម្មភាព ឬដំណើរការនៃការប្រាស្រ័យទាក់ទង ឬការផ្លាស់ប្តូរមតិយោបល់នៅក្នុងកិច្ចប្រជុំប្រចាំខែ វេទិកាផ្សព្វផ្សាយព័ត៌មាននិងការពិគ្រោះយោបល់ ដំណើរការរៀបចំផែនការថវិកា និងការផ្សព្វផ្សាយព័ត៌មានសាធារណៈ ដែលការទំនាក់ទំនងនេះនឹងជួយក្រុមប្រឹក្សាក្នុងកសាងបាននូវភាពជាដៃគូដ៏យូរអង្វែងមួយរវាងក្រុមប្រឹក្សា និងក្រុមប្រឹក្សា និងក្រុមប្រឹក្សាជាមួយប្រជាពលរដ្ឋ ប្រព័ន្ធផ្សព្វផ្សាយ អង្គការសង្គមស៊ីវិល អង្គការសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធដទៃទៀត និងដើម្បីឱ្យការបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងជោគជ័យ ។

## ៤. សារៈសំខាន់នៃការទំនាក់ទំនង

ការទំនាក់ទំនងគឺជាកត្តាសំខាន់ ហេតុដូច្នេះហើយទើបរាជរដ្ឋាភិបាលបង្កើតឱ្យមានគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តិនានា ដើម្បីបង្ហាញពីសារៈសំខាន់នៃការផ្សព្វផ្សាយ និងមធ្យោបាយផ្តល់ព័ត៌មានជាសាធារណៈដល់ប្រជាពលរដ្ឋ ដូចមានរៀបរាប់ខាងក្រោម ៖

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
  - **មាត្រា ៥១ (ទំព័រ១៥ - ១៦):** ក្រុមប្រឹក្សាត្រូវបង្កលក្ខណៈងាយស្រួលដល់សាធារណជនក្នុងការជូនព័ត៌មានជាសាធារណៈអំពីរបាយការណ៍ របៀបវារៈប្រជុំ កំណត់ហេតុប្រជុំ ដីកា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសទាំងអស់ដែលពាក់ព័ន្ធ និងឯកសារដទៃទៀតរបស់ក្រុមប្រឹក្សា។
  - **មាត្រា៥២ (ទំព័រ១៦):** ក្រុមប្រឹក្សាត្រូវមានក្តារព័ត៌មានជាសាធារណៈ ឬមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងទៀតនៅការិយាល័យកណ្តាលរបស់ខ្លួន និងនៅតាមទីកន្លែងនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតាមការចាំបាច់ ហើយទីកន្លែងទាំងនោះមានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋទទួលបានព័ត៌មានជាសាធារណៈទាំងនោះ ។
- **អនុក្រឹត្យ ស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក** លេខ២១៦ **អនក្រ.បក មាត្រា១៧២:**
  - រដ្ឋបាលក្រុង ស្រុក ត្រូវរៀបចំឱ្យមានក្តារព័ត៌មានសាធារណៈនៅមុខសាលាក្រុង ស្រុក ដែលសាធារណជនអាចពិនិត្យមើលបានដោយងាយស្រួល ។
  - ក្តារព័ត៌មានសាធារណៈនេះ ត្រូវបានសរសេរ ឬបានបិទផ្សាយសេចក្តីជូនដំណឹងជាផ្លូវការដល់សាធារណជន ។

- ការសរសេរនិងបិទផ្សាយព័ត៌មានខាងលើនេះ ត្រូវរក្សាទុកឱ្យបានយ៉ាងតិចដប់ (១០) ថ្ងៃ។
- ក្រៅពីក្តារព័ត៌មានសាធារណៈនៅមុខសាលាក្រុង ស្រុក ក្រុមប្រឹក្សាក្រុង ស្រុកត្រូវរៀបចំឱ្យមានក្តារព័ត៌មានសាធារណៈនៅទីសាធារណៈសមស្រប ដើម្បីបិទផ្សាយព័ត៌មានជូនសាធារណជន។
- ក្រៅពីការរៀបចំឱ្យមានក្តារព័ត៌មានសាធារណៈ ក្រុមប្រឹក្សាខេត្តត្រូវស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងៗទៀត ដើម្បីជូនដំណឹងអំពីកិច្ចការនានានៃរដ្ឋបាលរបស់ខ្លួនដល់ប្រជាពលរដ្ឋ។

យោងតាមអ្វីដែលបានរៀបរាប់នៅក្នុងគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តិខាងលើ ការផ្លាស់ប្តូរព័ត៌មានរវាងអាជ្ញាធរ និងប្រជាពលរដ្ឋ គឺមានសារៈសំខាន់ដល់ក្រុមប្រឹក្សាក្នុងការៈ

- សម្រេចនូវគោលបំណង និងគោលដៅអភិវឌ្ឍ
- លើកកម្ពស់អភិបាលកិច្ចល្អ គឺតម្លាភាព និងគណនេយ្យភាព
- បង្កើនការចូលរួម និងជំនឿទុកចិត្ត
- ជួយលើកទឹកចិត្តប្រជាពលរដ្ឋ អង្គការដៃគូ អង្គការសហគមន៍មូលដ្ឋាន ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកពាក់ព័ន្ធសំខាន់ដទៃទៀតមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការចូលរួមក្នុងកម្មភាពអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន
- អនុញ្ញាតឱ្យប្រជាពលរដ្ឋ អង្គការដៃគូ អង្គការសហគមន៍មូលដ្ឋាន ប្រព័ន្ធផ្សព្វផ្សាយបានៈ
    - ចូលរួមក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចទាំងនោះ
    - រួមចំណែកធ្វើអ្វីមួយដែលពាក់ព័ន្ធទៅនឹងផលប៉ះពាល់ចំពោះផលប្រយោជន៍របស់ពួកគេ។
    - ដឹង និងយល់ពីដំណើរការនៃការប្រតិបត្តិគម្រោងរបស់ក្រុមប្រឹក្សា
- កាត់បន្ថយគម្លាតនូវភាពយល់ច្រឡំនានា
- ចំណេញពេលវេលា
- ថវិកាបំរុងទុកត្រូវតាមតម្រូវការអាទិភាព
- កែលម្អគ្នាទៅវិញទៅមក ក្នុងន័យស្ថាបនា។ល។

## ៥. វិធីសាស្ត្រនៃការទំនាក់ទំនង

កត្តាជោគជ័យ អាស្រ័យដោយការទំនាក់ទំនងដែលមានប្រសិទ្ធភាព ដូច្នេះក្រុមប្រឹក្សាត្រូវដឹងអំពីវិធីសាស្ត្រ ដើម្បីកំណត់ថាការទំនាក់ទំនងបែបណាធ្វើឱ្យការទំនាក់ទំនងរបស់ក្រុមប្រឹក្សាជាមួយអ្នកពាក់ព័ន្ធទាំងអស់មានប្រសិទ្ធភាព។ ការទំនាក់ទំនងដែលមានប្រសិទ្ធភាពគឺៈ

- ធ្វើឱ្យអ្នកពាក់ព័ន្ធទទួលបានផលប្រយោជន៍ទាំងអស់គ្នា ពោលគឺ ទាំងក្រុមប្រឹក្សា ប្រជាពលរដ្ឋ អង្គការដៃគូ អង្គការសហគមន៍មូលដ្ឋាន ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកពាក់ព័ន្ធដទៃទៀត
- ត្រូវទំនាក់ទំនាក់ឱ្យចំអ្នកដែលពាក់ព័ន្ធផ្តល់ការយកចិត្តទុកដាក់ ដោយគ្មានការរើសអើង (អ្នកណាជាក្រុមគោលដៅ?)

មានវិធីសាស្រ្តសំខាន់៤ ដែលលើកយកពិភាក្សារួមមាន៖

- វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់
- កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមប្រឹក្សាស្រុក
- ដំណើរការរៀបចំផែនការថវិកាថ្នាក់ក្រុង ស្រុក
- ការផ្សព្វផ្សាយព័ត៌មានសាធារណៈ

## ចំណុចដែលមានប្រយោជន៍ និងគួរចងចាំ

វិធីសាស្រ្តទាំង៤ ខាងលើ៖ រាល់ការរៀបចំវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់ក្តី កិច្ចប្រជុំប្រចាំខែក្តី ដំណើរការរៀបចំផែនការថវិកាថ្នាក់ក្រុង ស្រុក និងការផ្សព្វផ្សាយព័ត៌មានសាធារណៈត្រូវអនុលោមតាមមធ្យោបាយ និងដំណើរការដែលជាមូលដ្ឋាន ៤ចំណុចសំខាន់ដូចខាងក្រោម៖

១) **សារព័ត៌មាននៃការទំនាក់ទំនងត្រូវកំណត់ច្បាស់លាស់** : ឧទាហរណ៍ : វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ ក្រុមប្រឹក្សា ត្រូវដឹងពីគោលបំណង និងកំណត់ថាមានព័ត៌មាន មានប្រយោជន៍អ្វីខ្លះសម្រាប់យកទៅចែករំលែក ហើយប្រមូលព័ត៌មានអ្វីខ្លះពីអ្នកចូលរួម

២) **លំហូរនៃព័ត៌មានដែលទំនាក់ទំនងត្រូវកើតមានទាំងសងខាង** : ឧទាហរណ៍ : វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ គឺជាមធ្យោបាយមួយដែលអនុញ្ញាតក្រុមប្រឹក្សាមិនត្រឹមតែជាការផ្តល់ព័ត៌មានប៉ុណ្ណោះទេ តែត្រូវប្រមូលត្រលប់មកវិញនូវ៖ បញ្ហា ក្តីកង្វល់ តម្រូវការអទិភាព និងដំណោះស្រាយ ។ល។

៣) **ចែករំលែកព័ត៌មានដោយគ្មានការលាក់លៀមទៅគ្រប់អ្នកពាក់ព័ន្ធ : ធានាថាព័ត៌មានដែលទទួលបានត្រូវបានចែករំលែក មិនស្ទះ ឬកប់ទុកនៅកន្លែងណាមួយ ។**

៤) **ធានានូវនិរន្តភាព មានន័យថាដំណើរការនេះមានសារៈប្រយោជន៍ ហើយយកទៅប្រើជារៀងរហូត** : ឧទាហរណ៍ ប្រសិនបើក្រុមប្រឹក្សា សង្កេតឃើញថា វិធីសាស្រ្តណាមួយដូចជា៖ ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ក្នុង

ទម្រង់ណាមួយ (ក្រុមតូច តាមផ្ទះ ក្រុមធំ ប្រជុំផ្សព្វផ្សាយព័ត៌មាន វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់) មានសារៈប្រយោជន៍ ក្រុមប្រឹក្សាគួរបន្តយកទៅប្រើប្រាស់ដើម្បីភាពជោគជ័យនិងការជឿទុកចិត្តពីប្រជាពលរដ្ឋ។

**<u>ការរំលឹកឡើងវិញ</u> :**

- **វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់** គឺជាដំណើរការនៃទំនាក់ទំនងជាប្រចាំរវាងក្រុមប្រឹក្សាជាមួយប្រជាពលរដ្ឋ ដើម្បីទទួលបានព័ត៌មាន និងគំនិតយោបល់ទៅវិញទៅមក។
- **កិច្ចប្រជុំប្រចាំខែ :** រៀបចំឡើងដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ហើយក៏ជាធាតុមួយដ៏សំខាន់ក្នុងចំណោមធាតុសំខាន់ទាំង៤ (តម្លាភាព គណនេយ្យភាព ការឆ្លើយតប និងការចូលរួម) នៃគោលការណ៍អភិបាលកិច្ចល្អដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។
- **ដំណើរការរៀបចំផែនការថវិកាថ្នាក់ក្រុង ស្រុក :** ដើម្បីឱ្យប្រជាពលរដ្ឋ អង្គការដៃគូ អង្គការសហគមន៍មូលដ្ឋាន ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកពាក់ព័ន្ធដទៃទៀតបានយល់អំពីដំណើរការនៃការរៀបចំថវិកាថ្នាក់ឃុំ សង្កាត់ ឬ ក្រុងស្រុក ឃុំនិង សង្កាត់ និងត្រៀមលក្ខណៈចូលរួម។
- **ការផ្សព្វផ្សាយព័ត៌មានសាធារណៈ** ដើម្បីឱ្យប្រជាពលរដ្ឋអង្គការដៃគូអង្គការសហគមន៍មូលដ្ឋាន ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកពាក់ព័ន្ធដទៃទៀតបានយល់អំពីផែនការសកម្មភាពពិគ្រោះយោបល់ និងត្រៀមលក្ខណៈចូលរួម។

## ៦. សេចក្តីសន្និដ្ឋាន

ក្រុមប្រឹក្សាឃុំ សង្កាត់ ឬស្រុក អាចបំពេញតួនាទីខ្លួនបានល្អ និងប្រកបដោយជោគជ័យ ទទួលបានការគាំទ្រពីប្រជាពលរដ្ឋ លុះត្រាតែក្រុមប្រឹក្សាឃុំ សង្កាត់ ឬក្រុងស្រុក នោះមានទេពកោសល្យខាងទំនាក់ទំនង និងការនិយាយជាសាធារណៈ។

**«អ្នកដែលមានទេពកោសល្យពូកែខាងទំនាក់ និងការនិយាយជាសាធារណៈ តែងតែឆ្លុះបញ្ចាំងខ្លួនឯងជានិច្ច អំពីវិធីសាស្ត្រដែលប្រើប្រាស់ហើយបានជោគជ័យ»**

**--- ចប់ ---**



# ថ្ងៃទី៣

# ម្លង់មេរៀនទី២

## ចំណងជើងមេរៀនៈ ជំនាញសម្របសម្រួល

**ពេលវេលាៈ**០៩:៣០ដល់១០:៣០ (៦០នាទី)

**គោលបំណងនៃមេរៀនៈ**នៅចុងបញ្ចប់មេរៀននេះអ្នកចូលរួមអាចៈ

១. រៀបរាប់បានអំពីអត្ថន័យនៃជំនាញសម្របសម្រួល

២. ពិពណ៌នាអំពីសារៈសំខាន់នៃជំនាញសម្របសម្រួល

៣. រៀបរាប់ពីដំណើរការសម្របសម្រួលកិច្ចប្រជុំក្រុមប្រឹក្សា

៤. កំណត់តួនាទីអ្នកសម្របសម្រួលល្អក្នុងកិច្ចប្រជុំ ។

## កំណត់ចំណាំរបស់អ្នកសម្របសម្រួល

១. ឆ្លុះបញ្ចាំងជាមួយអ្នកចូលរួមអំពីគោលបំណង និងលទ្ធផលរំពឹងទុកនៃមេរៀន

២. បំផុសគំនិតតាមរយៈការសួរសំណួរ ដើម្បីជួយឱ្យអ្នកចូលរួមបានយល់ដឹងៈ

- តើអ្វីទៅជាការសម្របសម្រួលក្នុងកិច្ចប្រជុំ?
- តើជំនាញសម្របសម្រួលអាចជួយឱ្យក្រុមប្រឹក្សាសម្រេចបានផលប្រយោជន៍អ្វីខ្លះពីកិច្ចប្រជុំនានា?
- តើអ្នកសម្របសម្រួលត្រូវធ្វើអ្វីខ្លះ នៅមុនពេល អំឡុងពេល និងក្រោយពេលកិច្ចប្រជុំនានា?
- តើត្រូវប្រើវិធីសាស្ត្រសម្របម្រួលដូចម្តេច ដើម្បីឱ្យប្រជាពលរដ្ឋបញ្ចេញមតិយោបល់ ក្នុងកិច្ចប្រជុំ?

៣. អ្នកសម្របសម្រួលអាចឆ្លុះបញ្ចាំងអំពីសកម្មភាពខ្លួនឯងថាតើការសម្របសម្រួលរបស់គាត់មានចំណុចល្អ និងចំណុចកែលម្អអ្វីខ្លះ?

## លទ្ធផលរំពឹងទុកនៃមេរៀន

អ្នកចូលរួម៖

១. យល់ និងរៀបរាប់បានអំពីអត្ថន័យនៃជំនាញសម្របសម្រួល
២. ពិពណ៌នាបានអំពីសារៈសំខាន់នៃជំនាញសម្របសម្រួល
៣. រៀបរាប់ពីដំណើរការសម្របសម្រួលកិច្ចប្រជុំក្រុមប្រឹក្សា
៤. យល់ដឹងពីតួនាទីក្នុងការសម្របសម្រួលកិច្ចប្រជុំ ។

## សម្ភារឧបទេ្ទសសម្រាប់បង្រៀន

- ឯកសារមេរៀន ស្តីពី ជំនាញសម្របសម្រួល
  - o បទបង្ហាញ/ស្លាយ
  - o ឯកសារចែក
- ហ្វឺតសរសេរក្រដាស ក្រដាសផ្ទាំងធំ ស្កុត
- កុំព្យូទ័រយួរដៃ និងម៉ាស៊ីនបញ្ចាំងឯកសារ/ស្លាយ

## ឯកសារយោង

- ឯកសារបណ្តុះបណ្តាលវគ្គដំបូងនៃកម្មវិធីល្អ មេរៀនទី៦
- ឯកសារបណ្តុះបណ្តាល ស្តីពីជំនាញសម្របសម្រួល ដែលរៀបចំដោយអង្គការ GIZ
- ឯកសារបណ្តុះបណ្តាលស្តីពីជំនាញសម្របសម្រួល សម្រាប់មន្ត្រីសម្របសម្រួលឃុំ សង្កាត់ របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

## របៀបសម្របសម្រួលមេរៀន

| ម៉ោង | សកម្មភាព និងវិធីសាស្ត្រ | សម្ភារ និងឯកសារចែកជូន |
|---|---|---|
| ៥នាទី | **សកម្មភាពទី១** :សេចក្តីផ្តើម និងគោលបំណងនៃមេរៀន<br>សំណួរបំផុសគំនិត និងពិភាក្សាក្រុមធំ<br>ជំនាញសម្របសម្រួលមានសារៈសំខាន់សម្រាប់ក្រុមប្រឹក្សាក្នុងការប្រតិបត្តិ | 💻 ស្លាយទី២<br>🗐 ក្រដាសផ្ទាំងធំ<br>🖉 ហ្វឺតកត់ត្រាចម្លើយ |

| | | |
|---|---|---|
| | កិច្ចប្រជុំ វេទិកា។ ដូច្នេះមេរៀននេះនឹងពិភាក្សាលំអិតពីអត្ថន័យ សារៈសំខាន់<br>- បង្ហាញស្លាយទី២ពីគោលបំណងនៃមេរៀន<br>- សួរសំណួរអ្នកចូលរួមចំនួន ២នាក់ អំពីការរំពឹងទុកថា តើអ្នកចង់ចេះអ្វីខ្លះពីមេរៀននេះ? ហើយកត់ត្រាចម្លើយអ្នកចូលរួម នៅលើក្រដាសផ្ទាំងធំ រួចបិទលើជញ្ជាំងសម្រាប់ផ្ទៀងផ្ទាត់នៅពេលបញ្ចប់មេរៀន<br>- បង្ហាញស្លាយទី២ពីការរំពឹងទុកនៃមេរៀន | និងបង់ស្អិត |
| ៥នាទី | <u>សកម្មភាពទី២:</u> **អត្ថន័យនៃជំនាញសម្របសម្រួល**<br>**សំណួរបំផុសគំនិត និងពិភាក្សាក្រុមធំ**<br>- សួរទៅកាន់អ្នកចូលរួមចំនួន៣នាក់**តើអ្វីទៅជាជំនាញសម្របសម្រួល?**<br>- កត់ត្រាចម្លើយអ្នកចូលរួម នៅលើក្រដាសផ្ទាំងធំ រួចបិទលើជញ្ជាំង<br>- បង្ហាញស្លាយទី៣និង៤ ដោយមានការសួរបញ្ជាក់ពីអ្នកចូលរួម | 💻 ស្លាយទី៣និង៤<br>🗐 ក្រដាសផ្ទាំងធំ<br>✎ ហ្វឺតកត់ត្រាចម្លើយ និងបង់ស្អិត |
| ៥នាទី | <u>សកម្មភាពទី៣:</u> **សារៈប្រយោជន៍នៃជំនាញសម្របសម្រួល**<br>**សំណួរបំផុសគំនិត និងពិភាក្សាក្រុមធំ**<br>- សួរទៅកាន់អ្នកចូលរួមចំនួន ៣នាក់**តើជំនាញសម្របសម្រួលជួយក្រុមប្រឹក្សាសម្រេចបានផលប្រយោជន៍អ្វីខ្លះ?**<br>- កត់ត្រាចម្លើយអ្នកចូលរួមនៅលើក្រដាសផ្ទាំងធំរួចបិទលើជញ្ជាំង<br>- បង្ហាញស្លាយទី៥-៨ ហើយធ្វើការពន្យល់បន្ថែម | 💻 ស្លាយទី៥-៨<br>🗐 ក្រដាសផ្ទាំងធំ<br>✎ ហ្វឺតកត់ត្រាចម្លើយ និងបង់ស្អិត |
| ១៥នាទី | <u>សកម្មភាពទី៤:</u> **ដំណើរការសម្របសម្រួលកិច្ចប្រជុំ**<br>**ពិភាក្សាក្រុមធំ**<br>- ពិភាក្សាសំណួរដូចខាងក្រោម៖<br>- **តើអ្នកសម្របសម្រួលត្រូវធ្វើអ្វីខ្លះនៅមុនពេល អំឡុងពេល និងក្រោយពេលកិច្ចប្រជុំ?**<br>- កត់ត្រាចម្លើយអ្នកចូលរួមនៅលើក្រដាសផ្ទាំងធំរួចបិទលើជញ្ជាំង<br>- អ្នកសម្របសម្រួលធ្វើការបូកសរុប និងបង្ហាញស្លាយទី៩ដល់ទី១៤ ដោយមានការចូលរួមបញ្ចេញយោបល់ និងសួរបញ្ជាក់ពីអ្នកចូលរួម | 💻 ស្លាយទី៩ទី១៤<br>✎ កត់ត្រាចំណុចចាប់អារម្មណ៍ |

| | | |
|---|---|---|
| ២០ នាទី | <u>*សកម្មភាពទី៥:*</u> **តួនាទីអ្នកសម្របសម្រួល**<br>**ពិភាក្សាក្រុមតូច**<br>• ចែកជា៤ក្រុមពិភាក្សា<br>ក្រុមទី១ **តើធ្វើដូចម្តេចដើម្បីគ្រប់គ្រងការពិភាក្សា និងបុគ្គលិកលក្ខណៈរបស់អ្នកចូលរួមក្នុងពេលប្រជុំ?**<br>  • គោរពពេលវេលាដែលបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង<br>  • ពេលនិយាយលើកដៃ<br>  • កាត់បន្ថយអ្នកដែលនិយាយច្រើន<br>  • គោរពតាមមតិភាគច្រើន<br>ក្រុមទី២ **តើធ្វើដូចម្តេចដើម្បីធានាថា អ្នកចូលរួមគ្រប់រូបបានបញ្ចេញយោបល់និងចែករំលែកព័តិមានក្នុងពេលប្រជុំ?**<br>  • ហៅអ្នកនិយាយតិចឱ្យបញ្ចេញយោបល់<br>  • ឧស្សាហ៍សួរបញ្ជាក់អ្នកនិយាយតិច<br>ក្រុមទី៣ **តើធ្វើដូចម្តេចដើម្បីរក្សាការពិភាក្សាឱ្យចំប្រធានបទក្នុងពេលប្រជុំ?**<br>  • រំលឹកអ្នកនិយាយចាកប្រធានបទ<br>  • រំលឹកពីបទបញ្ជាផ្ទៃក្នុង<br>  • បញ្ឈប់ការបញ្ចេញមតិ<br>ក្រុមទី៤ **តើធ្វើដូចម្តេចដើម្បីធានាថា មានការព្រមព្រៀងលើសេចក្តីសម្រេចចិត្ត និងបានកត់ត្រាក្នុងពេលកិច្ចប្រជុំ?**<br>  • សួរបញ្ជាក់ពីការព្រមព្រៀងលើការពិភាក្សាថា តើឯកភាពឬទេ?<br>  • ពិនិត្យមើលលើកំណត់ហេតុ<br>• បិទចម្លើយពិភាក្សាលើជញ្ជាំង<br>• បង្ហាញចម្លើយស្លាយទី១៥ ដល់១៩ ដោយមានការចូលរួម យោបល់និងសួរបញ្ជាក់ពីអ្នកចូលរួម | ស្លាយទី១៥ទី១៩ |

| | | |
|---|---|---|
| ៥នាទី | **<u>សកម្មភាពទី៦:</u> ឆ្លុះបញ្ចាំងសកម្មភាពអ្នកសម្របសម្រួលពិភាក្សាក្រុមធំ**<br>- អ្នកសម្របសម្រួលសួរទៅកាន់អ្នកចូលរួមថាតើការសម្របសម្រួលរបស់ខ្ញុំដូចម្តេចដែរ (ចំណុចល្អ និងចំណុចកែលម្អ)?<br>- បូកសរុប និងពន្យល់បន្ថែម ។ | 💻 ស្លាយទី២០ដល់២១<br>🗐 ប្រើប្រាស់កំណត់ត្រាលើការសម្តែង |
| ៥ នាទី | **<u>សកម្មភាពទី៧:</u> បូកសរុបមេរៀន**<br>- អ្នកសម្របសម្រួលផ្ទៀងផ្ទាត់លទ្ធផលរំពឹងទុករបស់អ្នកចូលរួមដែលបានកត់ត្រាលើក្រដាសផ្ទាំងធំបិទលើជញ្ជាំង និងសរុបនូវចំណុចសំខាន់៧នៃមេរៀនជំនាញសម្របសម្រួល<br>- លើកទឹកចិត្តអ្នកចូលរួមព្យាយាមយកចំណេះដឹងដែលរៀន ទៅអនុវត្តជាក់ស្តែង ហើយអង្គការដៃគូថ្នាក់ខេត្ត នឹងបន្តផ្តល់ការគាំទ្រ និងកែលម្អ ដើម្បីធ្វើឱ្យជំនាញការសម្របសម្រួលរបស់ក្រុមប្រឹក្សាកាន់តែល្អប្រសើរ ។ | 🗐 ក្រដាសផ្ទាំងធំដែលកត់ត្រាចម្លើយរបស់អ្នកចូលរួម |

# ថ្ងៃទី៣
# មេរៀនទី២:
# ជំនាញសម្របសម្រួល

សហការការិយាល័យសម្របសម្រួលគម្រោង DFGG ក្រសួងមហាផ្ទៃ អង្គការផែក កម្ពុជា

# គោលបំណង និងការរំពឹងទុកនៃមេរៀន

- រៀបរាប់បានអំពីអត្ថន័យនៃជំនាញសម្របសម្រួល
- ពិពណ៌នាអំពីសារៈសំខាន់នៃជំនាញសម្របសម្រួល
- រៀបរាប់ពីដំណើរការសម្របសម្រួលកិច្ចប្រជុំក្រុមប្រឹក្សា
- កំណត់តួនាទីអ្នកសម្របសម្រួលក្នុងកិច្ចប្រជុំ ។

**គោលបំណង**

- យល់ និងរៀបរាប់បានអំពីអត្ថន័យនៃជំនាញសម្របសម្រួល
- ពិពណ៌នាបានអំពីសារៈសំខាន់នៃជំនាញសម្របសម្រួល
- រៀបរាប់ពីដំណើរការសម្របសម្រួលកិច្ចប្រជុំក្រុមប្រឹក្សា
- យល់ដឹងពីតួនាទីក្នុងការសម្របសម្រួលកិច្ចប្រជុំ ។

**ការរំពឹងទុក?**

# អត្ថន័យនៃការសម្របសម្រួល

## អ្វីទៅជាជំនាញសម្របសម្រួល?

ជំនាញសម្របសម្រួល គឺជា**សិល្បៈ**នៃការដឹកនាំមនុស្ស តាមរយៈ**ដំណើរការ**ឆ្ពោះទៅរកការឯកភាពគ្នាទៅលើគោលបំណងរួមក្នុងលក្ខណៈដែលមានការលើកទឹកចិត្តឱ្យមានការ**ចូលរួម ភាពម្ចាស់ការ** និងភាពច្នៃប្រឌិតពីគ្រប់អ្នកចូលរួមទាំងអស់

# អត្ថន័យនៃការសម្របសម្រួល (ត)

- **សិល្បៈ :** សំដៅដល់ភាពប៉ិនប្រសប់ ការសម្តែងទឹកមុខ អាកប្បកិរិយា ការនិយាយស្តី
- **ដំណើរការ :** ក្នុងការរៀបចំតាក់តែងវិធី ឬសកម្មភាពផ្សេងៗ ដើម្បីសម្រេចគោលបំណង/ទិសដៅរួមបានដោយជោគជ័យ ។
- **ការចូលរួម :** អនុញ្ញាតិឱ្យអ្នកចូលរួមបានផ្តល់ជាគំនិត ឬយោបល់ បទពិសោធន៍ផ្សេងៗ របស់ពួកគេនៅក្នុងដំណើរការសម្របសម្រួល ។
- **ភាពម្ចាស់ការ :** អ្នកចាត់ចែង និងទទួលខុសត្រូវក្នុងការពិភាក្សា ឬធ្វើផែនការ ។
- **ភាពច្នៃប្រឌិត :** ការផ្តួចផ្តើមនូវអ្វីដែលថ្មី ។



# សារៈប្រយោជន៍នៃការសម្របសម្រួល

តើជំនាញសម្របសម្រួល
ជួយក្រុមប្រឹក្សាសម្រេច
បានផលប្រយោជន៍អ្វីខ្លះ?

# សារៈប្រយោជន៍នៃការសម្របសម្រួល (ត)

យល់ពីសុខទុក្ខរបស់ប្រជាពលរដ្ឋ

ជួយប្រជាពលរដ្ឋពេលគាត់ត្រូវការ

- ✓ ទទួលបានការគាំទ្រពីអ្នកចូលរួម ឬប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ

ការផ្តល់សេវាមានតម្លាភាព

ដឹងពីតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ

# សារៈប្រយោជន៍នៃការសម្របសម្រួល (ត)

ផ្តល់ឱកាសឱ្យប្រជាពលរដ្ឋចូលរួមក្នុងការពិគ្រោះយោបល់

ចុះពិគ្រោះយោបល់តាមផ្ទះ

បង្ហាញពីផែនការថវិកា

- ✓ ឆ្លុះបញ្ចាំងអំពីអភិបាលកិច្ចល្អ (តម្លាភាព គណនេយ្យភាព និងការឆ្លើយតប)

ស្វែងយល់ពីបញ្ហា

បង្ហាញពីផែនការសកម្មភាព

ប្រមូលយោបល់ត្រលប់

# សារៈប្រយោជន៍នៃការសម្របសម្រួល (ត)

✓ ការចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ ដោយគ្មានការស្ទើរស្ទាក់ ព្រោះតែក្រុមប្រឹក្សាបានពន្យល់ឱ្យគាត់យល់អំពីសិទ្ធិ បង្ហាញពីតម្លាភាព គណនេយ្យភាព និងការឆ្លើយតប



# តើអ្នកសម្របសម្រួល ធ្វើអ្វីខ្លះនៅមុនពេល ក្នុងកំឡុងពេល និងក្រោយពេលកិច្ចប្រជុំ?

# ដំណើរការសម្របសម្រួលកិច្ចប្រជុំ

១. មុនពេលសម្របសម្រួលកិច្ចប្រជុំ

២. អំឡុងពេលសម្របសម្រួលកិច្ចប្រជុំ

៣. ក្រោយពេលសម្របសម្រួលកិច្ចប្រជុំ



# មុនពេលសម្របសម្រួលកិច្ចប្រជុំ

ត្រូវត្រួតពិនិត្យឡើងវិញពីៈ



- ✓ ប្រធានបទ (ផ្តោតលើអ្វី?)
- ✓ គោលបំណង (ចង់បានអ្វី?)
- ✓ ក្រុមគោលដៅ (ទៅអ្នកណា?)
- ✓ ខ្លឹមសារ? (អ្វីដែលត្រូវយកទៅចែករំលែក?)
- ✓ កំណត់គោលដៅខ្លួនឯង : ត្រូវធ្វើដូចម្តេច? ហើយត្រៀមខ្លួនបែបណា? ដើម្បីសម្រេចគោលដៅតាមស្ថានភាពជាក់ស្តែង។
- ✓ រៀបចំប្លង់សម្របសម្រួល

# អំឡុងពេលសម្របសម្រួលកិច្ចប្រជុំ



- គ្រប់គ្រងការពិភាក្សា និងបុគ្គលិកលក្ខណៈរបស់អ្នកចូលរួម
- ធានាថា អ្នកចូលរួមគ្រប់រូបបានបញ្ចេញយោបល់ និងចែករំលែកព័ត៌មាន
- លើកទឹកចិត្តឱ្យអ្នកចូលរួមសួរសំណួរ
- ត្រួតពិនិត្យពេលវេលា
- រក្សាការពិភាក្សាឱ្យចំប្រធានបទ
- ស្តាប់ និងសង្ខេបយោបល់អ្នកចូលរួម
- ធានាថា មានការព្រមព្រៀងលើសេចក្តីសម្រេចចិត្ត និងបានកត់ត្រា

# ក្រោយពេលសម្របសម្រួលកិច្ចប្រជុំ



- ✓ ធ្វើកំណត់ហេតុ ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត
- ✓ ពិនិត្យកំណត់ហេតុ និងអនុម័ត
- ✓ ចាត់អាទិភាពបញ្ហា ក្ដីកង្វល់ ហើយស្នើសុំការគាំទ្រពីស្ថាប័នពាក់ព័ន្ធក្នុងការផ្ដល់ការឆ្លើយតបនៅក្នុងកិច្ចប្រជុំលើកក្រោយ និងកែលម្អការងារផ្ទៃក្នុង
- ✓ ផ្សព្វផ្សាយនូវអ្វីដែលជាសេចក្ដីសម្រេចនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាដល់ប្រជាពលរដ្ឋដោយបិទផ្សាយលើក្ដារព័ត៌មាន។

# តួនាទី
# សម្របសម្រួលកិច្ចប្រជុំ

# សំណួរពិភាក្សា

- ក្រុមទី១  តើធ្វើដូចម្តេចដើម្បីគ្រប់គ្រងការពិភាក្សា និងបុគ្គលិកលក្ខណៈរបស់អ្នកចូលរួមក្នុងពេលប្រជុំ ?
- ក្រុមទី២  តើធ្វើដូចម្តេចដើម្បីធានាថា អ្នកចូលរួមគ្រប់រូបបានបញ្ចេញយោបល់និងចែករំលែកព័ត៌មានក្នុងពេលប្រជុំ ?
- ក្រុមទី៣  តើធ្វើដូចម្តេចដើម្បីរក្សាការពិភាក្សាឱ្យចំប្រធានបទក្នុងពេលប្រជុំ ?
- ក្រុមទី៤ តើធ្វើដូចម្តេចដើម្បីធានាថា មានការព្រមព្រៀងលើសេចក្តីសម្រេចចិត្ត និងបានកត់ត្រាក្នុង ពេលកិច្ចប្រជុំ?

ចែកជា៤ក្រុម

ពេល១០នាទី

# តើធ្វើដូចម្តេចដើម្បីគ្រប់គ្រងការពិភាក្សា និងបុគ្គលិកលក្ខណៈរបស់អ្នកចូលរួមក្នុងពេលប្រជុំ?

- គោរពពេលវេលាដែលបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង
- ពេលនិយាយលើកដៃ
- កាត់បន្ថយអ្នកដែលនិយាយច្រើន
- គោរពតាមមតិភាគច្រើន

# តើធ្វើដូចម្ដេចដើម្បីធានាថា អ្នកចូលរួមគ្រប់រូបបានបញ្ចេញយោបល់និងចែករំលែកព័ត៌មានក្នុងពេលប្រជុំ?

- ហៅអ្នកនិយាយតិចឱ្យបញ្ចេញយោបល់
- ឧស្សាហ៍សួរបញ្ជាក់អ្នកនិយាយតិច

# តើធ្វើដូចម្តេចដើម្បីរក្សាការពិភាក្សាឲចំប្រធានបទក្នុងពេលប្រជុំ?

- រំលឹកអ្នកនិយាយចាកប្រធានបទ
- រំលឹកពីបទបញ្ជាផ្ទៃក្នុង
- បញ្ឈប់ការបញ្ចេញមតិ

# ក្រុមទី៤ តើធ្វើដូចម្តេចដើម្បីធានាថា មានការព្រមព្រៀងលើសេចក្តីសម្រេចចិត្ត និងបានកត់ត្រាក្នុង ពេលកិច្ចប្រជុំ?

- ស្នើរបញ្ជាក់ពីការព្រមព្រៀងលើការពិភាក្សា ថាតើឯកភាព ឬទេ?
- ពិនិត្យមើលលើកំណត់ហេតុ
- បិទចម្លើយពិភាក្សាលើជញ្ជាំង

# ការទទួលខុសត្រូវនៃអ្នកសម្របសម្រួល

- **ការទទួលខុសត្រូវ**

ធានាថាកិច្ចការដែលត្រូវសម្របសម្រួល សម្រេចបានដោយរលូន និងជោគជ័យទៅតាមទិសដៅ និងផែនការ ។







# ឆ្លុះបញ្ចាំងអំពីការសម្របសម្រួល!!!

## តើការសម្របសម្រួលរបស់ខ្ញុំដូចម្តេចដែរ (ចំណុចល្អ និងចំណុចកែលម្អ)?

សូមការស្ម័គ្រចិត្តចំនួនពនាក់



# ថ្ងៃទី៣

# ឯកសារចែក

## មេរៀនទី២: ជំនាញសម្របសម្រួល

## ១. គោលបំណងនិងលទ្ធផលរំពឹងទុកនៃមេរៀន:

**គោលបំណង** : នៅចុងបញ្ចប់មេរៀននេះអ្នកចូលរួមអាចៈ

១. រៀបរាប់បានអំពីអត្ថន័យនៃជំនាញសម្របសម្រួល
២. ពិពណ៌នាអំពីសារៈសំខាន់នៃជំនាញសម្របសម្រួល
៣. រៀបរាប់ពីដំណើរការសម្របសម្រួលកិច្ចប្រជុំក្រុមប្រឹក្សា
៤. កំណត់តួនាទីអ្នកសម្របសម្រួលល្អក្នុងកិច្ចប្រជុំ ។

**លទ្ធផលរំពឹងទុក**: នៅចុងបញ្ចប់នៃមេរៀនអ្នកចូលរួមៈ

១. យល់ និងរៀបរាប់បានអំពីអត្ថន័យនៃជំនាញសម្របសម្រួល
២. ពិពណ៌នាបានអំពីសារៈសំខាន់នៃជំនាញសម្របសម្រួល
៣. រៀបរាប់ពីដំណើរការសម្របសម្រួលកិច្ចប្រជុំក្រុមប្រឹក្សា
៤. យល់ដឹងពីតួនាទីក្នុងការសម្របសម្រួលកិច្ចប្រជុំ ។

## ២. និយមន័យនៃជំនាញសម្របសម្រួល:

**អ្វីទៅជាជំនាញសម្របសម្រួល?**

ជំនាញសម្របសម្រួល គឺជា**សិល្បៈ**នៃការដឹកនាំ មនុស្ស តាមរយៈ**ដំណើរការ** ឆ្ពោះទៅរកការឯកភាពគ្នាទៅលើគោលបំណងរួមក្នុងលក្ខណៈដែលមានការលើកទឹកចិត្តឱ្យមានការ**ចូលរួម** **ភាពម្ចាស់ការ** និង**ភាពច្នៃប្រឌិត**ពីគ្រប់អ្នកចូលរួមទាំងអស់ ។

- **សិល្បៈ** សំដៅដល់ភាពប៉ិនប្រសប់ ការសម្តែងទឹកមុខ អាកប្បកិរិយា ការនិយាយស្តី
- **ដំណើរការ** : ក្នុងការរៀបចំតាក់តែងវិធី ឬសកម្មភាពផ្សេងៗ ដើម្បីសម្រេចគោលបំណង/ទិសដៅរួមបានដោយជោគជ័យ ។
- **ការចូលរួម** : អនុញ្ញាតិឱ្យអ្នកចូលរួមបានផ្តល់ជាគំនិត ឬយោបល់ បទពិសោធន៍ផ្សេងៗ របស់ពួកគេនៅក្នុងដំណើរការសម្របសម្រួល ។
- **ភាពម្ចាស់ការ** : អ្នកចាត់ចែង និងទទួលខុសត្រូវក្នុងការពិភាក្សា ឬធ្វើផែនការ
- **ភាពច្នៃប្រឌិត** : ការផ្តួចផ្តើមនូវអ្វីដែលថ្មី ។

## ៣. សារៈប្រយោជន៍នៃជំនាញសម្របសម្រួល

ការសម្របសម្រួលមួយ ដោយមិនបានឆ្លងកាត់វគ្គសិក្សា ឬមិនមានជំនាញ អាចនឹងធ្វើឱ្យការសម្របសម្រួលនោះមិនបានល្អ មានកំហុសឆ្គងច្រើន អ្នកស្តាប់គឺមិនមានអារម្មណ៍ និងយកចិត្តទុកដាក់ស្តាប់ ។ ភាពប៉ិនប្រសប់ និងជំនាញសម្របសម្រួលជួយឱ្យក្រុមប្រឹក្សាអនុវត្តការងារប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ព្រោះៈ

- ទទួលបានការគាំទ្រពីអ្នកចូលរួម ដោយសារត្រៀមលក្ខណៈបានល្អ ទាំងរៀបចំខ្លឹមសារ ពាក្យពេចន៍ដែលប្រើប្រាស់មានមូលដ្ឋានត្រឹមត្រូវ បានយល់ច្បាស់អំពីដំណើរការនៃជំនាញសម្របសម្រួល មានភាពជឿជាក់ មិនបង្ហាញនូវភាពតក់ស្លុត ឬភ័យខ្លាច នៅពេលចុះពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ
- បានលើកទឹកចិត្តប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធចូលរួមតាមការស្វែងយល់ពីបញ្ហា ក្តីកង្វល់ តម្រូវការជាអាទិភាព ប្រមូលយោបល់ត្រលប់ ការបង្ហាញពីផែនការសកម្មភាព ការរៀបចំថវិកាសម្រាប់ការអភិវឌ្ឍមូលដ្ឋាន ផ្សព្វផ្សាយព័ត៌មាន កិច្ចប្រជុំនានា និងការពិគ្រោះយោបល់នៅមូលដ្ឋានរបស់ក្រុមប្រឹក្សា នេះគឺការឆ្លុះបញ្ចាំងអំពីអភិបាលកិច្ចល្អ : តម្លាភាព គណនេយ្យភាព និងការឆ្លើយតប ព្រោះបានឆ្លើយតប និងស្រាយបញ្ហា និងប្រមូលយោបល់ត្រលប់
- កាយវិការ អាកប្បកិរិយាបានសមសួន មានការគោរព យកចិត្តទុកដាក់ដល់អ្នកស្តាប់ អ្នកចូលរួម
- បង្ហាញឱ្យអ្នកចូលរួមឃើញនូវផលប្រយោជន៍ ដែលជាវិធីសាស្ត្រមួយដ៏សំខាន់ក្នុងការទាក់ទាញឱ្យអ្នកស្តាប់ អ្នកចូលរួមយកចិត្តទុកដាក់ មិនបែកអារម្មណ៍ ព្រោះគិតថា នេះគាត់ជាចំណែកមួយក្នុងការទទួលបាននូវប្រយោជន៍ទាំងនោះ ។
- ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធមានភាពម្ចាស់ការ ដោយសារអ្វីៗគឺជារបស់គាត់ ដូច្នេះហើយ ទើបគាត់ចូលរួមគាំទ្រ និងជួយដោយពេញលេញក្នុងសកម្មភាពរបស់ក្រុមប្រឹក្សា ព្រោះតែគាត់គឺជាចំណែកមួយនៃផលប្រយោជន៍ ហើយសកម្មភាពនានាមិនមែនជាបន្ទុកតែក្រុមប្រឹក្សាឃុំ សង្កាត់ ឬស្រុក ក្រុងឡើយ ។

## ៤. តើតួនាទីអ្នកសម្របសម្រួលល្អមានអ្វីខ្លះ?

អ្នកសម្របសម្រួលល្អ ជាដំបូងតែងតែគិតជាមុនពីៈ ប្រធានបទ (ផ្តោតលើអ្វី?) គោលបំណង (ចង់បានអ្វី?) ក្រុមគោលដៅ (ជាអ្នកណា?) ស្រាយបញ្ហា? (ហេតុអ្វី) ត្រូវធ្វើដូចម្តេច? ហើយត្រូវត្រៀមខ្លួនបែបណា? ដើម្បីសម្រេចគោលដៅតាមស្ថានភាពជាក់ស្តែង ។ អ្វីដែលបានរៀបរាប់ខាងលើ គ្រាន់តែជាតួនាទីទូទៅនៃអ្នកសម្របសម្រួលតែប៉ុណ្ណោះ តែចំពោះអ្វីដែលផ្តោតពេលនេះ គឺផ្តោតលើការសម្របសម្រួលដែលមានប្រសិទ្ធភាព ដើម្បីលើកកម្ពស់ លើកទឹកចិត្តប្រជាពលរដ្ឋឱ្យមានការចូលរួមកាន់តែសកម្មក្នុងការផ្សព្វផ្សាយអប់រំ វេទិកាផ្សព្វផ្សាយព័ត៌មាន និងពិភាក្សាពិគ្រោះយោបល់ហើយរិះរកវិធី

សាស្ត្រសមស្របណាមួយ ដើម្បីបង្ហាញឱ្យប្រជាពលរដ្ឋមើលឃើញនិងយល់ថា គាត់មានចំណែកក្នុងការទទួលបាននូវប្រយោជន៍ដែលជាសកម្មភាពអនុវត្តដោយក្រុមប្រឹក្សា។ តួនាទីសំខាន់ៗនៃអ្នកសម្របសម្រួលមានរៀបរាប់ដូចខាងក្រោម៖

- **មុនពេល : មានកត្តាសំខាន់ចំនួន៥៖**

   **១. ប្រធានបទ** (តើនឹងសម្រួមសម្រួលអំពីអ្វី?) លើកកម្ពស់ លើកទឹកចិត្តប្រជាពលរដ្ឋឱ្យមានការចូលរួមកាន់តែសកម្ម ក្នុងការផ្សព្វផ្សាយអប់រំ និងវេទិកាផ្សព្វផ្សាយព័ត៌មាននិងពិភាក្សាពិគ្រោះយោបល់។

   **២. អ្នកណា** (ក្រុមគោលដៅដែលត្រូវសម្របសម្រួល) ប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន

   **៣. ហេតុអ្វី** ត្រូវហៅពួកគាត់មកចូលរួម? ដើម្បីចង់ដឹងនូវបញ្ហាក្ដីកង្វល់ និងយោបល់ត្រលប់។

   **៣. ខ្លឹមសារ** អ្វីដែលត្រូវយកទៅចែករំលែក? ឧទាហរណ៍ គោលបំណងរបស់មេរៀននេះគឺ **ការលើកកម្ពស់លើកទឹកចិត្តប្រជាពលរដ្ឋ** ដូច្នេះដើម្បីលើកទឹកចិត្តគាត់បានលុះត្រាតែយើងធ្វើឱ្យគាត់យល់ពី៖

   - សារៈសំខាន់នៃការគាំទ្ររបស់ពួកគាត់ក្នុងការងារផ្សព្វផ្សាយអប់រំ និងការចូលរួមនៅក្នុងវេទិកាផ្សព្វផ្សាយព័ត៌មាននិងពិគ្រោះយោបល់
   - ផ្ដល់នូវគោលគំនិតសំខាន់ៗ អំពីមធ្យោបាយ និងការបើកទូលាយឱ្យប្រជាពលរដ្ឋចូលរួម
   - ប្រាប់ថាអ្នកណាខ្លះអាចចូលរួមក្នុងការផ្សព្វផ្សាយអប់រំ និងការចូលរួមនៅក្នុងវេទិកាផ្សព្វផ្សាយព័ត៌មាននិងពិគ្រោះយោបល់។
   - តើព័ត៌មានអ្វីខ្លះ ដែលនឹងយកទៅផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋបានដឹង? ឧទាហរណ៍
     - តម្លៃសេវាសាធារណៈ
     - ការសម្រេចចិត្តរបស់ក្រុមប្រឹក្សា
     - ផែនការអភិវឌ្ឍក្រុង ស្រុក និងឃុំ សង្កាត់ ។ល។

   **៤. កំណត់គោលដៅ គោលបំណងផ្ទាល់ខ្លួន :** គិតអំពីវិធីសាស្ត្រដែលនឹងយកមកប្រើដើម្បីឱ្យការសម្របសម្រួលមានប្រសិទ្ធភាព ពាក្យសម្ដី ពាក្យពេចន៍ សារ កាយវិការ និងអាកប្បកិរិយា។ល។

   **៥. រៀបចំតាក់តែង:**គឺជាការរៀបចំប្លង់សម្របសម្រួល ដែលប្លង់នេះ អាចបត់បែន អាស្រ័យទៅតាមស្ថានភាពជាក់ស្ដែង (ធម្មតា ឬផ្លូវការ) តែគួរផ្ដោតសំខាន់លើ៖

   - វិធីសាស្ត្រ (ប្រភេទនៃការពិភាក្សា ក្រុមតូច ក្រុមធំ)
   - ការលើកទឹកចិត្ត (ធ្វើយ៉ាងម៉េចឱ្យអ្នកចូលរួមបានចូលរួមផ្ដល់មតិយោបល់)
   - ពេលវេលា គ្រប់គ្រាន់សម្រាប់ការពិភាក្សា ផ្ដល់ពេលស្មើគ្នាដល់អ្នកចូលរួម ដោយគ្មានការរើសអើង
   - បង្កឱ្យមានបរិយាកាសរីករាយ ដូចជាការនិយាយរឿងទាក់ទងនឹងប្រធានបទ

- **អំឡុងពេល : មានកត្តាសំខាន់ដូចខាងក្រោម៖**

- គ្រប់គ្រងការពិភាក្សា និងបុគ្គលិកលក្ខណៈរបស់អ្នកចូលរួម
    - ធានាថា អ្នកចូលរួមគ្រប់រូបបានបញ្ចេញយោបល់ និងចែករំលែកព័ត៌មាន
    - លើកទឹកចិត្តឱ្យអ្នកចូលរួមសួរសំណួរ
    - ត្រួតពិនិត្យពេលវេលា
    - រក្សាការពិភាក្សាឱ្យចំប្រធានបទ
    - ស្តាប់ និងសង្ខេបយោបល់អ្នកចូលរួម
    - ធានាថា មានការព្រមព្រៀងលើសេចក្តីសម្រេចចិត្ត និងបានកត់ត្រា

**ក្រោយពេល: សូមអនុវត្តតាមជំហានដូចខាងក្រោម៖**

- ធ្វើកំណត់ហេតុ ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត
- ពិនិត្យកំណត់ហេតុ និងអនុម័ត
- ចាត់អាទិភាពបញ្ហា ក្តីកង្វល់ ហើយស្នើសុំការគាំទ្រពីស្ថាប័នពាក់ព័ន្ធ ក្នុងការផ្តល់ការឆ្លើយតបនៅក្នុងកិច្ចប្រជុំលើកក្រោយ និងកែលម្អការងារផ្ទៃក្នុង
- ផ្សព្វផ្សាយនូវអ្វីដែលជាសេចក្តីសម្រេចនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាដល់ប្រជាពលរដ្ឋដោយបិទផ្សាយលើក្តារព័ត៌មាន។

សម្របសម្រួលត្រូវមានការទទួលខុសត្រូវដើម្បីប្រសិទ្ធផលការងារសម្រេចបានទៅតាមទិសដៅ និងផែនការ។

## កត្តាសំខាន់ៗដែលគួរយល់ដឹង អ្នកសម្របសម្រួលត្រូវ៖

១. បង្ហាញ ឬញែកយ៉ាងច្បាស់អំពីភាពខុសគ្នារវាងគ្រូបង្រៀន បណ្តុះបណ្តាល និងអ្នកសម្របសម្រួល

២. ចរិតលក្ខណៈ អាកប្បកិរិយា របស់អ្នកសម្របសម្រួលល្អមានអ្វីខ្លះ?

៣. ត្រូវជំនាញយ៉ាងម៉េច?

៤. ប្រើប្រាស់វិធីសាស្ត្រ ឧបករណ៍អ្វី?

៥. មានប្រការអ្វីខ្លះគួរជៀសវាង?

សូមមើលតារាងខាងក្រោម៖

### ភាពខុសគ្នារវាងគ្រូបណ្តុះបណ្តាល និងអ្នកសម្របសម្រួល

| គ្រូបណ្តុះបណ្តាល | អ្នកសម្របសម្រួល |
|---|---|
| ▪ ផ្តល់ចំណេះដឹងនិងទ្រឹស្តី | ▪ ផ្តល់ដំណើរការ ឬ នីតិវិធី |
| ▪ មានការបត់បែនតិចដើម្បីសម្រេចគោលបំណង | ▪ ដើម្បីសម្រេចគោលបំណងរបស់សិក្ខាកាម |

| | |
|---|---|
| ▪ ស្តាប់តិចនិយាយច្រើន | ▪ ស្តាប់ច្រើននិយាយតិច |
| ▪ មានចំណេះដឹងស៊ីជម្រៅទៅលើប្រធានបទអ្វីមួយ | ▪ មានចំណេះដឹងក្នុងការប្រើប្រាស់វិធីសាស្ត្រច្រើន |
| ▪ ប្រាប់ពីអ្វីដែលត្រូវធ្វើ | ▪ បង្ហាញពីរបៀប ឬរបៀបនៃការគិតដើម្បីធ្វើ |
| ▪ វិនិច្ឆ័យថាខុសឬត្រូវ ល្អឬអាក្រក់ | ▪ ផ្តល់នីតិវិធីរបៀបនៃការគិតដើម្បីធ្វើ |
| ▪ យកចិត្តទុកដាក់បែងចែកភាពខុសនិងត្រូវ | ▪ លើកទឹកចិត្ត និងមិនវិនិច្ឆ័យទៅលើគំនិតចូលរួម |
| ▪ មានឋានៈខ្ពស់ជាងសិស្ស | ▪ ចាត់ទុកគ្រប់គ្នាមានភាពស្មើគ្នា |

| **អាកប្បកិរិយា** | **ជំនាញ** | **វិធីសាស្ត្រ និងឧបករណ៍** |
|---|---|---|
| • មានទឹកមុខរីករាយ<br>• មានចិត្តអត់ធ្មត់<br>• ចេះអត់ឱន<br>• ព្យាយាមរៀនសូត្រ<br>• មានភាពស្និទ្ធស្នាល<br>• ផ្តល់ការគោរពដល់អ្នកដទៃ<br>• មិនវិនិច្ឆ័យគំនិតអ្នកចូលរួម<br>• ជាគំរូល្អដល់អ្នកដទៃ<br>• ទទួលខុសត្រូវ<br>• រួសរាយរាក់ទាក់ ហើយយល់ដឹងស៊ីជម្រៅ | • ធ្វើឱ្យមានការចូលរួម<br>• ចេះសង្ខេប និងសំយោគគំនិតអ្នកចូលរួម<br>• ចេះរៀបចំចាត់ចែងដំណើរការ និងគ្រប់គ្រងពេលវេលា<br>• ប្រាស្រ័យទាក់ទង<br>• ចេះស្តាប់<br>• ចេះសង្កេត<br>• ធ្វើការឡើងបង្ហាញ<br>• ចេះសួរ<br>• លើកទឹកចិត្ត<br>• ដោះស្រាយបញ្ហា<br>• ផ្តល់យោបល់ត្រឡប់ | • បង្កើត និងប្រើប្រាស់សម្ភារជំនួយ<br>• ចេះកំប្លុកកំប្លែង<br>• ចេះបត់បែន<br>• បង្កើតកិច្ចតែងការ<br>• បង្កើត និងប្រើប្រាស់វិធីសាស្ត្រៈ<br>- បំផុសគំនិត<br>- ក្រុមតូច<br>- ការងារជាដៃគូ<br>- ការនិទានរឿង<br>- ល្បែងថាមពល<br>- ការដើរគយគន់<br>- ការសម្ភាសន៍ |

<u>សំគាល់:</u>

✓ វិធីសាស្ត្រមួយចំនួនមិនអាចប្រើប្រាស់ជាមួយការប្រជុំក្រុមប្រឹក្សាទេ ប៉ុន្តែអាចប្រើជាមួយការធ្វើវេទិកាសាធារណៈ ពិគ្រោះយោបល់ និងផ្សព្វផ្សាយព័ត៌មាន សិក្ខាសាលា និងការប្រជុំជាមួយប្រជាពលរដ្ឋ។

✓ ចំណុចដែលអ្នកសម្របសម្រួលគួរជៀសវាងៈ

១. មិនវាយតម្លៃគំនិតរបស់អ្នកចូលរួម

២. របៀបវារៈ និងគំនិតផ្ទាល់ខ្លួនតែងតែត្រឹមត្រូវ

៣. និយាយលើសលប់អ្នកដទៃ

៤. អានតាមតែឯកសារ

៥. និទាន ឬនិយាយរឿងមិនសមរម្យ

៦. និយាយហួសពីការពិត

៧. អនុញ្ញាតឱ្យសិក្ខាកាមចាប់កំហុសគ្នា

៨. លម្អៀងទៅក្រុមណាមួយ

៩. រើសអើងសិក្ខាកាមផ្អែកលើអាការៈខាងក្រៅ

១០. និយាយពីបទពិសោធន៍ និងប្រវត្តិផ្ទាល់ខ្លួនច្រើនពេក

## ៦. សេចក្តីសន្និដ្ឋាន

ការសម្របសម្រួលដែលមានប្រសិទ្ធភាព នឹងជួយឱ្យក្រុមប្រឹក្សាក្រុង ស្រុក និងឃុំ សង្កាត់ អាចបំពេញតួនាទីខ្លួនបានល្អ ប្រកបដោយជោគជ័យ ក្នុងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការផ្សព្វផ្សាយអប់រំ វេទិកាផ្សព្វផ្សាយព័ត៌មាន និងពិភាក្សាពិគ្រោះយោបល់ ។

« **អ្នកដែលមានទេពកោសល្យខាងសម្របសម្រួល តែងតែឆ្លុះបញ្ចាំងខ្លួនឯងជានិច្ចទៅលើវិធីសាស្ត្រ អាកប្បកិរិយា ឥរិយាបថ ខ្លឹមសារ និងពេលវេលា** »

# ថ្ងៃទី៣

# ម្លង់មេរៀនទី៣

## ចំណងជើងមេរៀនៈ ប្រសិទ្ធភាពនៃការកសាងភាពជាដៃគូ

**ពេលវេលាៈ** ១០:៣០ ដល់ ១១:៣០ (៦០នាទី)

**គោលបំណងនៃមេរៀនៈ នៅចុងបញ្ចប់មេរៀននេះអ្នកចូលរួមអាចៈ**

១. ពន្យល់បានអំពី**អត្ថន័យ**ភាពជាដៃគូ និងរៀបរាប់បានពី**សារៈប្រយោជន៍**នៃការកសាងភាពជាដៃគូ ។

២. **កំណត់សមាសភាព**ដៃគូសំខាន់ៗរបស់ក្រុមប្រឹក្សាក្នុងការអនុវត្តគម្រោង "ការរៀនសូត្រពីការអនុវត្តអភិបាលកិច្ចល្អ នៅថ្នាក់ក្រុង ស្រុក ឃុំ និងសង្កាត់" ។

៣. **កំណត់ និងឯកភាព**លើសកម្មភាពនៃការកសាងភាពជាដៃគូ ។

៦សកម្មភាព ការបំផុសគំនិត ពិភាក្សាក្រុមធំ ពិភាក្សាក្រុមតូច

## កំណត់ចំណាំរបស់អ្នកសម្របសម្រួល

១. ក្រុមប្រឹក្សា ពិសេសក្រុមប្រឹក្សាឃុំ សង្កាត់មានបទពិសោធន៍យ៉ាងច្រើនក្នុងការអនុវត្តការងារក្នុងភាពជាដៃគូជាមួយស្ថាប័ននានា ពិសេសជាមួយអង្គការសហគមន៍មូលដ្ឋាន (គណៈកម្មការកៀរគរសហគមន៍) និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការអនុវត្តសកម្មភាពអភិវឌ្ឍមូលដ្ឋាន ដូច្នេះអ្នកសម្របសម្រួល គួរព្យាយាមឆ្លុះបញ្ចាំងបទពិសោធន៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពង្រឹងភាពជាដៃគូក្នុងការអនុវត្តគម្រោងបន្ត ។

២. អង្គការសហគមន៍មូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលមានចំនួនច្រើន និងមានបទពិសោធន៍យ៉ាងច្រើនដែលអាចចូលរួមចំណែក ឬជួយគាំទ្រក្រុមប្រឹក្សាក្នុងការអនុវត្ត និងតាមដានគម្រោង ដូចជាការពង្រឹងសមត្ថភាព ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងថវិកាផងដែរ ។ ដូចគ្នាដែរ អ្នកផ្តល់សេវាឯកជនក៏មានការរីកចំរើនទាំងបរិមាណ និងគុណភាពនៃការផ្តល់សេវា ដូច្នេះអ្នកសម្របសម្រួលគួរយកចិត្តទុកដាក់ ដោយឆ្លុះបញ្ចាំងដើម្បីទាញយកធនធានដែលស្ថាប័នទាំងនោះមកជួយ ក្រុមប្រឹក្សាក្នុងការអនុវត្តគម្រោង ។

៣. អ្នកសម្របសម្រួលគួរផ្តោតយកចិត្តទុកដាក់ឱ្យក្រុមប្រឹក្សាមានភាពដៃគូជាមួយ**អ្នកសារព័ត៌មាន** ព្រោះថាពួកគាត់គឺជាតួអង្គក្នុងការតាមដាន និងគាំទ្រការអនុវត្តតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាដើម្បីលើកកម្ពស់តម្លាភាព និងគណនេយ្យភាព ។

៤. អ្នកសម្របសម្រួលអាចយោង (តារាងស្តីពីតួនាទី និងភារកិច្ចរបស់អ្នកដែលពាក់ព័ន្ធសំខាន់ក្នុងការអនុវត្តគម្រោង នៅក្នុងមេរៀនទី៩ **សិទ្ធិ និងតួនាទីរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ** ថ្ងៃទី១) ដើម្បីកំណត់ពីសមាសភាពដៃគូសំខាន់ៗក្នុងការអនុវត្តគម្រោង ។

**លទ្ធផលរំពឹងទុកនៃមេរៀន**

១. អ្នកចូលរួមបានយល់ពីអត្ថន័យភាពជាដៃគូ និងសារៈប្រយោជន៍នៃការកសាងភាពជាដៃគូ ។
២. ក្រុមប្រឹក្សាដឹង និងកំណត់បានពីសមាសភាពដៃគូសំខាន់ៗក្នុងការអនុវត្តគម្រោង “ការរៀនសូត្រពីការអនុវត្តអភិបាលកិច្ចល្អនៅថ្នាក់ក្រុង ស្រុក ឃុំ និងសង្កាត់” ។
៣. ក្រុមប្រឹក្សា អង្គការសង្គមស៊ីវិល និងអ្នកសារព័ត៌មានបានដឹងពីជំហានទាំង១១ក្នុងការកសាងភាពជាដៃគូ ។
៤. ក្រុមប្រឹក្សាឯកភាពលើសកម្មភាពសម្រាប់អនុវត្តក្នុងការកសាងភាពជាដៃគូ ។

## សម្ភារឧបទេសសម្រាប់បង្រៀន

- ឯកសារមេរៀន ស្តីពីការកសាងភាពជាដៃគូ
  - បទបង្ហាញ
  - ឯកសាចែក
- ហ្វឺតសរសេរក្រដាស ក្រដាសផ្ទាំងធំ ស្កុត
- កុំព្យូទ័រយួរដៃ និងម៉ាស៊ីនបញ្ចាំងឯកសារបទបង្ហាញ

## ឯកសារយោង

- សៀវភៅណែនាំអំពីការកសាងភាពជាដៃគូ បោះពុម្ពដោយអង្គការផេកកម្ពុជា

## របៀបសម្របសម្រួលមេរៀន

| ម៉ោង | <u>សកម្មភាព និងវិធីសាស្ត្រ</u> | សម្ភារ និង ឯកសារចែកជូន |
|---|---|---|
| ៥ នាទី | **<u>សកម្មភាពទី១ សេចក្តីផ្តើម និងគោលបំណងមេរៀន</u>**<br>**បទបង្ហាញក្រុមធំ** | 💻 ស្លាយទី២<br>🗐 ក្រដាសផ្ទាំងធំ |

| | | |
|---|---|---|
| | • អ្នកសម្របសម្រួលចាប់និយាយពី ភាពជាដៃគូគឺជាមធ្យោបាយដ៏ល្អប្រសើរបំផុតសម្រាប់ក្រុមប្រឹក្សា និងអង្គការសង្គមស៊ីវិលធ្វើការជាមួយគ្នាដើម្បីធ្វើឱ្យសហគមន៍មានភាពប្រសើរឡើង ។ ភាពជាដៃគូអាចជួយឱ្យក្រុមប្រឹក្សាមានលទ្ធភាពបង្កើននូវសេវាកម្មនានាដែលត្រូវផ្តល់ដល់ប្រជាពលរដ្ឋ និងធនធានដែលអាចរកបាន បង្កើនការចូលរួម ការសម្របសម្រួល និងការអនុវត្តគម្រោង ។ ដូច្នេះមេរៀនទី៣នេះនឹងពិភាក្សាអំពី (១) អត្ថន័យនៃភាពជាដៃគូ (២) តើក្រុមប្រឹក្សាគួរចាប់ដៃគូជាមួយអ្នកពាក់ព័ន្ធណាខ្លះ ដើម្បីអនុវត្តគម្រោងឱ្យមានប្រសិទ្ធភាព? (៣) តើក្រុមប្រឹក្សាទទួលបានសារៈប្រយោជន៍អ្វីខ្លះក្នុងការធ្វើការរួមគ្នាជាដៃគូ? ឬតើដៃគូនីមួយៗ ជួយគាំទ្រអ្វីខ្លះដល់ក្រុមប្រឹក្សាក្នុងការអនុវត្តគម្រោង? (៤) តើមានជំហាន ឬសកម្មភាពអ្វីខ្លះក្នុងដំណើរការកសាងភាពជាដៃគូ?<br>• អ្នកសម្របសម្រួលបង្ហាញគោលបំណងមេរៀន (ស្លាយទី២) | 🖉 ហ្វឺតកត់ត្រាចម្លើយ និងបង់ស្អិត |
| ១០ នាទី | <u>**សកម្មភាពទី២ - អត្ថន័យភាពជាដៃគូ និងលក្ខណៈដៃគូដែលជោគជ័យ**</u><br>**សំណួរបំផុសគំនិត និងពិភាក្សាក្រុមធំ**<br>• អ្នកសម្របសម្រួលសួរសំណួរ និងផ្តល់ឱកាសឱ្យអ្នកចូលរួមចំនួន៣នាក់ឆ្លើយ “តើភាពជាដៃគូមានន័យដូចម្តេច?”<br>• កត់ត្រាចម្លើយអ្នកចូលរួម<br>• បង្ហាញអត្ថន័យភាពជាដៃគូ និងលក្ខណៈដៃគូដែលទទួលជោគជ័យ ដោយអនុញ្ញាតិឱ្យអ្នកចូលរួមសួរបញ្ជាក់ និងចែករំលែកបទពិសោធន៍ | 💻 ស្លាយទី៣-៤<br>🗐 ក្រដាសផ្ទាំងធំ<br>🖉 ហ្វឺតកត់ត្រាចម្លើយ និងបង់ស្អិត |
| ១៥ នាទី | <u>**សកម្មភាពទី៣ - សមាសភាពដៃគូរបស់ក្រុមប្រឹក្សា**</u><br>**សំណួរបំផុសគំនិត និងពិភាក្សាក្រុមធំ**<br>• អ្នកសម្របសម្រួលសួរបំផុសគំនិតដល់អ្នកចូលរួម ថាកន្លងមកតើក្រុមប្រឹក្សាធ្លាប់មានដៃគូជាមួយនរណាខ្លះនៅមូលដ្ឋាន?<br>• ផ្តល់ឱកាសឱ្យអ្នកចូលរួមចំនួន៣នាក់ឆ្លើយសំណួរខាងលើ | 💻 ស្លាយទី៥-៩<br>🗐 ក្រដាសផ្ទាំងធំ<br>🖉 ហ្វឺតកត់ត្រាចម្លើយ និងបង់ស្អិត |

| | | |
|---|---|---|
| | • កត់ត្រាចម្លើយអ្នកចូលរួម<br>• បង្ហាញពីសមាសភាពដៃគូនៅក្នុងមូលដ្ឋាន (ស្លាយទី៥ដល់៩)<br>• អ្នកសម្របសម្រួលសួរសំណួរថាតើមានដៃគូ **<u>ចំបង១ណាខ្លះ? នៅក្នុងមូលដ្ឋានលោកអ្នកហើយដៃគូទាំងនោះជួយគាំទ្រអ្វីខ្លះ</u>** ក្នុងការអនុវត្តគម្រោង<br>• អ្នកសម្របសម្រួលអាចរំលឹកឡើងវិញពីសកម្មភាពការងាររបស់គម្រោង "ការរៀនសូត្រពីការអនុវត្តគម្រោងអភិបាលកិច្ចល្អនៅថ្នាក់ក្រុង ស្រុក ឃុំ និងសង្កាត់" មេរៀនទី១ ថ្ងៃទី១ ស្លាយទី៧ និង៨<br>• អ្នកសម្របសម្រួលឆ្លុះបញ្ចាំងចម្លើយលើក្រដាសផ្ទាំងធំ<br>• អ្នកសម្របសម្រួលបូកសរុប | |
| ១០នាទី | **<u>សកម្មភាពទី៤ សារៈប្រយោជន៍នៃការកសាងភាពជាដៃគូ និងសកម្មភាពជាដៃគូ</u>**<br>**សំណួរបំផុសគំនិត និងពិភាក្សាក្រុមធំ**<br>• អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យអ្នកចូលរួមចំនួន៣នាក់ឆ្លើយសំណួរ **តើក្រុមប្រឹក្សាទទួលបានសារៈប្រយោជន៍អ្វីខ្លះក្នុងការធ្វើការរួមគ្នាជាដៃគូ? ឬតើដៃគូនីមួយៗ ជួយគាំទ្រអ្វីខ្លះដល់ក្រុមប្រឹក្សាក្នុងការអនុវត្តគម្រោង?**<br>• កត់ត្រាចម្លើយអ្នកចូលរួម<br>• អ្នកសម្របសម្រួលបង្ហាញពីសារៈប្រយោជន៍នៃការកសាងភាពជាដៃគូ និងសកម្មភាពរបស់ក្រុមប្រឹក្សាអាចធ្វើការជាមួយដៃគូ ដោយអនុញ្ញាតិឱ្យអ្នកចូលរួមសួរបញ្ជាក់ និងចែករំលែកបទពិសោធន៍ជាក់ស្តែង (ស្លាយទី១០-១២) | 💻 ស្លាយទី១០-១២<br>🗐 ក្រដាសផ្ទាំងធំ<br>✎ ហ្វឺតកត់ត្រាចម្លើយ និងបង់ស្អិត |

| | | |
|---|---|---|
| ១៥ នាទី | **<u>សកម្មភាពទី៥ - សកម្មភាព ឬជំហានកសាងភាពជាដៃគូ</u>**<br>**ពិភាក្សាក្រុមតូច**<br>• យើងបានកំណត់ពីដៃគូសម្រាប់ការអនុវត្តគម្រោង "ការរៀនសូត្រពីការអនុវត្តអភិបាលកិច្ចល្អនៅថ្នាក់ក្រុង ស្រុក ឃុំ និងសង្កាត់"នៅសកម្មភាពទី៣ខាងលើ ដូច្នេះ យើងនឹងពិភាក្សាបន្តទៀតថា <u>តើមានកិច្ចការអ្វីខ្លះដែលត្រូវអនុវត្តសម្រាប់ការកសាងភាពជាដៃគូជាមួយក្រុមទាំងនោះ (ដៃគូចំនួនបីខាងលើ)?</u> ។<br>• អ្នកសម្របសម្រួលបង្ហាញបទបង្ហាញពីជំហានទាំង១១ ដោយបើកឱកាសឱ្យអ្នកចូលរួមសួរបញ្ជាក់ (ស្លាយទី១៣-២៣)<br>• ចែកសិក្ខាកាមជា៤ក្រុម ពិភាក្សាលើសំណួរ តើមានកិច្ចការអ្វីខ្លះដែលត្រូវអនុវត្តសម្រាប់ជំហាននីមួយៗនៃការកសាងភាពជាដៃគូជាមួយក្រុមទាំងអស់<u>(ដៃគូចំនួនបីខាងលើ)?</u> ដែលបានកំណត់ក្នុងសកម្មភាពទី៣ (ការកំណត់ដៃគូចំបងៗក្នុងក្រុមពិភាក្សា)?<br>• អ្នកសម្របសម្រួល**<u>បូកសរុបលទ្ធផល</u>**ក្រុមដោយស្រង់ចេញពីលទ្ធផលក្រុមពិភាក្សា ហើយយកលទ្ធផលទៅ**<u>ពិភាក្សា និងឯកភាព</u>**ជាមួយអ្នកចូលរួម ។ លទ្ធផលបូកសរុបរបស់ក្រុមពិភាក្សាដែលបាន**<u>ពិភាក្សា និងឯកភាព</u>**នឹងយកទៅដាក់ក្នុង ផែនការសកម្មភាព មេរៀនទី៤ ការរៀបចំផែនការសកម្មភាព ។ | 💻 ស្លាយទី១៣-២៣<br>🗐 ក្រដាសផ្ទាំងធំ<br>🖉 ហ្វឺតកត់ត្រាចម្លើយ និងបង់ស្អិត |
| ៥ នាទី | **<u>សកម្មភាពទី៦ បូកសរុប</u>**<br>• យើងបានពិភាក្សាពីអត្ថន័យ សមាសភាព និងសារៈប្រយោជន៍នៃភាពជាដៃគូ<br>• ហើយក៏បានកំណត់ និងឯកភាពពីកិច្ចការដែលត្រូវអនុវត្តសម្រាប់ការកសាងភាពជាដៃគូផងដែរ ហើយលទ្ធផលទាំងនេះនឹងយកទៅដាក់បញ្ចូលក្នុងផែនការសកម្មភាពនៅមេរៀនទី៤ស្តីពីការរៀបចំផែនការសកម្មភាព ។ | 🗐 ក្រដាសផ្ទាំងធំដែលកត់ត្រាចម្លើយរបស់អ្នកចូលរួម |

ថ្ងៃទី៣មេរៀនទី៣

# ប្រសិទ្ធភាពនៃ
# ការកសាងភាពជាដៃគូ

# គោលបំណងនៃមេរៀន

១. ពន្យល់បានពីអត្ថន័យនៃភាពជាដៃគូ និងរៀបរាប់បានពីសារៈសំខាន់នៃការកសាងភាពជាដៃគូ ។

២. កំណត់សមាសភាពដៃគូសំខាន់ៗរបស់ក្រុមប្រឹក្សាក្នុងការអនុវត្តគម្រោង "ការរៀនសូត្រពីការអនុវត្តអភិបាលកិច្ចល្អនៅថ្នាក់ក្រុង ស្រុក ឃុំ និងសង្កាត់" ។

៣. កំណត់ និងឯកភាពលើសកម្មភាពនៃការកសាងភាពជាដៃគូ ។

# តើភាពជាដៃគូមានន័យដូចម្តេច?

ភាពជាដៃគូ មានច្រើនប្រភេទខុសៗគ្នា។ ជាទូទៅ ភាពជាដៃគូធ្វើឡើងដើម្បីសម្រេចកិច្ចការណាដែលមិនអាចធ្វើតែឯកឯងបាន ឬចាំបាច់ត្រូវធ្វើការរួមគ្នាដើម្បីទទួលលទ្ធផលល្អប្រសើរជាងធ្វើការតែឯកឯង។

# លក្ខណៈដៃគូដែលទទួលជោគជ័យ

**ការទំនាក់ទំនង** - ដៃគូដែលជោគជ័យត្រូវការទាក់ទងគ្នាទៅវិញទៅមក ដោយស្មោះត្រង់ និងដោយឥតលាក់លៀម

**ការសិក្សា** - ដៃគូដែលជោគជ័យត្រូវរៀនសូត្រពីគ្នាទៅវិញទៅមក

**ការប្តេជ្ញាចិត្ត** - ដៃគូដែលជោគជ័យត្រូវមានគោលដៅរួម និងប្តេជ្ញាចិត្តរួមគ្នាដើម្បីសំរេចគោលដៅ

**ការគាំទ្រ** - ដៃគូដែលជោគជ័យត្រូវទុកចិត្តគ្នា គោរពគ្នា និងគាំទ្រគ្នាវិញទៅមក

# ដៃគូនៅមូលដ្ឋាន

**ក្រុមប្រឹក្សាដូចគ្នា** - ជួនកាលក្រុមប្រឹក្សាមួយមិនមានធនធានខ្លួនឯងគ្រប់គ្រាន់សម្រាប់អនុវត្តន៏គម្រោងរបស់ខ្លួនទេ តែអាចធ្វើបានបើសិនជាឃុំសង្កាត់ពីរ ឬច្រើនចូលរួមគ្នាអនុវត្ត ដោយហេតុថាក្រុមប្រឹក្សាឃុំ សង្កាត់ផ្សេងទៀតអាចមានប្រភពធនធានមានតម្លៃ មានគំនិតយោបល់ និងបទពិសោធន៏ល្អៗផ្សេងៗគ្នា ។

**ស្ថាប័នរដ្ឋាភិបាល** - កិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងជាមួយស្ថាប័នរដ្ឋាភិបាលថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិ មានសារសំខាន់ណាស់សម្រាបកិច្ចការទាំងអស់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

# ដៃគូនៅមូលដ្ឋាន (ត)

**អង្គការមិនមែនរដ្ឋាភិបាល** - ទាំងអង្គការជាតិ និងអង្គការអន្តរជាតិមានបទពិសោធន៍ច្រើនក្នុងការងារអភិវឌ្ឍន៍ដោយធ្វើការជាមួយសហគមន៍ ដើម្បីសម្រេចនូវគោលបំណងរបស់ពួកគេ។ មានអង្គការខ្លះធ្វើការងារផ្តោតទៅលើវិស័យមួយចូបជាៈ ផ្នែកសុខភាព អបរំ សិទ្ធិមនុស្ស ហើយមានអង្គការខ្លះធ្វើការងារផ្តោតលើវិស័យច្រើនលើគម្រោងអភិវឌ្ឍន៍សហគមន៍។

**អង្គការសហគមន៍មូលដ្ឋាន** - អង្គការសហគមន៍មូលដ្ឋាន ធនាគារជ្រូក ធនាគារគោ ធនាគារស្រូវ សហគមន៍ព្រៃឈើ ក្រុមសហគមន៍ប្រើប្រាស់ទឹកស្អាត និងក្រុមជួយខ្លួនឯង គឺជាផ្នែកសំខាន់នៃអង្គការសហគមន៍មូលដ្ឋាន ហើយសមាជិកដែលចូលរួមក្នុងក្រុមទាំងនោះមកពីភូមិនានានៅក្នុងឃុំ។

# ដៃគូនៅមូលដ្ឋាន (ត)

**សមាគមព្រះសង្ឃនិងវត្តអារាម** -វត្តអារាមជាកន្លែងយ៉ាងប្រពៃ និងសំខាន់សម្រាបប្រជាពលរដ្ឋរសនៅក្នុងភូមិធ្វើសក្ការះបូជា និងជាកន្លែងអង្គាសបច្ច័យដើម្បីគាំទ្រដលើការក៏សាងសមិទ្ធិផលផ្សេងៗ។

**ចាស់ព្រឹទ្ធាចារ្យ** - ចាស់ព្រឹទ្ធាចារ្យនៅក្នុងភូមិដូចជា លោកអសាចារ្យ មានឥទ្ធិពលខ្លាំងលើសេចក្តីសម្រេចចិត្តនានារបស់សហគមន៍។ គាត់គឺជាដៃគូយ៉ាងសំខាន់នៅពេលដែលចាំបាច់ ក្នុងការគៀរគរការគាំទ្រ ឬការចូលរួមនានាពីសហគមន៍។

# ដៃគូនៅមូលដ្ឋាន (ត)

**អាជីវកម្ម ឬវិនិយោគទុន** - ជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងសហគមន៍មូលដ្ឋាន ។ ពួកគេជាអ្នកបង្កើតការងារដល់ប្រជាពលរដ្ឋឱ្យមានការងារធ្វើ និងចូលរួមចំណែកជួយធ្វើឱ្យប្រសើរឡើងនូវសេដ្ឋកិច្ចនៅថ្នាក់មូលដ្ឋាន ។

**សមាគមន៍យុវជន** - ជាង ៤០ ភាគរយនៃប្រជាជនកម្ពុជាមានអាយុតិចជាង ១៥ឆ្នាំ ។ ដូច្នេះបញ្ហាដែលប៉ះពាល់ដល់យុវជន គឺជាបញ្ហាចំបងដែលត្រូវយកចិត្តទុកដាក់ ។ សហគមយុវជនជាវេទិកាដ៏ប្រសើរបំផុតក្នុងការគៀងគរការចូលរួមពីសមាជិកយុវជននៅក្នុងសហគមន៍ ។

# ដៃគូនៅមូលដ្ឋាន (ត)

**ក្រុមស្ត្រី** - ស្ត្រីមិនសូវមានតំណាងរបស់ខ្លួននៅគ្រប់ជាន់ថ្នាក់ក្នុងជួររដ្ឋាភិបាលនៅកម្ពុជា ប៉ុន្តែតួនាទី និងសំឡេងរបស់ស្ត្រីនៅក្នុងសង្គម គឺមានសារៈ សំខាន់ណាស់ ។ ក្រុមស្ត្រីអាចធ្វើឱ្យក្រុមប្រឹក្សាឃុំ សង្កាត់លើកទឹកចិត្ត និងការគាំទ្រការចូលរួមរបស់ស្ត្រីលើការផ្តួចផ្តើមគំនិតផ្សេងៗនៅមូលដ្ឋាន ។

**សមាគមកម្មករ** - មានដូចជាសមាគមកសិករ ក្រុមអាជីវករ សមាគមម្ចាស់មូតូឌុប សមាគមអ្នកជិះរ៉ឺម៉កកង់ ។ល ។ អាចផ្តល់នូវព័ត៌មានសំខាន់ៗឬជួយគាំទ្រនិងការអប់រំដល់សហគមន៍ ។

# សារៈប្រយោជន៍នៃការកសាងភាពជាដៃគូ

**កំណើនធនធាន** - ពេលណាដៃគូរួមគ្នា ពួកគេអាចដាក់បញ្ចូលធនធានជាមួយគ្នា។ ជាលទ្ធផលនឹងមានការកើនឡើងនូវធនធានមនុស្សចូលរួមក្នុងគម្រោង មានជំនាញផ្សេងៗច្រើន មានថវិកា សម្ភារៈច្រើនសំរាប់អនុវត្ត  គម្រោង។

**ការចូលរួមច្រើន** - ពេលដែលក្រុមប្រឹក្សា ចាប់ដៃគូជាមួយអង្គការសង្គមស៊ីវិល ដូចជាអង្គការក្រៅរដ្ឋាភិបាល ឬក្រុមសមាគមន៍នានា និងអ្នកសារពតិមាន នឹងលើកកម្ពស់ការចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាពលរដ្ឋក្នុងដំណើរការអនុវត្តគម្រោង

**សេវាកម្មល្អប្រសើរ** - ការធ្វើការរួមគ្នា ដៃគូអាចផ្តល់សេវាកម្មប្រកបដោយតម្លាភាព មានគណនេយ្យភាព និងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

# សារៈប្រយោជន៍នៃការកសាងភាពជាដៃគូ (ត)

**ការសម្របសម្រួលល្អប្រសើរ** - ជូនកាលទាំងក្រុមប្រឹក្សា អង្គការសង្គមស៊ីវិល ឬក្រុមសមាគមន៍នានា ធ្វើការដូចគ្នាក្នុងពេលតែមួយ ។ ក្រុមប្រឹក្សា និងក្រុមទាំងនោះសម្រេចធ្វើការក្នុងភាពជាដៃគូជាមួយគ្នា ពួកគេអាចសម្របសម្រួលការងារបានល្អ ហើយផ្តល់នូវផលប្រយោជន៍បានច្រើនដោយចំណាយថ្លៃដើមទាប ។

**គម្រោងអាចបញ្ចប់បានឆាប់រហ័ស** - ពេលដែលដៃគូធ្វើការរួមគ្នា ដើម្បីសម្រេចបាននូវគោលបំណងរួម ពួកគេអាចបញ្ចប់គម្រោងនោះបានឆាប់រហ័ស និងល្អប្រសើរជាងការអនុវត្តន៍គម្រោងម្នាក់ឯង ។

# សកម្មភាពរបស់ក្រុមប្រឹក្សាអាចធ្វើការជាមួយដៃគូ

**សកម្មភាពអភិវឌ្ឍ** - ចូលរួមផ្តល់ប្រឹក្សាបច្ចេកទេស និងជំនួយផ្សេងៗដូចជា៖ ការប៉ាន់ប្រមាណតម្រូវការអ្នកភូមិ ការរៀបចំនិងអនុវត្តផែនការ ការត្រួតពិនិត្យ និងការស្វែងរកថវិកាជាដើម ។

**គោលនយោបាយ** - ជួយក្នុងការអនុម័ត “ដីកា និងសេចក្តីសម្រេច” ដោយផ្តល់ការអប់រំអំពីច្បាប់ និងរៀបចំសេចក្តីសម្រេច ។

**ការសម្រុះសម្រួល** - ជួយសម្រុះសម្រួលជម្លោះដូចជា អំពើហឹង្សាក្នុងគ្រួសារ ទំនាស់ដីធ្លី ឬកើរ្តឹមរតក ។ ផ្តល់ព័ត៌មានត្រឡប់ដល់ក្រុមប្រឹក្សាក្នុងការអនុវត្ត និងការធ្វើសេចក្តីសម្រេចនានា ។

**សេវាសាធារណៈ** - អាចជួយក្រុមប្រឹក្សាផ្តល់សេវាសាធារណៈ

# ដំណាក់កាលសំខាន់ៗក្នុងការកសាងភាពជាដៃគូ

**ជំហានទី១** ហេតុអ្វីត្រូវមានភាពជាដៃគូ?

**ជំហានទី២** ប្រភេទនៃភាពជាដៃគូ

**ជំហានទី៣** ការជ្រើសរើសដៃគូ

**ជំហានទី៤:** ការជ្រើសរើសក្រុមការងារ

**ជំហានទី៥** ចែករំលែកការរំពឹងទុក

**ជំហានទី៦** ការព្រមព្រៀងលើគោលការណ៍

**ជំហានទី៧** កំណត់គោលដៅ

**ជំហានទី៨** ការរៀបចំផែនការសកម្មភាព

**ជំហានទី៩** ការកៀរគរធនធាន

**ជំហានទី១០** អនុវត្តសកម្មភាព

**ជំហានទី១១** ការវាយតម្លៃ

# ជំហានទី១: ហេតុអ្វីត្រូវមានភាពជាដៃគូ?

- ត្រូវសម្រេចចិត្តថា ហេតុអ្វីបានជាចាប់អារម្មណ៍ក្នុងការមានភាពជាដៃគូ?
- តើយើងចង់បានដៃគូដោយសាតែយើងខ្វះខាតធនធានឬ?
- តើយើងចង់បានដៃគូដោយសាតែយើងចង់បង្កើនការចូលរួមពីសាធារណៈ ឱ្យបានច្រើនឬ?
- តើយើងចង់បានដៃគូដោយសាតែយើងខ្វះខាតជំនាញឬ?
- តើភាពជាដៃគូនឹងផ្តល់ប្រយោជន៍ដល់សហគមន៍មូលដ្ឋានដែរឬទេ?
- តើមានជំរើសអ្វីផ្សេងទៀតទេ ចំពោះភាពជាដៃគូ?
- អ្វីជាផលប្រយោជន៍នៃភាពជាដៃគូ?
- អ្វីជាផលមិនល្អបណ្តាលមកពីភាពជាដៃគូ?
- តើនឹងមានផលលំបាកអ្វីខ្លះ បើសិនជាភាពជាដៃគូមិនទទួលបានជោគជ័យ?

# ជំហានទី២ ប្រភេទនៃភាពជាដៃគូ

## ត្រូវសម្រេចចិត្តឱ្យបានច្បាស់ថា តើដៃគូប្រភេទណាដែលត្រូវការ!!!

**ការសម្របសម្រួល** កើតឡើងនៅពេលណាដែលដៃគូរបស់ខ្លួនធ្វើការដោយឡែកពីគ្នា ប៉ុន្តែចាំបាច់ត្រូវការសម្របសម្រួលសកម្មភាព ដើម្បីជៀសវាងការធ្វើការត្រួតគ្នា និងអាចចែករំលែកធនធាន ។

**ការពិគ្រោះយោបល់** ប្រព្រឹតទៅតាមរយៈការសួរជាសំនួរ ស្តាប់ការបកស្រាយ និងសិក្សាពីប្រជាពលរដ្ឋរស់នៅក្នុង និងក្រៅតំបន់គ្រប់គ្រងរបស់ក្រុមប្រឹក្សា ។ ការពិគ្រោះយោបល់កើតឡើងនៅពេលក្រុមប្រឹក្សាត្រូវការពត៌មាន ជំនាញបច្ចេកទេស ចំណេះដឹង បទពិសោធន៍គំនិត និងយោបល់នានា ដើម្បីយកមកធ្វើការសម្រេចចិត្តលើអ្វីមួយ ។

**កិច្ចសហការ** កើតឡើងនៅពេលក្រុមប្រឹក្សា និងដៃគូរបស់ខ្លួនធ្វើការរួមគ្នា ដើម្បីសម្រេចគោលដៅរួម ។ វាត្រូវការរួមបញ្ចូលការពិគ្រោះយោបល់ និងការសម្របសម្រួល ។

# ជំហានទី៣ ការជ្រើសរើសដៃគូ

**១.មានការចូលរួម** ត្រូវមានការចូលរួមពីសមាជិកពាក់ព័ន្ធទាំងអស់របស់គម្រោង។

**២.កំណត់តម្រូវការ** ក្រុមប្រឹក្សាត្រូវកំណត់ពីតម្រូវការរបស់ខ្លួនជាមុនសិន និងស្វែងរកដៃគូណាដែលអាចបំពេញតម្រូវការនោះ ។

**៣.អ្នកណាជាដៃគូ** រៀបចំបញ្ជីឈ្មោះដៃគូ

**៤.តើដៃគូសមស្របមានលក្ខណៈដូចម្តេច?** ចំណេះដឹង បទពិសោធន៍ ទីតាំង ធ្លាប់អនុវត្តគម្រោងស្រដៀងគ្នា យល់ដឹងពីបញ្ហាក្នុងតំបន់ ត្រូវចំណាយថវិកាប៉ុន្មានដើម្បីធ្វើការជាដៃគូ ។

**៥.ផលប្រយោជន៍** បើធ្វើការជាមួយដៃគូទាំងនោះ តើទទួលបានផលប្រយោជន៍អ្វីខ្លះ?

# ជំហានទី៤ ការជ្រើសរើសក្រុមការងារ

ត្រូវជ្រើសរើសមនុស្សមកធ្វើការក្នុងក្រុមការងារភាពជាដៃគូ  ហើយពួកគេត្រូវមានជំនាញ និងសមត្ថភាពអនុវត្តការងារ និងព្រមទាំងមាន៖

១. **ការប្តេជ្ញាចិត្ត** មានការប្តេជ្ញាចិត្តដើម្បីជោគជ័យ ។

២. **ជំនាញ** មានជំនាញពិតប្រាកដដែលអាចជួយដល់ដៃគូ  ។

៣. **ពេលវេលា** មានពេលវេលាគ្រប់គ្រាន់សម្រាប់បំពេញកិច្ចការ  ។

# ជំហានទី៥ ការចែករំលែកការរំពឹងទុក

- ត្រូវធ្វើការប្រជុំជាមួយដៃគូដើម្បីពិភាក្សា និងចែករំលែកពីការរំពឹងទុកក្នុងភាពជាដៃគូ ។
- ត្រូវយល់ឱ្យច្បាស់ពីការរំពឹងទុក ដែលអ្នកថានឹងទទួលបានពីដៃគូ
- ត្រូវស្តាប់ពីការរំពឹងទុករបស់ដៃគូដែរ ។

# ជំហានទី៦ ការព្រមព្រៀងលើគោលការណ៍

ត្រូវព្រមព្រៀងលើគោលការណ៍នានាដែលណែនាំពីភាពជាដៃគូ និងការកំណត់លក្ខខណ្ឌរួម ។ គោលការណ៍គួរពិចារណា ៖

- គោរពគ្នាទៅវិញទៅមក
- មានភាពស្មោះត្រង់ទៅវិញទៅមក
- ចូលរួមពីគ្នាទៅវិញទៅមក
- ផ្សេងៗដែលព្រមព្រៀងដោយភាគីទាំងសងខាង ។

# ជំហានទី៧ ការកំណត់គោលដៅ

ការកំណត់គោលដៅសម្រាប់ភាពជាដៃគូមានសារៈសំខាន់ណាស់ ហើយវាជាការព្រមព្រៀងដែលភាពជាដៃគូត្រូវសម្រេចឱ្យបាន ។

ត្រូវប្រាកដថា គោលដៅនោះច្បាស់លាស់ និងអាចសម្រេចបាន ។

# ជំហានទី៨ ការរៀបចំផែនការ

ផែនការសកម្មភាពគួរតែរៀបចំរួមជាមួយគ្នា ដោយឆ្លើយតបនឹងគោលដៅនៃភាពជាដៃគូ ថាតើគោលដៅនោះសម្រេចបានដោយរបៀបណា? នៅពេលណា? និងដោយនរណា? ផែនការត្រូវមាន ៖

- គោលដៅ
- សកម្មភាពការងារ និងអ្នកទទួលខុសត្រូវ
- តារាងពេលវេលាសម្រាប់អនុវត្តសកម្មភាពនីមួយៗ និងធនធានសម្រាប់អនុវត្ត
- មធ្យោបាយវាស់វែង

# ជំហានទី៩ ការត្រៀមធនធាន

លោកអ្នកត្រូវដឹងពីធនធានដែលអ្នកនឹងផ្តល់ទៅឱ្យដៃគូហើយ និងធនធានដែលដៃគូ និងផ្តល់ឱ្យអ្នកវិញ ដើម្បីជៀសវាងកុំឱ្យមានជម្លោះ និងការយល់ច្រឡំគ្នាទៅថ្ងៃក្រោយ។

**ធនធានដែលត្រូវការសម្រាប់សកម្មភាពខុសៗគ្នារួមមាន៖**

- ពេលវេលាធ្វើការលើគម្រោង
- កិច្ចខំប្រឹងប្រែងដើម្បីបញ្ចប់គម្រោង
- សម្ភារចាំបាច់សម្រាប់អនុវត្តសកម្មភាព ឧទាហរណ៍ដូចជា ឥដ្ឋសម្រាប់សាងសងបន្ទប់ថ្មីមួយជាដើម
- មធ្យោបាយធ្វើដំណើរ និងដឹកជញ្ជូនសម្ភារៈ
- ការចំណាយផ្នែករដ្ឋបាល ដូចជាសម្ភារៈការិយាល័យ ថតចម្លងនិងបោះពុម្ពឯកសារ
- ម្ហូបអាហារនិងការស្នាក់អាស្រ័យ ពិសេសនៅពេលសកម្មភាពរបស់អ្នកត្រូវអនុវត្តនៅឆ្ងាយពីផ្ទះ
- ថវិកាសម្រាប់ទិញធនធាននានាដែលមិនអាចទទួលបានពីការបរិច្ចាក

# ជំហានទី១០ ការអនុវត្តសម្ភាព

ការអនុវត្តតាមផែនការសកម្មភាព ត្រូវពិភាក្សាពីធនធានដែលត្រូវការជាមួយដៃគូមុននឹងអនុវត្តសកម្មភាព ៖

- **ការប្ដេជ្ញាអនុវត្ត** ត្រូវអនុវត្តផែនការសកម្មភាពឱ្យចប់ ។
- **ផ្ដោតលើការទទួលខុសត្រូវ** គ្រប់អ្នកពាក់ព័ន្ធក្នុងផែនការសកម្មភាពត្រូវបំពេញតួនាទី និងការទទួលខុសត្រូវក្នុងភាពជាដៃគូ ។
- **ទំនាក់ទំនង** ត្រូវធ្វើការទំនាក់ទំនងឱ្យបានញឹកញាប់ជាមួយដៃគូ
- **មិនព្រងើយកន្តើយចំពោះជម្លោះដែលកើតឡើង** ពេលមានខ្វែងគំនិតគ្នា បញ្ហាត្រូវយកមកពិភាក្សា និងដោះស្រាយឱ្យបានរហ័ស ។

# ជំហានទី១១ ការវាយតម្លៃ

គ្រប់សកម្មភាពនៃភាពជាដៃគូត្រូវធ្វើការត្រួតពិនិត្យ និងវាយតម្លៃ។ ដូច្នេះ យើងអាចរៀនសូត្រនូវអ្វីដែលយើងធ្វើទៅបានល្អ និងអ្វីដែលត្រូវកែតម្រូវ។ ការរៀនសូត្រទាំងនោះមានប្រយោជន៍ដល់ការធ្វើផែនការ និងការអនុវត្តផែនការបានល្អនាពេលអនាគត ។

# ថ្ងៃទី៣

# ឯកសារចែក

## មេរៀនទី៣: ប្រសិទ្ធភាពនៃការកសាងភាពជាដៃគូ

## ១.សេចក្តីផ្តើម

ភាពជាដៃគូ គឺជាមធ្យោបាយដ៏ប្រសើរបំផុតសម្រាប់ក្រុមប្រឹក្សា និងអង្គការសង្គមស៊ីវិលធ្វើការជាមួយគ្នា ដើម្បីធ្វើឱ្យសហគមន៍មានភាពប្រសើរឡើង។ ភាពជាដៃគូអាចជួយឱ្យក្រុមប្រឹក្សាមានលទ្ធភាពបង្កើននូវសេវាកម្មនានាដែលត្រូវផ្តល់ដល់ប្រជាពលរដ្ឋ និងធនធានដែលអាចរកបាន បង្កើនការចូលរួម ការសម្របសម្រួល និងការអនុវត្តគំរោង។ ការកសាងភាពជាដៃគូប្រកបដោយចេរភាព ជាដំណើរការដ៏លំបាកដែលតម្រូវឱ្យមានជំនាញ និងធនធានចាំបាច់មួយចំនួន។ ផ្អែកលើបទពិសោធន៍ពីការស្រាវជ្រាវស្តីពីភាពជាដៃគូនៅក្នុងប្រទេសកម្ពុជានិងបទពិសោធន៍នៅប្រទេសមួយចំនួន ឯកសារនេះនឹងបង្ហាញនូវគំរូ ១១ជំហាន នៃការកសាងភាពជាដៃគូ ដែលអាចជួយដល់លោកអ្នកក្នុងការកសាងភាពជាដៃគូបានប្រកបដោយភាពរឹងមាំ និងជោគជ័យ ។

## ២.គោលបំណងនៃការកសាងភាពជាដៃគូ

- ភាពជាដៃគូអាចជួយឱ្យក្រុមប្រឹក្សាមានលទ្ធភាពបង្កើននូវសេវាកម្មនានាសំរាប់ផ្តល់ដល់ប្រជាពលរដ្ឋ
- បង្កើនការចូលរួម ការសម្របសម្រួល និងការអនុវត្តគំរោង
- បង្កើនបាននូវធនធាន (ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ)
- បង្កើនការទំនាក់ទំនងរវាងគ្នានឹងគ្នា ការសិក្សា ការសម្រេចចិត្ត ការគាំទ្រ និងការប្តេជ្ញាចិត្ត

## ៣. អ្វីទៅដែលហៅថាភាពជាដៃគូ ?

ឯកសារនេះបង្ហាញអំពីអត្ថប្រយោជន៍នៃភាពជាដៃគូ និងមធ្យោបាយសំខាន់ៗដែលអាចកសាងភាពជាដៃគូនៅថ្នាក់ឃុំ សង្កាត់ ដែលរៀបចំឡើងដើម្បីជាជំនួយដល់ក្រុមប្រឹក្សា សង្គមស៊ីវិល និងផ្នែកឯកជនដែលពាក់ពន្ធ័។ ភាពជាដៃគូមានច្រើនប្រភេទខុសៗគ្នា។ ជារឿយៗភាពជាដៃគូធ្វើឡើងដើម្បីសម្រេចកិច្ចការណា ដែលមិនអាចធ្វើតែឯកឯងបាន ឬចាំបាច់ត្រូវធ្វើការរួមគ្នា ដើម្បីទទួលបានលទ្ធផលល្អប្រសើរជាងការធ្វើការតែឯកឯង។ ភាពជាដៃគូនៅថ្នាក់ឃុំ សង្កាត់ គឺជាទំនាក់ទំនងរវាងក្រុមប្រឹក្សា និងសង្គមស៊ីវិលឬក្រុមផ្សេងទៀត។ ភាពជាដៃគូទាំងនេះគឺធ្វើឡើងដើម្បីសម្រេចគោលដៅរួម។ មិនថាភាពជាដៃគូប្រភេទណាទេ ភាពជាដៃគូដែលទទួលបានជោគជ័យទាំងអស់គឺសុទ្ធតែមានលក្ខណៈរួមដូចខាងក្រោម។

☞ **ការទំនាក់ទំនង:** ដៃគូដែលជោគជ័យត្រូវទាក់ទងគ្នាទៅវិញទៅមកដោយស្មោះត្រង់និងដោយឥតលាក់លៀម

- **ការសិក្សា**: ដៃគូដែលជោគជ័យត្រូវរៀនពីគ្នាទៅវិញទៅមក
- **ការគាំទ្រ**: ដៃគូដែលជោគជ័យ ត្រូវទុកចិត្តគ្នា គោរពគ្នា និងគាំទ្រគ្នាទៅវិទៅមក
- **ការប្តេជ្ញាចិត្ត**: ដៃគូដែលជោគជ័យត្រូវមានគោលដៅរួមនិងប្តេជ្ញាចិត្តរួមគ្នាដើម្បីសម្រេចគោលដៅនោះ

## ៤. អត្ថប្រយោជន៍នៃភាពជាដៃគូ

ភាពជាដៃគូដែលជោគជ័យអាចផ្តល់នូវផលប្រយោជន៍សំខាន់ៗដល់គ្នាទៅវិញទៅមកទាំងអ្នកដែលជាដៃគូ និងអ្នកដែលជួយគាំទ្រ។ អត្ថប្រយោជន៍ទាំងនោះរួមមាន៖

១. **កំណើនធនធាន**: ពេលណាដៃគូរួមគ្នា ពួកគេអាចដាក់បញ្ចូលធនធានជាមួយគ្នា។ ជាលទ្ធផលនឹងមានការកើនឡើងនូវធនធានមនុស្ស និងជំនាញផ្សេងៗច្រើន មានថវិកា និងសម្ភារៈច្រើនសម្រាប់អនុវត្តគម្រោង

២. **ការចូលរួមច្រើន**: ពេលដែលក្រុមប្រឹក្សាមានភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិលដូចជា អង្គការមិនមែនរដ្ឋាភិបាល ឬក្រុមសហគមន៍នានា និងធ្វើឱ្យមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋ បានល្អប្រសើរក្នុងដំណើរការអនុវត្តគំរោងនានា។

៣. **សេវាកម្មល្អប្រសើរ**: ធ្វើការរួមគ្នា ដៃគូអាចផ្តល់សេវាកម្មបានល្អប្រសើរជាងការធ្វើតែម្នាក់ឯង។

៤. **ការសម្របសម្រួលល្អប្រសើរ**: ជួនកាលទាំងក្រុមប្រឹក្សា អង្គការសង្គមស៊ីវិល ឬក្រុមសហគមន៍នានាធ្វើការដូចគ្នាក្នុងពេលតែមួយ។ ពេលដែលក្រុមប្រឹក្សា និងក្រុមទាំងនោះសម្រេចធ្វើការក្នុងភាពជាដៃគូជាមួយគ្នា ពួកគេអាចសម្របសម្រួលការងារបានល្អហើយផ្តល់នូវផលប្រយោជន៍
បានច្រើនដោយចំណាយថ្លៃដើមទាប។

៥. **គម្រោងអាចបញ្ចប់បានឆាប់រហ័ស**: ពេលដែលដៃគូធ្វើការរួមគ្នា ដើម្បីសម្រេចបាននូវគោលបំណងរួម ពួកគេអាចបញ្ចប់គម្រោងនេះបានឆាប់រហ័សនិងល្អប្រសើរជាងការអនុវត្តគម្រោងម្នាក់ឯង។

## ៥. តើអ្នកណាខ្លះជាដៃគូនៃក្រុមប្រឹក្សា?

ក្រុមប្រឹក្សាអាចជ្រើសរើសដៃគូអាស្រ័យលើគោលដៅ និងតម្រូវការរបស់ខ្លួន។ ដៃគូដែលក្រុមប្រឹក្សាឃុំសង្កាត់អាចធ្វើការជាមួយគ្នាបានមានដូចជា៖

| | |
|---|---|
| ក្រុមប្រឹក្សាដូចគ្នា | ជួនកាលឃុំ សង្កាត់មួយមិនមានធនធានខ្លួនឯងគ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងរបស់ខ្លួនទេ តែអាចធ្វើបានបើសិនជាឃុំ សង្កាត់ ឬច្រើនចូលរួមគ្នាអនុវត្ត ដោយហេតុថាក្រុមប្រឹក្សាផ្សេងទៀតអាចមានប្រភពធនធានមានតម្លៃ មានគំនិតយោបល់ និងបទពិសោធន៍ល្អៗផ្សេងៗគ្នា។ |
| ស្ថាប័នរដ្ឋាភិបាល | កិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងជាមួយស្ថាបន័រដ្ឋាភិបាលថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិ មានសារសំខាន់ណាស់សម្រាប់កិច្ចការទាំងអស់របស់ក្រុមប្រឹក្សា ។ |

| | |
|---|---|
| **អង្គការមិនមែនរដ្ឋាភិបាល** | ទាំងអង្គការជាតិ និងអង្គការអន្តរជាតិមានបទពិសោធន៏ច្រើនក្នុងការងារអភិវឌ្ឍ ដោយធ្វើការជាមួយសហគមន៍ ដើម្បីសម្រេចនូវគោលបំណងរបស់ពួកគេ។ មាន អង្គការខ្លះធ្វើការងារផ្តោតទៅលើវិស័យមួយដូចជា: ផ្នែកសុខភាព អប់រំ សិទ្ធិមនុស្ស និងលើគម្រោងអភិវឌ្ឍសហគមន៍ ។ល។ |
| **អង្គការសហគមន៍មូលដ្ឋាន** | អង្គការសហគមន៍មូលដ្ឋាន ធនាគារជ្រូក ធនាគារគោ ធនាគារស្រូវ សហគមន៍ ព្រៃឈើ ក្រុមសហគមន៍ប្រើប្រាស់ទឹកស្អាតនិងក្រុមជួយខ្លួនឯង គឺជាផ្នែកសំខាន់នៃ អង្គការសហគមន៍មូលដ្ឋានហើយសមាជិកដែលចូលរួមក្នុងក្រុមទាំងនោះមកពីភូមិ នានានៅក្នុងឃុំ។ |
| **សមាគមព្រះសង្ឃ និងវត្តអារាម** | វត្តអារាមជាកន្លែងយ៉ាងប្រពៃ និងសំខាន់សម្រាប់ប្រជាពលរដ្ឋរស់នៅក្នុងភូមិធ្វើ សក្ការៈបូជានិងជាកន្លែងអង្គាសបច្ច័យ ដើម្បីគាំទ្រលើការកសាងសមិទ្ធិផលផ្សេងៗ។ |
| **ចាស់ព្រឹទ្ធាចារ្យ** | ចាស់ព្រឹទ្ធាចារ្យនៅក្នុងភូមិដូចជា លោកអាចារ្យ មានឥទ្ធិពលខ្លាំងណាស់លើសេចក្តី សម្រេចចិត្តនានារបស់សហគមន៍ ។គាត់គឺជាដៃគូយ៉ាងសំខាន់នៅពេលដែលចាំបាច់ ក្នុងការកៀរគរការគាំទ្រ ឬការចូលរួមនានាពីសហគមន៍។ |
| **អាជីវកម្ម ឬវិនិយោគទុន** | អាជីវកម្ម ឬវិនិយោគទុនជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងសហគមន៍មូលដ្ឋាន។ ពួក គេជាអ្នកបង្កើតការងារដល់ប្រជាពលរដ្ឋឱ្យមានការងារធ្វើ និងចូលរួមចំណែកជួយ ធ្វើឱ្យប្រសើរឡើងនូវសេដ្ឋកិច្ចនៅថ្នាក់មូលដ្ឋាន។ |
| **សមាគមយុវជន** | ជាង ៤០% នៃប្រជាជនកម្ពុជាមានអាយុតិចជាង១៥ឆ្នាំ។ ដូច្នេះបញ្ហាដែលប៉ះពាល់ ដល់យុវជន គឺជាបញ្ហាចំបងដែលត្រូវយកចិត្តទុកដាក់។ សមាគមយុវជនជាវេទិកាដ៏ ប្រសើរបំផុតក្នុងការកៀរគរការចូលរួមពីសមាជិកជាយុវជននៅក្នុងសហគមន៍។ |
| **ក្រុមស្ត្រី** | ស្ត្រីមិនសូវមានតំណាងរបស់ខ្លួននៅគ្រប់ជាន់ថ្នាក់ ក្នុងជួររដ្ឋាភិបាលនៅកម្ពុជា ប៉ុន្តែតួនាទី និងសម្លេងរបស់ស្ត្រីនៅក្នុងសង្គម គឺមានសារៈសំខាន់ណាស់។ ក្រុមស្ត្រី អាចធ្វើឱ្យក្រុមប្រឹក្សាឃុំ សង្កាត់លើកទឹកចិត្តនិងគាំទ្រការចូលរួមរបស់ស្ត្រីលើការផ្តួច ផ្តើមគំនិតផ្សេងៗនៅមូលដ្ឋាន ។ |
| **សមាគមកម្មករ** | មានដូចជាសមាគមកសិករ ក្រុមអាជីវករ សមាគមម៉ូតូឌុប សមាគមអ្នកជិះរ៉ឺរ កៅស៊ូ ។ល។ អាចផ្តល់នូវព័ត៌មានសំខាន់ៗឬជួយគាំទ្រនិងការអប់រំដល់សហគមន៍។ |

## ៦. សកម្មភាពនៃភាពជាដៃគូ

មានសកម្មភាពជាច្រើនដែលក្រុមប្រឹក្សាអាចធ្វើការជាមួយដៃគូពាក់ពន្ធ័នានា ដើម្បីសម្រេចគោលដៅដូចជា:

- **សកម្មភាពអភិវឌ្ឍ:** សកម្មភាពសំខាន់ៗរបស់ក្រុមប្រឹក្សា គឺរៀបចំគម្រោងអភិវឌ្ឍដោយប្រើប្រាស់មូលនិធិឃុំ សង្កាត់ ។គម្រោងអភិវឌ្ឍទាំងនោះរួមមាន ការកសាងហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវ ប្រពន្ធ័ស្រោចស្រព ឬបណ្ដាញអគ្គីសនី ។ល ។ ការបណ្ដុះបណ្ដាលពង្រឹងបច្ចេកទេសកសិកម្ម ការការពារបរិស្ថាន និងគម្រោងផែនការជួសជុលផ្លូវលំជាដើម ។ ដៃគូក្រុមប្រឹក្សាឃុំ សង្កាត់មានភារកិច្ចចូលរួមយ៉ាងសកម្មក្នុងសកម្មភាពខាងលើនេះ តាមរយៈការផ្ដល់ប្រឹក្សាបច្ចេកទេសនិងជំនួយផ្សេងៗទៀតដូចជា: ការប៉ាន់ប្រមាណតម្រូវការអ្នកភូមិ ការធ្វើផែនការ ការអនុវត្តផែនការ ការត្រួតពិនិត្យ ការរៀបចំគម្រោងថវិកា និងការស្វែងរកថវិកា ។
- **គោលនយោបាយ:** ដៃគូអាចជួយក្រុមប្រឹក្សាក្នុងការអនុមត័ "ដីកា" ឬ "បទបញ្ញត្តិនានា" នៅក្នុងឃុំ សង្កាត់ តាមរយៈការផ្ដល់ការអប់រំអំពីច្បាប់និងធ្វើសេចក្ដីព្រៀងបទបញ្ញត្តិ ទាំងនោះ ។ ក្រៅពីនេះ ក្រុមប្រឹក្សាអាចផ្ដល់នូវគំរូនិងព័ត៌មានផ្សេងៗស្ដីពីដីកានានា ដែលបានអនុម័តផងដែរដល់ដៃគូរបស់ខ្លួន ។
- **ការសម្រុះសម្រួល:** ដៃគូអាចជួយសម្រុះសម្រួលជម្លោះក្នុងបញ្ហាមួយចំនួននៅក្នុងមូលដ្ឋានដូចជា៖ ទំនាស់ដីធ្លី អំពើហឹង្សាក្នុងគ្រួសារ ទំនាស់កើ្តមរតក ឬការសងបំណុលជាដើម ។ ដៃគូអាចផ្ដល់ព័ត៌មានដល់ក្រុមប្រឹក្សាឃុំ សង្កាត់ អំពីគោលនយោបាយ និងសកម្មភាពផ្សេងៗដែលផ្ដួចផ្ដើមឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់ទៅថ្នាក់ភូមិ ។ ដៃគូក៏អាចជួយក្រុមប្រឹក្សាផងដែរតាមរយៈការអប់រំពី របៀបដោះស្រាយជម្លោះដីធ្លីនិង ច្បាប់ឬវិធីសាស្ត្រសម្រុះសម្រួលដើម្បីឱ្យពួកគាត់អាចផ្ដល់ប្រឹក្សាល្អៗ ដល់អ្នកភូមិក៏ដូចជាការតាមដានដំណើរការរីកចំរើននានាផងដែរ ។
- **ការតស៊ូមតិ:** ការតស៊ូមតិ គឺជាបណ្ដុំសកម្មភាពមួយចំនួនដែលធ្វើឡើងដើម្បី បញ្ចុះបញ្ចូល ឬជំរុញអ្នកដែលមានអំណាចផ្នែកសេដ្ឋកិច្ច នយោបាយ និងរដ្ឋាភិបាល ធ្វើការផ្លាស់ប្ដូរការសម្រេចចិត្ត ឬទទួលយកទៅអនុវត្តនូវតាមគោលនយោបាយសាធារណៈ ដែលផ្ដល់ផលប្រយោជន៏ទៅដល់អ្នកក្រីក្រ និងអ្នកនយោបាយដែលមិនសូវមានអំណាច ។ បញ្ហាទូទៅដែលក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើការតស៊ូមតិរួមមាន បញ្ហាទាក់ទងនិងអំពើពុករលួយ ជម្លោះដីធ្លី ការគ្រប់គ្រងព្រៃឈើ អនាម័យទីផ្សារ ត្រួតពិនិត្យ និងថែទាំផ្លូវការទប់ស្កាត់ការកើតឡើងនូវជម្លោះក្នុងចំណោមយុវជននិងការចាត់វិធានការទប់ស្កាត់បទល្មើសនេសាទ ។
- **សេវាសាធារណៈ:** ដៃគូដែលជាផ្នែកឯកជន អាចជួយក្រុមប្រឹក្សាក្នុងការផ្ដល់សេវាសាធារណៈដូចជាអគ្គីសនី ទឹកស្អាត និងការគ្រប់គ្រងកាកសំណល់ ។ ដៃគូក៏អាចផ្ដល់ផងដែរនូវគំរូនៃគម្រោងសេវាកម្មសាធារណៈដែលទទួលជោគជ័យដល់ក្រុមប្រឹក្សាឃុំសង្កាត់ឬក៏បង្ហាញពីសម្ភារៈដែលត្រូវការដើម្បីផ្ដួចផ្ដើម និងបង្កើតសេវាកម្មថ្មី ។

## ៧. ការកសាងភាពជាដៃគូ

នៅក្នុងផ្នែកនេះយើងនឹងបង្ហាញជូនពីជំហាននានា ដែលលោកអ្នកអាចយកទៅប្រើប្រាស់ បានក្នុងការកសាងភាពជាដៃគូឱ្យបានជោគជ័យ ។

| | | | |
|---|---|---|---|
| **ជំហានទី ១** | ហេតុអ្វីត្រូវមានភាពជាដៃគូ? | **ជំហានទី ៧** | កំណត់គោលដៅ |
| **ជំហានទី ២** | ប្រភេទនៃភាពជាដៃគូ | **ជំហានទី ៨** | ការធ្វើផែនការសកម្មភាព |
| **ជំហានទី ៣** | ការជ្រើសរើសដៃគូ | **ជំហានទី ៩** | ការកៀរគរធនធាន |
| **ជំហានទី ៤** | ការជ្រើសរើសក្រុមការងារ | **ជំហានទី ១០** | អនុវត្តសកម្មភាព |
| **ជំហានទី ៥** | ចែករំលែកការរំពឹងទុក | **ជំហានទី ១១** | ការវាយតម្លៃ |
| **ជំហានទី ៦** | ការព្រមព្រៀងលើគោលការណ៍ | | |

## ជំហានទី១ ហេតុអ្វីត្រូវមានភាពជាដៃគូ?

ការសម្រេចចិត្តជាដំបូងរបស់ក្រុមប្រឹក្សាគឺត្រូវសម្រេចចិត្តថា ហេតុអ្វីបានជាចាប់អារម្មណ៍ក្នុងការមានភាពជាដៃគូ? ក្រុមប្រឹក្សាត្រូវគិតពិចារណាលើចំណុចដូចជា៖

- តើយើងចង់បានដៃគូដោយសារតែយើងខ្វះខាតធនធានឬ ?
- តើយើងចង់បានដៃគូដោយសារតែយើងចង់បង្កើនការចូលរួមពីសាធារណៈឱ្យបានច្រើនឬ?
- តើយើងចង់បានដៃគូដោយសារតែយើងខ្វះខាតជំនាញឬ ?
- តើភាពជាដៃគូនឹងផ្តល់ប្រយោជន៍ដល់សហគមន៍មូលដ្ឋានដែរឬទេ ?
- តើមានជំរើសអ្វីផ្សេងទៀតទេ ចំពោះភាពជាដៃគូ?
- អ្វីជាផលប្រយោជន៍នៃភាពជាដៃគូ ?
- អ្វីជាផលអាក្រក់នៃភាពជាដៃគូ ?
- តើក្រុមប្រឹក្សានឹងមានផលលំបាកអ្វីខ្លះ បើសិនជាភាពជាដៃគូមិនទទួលបានជោគជ័យ ។

> វាជាការសំខាន់ផងដែរដើម្បីជជែកពិភាក្សាជាមួយសហគមន៍នូវមូលហេតុផ្សេងៗទៀតថាតើហេតុអ្វីបានជាក្រុមប្រឹក្សាចង់បង្កើតភាពជាដៃគូ និងពន្យល់អំពីអ្វីជាផលប្រយោជន៍ឬការលំបាកដែលអាចកើតមាន ។

## ជំហានទី ២ ប្រភេទនៃភាពជាដៃគូ

សកម្មភាពសំខាន់បន្ទាប់ គឺការសម្រេចចិត្តឱ្យបានច្បាស់ថា តើដៃគូប្រភេទណាដែលក្រុមប្រឹក្សាកំពង់ត្រូវការ ។ មានមធ្យោបាយជាច្រើនសម្រាប់ក្រុមប្រឹក្សាអាចធ្វើការជាមួយដៃគូ៖

> **ការសម្របសម្រួល** : ការសម្របសម្រួលកើតឡើងនៅពេលណាដែលក្រុមប្រឹក្សា និងដៃគូរបស់ខ្លួនធ្វើការដោយឡែកពីគ្នា ប៉ុន្តែចាំបាច់ត្រូវការសម្របសម្រួលសកម្មភាព ដើម្បីជៀសវាងការធ្វើការត្រួតគ្នា ។ នៅពេលដែលក្រុមប្រឹក្សាមួយធ្វើការសម្របសម្រួល សកម្មភាពចាំបាច់មួយដៃគូដែលមានគោលដៅដូចគ្នា គឺអាចចែករំលែកធនធានទៅឱ្យគ្នាទៅវិញទៅមក ធ្វើការប្រើប្រាស់នូវ ធនធានដែលមានតិចតួចកាន់តែប្រសើរឡើងនិងសហគមន៍មូលដ្ឋានទទួលបានផលប្រយោជន៍កាន់តែប្រសើរឡើង ។

**ការពិគ្រោះយោបល់** : ដៃគូប្រភេទនេះច្រើនតែ ប្រព្រឹត្តទៅតាមរយៈការសួរជាសំនួរ ស្តាប់ការបកស្រាយ និងសិក្សាពីប្រជាពលរដ្ឋរស់នៅក្នុង និងអ្នកនៅក្រៅឃុំ សង្កាត់ ការពិគ្រោះយោបល់កើតឡើងនៅពេលក្រុមប្រឹក្សាត្រូវការព័ត៌មាន ជំនាញ បច្ចេកទេស ចំណេះដឹង បទពិសោធន៍គំនិត និងយោបល់នានា ដើម្បីយកមកធ្វើការសម្រេចចិត្តលើអ្វីមួយ ។ ដៃគូអាចជួយដល់ក្រុមប្រឹក្សាឃុំសង្កាត់បានច្រើនក្នុងការធ្វើការសម្រេចចិត្តឱ្យបានល្អប្រសើរ ដែលផ្តល់ផលប្រយោជន៍ដល់សហគមន៍ ។

**កិច្ចសហការ:** កិច្ចសហការកើតឡើងនៅពេលក្រុមប្រឹក្សាឃុំ សង្កាត់ និងដៃគូរបស់ខ្លួនធ្វើការរួមគ្នាដើម្បីសម្រេចគោលដៅរួម ។កិច្ចសហការអាចជោគជ័យបាននៅពេលដៃគូទាំងអស់ធ្វើការយ៉ាងជិតស្និតជាមួយគ្នាដែលកិច្ចសហការនេះ និងផ្តល់មកវិញនូវផលចំណេញយ៉ាងច្រើន ។ ដើម្បីសម្រេចបានជោគជ័យនូវកិច្ចសហការក្នុងភាពជាដៃគូប្រភេទនេះគឺត្រូវរួមបញ្ចូលទាំងការពិគ្រោះយោបល់ ។

## ជំហានទី ៣ ការជ្រើសរើសដៃគូ

ការជ្រើសរើសដៃគូគួរតែធ្វើឡើងដោយមានការចូលរួមពីសមាជិកពាក់ពន្ធ័ទាំងអស់នៃក្រុមប្រឹក្សា និងក្រុមផ្សេងៗទៀតដែលចាប់អារម្មណ៍លើគម្រោង ។ មុននិងក្រុមប្រឹក្សាជ្រើសរើសដៃគូណាមួយមកធ្វើការជាមួយនោះជាដំបូងត្រូវកំណត់នូវតម្រូវការរបស់ខ្លួនឱ្យបានច្បាស់លាស់ជាមុនសិន និងស្វែងយល់ថាតើដៃគូនោះអាចជួយបំពេញនូវតម្រូវការដែលបានរកឃើញនោះដែរឬទេ? ។ ការជ្រើសរើសនេះក្រុមប្រឹក្សាឃុំសង្កាត់ត្រូវគិតអំពី:

### ✍ អ្នកណាខ្លះអាចជាដៃគូ?

- *ជាការល្អត្រូវរៀបចំបញ្ជីឈ្មោះដៃគូទាំងនោះព្រោះជួនកាលមានតែអង្គការ មួយគត់នៅក្នុងបញ្ជីហើយជួនកាលមានអង្គការច្រើន ។*

### ✍ តើដៃគូដែលសមស្របមានលក្ខណៈដូចម្តេចខ្លះ ?

- ✓ តើចំណេះដឹងនិងបទពិសោធន៏របស់គេជាអ្វីខ្លះ?
- ✓ តើដៃគូមានទីតាំងនៅកន្លែងណា?
- ✓ តើដៃគូអាចចាប់ផ្តើមបាននៅពេលណា?
- ✓ តើដៃគូយល់ដឹងពីបញ្ហានានានៅក្នុងតំបន់អ្នកដែរឬទេ?
- ✓ តើដៃគូធ្លាប់អនុវត្តគម្រោងស្រដៀងគ្នានេះពីមុនដែរឬទេ?
- ✓ តើយើងត្រូវចំណាយថវិកាប៉ុន្មានដើម្បីធ្វើការជាមួយដៃគូ?

### ✍ បើធ្វើការជាមួយដៃគូទាំងនោះ តើអាចទទួលបានផលប្រយោជន៏អ្វីខ្លះ ?

- ផលប្រយោជន៍ពីដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាល គឺខុសគ្នាពីផលប្រយោជន៍ដែលបានមកពីសមាគមមូលដ្ឋាន

**ជំហានទី៤ ការជ្រើសរើសក្រុមការងារ**

បន្ទាប់ពីក្រុមប្រឹក្សាជ្រើសរើសដៃគូបានមកត្រូវជ្រើសរើសអ្នកធ្វើការក្នុងក្រុមការងារភាពជាដៃគូ មិនមែនចាំបាច់ត្រូវតែឱ្យសមាជិកក្រុមប្រឹក្សាទាំងអស់ធ្វើការក្នុងភាពជាដៃគូនោះទេ ហើយក្រុមការងារនោះក៏មិនគួធំពេកដែរ ។ ក្រុមការងារអាចធ្វើរបាយការណ៍ដល់សមាជិកក្រុមប្រឹក្សាផ្សេងទៀត ។ វាជារឿងសំខាន់ណាស់ដែលត្រូវជ្រើសរើសមនុស្សដែលមានជំនាញ និងសមត្ថភាពត្រឹមត្រូវ ហើយអ្នកទាំងនោះគួតែះ

| **ការប្តេជ្ញាចិត្ត** | **ជំនាញ** | **ពេលវេលា** |
| --- | --- | --- |
| មានការប្តេជ្ញាចិត្ត ដើម្បីជោគជ័យ | មានជំនាញពិតប្រាកដ ដែលអាចជួយដល់ដៃគូ | មានពេលវេលាគ្រប់គ្រាន់ សម្រាប់ធ្វើការ |

**ជំហានទី៥ ចែករំលែកការរំពឹងទុក**

ឥឡូវនេះជាពេលដែលត្រូវចាប់ផ្តើមកសាងភាពជាដៃគូ ហើយនេះជាជំហានដំបូងដែលអ្នកត្រូវធ្វើសេចក្តីសម្រេចចិត្តជាមួយដៃគូរបស់អ្នក ។ សកម្មភាពដំបូងយើងត្រូវធ្វើការប្រជុំគ្នាជាមួយដៃគូរបស់អ្នក ដើម្បីពិភាក្សាជាដៃគូ ។ នៅពេលដែលភាគីទាំងពីរបានយល់ព្រមគ្នា អ្នកអាចចាប់ផ្តើមចែករំលែកនូវការរំពឹងទុកអំពីភាពជាដៃគូ ។ ដំណាក់កាលនេះសំខាន់ណាស់ព្រោះថា អ្នកត្រូវគិតឱ្យបានច្បាស់លាស់ពីក្តីសង្ឃឹម ដែលអ្នករំពឹងថា និងទទួលបានពីដៃគូរបស់អ្នក តើអ្នកសង្ឃឹមថាបានអ្វី? អ្នកក៏ត្រូវស្តាប់ការរំពឹងទុកពីដៃគូរបស់អ្នកវិញដែរ ។ តាមរយៈការបង្ហាញពីទស្សនៈឱ្យគ្នាទៅវិញទៅមកនេះ លោកអ្នក អាចនឹងកំណត់បាននូវសេចក្តីរំពឹងទុកនានាដែលអ្នកនិងដៃគូរបស់អ្នកចង់បានរួមគ្នា ។

**ជំហានទី ៦ ការព្រមព្រៀងលើគោលការណ៍**

ជំហាននេះគឺ ការព្រមព្រៀងលើគោលការណ៍នានាដែលណែនាំពីភាពជាដៃគូរបស់លោកអ្នក រួមទាំងការកំណត់រកល័ក្ខខ័ណ្ឌរួមសម្រាប់ដៃគូ ។ អ្នកគួពិចារណាលើគោលការណ៍មួយចំនួនដូចជាះ

→ ការគោរពគ្នាទៅវិញទៅមកគ្រប់ពេលវេលា

→ មានភាពស្មោះត្រង់

→ សម្របសម្រួលគ្នានៅពេលចាំបាច់

→ រីករាយនិងទទួលយកនូវគំនិតយោបល់ពីគ្នាទៅវិញទៅមក

→ មានការចូលរួមពីគ្នាទៅវិញទៅមក

**ជាឧទាហរណ៍:** បើអ្នកយល់ព្រមថា ជួបគ្នានៅពេលណាមួយ ថ្ងៃណាមួយជាក់លាក់ អ្នកត្រូវតែចូលរួមតាមការព្រមព្រៀងនោះ។ មានន័យថាអ្នកត្រៀមខ្លួនជាស្រេច ដើម្បីចូលរួមក្នុងការប្រជុំនោះ ឬអាចជាសកម្មភាពផ្សេងទៀតដែលអ្នករៀបចំជាមួយដៃគូរបស់អ្នក។

**ជំហានទី ៧ កំណត់គោលដៅ**

ការកំនត់គោលដៅសម្រាប់ភាពជាដៃគូ គឺជាសកម្មភាពសំខាន់បំផុតក្នុងការកសាងភាពជាដៃគូ។ នេះជាការព្រមព្រៀងដែលភាពជាដៃគូត្រូវសម្រេចបាន។ ពេលដែលលោកអ្នកពិភាក្សាជាមួយដៃគូពីគោលដៅរួម លោកអ្នកនឹងអាចឃើញថា គោលដៅនោះអាចទូលំទូលាយពេក ឬអាចមានមហិច្ឆតាពេក ។ ដូច្នេះមុននឹងលោកអ្នកយល់ព្រមជាចុងក្រោយជាមួយដៃគូ លោកអ្នកត្រូវប្រាកដក្នុងចិត្តថាគោលដៅនោះច្បាស់លាស់និងអាចសម្រេចជោគជ័យបាន។

ឧទាហរណ៍: មួយចំនួនដែលបង្ហាញពីគោលដៅនៃភាពជាដៃគូរវាងក្រុមប្រឹក្សា និងសង្គមស៊ីវិល។

→ ប៉ាន់ប្រមាណពីតម្រូវការនៅក្នុងភូមិ ដែលមានការចូលរួមសម្រាប់សកម្មភាពទៅអនាគតរបស់ក្រុមប្រឹក្សាឃុំសង្កាត់។
→ ចែករំលែកព័ត៌មានពីគម្រោង និងកម្មវិធីអភិវឌ្ឍឃុំ សង្កាត់
→ សហការលើគម្រោង និងកម្មវិធីអភិវឌ្ឍជាក់លាក់ណាមួយ
→ កសាងសមត្ថភាពក្រុមប្រឹក្សា
→ ការបែងចែកយ៉ាងទូលំទូលាយពីព័ត៌មាន និងការសម្រេចចិត្តរបស់ក្រុមប្រឹក្សា
→ ការរៀបចំ និងការបង្កើនការចូលរួមឱ្យបានច្រើននៅក្នុងវេទិកាសាធារណៈ
→ កំណត់រក និងដោះស្រាយបញ្ហាសង្គម និងសណ្តាប់ធ្នាប់សាធារណៈសំខាន់ៗក្នុងឃុំ សង្កាត់
→ ចាត់ចែងឱ្យមានការចូលរួមពីស្ត្រី និងជនជាតិភាគតិចក្នុងសកម្មភាពឃុំ សង្កាត់
→ ពង្រឹងតម្លាភាព និងគណនេយ្យភាពនៃសកម្មភាពរបស់ក្រុមប្រឹក្សា
→ ត្រួតពិនិត្យការអនុវត្តរបស់ក្រុមប្រឹក្សាដែលជំរុញដល់ការរីកចំរើនក្នុងការងារឃុំ សង្កាត់
→ ត្រួតពិនិត្យកិច្ចសន្យារវាងក្រុមប្រឹក្សា និងផ្នែកឯកជន និងគម្រោងកសាងហេដ្ឋារចនាសម្ព័ន្ធ

**ជំហានទី ៨ ការធ្វើផែនការសកម្មភាព**

ពេលដែលដៃគូព្រមព្រៀងលើអ្វីដែលត្រូវធ្វើរួមគ្នាហើយនោះ ជំហានបន្ទាប់ទៀតគឺការសម្រេចចិត្ត ថាតើគេត្រូវធ្វើកិច្ចការនោះដោយរបៀបណា?

ផែនការសកម្មភាពគួតែរៀបចំជាមួយគ្នា និងបង្ហាញពីគោលដៅនៃភាពជាដៃគូ ថា តើគោលដៅនោះសម្រេចបានដោយរបៀបណា នៅពេលណា និងដោយអ្នកណា? ផែនការសកម្មភាពត្រូវមាន៖

- ✓ *គោលដៅច្បាស់លាស់*
- ✓ *បញ្ជីសកម្មភាព ដែលបង្ហាញពីកិច្ចការដែលត្រូវអនុវត្តដើម្បីសម្រេចគោលដៅ*
- ✓ *អ្នកទទួលខុសត្រូវ និងដឹកនាំសកម្មភាពទាំងនោះ*
- ✓ *ដំណាក់កាលអនុវត្តលើសកម្មភាពនីមួយៗ*
- ✓ *តារាងពេលវេលាសម្រាប់សកម្មភាពនីមួយៗ ថាត្រូវចាប់ផ្តើមនៅពេលណាហើយ បញ្ចប់នៅពេលណា?*
- ✓ *ធនធានដែលត្រូវការសម្រាប់សកម្មភាពនីមួយៗ និងអ្នកដែលជួយផ្គត់ផ្គង់ធនធានទាំងនោះ*
- ✓ *មធ្យោបាយវាស់វែងដើម្បីឱ្យដឹងថាយើងសម្រេចបានដល់គោលដៅដែរឬទេ ?*

**ជំហានទី ៩ ការកៀរគរធនធាន**

ជំហានចុងក្រោយមុននិងចាប់ផ្តើមអនុវត្តការងារ គឺការកៀរគរធនធាន ។ ពេលដែលអ្នកបានបញ្ចប់ផែនការសកម្មភាពរបស់អ្នក អ្នកនឹងដឹងថា ធនធានអ្វីខ្លះដែលត្រូវការជាចាំបាច់ដើម្បីធ្វើឱ្យគោលដៅរបស់អ្នកអាចសម្រេចបាន។

ធនធានចាំបាច់សម្រាប់ភាពជាដៃគូអាស្រ័យទៅលើប្រភេទដៃគូដែលអ្នកបានបង្កើតឡើង និងសកម្មភាពនានាដែលបានដាក់បញ្ចូលពេលធ្វើផែនការជាមួយដៃគូរបស់អ្នក។ ជួនកាលធនធានហិរញ្ញវត្ថុ និងសម្ភារៈត្រូវការជាចាំបាច់ហើយជួនកាលទៀតសកម្មភាពនោះត្រូវការតែពេលវេលា និងកិច្ចខិតខំប្រឹងប្រែង ឬធនធានបរិច្ចាគ ឬត្រូវការចូលរួមដោយអ្នកស្ម័គ្រចិត្តពីសមាជិកសហគមន៍តែប៉ុណ្ណោះ ។

ជាការសំខាន់ណាស់ ដែលអ្នកត្រូវពិភាក្សាពីធនធានដែលត្រូវការជាមួយដៃគូមុននឹងអនុវត្តសកម្មភាព។ លោកអ្នកត្រូវដឹងពីធនធានដែលអ្នកនឹងផ្តល់ទៅឱ្យដៃគូហើយ និងធនធានដែលដៃគូ និងផ្តល់ឱ្យអ្នកវិញ ដើម្បីជៀសវាងកុំឱ្យមានជម្លោះ និងការយល់ច្រឡំគ្នាទៅថ្ងៃក្រោយ ។

**ធនធានដែលត្រូវការសម្រាប់សកម្មភាពខុសៗគ្នារួមមានៈ**

- ✎ ពេលវេលាធ្វើការលើគម្រោង
- ✎ កិច្ចខំប្រឹងប្រែងដើម្បីបញ្ចប់គម្រោង
- ✎ សម្ភារចាំបាច់សម្រាប់អនុវត្តសកម្មភាព *ឧទាហរណ៍ដូចជា ឥដ្ឋសម្រាប់សាងសងបន្ទប់ថ្មីមួយជាដើម*
- ✎ មធ្យោបាយធ្វើដំណើរ និងដឹកជញ្ជូនសម្ភារៈ
- ✎ ការចំណាយផ្នែករដ្ឋបាល *ដូចជាសម្ភារៈការិយាល័យ ថតចម្លងនិងបោះ ពុម្ពឯកសារ*
- ✎ ម្ហូបអាហារនិងការស្នាក់អាស្រ័យ
  ពិសេសនៅពេលដែលសកម្មភាពរបស់អ្នកត្រូវអនុវត្តនៅឆ្ងាយពីផ្ទះ

- ថវិកាសម្រាប់ទិញធនធាននានាដែលមិនអាចទទួលបានពីការបរិច្ចាគ

## ជំហានទី ១០ អនុវត្តសកម្មភាព

បន្ទាប់ពីមានការព្រមព្រៀងជាមួយដៃគូអ្នកលើគោលដៅ និងរបៀបដែលអាចសម្រេចជោគជ័យបានរួចមក អ្នកអាចចាប់ផ្តើមអនុវត្តសកម្មភាពបានហើយ ។ ដើម្បីសម្រេចគោលដៅដែលបានព្រមព្រៀងគ្នានោះ ផែនការសកម្មភាពរបស់លោកអ្នកគួមានលក្ខណៈដូចខាងក្រោមនេះ៖

- **ប្តេជ្ញាអនុវត្ត** : ប្តេជ្ញាអនុវត្តផែនការសកម្មភាពរបស់លោកអ្នកឱ្យបានចប់ចុងចប់ដើម ។
- **ផ្តោតលើការទទួលខុសត្រូវ** : គ្រប់អ្នកពាក់ព័ន្ធក្នុងផែនការសកម្មភាពត្រូវបំពេញតួនាទី និងការទទួលខុសត្រូវក្នុងភាពជាដៃគូ ។
- **ទំនាក់ទំនង** : ចាប់តាំងពីពេលចាប់ផ្តើមអនុវត្តផែនការសកម្មភាព ការទំនាក់ទំនងត្រូវធ្វើឱ្យបានញឹកញាប់ជាមួយដៃគូរបស់ខ្លួន ព្រោះថាការទំនាក់ទំនងស្អិតរមួតនេះនិងអាចដោះស្រាយបញ្ហា និងជំរុញឱ្យមានការពង្រឹងការប្តេជ្ញាចិត្តចំពោះភាពជាដៃគូផ្សេងទៀតផង ។
- **មិនត្រូវព្រងើយកន្តើយ ឬ គេចវេសចំពោះជម្លោះដែលកើតឡើង** : ការមិនឯកភាពគ្នាក៏អាចកើតមានដែរ ទោះបីជាភាពជាដៃគូមានភាពរឹងមាំបំផុតក៏ដោយ ។ ជាការសំខាន់ ណាស់នៅពេលដែលមានបញ្ហាខ្វែងគំនិតគ្នា ឬមានជម្លោះអ្វីកើតឡើងជាមួយដៃគូបញ្ហានោះត្រូវបានយកមកពិភាក្សា និងដោះស្រាយឱ្យបានឆាប់រហ័ស បើពុំនោះទេវាវិតតែរីកធំឡើងៗ ហើយនឹងអាចធ្វើឱ្យមានការពិបាកក្នុងការដោះស្រាយ ។

## ជំហានទី ១១ ការវាយតម្លៃ

គ្រប់សកម្មភាពនៃភាពជាដៃគូត្រូវធ្វើការត្រួតពិនិត្យ និងវាយតម្លៃ ។ ធ្វើដូច្នេះយើងអាចរៀនសូត្រនូវអ្វីដែលយើងធ្វើទៅបានល្អ និងអ្វីដែលត្រូវកែតម្រូវ ។ ការរៀនសូត្រទាំងនោះមានប្រយោជន៍ដល់ការធ្វើផែនការ និងការអនុវត្តផែនការបានល្អនាពេលអនាគត ។

- **ការត្រួតពិនិត្យ** : ការប្រមូលព័ត៌មានដើម្បីវាស់វែងពីភាពជោគជ័យនៃសកម្មភាពការងារនោះហៅថា "ការត្រួតពិនិត្យ" ។ ព័ត៌មានដែលយើងត្រូវប្រមូលនោះគួមាននៅក្នុងផែនការសកម្មភាព ប្រសិនបើយើងធ្វើការត្រួតពិនិត្យជាទៀងទាត់អាចឱ្យយើងដឹងថា តើសកម្មភាពទាំងនោះអាចជួយយើងឱ្យសម្រេចគោលដៅរបស់យើងដែរឬទេ? ។ ការត្រួតពិនិត្យអាចជួយឱ្យក្រុមប្រឹក្សាមានគណនេយ្យភាពលើការធ្វើអ្វីដែលបាននិយាយ និងអ្វីដែលត្រូវសម្រេចបាន ។ ប្រសិនបើយើងកំពង់អនុវត្តកម្មវិធីមួយដែលកម្មវិធីនោះមានគោលបណងបង្កើនការចូលរួមរបស់ស្ត្រីក្នុងរដ្ឋបាលមូលដ្ឋាន ពេលនោះយើងពិនិត្យលើចំនួនស្ត្រីដែលចូលរួមក្នុងអង្គប្រជុំនានារបស់ក្រុមប្រឹក្សា ។ ម្យ៉ាងវិញទៀត បើភាពជាដៃគូ

របស់យើងទាក់ទងដល់ការនេសាទខុសច្បាប់ យើងអាចត្រួតពិនិត្យលើចំនួនជនល្មើសដែលត្រូវបានចាប់ខ្លួននិងឧបករណ៍ល្មើសច្បាប់ដែលរឹបអូសបានមក ឬថាតើសមាជិកសហគមន៍បានចូលរួមនៅក្នុងកិច្ចប្រជុំពិភាក្សាពីបញ្ហា ដែលបានចែងក្នុងផែនការដែរឬទេ?

- **ការវាយតម្លៃ** : ក្រុមប្រឹក្សាគួតែវិភាគព័ត៌មាន ដែលបានប្រមូលក្នុងដំណើរការត្រួតពិនិត្យនៅ ក្នុងពេលណាមួយនៃការធ្វើការក្នុងភាពជាដៃគូ។ ការវិភាគនេះហៅថា "ការវាយតម្លៃ" ។ ការ វាយតម្លៃអាចជួយឱ្យក្រុមប្រឹក្សារៀនសូត្រអំពីសកម្មភាពណាដែលធ្វើបានល្អ ហើយសកម្មភាពណាដែលត្រូវធ្វើការកែតម្រូវ ។ យើងគួរពិនិត្យមើលថាយើងប្រើប្រាស់ធនធានរបស់យើងមានប្រសិទ្ធភាពកំរិតណាហើយបានសម្រេចអ្វីខ្លះ? ក្រុមប្រឹក្សាគួរវាយតម្លៃសកម្មភាពការងារនៅក្នុងអំឡុងពេលដំណើរការភាពជាដៃគូដើម្បីសម្រេចថាតើត្រូវផ្លាស់ប្តូរផែនការសកម្មភាពដែរឬទេ? ប្រសិនបើសកម្មភាពណាមួយមិនដំណើរការនោះអ្នកគួតែធ្វើការផ្លាស់ប្តូរ ។ ក្រុមប្រឹក្សាអាចធ្វើការវាយតម្លៃសកម្មភាពការងារនៅពេលដែលគម្រោងបានបញ្ចប់សព្វគ្រប់ ។ ការវាយតម្លៃចុងក្រោយនេះអាចជួយដល់ក្រុមប្រឹក្សាក្នុងការធ្វើផែនការសកម្មភាពបន្ទាប់ទៀត ប្រសិនបើគោលដៅមិនបានសម្រេចដូចការគ្រោងទុក ។ បទពិសោធន៍ ដែលបានមកពីការវាយតម្លៃនេះនឹងជួយដល់ការកែលម្អគម្រោង និងភាពជាដៃគូទៅអនាគត ។

## ៨. សេចក្តីសន្និដ្ឋាន

ភាពជាដៃគូមានសារៈសំខាន់ណាស់ក្នុងការធ្វើឱ្យរដ្ឋបាលមូលដ្ឋានទទួលបានជោគជ័យ និងជួយដល់ការអភិវឌ្ឍមូលដ្ឋាន ។ ដោយហេតុថា ក្រុមប្រឹក្សា នៅកម្ពុជាមិនទាន់មានជំនាញ និងធនធានគ្រប់គ្រាន់សម្រាប់អនុវត្តការងារតែឯកឯងបាន ទើបការបង្កើតភាពជាដៃគូជាមួយអង្គការនានា និងសហគមន៍មូលដ្ឋានអាចធ្វើឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាចទទួលបាននូវធនធានច្រើនបង្កើនភាពជាដៃគូ ធ្វើឱ្យប្រសើរឡើងនូវសេវាសាធារណៈ ទទួលបានអភិបាលកិច្ចល្អ មានការសម្របសម្រួលសកម្មភាពល្អប្រសើរ និងធ្វើឱ្យការអនុវត្តគម្រោងអាចបញ្ចប់បានឆាប់រហ័ស ។

--- ចប់ ---

# ថ្ងៃទី៣

## ម្លប់មេរៀនទី៣

## ចំណងជើងមេរៀនៈ ប្រសិទ្ធភាពនៃការកសាងភាពជាដៃគូ

**ពេលវេលាៈ** ១០:៣០ ដល់ ១១:៣០ (៦០នាទី)

**គោលបំណងនៃមេរៀនៈ នៅចុងបញ្ចប់មេរៀននេះអ្នកចូលរួមអាចៈ**

១. ពន្យល់បានអំពី**អត្ថន័យ**ភាពជាដៃគូ និងរៀបរាប់បានពី**សារៈប្រយោជន៍**នៃការកសាងភាពជាដៃគូ ។

២. **កំណត់សមាសភាព**ដៃគូសំខាន់ៗរបស់ក្រុមប្រឹក្សាក្នុងការអនុវត្តគម្រោង "ការរៀនសូត្រពីការអនុវត្តអភិបាលកិច្ចល្អនៅថ្នាក់ក្រុង ស្រុក ឃុំ និងសង្កាត់" ។

៣. **កំណត់ និងឯកភាព**លើសកម្មភាពនៃការកសាងភាពជាដៃគូ ។

៦សកម្មភាព ការបំផុសគំនិត ពិភាក្សាក្រុមធំ ពិភាក្សាក្រុមតូច

## កំណត់ចំណាំរបស់អ្នកសម្របសម្រួល

១. ក្រុមប្រឹក្សា ពិសេសក្រុមប្រឹក្សាឃុំ សង្កាត់មានបទពិសោធន៍យ៉ាងច្រើនក្នុងការអនុវត្តការងារក្នុងភាពជាដៃគូជាមួយស្ថាប័ននានា ពិសេសជាមួយអង្គការសហគមន៍មូលដ្ឋាន (គណៈកម្មការកៀរគរសហគមន៍) និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការអនុវត្តសកម្មភាពអភិវឌ្ឍមូលដ្ឋាន ដូច្នេះអ្នកសម្របសម្រួល គួរព្យាយាមឆ្លុះបញ្ចាំងបទពិសោធន៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពង្រឹងភាពជាដៃគូក្នុងការអនុវត្តគម្រោងបន្ត ។

២. អង្គការសហគមន៍មូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលមានចំនួនច្រើន និងមានបទពិសោធន៍យ៉ាងច្រើនដែលអាចចូលរួមចំណែក ឬជួយគាំទ្រក្រុមប្រឹក្សាក្នុងការអនុវត្ត និងតាមដានគម្រោង ដូចជាការពង្រឹងសមត្ថភាព ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងថវិកាផងដែរ ។ ដូចគ្នាដែរ អ្នកផ្តល់សេវាឯកជនក៏មានការរីកចំរើនទាំងបរិមាណ និងគុណភាពនៃការផ្តល់សេវា ដូច្នេះអ្នកសម្របសម្រួលគួរយកចិត្តទុកដាក់ ដោយឆ្លុះបញ្ចាំងដើម្បីទាញយកធនធានដែលស្ថាប័នទាំងនោះមកជួយ ក្រុមប្រឹក្សាក្នុងការអនុវត្តគម្រោង ។

៣. អ្នកសម្របសម្រួលគួរផ្តោតយកចិត្តទុកដាក់ឱ្យក្រុមប្រឹក្សាមានភាពដៃគូជាមួយ**អ្នកសារព័ត៌មាន** ព្រោះថាពួកគាត់គឺជាតួអង្គក្នុងការតាមដាន និងគាំទ្រការអនុវត្តតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាដើម្បីលើកកម្ពស់តម្លាភាព និងគណនេយ្យភាព ។

៤. អ្នកសម្របសម្រួលអាចយោង (តារាងស្តីពីតួនាទី និងភារកិច្ចរបស់អ្នកដែលពាក់ព័ន្ធសំខាន់ក្នុងការអនុវត្តគម្រោង នៅក្នុងមេរៀនទី៥ **សិទ្ធិ និងតួនាទីរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ** ថ្ងៃទី១) ដើម្បីកំណត់ពីសមាសភាពដៃគូសំខាន់ៗក្នុងការអនុវត្តគម្រោង ។

## លទ្ធផលរំពឹងទុកនៃមេរៀន

១. អ្នកចូលរួមបានយល់ពីអត្ថន័យភាពជាដៃគូ និងសារៈប្រយោជន៍នៃការកសាងភាពជាដៃគូ ។
២. ក្រុមប្រឹក្សាដឹង និងកំណត់បានពីសមាសភាពដៃគូសំខាន់ៗក្នុងការអនុវត្តគម្រោង “ការរៀនសូត្រពីការអនុវត្តអភិបាលកិច្ចល្អនៅថ្នាក់ក្រុង ស្រុក ឃុំ និងសង្កាត់” ។
៣. ក្រុមប្រឹក្សា អង្គការសង្គមស៊ីវិល និងអ្នកសារព័ត៌មានបានដឹងពីជំហានទាំង១១ក្នុងការកសាងភាពជាដៃគូ ។
៤. ក្រុមប្រឹក្សាឯកភាពលើសកម្មភាពសម្រាប់អនុវត្តក្នុងការកសាងភាពជាដៃគូ ។

## សម្ភារឧបទ្ទេសសម្រាប់បង្រៀន

- ឯកសារមេរៀន ស្តីពីការកសាងភាពជាដៃគូ
  - បទបង្ហាញ
  - ឯកសាចែក
- ហ្វឺតសរសេរក្រដាស ក្រដាសផ្ទាំងធំ ស្កុត
- កុំព្យូទ័រយួរដៃ និងម៉ាស៊ីនបញ្ចាំងឯកសារបទបង្ហាញ

## ឯកសារយោង

- សៀវភៅណែនាំអំពីការកសាងភាពជាដៃគូ បោះពុម្ពដោយអង្គការផេកកម្ពុជា

## របៀបសម្របសម្រួលមេរៀន

| ម៉ោង | <u>សកម្មភាព និងវិធីសាស្ត្រ</u> | សម្ភារ និង ឯកសារចែកជូន |
|---|---|---|
| ៥ នាទី | **<u>សកម្មភាពទី១ សេចក្តីផ្តើម និងគោលបំណងមេរៀន</u>**<br>**បទបង្ហាញក្រុមធំ** | 💻 ស្លាយទី២<br>📄 ក្រដាសផ្ទាំងធំ |

| | | |
|---|---|---|
| | • អ្នកសម្របសម្រួលចាប់និយាយពី ភាពជាដៃគូគឺជាមធ្យោបាយដ៏ល្អប្រសើរបំផុតសម្រាប់ក្រុមប្រឹក្សា និងអង្គការសង្គមស៊ីវិលធ្វើការជាមួយគ្នាដើម្បីធ្វើឱ្យសហគមន៍មានភាពប្រសើរឡើង ។ ភាពជាដៃគូអាចជួយឱ្យក្រុមប្រឹក្សាមានលទ្ធភាពបង្កើននូវសេវាកម្មនានាដែលត្រូវផ្តល់ដល់ប្រជាពលរដ្ឋ និងធនធានដែលអាចរកបាន បង្កើនការចូលរួម ការសម្របសម្រួល និងការអនុវត្តគម្រោង ។ ដូច្នេះមេរៀនទី៣នេះនឹងពិភាក្សាអំពី (១) អត្ថន័យនៃភាពជាដៃគូ (២) តើក្រុមប្រឹក្សាគួរចាប់ដៃគូជាមួយអ្នកពាក់ព័ន្ធណាខ្លះ ដើម្បីអនុវត្តគម្រោងឱ្យមានប្រសិទ្ធភាព? (៣) តើក្រុមប្រឹក្សាទទួលបានសារៈប្រយោជន៍អ្វីខ្លះក្នុងការធ្វើការរួមគ្នាជាដៃគូ? ឬតើដៃគូនីមួយៗ ជួយគាំទ្រអ្វីខ្លះដល់ក្រុមប្រឹក្សាក្នុងការអនុវត្តគម្រោង? (៤) តើមានជំហាន ឬសកម្មភាពអ្វីខ្លះក្នុងដំណើរការកសាងភាពជាដៃគូ?<br>• អ្នកសម្របសម្រួលបង្ហាញគោលបំណងមេរៀន (ស្លាយទី២) | ✎ ហ្វឺតកត់ត្រាចម្លើយ និងបង់ស្អិត |
| ១០ នាទី | **<u>សកម្មភាពទី២ - អត្ថន័យភាពជាដៃគូ និងលក្ខណៈដៃគូដែលជោគជ័យ</u>**<br>**សំណួរបំផុសគំនិត និងពិភាក្សាក្រុមធំ**<br>• អ្នកសម្របសម្រួលសួរសំណួរ និងផ្តល់ឱកាសឱ្យអ្នកចូលរួមចំនួន៣នាក់ឆ្លើយ "តើភាពជាដៃគូមានន័យដូចម្តេច?"<br>• កត់ត្រាចម្លើយអ្នកចូលរួម<br>• បង្ហាញអត្ថន័យភាពជាដៃគូ និងលក្ខណៈដៃគូដែលទទួលជោគជ័យ ដោយអនុញ្ញាតិឱ្យអ្នកចូលរួមសួរបញ្ជាក់ និងចែករំលែកបទពិសោធន៍ | 💻 ស្លាយទី៣-៤<br>🗐 ក្រដាសផ្ទាំងធំ<br>✎ ហ្វឺតកត់ត្រាចម្លើយ និងបង់ស្អិត |
| ១៥ នាទី | **<u>សកម្មភាពទី៣ - សមាសភាពដៃគូរបស់ក្រុមប្រឹក្សា</u>**<br>**សំណួរបំផុសគំនិត និងពិភាក្សាក្រុមធំ**<br>• អ្នកសម្របសម្រួលសួរបំផុសគំនិតដល់អ្នកចូលរួម ថាកន្លងមកតើក្រុមប្រឹក្សាធ្លាប់មានដៃគូជាមួយនរណាខ្លះនៅមូលដ្ឋាន?<br>• ផ្តល់ឱកាសឱ្យអ្នកចូលរួមចំនួន៣នាក់ឆ្លើយសំណួរខាងលើ | 💻 ស្លាយទី៥-៩<br>🗐 ក្រដាសផ្ទាំងធំ<br>✎ ហ្វឺតកត់ត្រាចម្លើយ និងបង់ស្អិត |

| | | |
|---|---|---|
| | • កត់ត្រាចម្លើយអ្នកចូលរួម<br>• បង្ហាញពីសមាសភាពដៃគូនៅក្នុងមូលដ្ឋាន (ស្លាយទី៥ដល់៩)<br>• អ្នកសម្របសម្រួលសួរសំណួរថាតើមានដៃគូ **<u>ចំបង១ណាខ្លះ? នៅក្នុងមូលដ្ឋានលោកអ្នកហើយដៃគូទាំងនោះជួយគាំទ្រអ្វីខ្លះ</u>** ក្នុងការអនុវត្តគម្រោង<br>• អ្នកសម្របសម្រួលអាចរំលឹកឡើងវិញពីសកម្មភាពការងាររបស់គម្រោង "ការរៀនសូត្រពីការអនុវត្តគម្រោងអភិបាលកិច្ចល្អនៅថ្នាក់ក្រុង ស្រុក ឃុំ និងសង្កាត់" មេរៀនទី១ ថ្ងៃទី១ ស្លាយទី៧ និង៨<br>• អ្នកសម្របសម្រួលឆ្លុះបញ្ចាំងចម្លើយលើក្រដាសផ្ទាំងធំ<br>• អ្នកសម្របសម្រួលបូកសរុប | |
| ១០នាទី | **<u>សកម្មភាពទី៤ សារៈប្រយោជន៍នៃការកសាងភាពជាដៃគូ និងសកម្មភាពជាដៃគូ</u>**<br>**សំណួរបំផុសគំនិត និងពិភាក្សាក្រុមធំ**<br>• អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យអ្នកចូលរួមចំនួន៣នាក់ឆ្លើយសំណួរ **តើក្រុមប្រឹក្សាទទួលបានសារៈប្រយោជន៍អ្វីខ្លះក្នុងការធ្វើការរួមគ្នាជាដៃគូ? ឬតើដៃគូនីមួយៗ ជួយគាំទ្រអ្វីខ្លះដល់ក្រុមប្រឹក្សាក្នុងការអនុវត្តគម្រោង?**<br>• កត់ត្រាចម្លើយអ្នកចូលរួម<br>• អ្នកសម្របសម្រួលបង្ហាញពីសារៈប្រយោជន៍នៃការកសាងភាពជាដៃគូ និងសកម្មភាពរបស់ក្រុមប្រឹក្សាអាចធ្វើការជាមួយដៃគូ ដោយអនុញ្ញាតិឱ្យអ្នកចូលរួមសួរបញ្ជាក់ និងចែករំលែកបទពិសោធន៍ជាក់ស្តែង (ស្លាយទី១០-១២) | 💻 ស្លាយទី១០-១២<br>📄 ក្រដាសផ្ទាំងធំ<br>✏ ហ្វឺតកត់ត្រាចម្លើយ និងបង់ស្អិត |

| | | |
|---|---|---|
| ១៥ នាទី | **<u>សកម្មភាពទី៥ - សកម្មភាព ឬជំហានកសាងភាពជាដៃគូ</u>**<br>**ពិភាក្សាក្រុមតូច**<br>• យើងបានកំណត់ពីដៃគូសម្រាប់ការអនុវត្តគម្រោង "ការរៀនសូត្រពីការអនុវត្តអភិបាលកិច្ចល្អនៅថ្នាក់ក្រុង ស្រុក ឃុំ និងសង្កាត់"នៅសកម្មភាពទី៣ខាងលើ ដូច្នេះ យើងនឹងពិភាក្សាបន្តទៀតថា <u>តើមានកិច្ចការអ្វីខ្លះដែលត្រូវអនុវត្តសម្រាប់ការកសាងភាពជាដៃគូជាមួយក្រុមទាំងនោះ (ដៃគូចំនួនបីខាងលើ)?</u> ។<br>• អ្នកសម្របសម្រួលបង្ហាញបទបង្ហាញពីជំហានទាំង១១ ដោយបើកឱកាសឱ្យអ្នកចូលរួមសួរបញ្ជាក់ (ស្លាយទី១៣-២៣)<br>• ចែកសិក្ខាកាមជា៤ក្រុម ពិភាក្សាលើសំណួរ តើមានកិច្ចការអ្វីខ្លះដែលត្រូវអនុវត្តសម្រាប់ជំហាននីមួយៗនៃការកសាងភាពជាដៃគូជាមួយក្រុមទាំងអស់<u>(ដៃគូចំនួនបីខាងលើ)?</u> ដែលបានកំណត់ក្នុងសកម្មភាពទី៣ (ការកំណត់ដៃគូចំបង៧ក្នុងក្រុមពិភាក្សា)?<br>• អ្នកសម្របសម្រួល**<u>បូកសរុបលទ្ធផល</u>**ក្រុមដោយស្រង់ចេញពីលទ្ធផលក្រុមពិភាក្សា ហើយយកលទ្ធផលទៅ**<u>ពិភាក្សា និងឯកភាព</u>**ជាមួយអ្នកចូលរួម ។ លទ្ធផលបូកសរុបរបស់ក្រុមពិភាក្សាដែលបាន**<u>ពិភាក្សា និងឯកភាព</u>**នឹងយកទៅដាក់ក្នុង ផែនការសកម្មភាព មេរៀនទី៤ ការរៀបចំផែនការសកម្មភាព ។ | 💻 ស្លាយទី១៣-២៣<br>🗐 ក្រដាសផ្ទាំងធំ<br>🖉 ហ្វឹតកត់ត្រាចម្លើយ និងបង់ស្អិត |
| ៥ នាទី | **<u>សកម្មភាពទី៦ បូកសរុប</u>**<br>• យើងបានពិភាក្សាពីអត្ថន័យ សមាសភាព និងសារៈប្រយោជន៍នៃភាពជាដៃគូ<br>• ហើយក៏បានកំណត់ និងឯកភាពពីកិច្ចការដែលត្រូវអនុវត្តសម្រាប់ការកសាងភាពជាដៃគូផងដែរ ហើយលទ្ធផលទាំងនេះនឹងយកទៅដាក់បញ្ចូលក្នុងផែនការសកម្មភាពនៅមេរៀនទី៤ស្តីពីការរៀបចំផែនការសកម្មភាព ។ | 🗐 ក្រដាសផ្ទាំងធំ ដែលកត់ត្រាចម្លើយរបស់អ្នកចូលរួម |

## ថ្ងៃទី៣មេរៀនទី៣

# ប្រសិទ្ធភាពនៃ
# ការកសាងភាពជាដៃគូ

# គោលបំណងនៃមេរៀន

១. ពន្យល់បានពីអត្ថន័យនៃភាពជាដៃគូ និងរៀបរាប់បានពីសារៈសំខាន់នៃការកសាងភាពជាដៃគូ ។

២. កំណត់សមាសភាពដៃគូសំខាន់ៗរបស់ក្រុមប្រឹក្សាក្នុងការអនុវត្តគម្រោង “ការរៀនសូត្រពីការអនុវត្តអភិបាលកិច្ចល្អនៅថ្នាក់ក្រុង ស្រុក ឃុំ និងសង្កាត់” ។

៣. កំណត់ និងឯកភាពលើសកម្មភាពនៃការកសាងភាពជាដៃគូ ។

# តើភាពជាដៃគូមានន័យដូចម្តេច?

ភាពជាដៃគូ មានច្រើនប្រភេទខុសៗគ្នា ។ ជាទូទៅ ភាពជាដៃគូធ្វើឡើងដើម្បីសម្រេចកិច្ចការណាដែលមិនអាចធ្វើតែឯកឯងបាន ឬចាំបាច់ត្រូវធ្វើការរួមគ្នាដើម្បីទទួលលទ្ធផលល្អប្រសើរជាងធ្វើការតែឯកឯង ។

# លក្ខណៈដៃគូដែលទទួលជោគជ័យ

**ការទំនាក់ទំនង** - ដៃគូដែលជោគជ័យត្រូវការទាក់ទងគ្នាទៅវិញទៅមក ដោយស្មោះត្រង់ និងដោយឥតលាក់លៀម

**ការសិក្សា** - ដៃគូដែលជោគជ័យត្រូវរៀនសូត្រពីគ្នាទៅវិញទៅមក

**ការប្តេជ្ញាចិត្ត** - ដៃគូដែលជោគជ័យត្រូវមានគោលដៅរួម និងប្តេជ្ញាចិត្តរួមគ្នាដើម្បីសំរេចគោលដៅ

**ការគាំទ្រ** - ដៃគូដែលជោគជ័យត្រូវទុកចិត្តគ្នា គោរពគ្នា និងគាំទ្រគ្នាវិញទៅមក

# ដៃគូនៅមូលដ្ឋាន

**ក្រុមប្រឹក្សាដូចគ្នា** - ជួនកាលក្រុមប្រឹក្សាមួយមិនមានធនធានខ្លួនឯងគ្រប់គ្រាន់សម្រាប់អនុវត្តន៏គម្រោងរបស់ខ្លួនទេ តែអាចធ្វើបានបើសិនជាឃុំ សង្កាត់ពីរ ឬច្រើនចូលរួមគ្នាអនុវត្ត ដោយហេតុថាក្រុមប្រឹក្សាឃុំ សង្កាត់ផ្សេងទៀតអាចមានប្រភពធនធានមានតម្លៃ មានគំនិតយោបល់ និងបទពិសោធន៏ល្អៗផ្សេងៗគ្នា។

**ស្ថាប័នរដ្ឋាភិបាល** - កិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងជាមួយស្ថាប័នរដ្ឋាភិបាលថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិ មានសារសំខាន់ណាស់សម្រាបកិច្ចការទាំងអស់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

# ដៃគូនៅមូលដ្ឋាន (ត)

**អង្គការមិនមែនរដ្ឋាភិបាល** - ទាំងអង្គការជាតិ និងអង្គការអន្តរជាតិមានបទពិសោធន៍ច្រើនក្នុងការងារអភិវឌ្ឍន៍ដោយធ្វើការជាមួយសហគមន៍ ដើម្បីសម្រេចនូវគោលបំណងរបស់ពួកគេ។ មានអង្គការខ្លះធ្វើការងារផ្តោតទៅលើវិស័យមួយចូបជា៖ ផ្នែកសុខភាព អប់រំ សិទ្ធិមនុស្ស ហើយមានអង្គការខ្លះធ្វើការងារផ្តោតលើវិស័យច្រើនលើគម្រោងអភិវឌ្ឍន៍សហគមន៍។

**អង្គការសហគមន៍មូលដ្ឋាន** - អង្គការសហគមន៍មូលដ្ឋាន ធនាគារជ្រូក ធនាគារគោ ធនាគារស្រូវ សហគមន៍ព្រៃឈើ ក្រុមសហគមន៍ប្រើប្រាស់ទឹកស្អាត និងក្រុមជួយខ្លួនឯង គឺជាផ្នែកសំខាន់នៃអង្គការសហគមន៍មូលដ្ឋាន ហើយសមាជិកដែលចូលរួមក្នុងក្រុមទាំងនោះមកពីភូមិនានានៅក្នុងឃុំ។

# ដៃគូនៅមូលដ្ឋាន (ត)

**សមាគមព្រះសង្ឃនិងវត្តអារាម** -វត្តអារាមជាកន្លែងយ៉ាងប្រពៃ និងសំខាន់សម្រាប់ប្រជាពលរដ្ឋរសនៅក្នុងភូមិធ្វើសក្ការៈបូជា និងជាកន្លែងអង្គាសបច្ច័យដើម្បីគាំទ្រដលើការកសាងសមិទ្ធិផលផ្សេងៗ។

**ចាស់ព្រឹទ្ធាចារ្យ** - ចាស់ព្រឹទ្ធាចារ្យនៅក្នុងភូមិដូចជា លោកអាចារ្យ មានឥទ្ធិពលខ្លាំងលើសេចក្តីសម្រេចចិត្តនានារបស់សហគមន៍។ គាត់គឺជាដៃគូយ៉ាងសំខាន់នៅពេលដែលចាំបាច់ ក្នុងការគៀរគរការគាំទ្រ ឬការចូលរួមនានាពីសហគមន៍។

# ដៃគូនៅមូលដ្ឋាន (ត)

**អាជីវកម្ម ឬវិនិយោគទុន** - ជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងសហគមន៍មូលដ្ឋាន។ ពួកគេជាអ្នកបង្កើតការងារដល់ប្រជាពលរដ្ឋឱ្យមានការងារធ្វើ និងចូលរួមចំណែកជួយធ្វើឱ្យប្រសើរឡើងនូវសេដ្ឋកិច្ចនៅថ្នាក់មូលដ្ឋាន។

**សមាគមន៍យុវជន** - ជាង ៤០ ភាគរយនៃប្រជាជនកម្ពុជាមានអាយុតិចជាង ១៥ឆ្នាំ ។ ដូច្នេះបញ្ហាដែលប៉ះពាល់ដល់យុវជន គឺជាបញ្ហាចំបងដែលត្រូវយកចិត្តទុកដាក់ ។ សហគមយុវជនជាវេទិកាដ៏ប្រសើរបំផុតក្នុងការគៀងគរការចូលរួមពីសមាជិកយុវជននៅក្នុងសហគមន៍ ។

# ដៃគូនៅមូលដ្ឋាន (ត)

**ក្រុមស្ត្រី** - ស្ត្រីមិនសូវមានតំណាងរបស់ខ្លួននៅគ្រប់ជាន់ថ្នាក់ក្នុងជួររដ្ឋាភិបាលនៅកម្ពុជា ប៉ុន្តែតួនាទី និងសំម្លេងរបស់ស្ត្រីនៅក្នុងសង្គម គឺមានសារៈ សំខាន់ណាស់ ។ ក្រុមស្ត្រីអាចធ្វើឱ្យក្រុមប្រឹក្សាឃុំ សង្កាត់លើកទឹកចិត្ត និងការគាំទ្រការចូលរួមរបស់ស្ត្រីលើការផ្តួចផ្តើមគំនិតផ្សេងៗនៅមូលដ្ឋាន ។

**សមាគមកម្មករ** - មានដូចជាសមាគមកសិករ ក្រុមអាជីវករ សមាគមម្ចូតូឌុប សមាគមអ្នកជៀវជ័រកៅស៊ូ ។ល ។ អាចផ្តលនូវពត៌មានសំខាន់ៗឬជួយគាំទ្រនិងការអបរំដល់សហាគមន៍ ។

# សារៈប្រយោជន៍នៃការកសាងភាពជាដៃគូ

**កំណើនធនធាន** - ពេលណាដៃគូរួមគ្នា ពួកគេអាចដាក់បញ្ចូលធនធានជាមួយគ្នា។ ជាលទ្ធផលនឹងមានការកើនឡើងនូវធនធានមនុស្សចូលរួមក្នុងគម្រោង មានជំនាញផ្សេងៗច្រើន មានថវិកា សម្ភារៈច្រើនសំរាប់អនុវត្ត គម្រោង។

**ការចូលរួមច្រើន** - ពេលដែលក្រុមប្រឹក្សា ចាប់ដៃគូជាមួយអង្គការសង្គមស៊ីវិលដូចជាអង្គការក្រៅរដ្ឋភិបាល ឬក្រុមសមាគមន៍នានា និងអ្នកសារពតិមាន នឹងលើកកម្ពស់ការចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាពលរដ្ឋក្នុងដំណើរការអនុវត្តគម្រោង

**សេវាកម្មល្អប្រសើរ** - ការធ្វើការរួមគ្នា ដៃគូអាចផ្តល់សេវាកម្មប្រកបដោយតម្លាភាព មានគណនេយ្យភាព និងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

# សារៈប្រយោជន៍នៃការកសាងភាពជាដៃគូ (ត)

**ការសម្របសម្រួលល្អប្រសើរ** - ជូនកាលទាំងក្រុមប្រឹក្សា អង្គការសង្គមស៊ីវិល ឬក្រុមសមាគមន៍នានា ធ្វើការដូចគ្នាក្នុងពេលតែមួយ ។ ក្រុមប្រឹក្សា និងក្រុមទាំងនោះសម្រេចធ្វើការក្នុងភាពជាដៃគូជាមួយគ្នា ពួកគេអាចសម្របសម្រួលការងារបានល្អ ហើយផ្តល់នូវផលប្រយោជន៍បានច្រើនដោយចំណាយថ្លៃដើមទាប ។

**គម្រោងអាចបញ្ចប់បានឆាប់រហ័ស** - ពេលដែលដៃគូធ្វើការរួមគ្នា ដើម្បីសម្រេចបាននូវគោលបំណងរួម ពួកគេអាចបញ្ចប់គម្រោងនោះបានឆាប់រហ័ស និងល្អប្រសើរជាងការអនុវត្តន៍គម្រោងម្នាក់ឯង ។

# សកម្មភាពរបស់ក្រុមប្រឹក្សាអាចធ្វើការជាមួយដៃគូ

**សកម្មភាពអភិវឌ្ឍ** - ចូលរួមផ្តល់ប្រឹក្សាបច្ចេកទេស និងជំនួយផ្សេងៗដូចជា៖ ការប៉ាន់ប្រមាណតម្រូវការអ្នកភូមិ ការរៀបចំនិងអនុវត្តផែនការ ការត្រួតពិនិត្យ និងការស្វែងរកថវិកាជាដើម។

**គោលនយោបាយ** - ជួយក្នុងការអនុម័ត "ដីកា និងសេចក្តីសម្រេច" ដោយផ្តល់ការអប់រំអំពីច្បាប់ និងរៀបចំសេចក្តីសម្រេច។

**ការសម្រុះសម្រួល** - ជួយសម្រុះសម្រួលជម្លោះដូចជា អំពើហឹង្សាក្នុងគ្រួសារ ទំនាស់ដីធ្លី ឬកេរ្តិ៍មរតក។ ផ្តល់ព័ត៌មានត្រឡប់ដល់ក្រុមប្រឹក្សាក្នុងការអនុវត្ត និងការធ្វើសេចក្តីសម្រេចនានា។

**សេវាសាធារណៈ** - អាចជួយក្រុមប្រឹក្សាផ្តល់សេវាសាធារណៈ

# ជំហានសំខាន់ៗក្នុងការកសាងភាពជាដៃគូ

**ជំហានទី១** ហេតុអ្វីត្រូវមានភាពជាដៃគូ?

**ជំហានទី២** ប្រភេទនៃភាពជាដៃគូ

**ជំហានទី៣** ការជ្រើសរើសដៃគូ

**ជំហានទី៤:** ការជ្រើសរើសក្រុមការងារ

**ជំហានទី៥** ចែករំលែកការរំពឹងទុក

**ជំហានទី៦** ការព្រមព្រៀងលើគោលការណ៍

**ជំហានទី៧** កំណត់គោលដៅ

**ជំហានទី៨** ការរៀបចំផែនការសកម្មភាព

**ជំហានទី៩** ការកៀរគរធនធាន

**ជំហានទី១០** អនុវត្តសកម្មភាព

**ជំហានទី១១** ការវាយតម្លៃ

# ជំហានទី១: ហេតុអ្វីត្រូវមានភាពជាដៃគូ?

- ត្រូវសម្រេចចិត្តថា ហេតុអ្វីបានជាចាប់អារម្មណ៍ក្នុងការមានភាពជាដៃគូ?
- តើយើងចង់បានដៃគូដោយសារតែយើងខ្វះខាតធនធានឬ?
- តើយើងចង់បានដៃគូដោយសារតែយើងចង់បង្កើនការចូលរួមពីសាធារណៈ ឱ្យបានច្រើនឬ?
- តើយើងចង់បានដៃគូដោយសារតែយើងខ្វះខាតជំនាញឬ?
- តើភាពជាដៃគូនឹងផ្តល់ប្រយោជន៍ដល់សហគមន៍មូលដ្ឋានដែរឬទេ?
- តើមានជំរើសអ្វីផ្សេងទៀតទេ ចំពោះភាពជាដៃគូ?
- អ្វីជាផលប្រយោជន៍នៃភាពជាដៃគូ?
- អ្វីជាផលមិនល្អបណ្តាលមកពីភាពជាដៃគូ?
- តើនឹងមានផលលំបាកអ្វីខ្លះ បើសិនជាភាពជាដៃគូមិនទទួលបានជោគជ័យ?

# ជំហានទី២ ប្រភេទនៃភាពជាដៃគូ

## ត្រូវសម្រេចចិត្តឱ្យបានច្បាស់ថា តើដៃគូប្រភេទណាដែលត្រូវការ!!!

**ការសម្របសម្រួល** កើតឡើងនៅពេលណាដែលដៃគូរបស់ខ្លួនធ្វើការដោយឡែកពីគ្នា ប៉ុន្តែចាំបាច់ត្រូវការសម្របសម្រួលសកម្មភាព ដើម្បីជៀសវាងការធ្វើការត្រួតគ្នា និងអាចចែករំលែកធនធាន ។

**ការពិគ្រោះយោបល់** ប្រព្រឹតទៅតាមរយៈការសួរជាសំនួរ ស្តាប់ការបកស្រាយ និងសិក្សាពីប្រជាពលរដ្ឋរស់នៅក្នុង និងក្រៅតំបន់គ្រប់គ្រងរបស់ក្រុមប្រឹក្សា ។ ការពិគ្រោះយោបល់កើតឡើងនៅពេលក្រុមប្រឹក្សាត្រូវការពតិមាន ជំនាញបច្ចេកទេស ចំណេះដឹង បទពិសោធន៍គំនិត និងយោបល់នានា ដើម្បីយកមកធ្វើការសម្រេចចិត្តលើអ្វីមួយ ។

**កិច្ចសហការ** កើតឡើងនៅពេលក្រុមប្រឹក្សា និងដៃគូរបស់ខ្លួនធ្វើការរួមគ្នាដើម្បីសម្រេចគោលដៅរួម ។ វាត្រូវការរួមបញ្ចូលការពិគ្រោះយោបល់ និងការសម្របសម្រួល ។

# ជំហានទី៣ ការជ្រើសរើសដៃគូ

**១.មានការចូលរួម** ត្រូវមានការចូលរួមពីសមាជិកពាក់ព័ន្ធទាំងអស់របស់គម្រោង។

**២.កំណត់តម្រូវការ** ក្រុមប្រឹក្សាត្រូវកំណត់ពីតម្រូវការរបស់ខ្លួនជាមុនសិន និងស្វែងរកដៃគូណាដែលអាចបំពេញតម្រូវការនោះ ។

**៣.អ្នកណាជាដៃគូ** រៀបចំបញ្ជីឈ្មោះដៃគូ

**៤.តើដៃគូសមស្របមានលក្ខណៈដូចម្តេច?** ចំណេះដឹង បទពិសោធន៍ ទីតាំង ធ្លាប់អនុវត្តគម្រោងស្រដៀងគ្នា យល់ដឹងពីបញ្ហាក្នុងតំបន់ ត្រូវចំណាយថវិកាប៉ុន្មានដើម្បីធ្វើការជាដៃគូ ។

**៥.ផលប្រយោជន៍** បើធ្វើការជាមួយដៃគូទាំងនោះ តើទទួលបានផលប្រយោជន៍អ្វីខ្លះ?

# ជំហានទី៤ ការជ្រើសរើសក្រុមការងារ

ត្រូវជ្រើសរើសមនុស្សមកធ្វើការក្នុងក្រុមការងារភាពជាដៃគូ ហើយពួកគេត្រូវមានជំនាញ និងសមត្ថភាពអនុវត្តការងារ និងព្រមទាំងមាន៖

១. **ការប្តេជ្ញាចិត្ត** មានការប្តេជ្ញាចិត្តដើម្បីជោគជ័យ ។

២. **ជំនាញ** មានជំនាញពិតប្រាកដដែលអាចជួយដល់ដៃគូ ។

៣. **ពេលវេលា** មានពេលវេលាគ្រប់គ្រាន់សម្រាប់បំពេញកិច្ចការ ។

# ជំហានទី៥ ការចែករំលែកការរំពឹងទុក

- ត្រូវធ្វើការប្រជុំជាមួយដៃគូដើម្បីពិភាក្សា និងចែករំលែកពីការរំពឹងទុកក្នុងភាពជាដៃគូ ។
- ត្រូវយល់ឱ្យច្បាស់ពីការរំពឹងទុក ដែលអ្នកថានឹងទទួលបានពីដៃគូ
- ត្រូវស្តាប់ពីការរំពឹងទុករបស់ដៃគូដែរ ។

# ជំហានទី៦ ការព្រមព្រៀងលើគោលការណ៍

ត្រូវព្រមព្រៀងលើគោលការណ៍នានាដែលណែនាំពីភាពជាដៃគូ និងការកំណត់លក្ខខណ្ឌរួម ។ គោលការណ៍គួរពិចារណា ៖

- គោរពគ្នាទៅវិញទៅមក
- មានភាពស្មោះត្រង់ទៅវិញទៅមក
- ចូលរួមពីគ្នាទៅវិញទៅមក
- ផ្សេងៗដែលព្រមព្រៀងដោយភាគីទាំងសងខាង ។

# ជំហានទី៧ ការកំណត់គោលដៅ

ការកំណត់គោលដៅសម្រាប់ភាពជាដៃគូមានសារៈសំខាន់ណាស់ ហើយវាជាការព្រមព្រៀងដែលភាពជាដៃគូត្រូវសម្រេចឱ្យបាន ។
ត្រូវប្រាកដថា គោលដៅនោះច្បាស់លាស់ និងអាចសម្រេចបាន ។

# ជំហានទី៨ ការរៀបចំផែនការ

ផែនការសកម្មភាពគួរតែរៀបចំរួមជាមួយគ្នា ដោយឆ្លើយតបនឹងគោលដៅនៃភាពជាដៃគូ ថាតើគោលដៅនោះសម្រេចបានដោយរបៀបណា? នៅពេលណា? និងដោយនរណា? ផែនការត្រូវមាន ៖

- គោលដៅ
- សកម្មភាពការងារ និងអ្នកទទួលខុសត្រូវ
- តារាងពេលវេលាសម្រាប់អនុវត្តសកម្មភាពនីមួយៗ និងធនធានសម្រាប់អនុវត្ត
- មធ្យោបាយវាស់វែង

# ជំហានទី១០ ការអនុវត្តសម្ភាព

ការអនុវត្តតាមផែនការសកម្មភាព ត្រូវពិភាក្សាពីធនធានដែលត្រូវការជាមួយដៃគូមុននឹងអនុវត្តសកម្មភាព ៖

- **ការប្ដេជ្ញាអនុវត្ត** ត្រូវអនុវត្តផែនការសកម្មភាពឱ្យចប់ ។
- **ផ្ដោតលើការទទួលខុសត្រូវ** គ្រប់អ្នកពាក់ព័ន្ធក្នុងផែនការសកម្មភាពត្រូវបំពេញតួនាទី និងការទទួលខុសត្រូវក្នុងភាពជាដៃគូ ។
- **ទំនាក់ទំនង** ត្រូវធ្វើការទំនាក់ទំនងឱ្យបានញឹកញាប់ជាមួយដៃគូ
- **មិនព្រងើយកន្តើយចំពោះជម្លោះដែលកើតឡើង** ពេលមានខ្វែងគំនិតគ្នាបញ្ហាត្រូវយកមកពិភាក្សា និងដោះស្រាយឱ្យបានរហ័ស ។

# ជំហានទី១១ ការវាយតម្លៃ

គ្រប់សកម្មភាពនៃភាពជាដៃគូត្រូវធ្វើការត្រួតពិនិត្យ និងវាយតម្លៃ។ ដូច្នេះ យើងអាចរៀនសូត្រនូវអ្វីដែលយើងធ្វើទៅបានល្អ និងអ្វីដែលត្រូវកែតម្រូវ។ ការរៀនសូត្រទាំងនោះមានប្រយោជន៍ដល់ការធ្វើផែនការ និងការអនុវត្តផែនការបានល្អនាពេលអនាគត ។

# ថ្ងៃទី៣

# ឯកសារចែក

## មេរៀនទី៣: ប្រសិទ្ធភាពនៃការកសាងភាពជាដៃគូ

## ១.សេចក្តីផ្តើម

ភាពជាដៃគូ គឺជាមធ្យោបាយដ៏ប្រសើរបំផុតសម្រាប់ក្រុមប្រឹក្សា និងអង្គការសង្គមស៊ីវិលធ្វើការជាមួយគ្នា ដើម្បីធ្វើឱ្យសហគមន៍មានភាពប្រសើរឡើង។ ភាពជាដៃគូអាចជួយឱ្យក្រុមប្រឹក្សាមានលទ្ធភាពបង្កើននូវសេវាកម្មនានាដែលត្រូវផ្តល់ដល់ប្រជាពលរដ្ឋ និងធនធានដែលអាចរកបាន បង្កើនការចូលរួម ការសម្របសម្រួល និងការអនុវត្តគំរោង។ ការកសាងភាពជាដៃគូប្រកបដោយចេរភាព ជាដំណើរការដ៏លំបាកដែលតម្រូវឱ្យមានជំនាញ និងធនធានចាំបាច់មួយចំនួន។ ផ្អែកលើបទពិសោធន៍ពីការស្រាវជ្រាវស្តីពីភាពជាដៃគូនៅក្នុងប្រទេសកម្ពុជានិងបទពិសោធន៍នៅប្រទេសមួយចំនួន ឯកសារនេះនឹងបង្ហាញនូវគំរូ ១១ជំហាន នៃការកសាងភាពជាដៃគូ ដែលអាចជួយដល់លោកអ្នកក្នុងការកសាងភាពជាដៃគូបានប្រកបដោយភាពរឹងមាំ និងជោគជ័យ ។

## ២.គោលបំណងនៃការកសាងភាពជាដៃគូ

- ភាពជាដៃគូអាចជួយឱ្យក្រុមប្រឹក្សាមានលទ្ធភាពបង្កើននូវសេវាកម្មនានាសំរាប់ផ្តល់ដល់ប្រជាពលរដ្ឋ
- បង្កើនការចូលរួម ការសម្របសម្រួល និងការអនុវត្តគំរោង
- បង្កើនបាននូវធនធាន (ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ)
- បង្កើនការទំនាក់ទំនងរវាងគ្នានឹងគ្នា ការសិក្សា ការសម្រេចចិត្ត ការគាំទ្រ និងការប្តេជ្ញាចិត្ត

## ៣. អ្វីទៅដែលហៅថាភាពជាដៃគូ ?

ឯកសារនេះបង្ហាញអំពីអត្ថប្រយោជន៍នៃភាពជាដៃគូ និងមធ្យោបាយសំខាន់ៗដែលអាចកសាងភាពជាដៃគូនៅថ្នាក់ឃុំ សង្កាត់ ដែលរៀបចំឡើងដើម្បីជាជំនួយដល់ក្រុមប្រឹក្សា សង្គមស៊ីវិល និងផ្នែកឯកជនដែលពាក់ពន្ធ័។ ភាពជាដៃគូមានច្រើនប្រភេទខុសៗគ្នា។ ជារឿយៗភាពជាដៃគូធ្វើឡើងដើម្បីសម្រេចកិច្ចការណា ដែលមិនអាចធ្វើតែឯកឯងបាន ឬចាំបាច់ត្រូវធ្វើការរួមគ្នា ដើម្បីទទួលបានលទ្ធផលល្អប្រសើរជាងការធ្វើការតែឯកឯង។ ភាពជាដៃគូនៅថ្នាក់ឃុំ សង្កាត់ គឺជាទំនាក់ទំនងរវាងក្រុមប្រឹក្សា និងសង្គមស៊ីវិលឬក្រុមផ្សេងទៀត។ ភាពជាដៃគូទាំងនេះគឺធ្វើឡើងដើម្បីសម្រេចគោលដៅរួម។ មិនថាភាពជាដៃគូប្រភេទណាទេ ភាពជាដៃគូដែលទទួលបានជោគជ័យទាំងអស់គឺសុទ្ធតែមានលក្ខណៈរួមដូចខាងក្រោម។

☞ **ការទំនាក់ទំនង:** ដៃគូដែលជោគជ័យត្រូវទាក់ទងគ្នាទៅវិញទៅមកដោយស្មោះត្រង់និងដោយឥតលាក់លៀម

- ☞ **ការសិក្សា**: ដៃគូដែលជោគជ័យត្រូវរៀនពីគ្នាទៅវិញទៅមក
- ☞ **ការគាំទ្រ**: ដៃគូដែលជោគជ័យ ត្រូវទុកចិត្តគ្នា គោរពគ្នា និងគាំទ្រគ្នាទៅវិទៅមក
- ☞ **ការប្តេជ្ញាចិត្ត**: ដៃគូដែលជោគជ័យត្រូវមានគោលដៅរួមនិងប្តេជ្ញាចិត្តរួមគ្នាដើម្បីសម្រេចគោលដៅនោះ

## ៤. អត្ថប្រយោជន៍នៃភាពជាដៃគូ

ភាពជាដៃគូដែលជោគជ័យអាចផ្តល់នូវផលប្រយោជន៍សំខាន់ៗដល់គ្នាទៅវិញទៅមកទាំងអ្នកដែលជាដៃគូ និងអ្នកដែលជួយគាំទ្រ ។ អត្ថប្រយោជន៍ទាំងនោះរួមមាន៖

១. **កំណើនធនធាន**: ពេលណាដៃគូរួមគ្នា ពួកគេអាចដាក់បញ្ចូលធនធានជាមួយគ្នា ។ ជាលទ្ធផលនឹងមានការកើនឡើងនូវធនធានមនុស្ស និងជំនាញផ្សេងៗច្រើន មានថវិកា និងសម្ភារៈច្រើនសម្រាប់អនុវត្តគម្រោង

២. **ការចូលរួមច្រើន**: ពេលដែលក្រុមប្រឹក្សាមានភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិលដូចជា អង្គការមិនមែនរដ្ឋាភិបាល ឬក្រុមសហគមន៍នានា និងធ្វើឱ្យមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋ បានល្អប្រសើរក្នុងដំណើរការអនុវត្តគំរោងនានា ។

៣. **សេវាកម្មល្អប្រសើរ**: ធ្វើការរួមគ្នា ដៃគូអាចផ្តល់សេវាកម្មបានល្អប្រសើរជាងការធ្វើតែម្នាក់ឯង ។

៤. **ការសម្របសម្រួលល្អប្រសើរ**: ជួនកាលទាំងក្រុមប្រឹក្សា អង្គការសង្គមស៊ីវិល ឬក្រុមសហគមន៍នានាធ្វើការដូចគ្នាក្នុងពេលតែមួយ ។ ពេលដែលក្រុមប្រឹក្សា និងក្រុមទាំងនោះសម្រេចធ្វើការក្នុងភាពជាដៃគូជាមួយគ្នា ពួកគេអាចសម្របសម្រួលការងារបានល្អហើយផ្តល់នូវផលប្រយោជន៍ បានច្រើនដោយចំណាយថ្លៃដើមទាប ។

៥. **គម្រោងអាចបញ្ចប់បានឆាប់រហ័ស**: ពេលដែលដៃគូធ្វើការរួមគ្នា ដើម្បីសម្រេចបាននូវគោលបំណងរួម ពួកគេអាចបញ្ចប់គម្រោងនេះបានឆាប់រហ័សនិងល្អប្រសើរជាងការអនុវត្តគម្រោងម្នាក់ឯង ។

## ៥. តើអ្នកណាខ្លះជាដៃគូនៃក្រុមប្រឹក្សា?

ក្រុមប្រឹក្សាអាចជ្រើសរើសដៃគូអាស្រ័យលើគោលដៅ និងតម្រូវការរបស់ខ្លួន ។ ដៃគូដែលក្រុមប្រឹក្សាឃុំសង្កាត់អាចធ្វើការជាមួយគ្នាបានមានដូចជា៖

| | |
|---|---|
| ក្រុមប្រឹក្សាដូចគ្នា | ជួនកាលឃុំ សង្កាត់មួយមិនមានធនធានខ្លួនឯងគ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងរបស់ខ្លួនទេ តែអាចធ្វើបានបើសិនជាឃុំ សង្កាត់ ឬច្រើនចូលរួមគ្នាអនុវត្ត ដោយហេតុថាក្រុមប្រឹក្សាផ្សេងទៀតអាចមានប្រភពធនធានមានតម្លៃ មានគំនិតយោបល់ និងបទពិសោធន៍ល្អៗផ្សេងៗគ្នា ។ |
| ស្ថាប័នរដ្ឋាភិបាល | កិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងជាមួយស្ថាបន័រដ្ឋាភិបាលថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិ មានសារសំខាន់ណាស់សម្រាប់កិច្ចការទាំងអស់របស់ក្រុមប្រឹក្សា ។ |

| | |
|---|---|
| **អង្គការមិនមែនរដ្ឋាភិបាល** | ទាំងអង្គការជាតិ និងអង្គការអន្តរជាតិមានបទពិសោធន៍ច្រើនក្នុងការងារអភិវឌ្ឍ ដោយធ្វើការជាមួយសហគមន៍ ដើម្បីសម្រេចនូវគោលបំណងរបស់ពួកគេ។ មានអង្គការខ្លះធ្វើការងារផ្តោតទៅលើវិស័យមួយដូចជា: ផ្នែកសុខភាព អប់រំ សិទ្ធិមនុស្ស និងលើកគម្រោងអភិវឌ្ឍសហគមន៍។ល។ |
| **អង្គការសហគមន៍មូលដ្ឋាន** | អង្គការសហគមន៍មូលដ្ឋាន ធនាគារជ្រូក ធនាគារគោ ធនាគារស្រូវ សហគមន៍ព្រៃឈើ ក្រុមសហគមន៍ប្រើប្រាស់ទឹកស្អាតនិងក្រុមជួយខ្លួនឯង គឺជាផ្នែកសំខាន់នៃអង្គការសហគមន៍មូលដ្ឋានហើយសមាជិកដែលចូលរួមក្នុងក្រុមទាំងនោះមកពីភូមិនានានៅក្នុងឃុំ។ |
| **សមាគមព្រះសង្ឃ និងវត្តអារាម** | វត្តអារាមជាកន្លែងយ៉ាងប្រពៃ និងសំខាន់សម្រាប់ប្រជាពលរដ្ឋរស់នៅក្នុងភូមិធ្វើសក្ការៈបូជានិងជាកន្លែងអង្គាសបច្ច័យ ដើម្បីគាំទ្រលើការកសាងសមិទ្ធិផលផ្សេងៗ។ |
| **ចាស់ព្រឹទ្ធាចារ្យ** | ចាស់ព្រឹទ្ធាចារ្យនៅក្នុងភូមិដូចជា លោកអាចារ្យ មានឥទ្ធិពលខ្លាំងណាស់លើសេចក្តីសម្រេចចិត្តនានារបស់សហគមន៍។គាត់គឺជាដៃគូយ៉ាងសំខាន់នៅពេលដែលចាំបាច់ក្នុងការកៀរគរការគាំទ្រ ឬការចូលរួមនានាពីសហគមន៍។ |
| **អាជីវកម្ម ឬវិនិយោគទុន** | អាជីវកម្ម ឬវិនិយោគទុនជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងសហគមន៍មូលដ្ឋាន។ ពួកគេជាអ្នកបង្កើតការងារដល់ប្រជាពលរដ្ឋឱ្យមានការងារធ្វើ និងចូលរួមចំណែកជួយធ្វើឱ្យប្រសើរឡើងនូវសេដ្ឋកិច្ចនៅថ្នាក់មូលដ្ឋាន។ |
| **សមាគមយុវជន** | ជាង ៤០% នៃប្រជាជនកម្ពុជាមានអាយុតិចជាង១៥ឆ្នាំ។ ដូច្នេះបញ្ហាដែលប៉ះពាល់ដល់យុវជន គឺជាបញ្ហាចំបងដែលត្រូវយកចិត្តទុកដាក់។ សមាគមយុវជនជាវេទិកាដ៏ប្រសើរបំផុតក្នុងការកៀរគរការចូលរួមពីសមាជិកជាយុវជននៅក្នុងសហគមន៍។ |
| **ក្រុមស្ត្រី** | ស្ត្រីមិនសូវមានតំណាងរបស់ខ្លួននៅគ្រប់ជាន់ថ្នាក់ ក្នុងជួររដ្ឋាភិបាលនៅកម្ពុជា ប៉ុន្តែតួនាទី និងសម្លេងរបស់ស្ត្រីនៅក្នុងសង្គម គឺមានសារៈសំខាន់ណាស់។ ក្រុមស្ត្រីអាចធ្វើឱ្យក្រុមប្រឹក្សាឃុំ សង្កាត់លើកទឹកចិត្តនិងគាំទ្រការចូលរួមរបស់ស្ត្រីលើការផ្តួចផ្តើមគំនិតផ្សេងៗនៅមូលដ្ឋាន ។ |
| **សមាគមកម្មករ** | មានដូចជាសមាគមកសិករ ក្រុមអាជីវករ សមាគមម៉ូតូឌុប សមាគមអ្នកជិះរ៉ឺរកៅស៊ូ។ល។ អាចផ្តល់នូវព័ត៌មានសំខាន់ៗឬជួយគាំទ្រនិងការអប់រំដល់សហគមន៍។ |

## ៦. សកម្មភាពនៃភាពជាដៃគូ

មានសកម្មភាពជាច្រើនដែលក្រុមប្រឹក្សាអាចធ្វើការជាមួយដៃគូពាក់ពន្ធ័នានា ដើម្បីសម្រេចគោលដៅដូចជា:

- **សកម្មភាពអភិវឌ្ឍ:** សកម្មភាពសំខាន់ៗរបស់ក្រុមប្រឹក្សា គឺរៀបចំគម្រោងអភិវឌ្ឍដោយប្រើប្រាស់មូលនិធិឃុំ សង្កាត់ ។គម្រោងអភិវឌ្ឍទាំងនោះរួមមាន ការកសាងហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវ ប្រពន្ធ័ស្រោចស្រព ឬបណ្តាញអគ្គីសនី ។ល ។ ការបណ្តុះបណ្តាលពង្រឹងបច្ចេកទេសកសិកម្ម ការការពារបរិស្ថាន និងគម្រោងផែនការជួសជុលផ្លូវលំជាដើម ។ ដៃគូក្រុមប្រឹក្សាឃុំ សង្កាត់មានភារកិច្ចចូលរួមយ៉ាងសកម្មក្នុងសកម្មភាពខាងលើនេះ តាមរយៈការផ្តល់ប្រឹក្សាបច្ចេកទេសនិងជំនួយផ្សេងៗទៀតដូចជា: ការប៉ាន់ប្រមាណតម្រូវការអ្នកភូមិ ការធ្វើផែនការ ការអនុវត្តផែនការ ការត្រួតពិនិត្យ ការរៀបចំគម្រោងថវិកា និងការស្វែងរកថវិកា ។
- **គោលនយោបាយ:** ដៃគូអាចជួយក្រុមប្រឹក្សាក្នុងការអនុម័ត "ដីកា" ឬ "បទបញ្ញត្តិនានា" នៅក្នុងឃុំ សង្កាត់ តាមរយៈការផ្តល់ការអប់រំអំពីច្បាប់និងធ្វើសេចក្តីព្រៀងបទបញ្ញត្តិ ទាំងនោះ ។ ក្រៅពីនេះ ក្រុមប្រឹក្សាអាចផ្តល់នូវគំរូនិងព័ត៌មានផ្សេងៗស្តីពីដីកានានា ដែលបានអនុម័តផងដែរដល់ដៃគូរបស់ខ្លួន ។
- **ការសម្រុះសម្រួល:** ដៃគូអាចជួយសម្រុះសម្រួលជម្លោះក្នុងបញ្ហាមួយចំនួននៅក្នុងមូលដ្ឋានដូចជា៖ ទំនាស់ដីធ្លី អំពើហិង្សាក្នុងគ្រួសារ ទំនាស់កើតមីរតក ឬការសងបំណុលជាដើម ។ ដៃគូអាចផ្តល់ព័ត៌មានដល់ក្រុមប្រឹក្សាឃុំ សង្កាត់ អំពីគោលនយោបាយ និងសកម្មភាពផ្សេងៗដែលផ្តួចផ្តើមឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់ទៅថ្នាក់ភូមិ ។ ដៃគូក៏អាចជួយក្រុមប្រឹក្សាផងដែរតាមរយៈការអប់រំពី របៀបដោះស្រាយជម្លោះដីធ្លីនិង ច្បាប់ឬវិធីសាស្រ្តសម្រុះសម្រួលដើម្បីឱ្យពួកគាត់អាចផ្តល់ប្រឹក្សាល្អៗ ដល់អ្នកភូមិក៏ដូចជាការតាមដានដំណើរការរីកចំរើននានាផងដែរ ។
- **ការតស៊ូមតិ:** ការតស៊ូមតិ គឺជាបណ្តុំសកម្មភាពមួយចំនួនដែលធ្វើឡើងដើម្បី បញ្ចុះបញ្ចូល ឬជំរុញអ្នកដែលមានអំណាចផ្នែកសេដ្ឋកិច្ច នយោបាយ និងរដ្ឋាភិបាល ធ្វើការផ្លាស់ប្តូរការសម្រេចចិត្ត ឬទទួលយកទៅអនុវត្តនូវតាមគោលនយោបាយសាធារណៈ ដែលផ្តល់ផលប្រយោជន៏ទៅដល់អ្នកក្រីក្រ និងអ្នកនយោបាយដែលមិនសូវមានអំណាច ។ បញ្ហាទូទៅដែលក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើការតស៊ូមតិរួមមាន បញ្ហាទាក់ទងនិងអំពើពុករលួយ ជម្លោះដីធ្លី ការគ្រប់គ្រងព្រៃឈើ អនាម័យទីផ្សារ ត្រួតពិនិត្យ និងថែទាំផ្លូវការទប់ស្កាត់ការកើតឡើងនូវជម្លោះក្នុងចំណោមយុវជននិងការចាត់វិធានការទប់ស្កាត់បទល្មើសនេសាទ ។
- **សេវាសាធារណៈ:** ដៃគូដែលជាផ្នែកឯកជន អាចជួយក្រុមប្រឹក្សាក្នុងការផ្តល់សេវាសាធារណៈដូចជាអគ្គីសនី ទឹកស្អាត និងការគ្រប់គ្រងកាកសំណល់ ។ ដៃគូក៏អាចផ្តល់ផងដែរនូវគំរូនៃគម្រោងសេវាកម្មសាធារណៈដែលទទួលជោគជ័យដល់ក្រុមប្រឹក្សាឃុំសង្កាត់ឬក៏បង្ហាញពីសម្ភារៈដែលត្រូវការដើម្បីផ្តួចផ្តើម និងបង្កើតសេវាកម្មថ្មី ។

## ៧. ការកសាងភាពជាដៃគូ

នៅក្នុងផ្នែកនេះយើងនឹងបង្ហាញជូនពីជំហាននានា ដែលលោកអ្នកអាចយកទៅប្រើប្រាស់ បានក្នុងការកសាងភាពជាដៃគូឱ្យបានជោគជ័យ ។

| | | | |
|---|---|---|---|
| **ជំហានទី ១** | ហេតុអ្វីត្រូវមានភាពជាដៃគូ? | **ជំហានទី ៧** | កំណត់គោលដៅ |
| **ជំហានទី ២** | ប្រភេទនៃភាពជាដៃគូ | **ជំហានទី ៨** | ការធ្វើផែនការសកម្មភាព |
| **ជំហានទី ៣** | ការជ្រើសរើសដៃគូ | **ជំហានទី ៩** | ការកៀរគរធនធាន |
| **ជំហានទី ៤** | ការជ្រើសរើសក្រុមការងារ | **ជំហានទី ១០** | អនុវត្តសកម្មភាព |
| **ជំហានទី ៥** | ចែករំលែកការរំពឹងទុក | **ជំហានទី ១១** | ការវាយតម្លៃ |
| **ជំហានទី ៦** | ការព្រមព្រៀងលើគោលការណ៍ | | |

## ជំហានទី១ ហេតុអ្វីត្រូវមានភាពជាដៃគូ?

ការសម្រេចចិត្តជាដំបូងរបស់ក្រុមប្រឹក្សាគឺត្រូវសម្រេចចិត្តថា ហេតុអ្វីបានជាចាប់អារម្មណ៍ក្នុងការមានភាពជាដៃគូ? ក្រុមប្រឹក្សាត្រូវគិតពិចារណាលើចំណុចដូចជា៖

- តើយើងចង់បានដៃគូដោយសារតែយើងខ្វះខាតធនធានឬ ?
- តើយើងចង់បានដៃគូដោយសារតែយើងចង់បង្កើនការចូលរួមពីសាធារណៈឱ្យបានច្រើនឬ?
- តើយើងចង់បានដៃគូដោយសារតែយើងខ្វះខាតជំនាញឬ ?
- តើភាពជាដៃគូនិងផ្តល់ប្រយោជន៍ដល់សហគមន៍មូលដ្ឋានដែរឬទេ ?
- តើមានជំរើសអ្វីផ្សេងទៀតទេ ចំពោះភាពជាដៃគូ?
- អ្វីជាផលប្រយោជន៍នៃភាពជាដៃគូ ?
- អ្វីជាផលអាក្រក់នៃភាពជាដៃគូ ?
- តើក្រុមប្រឹក្សានឹងមានផលលំបាកអ្វីខ្លះ បើសិនជាភាពជាដៃគូមិនទទួលបានជោគជ័យ ។

> វាជាការសំខាន់ផងដែរដើម្បីជជែកពិភាក្សាជាមួយសហគមន៍នូវមូលហេតុផ្សេងៗទៀតថាតើហេតុអ្វីបានជាក្រុមប្រឹក្សាចង់បង្កើតភាពជាដៃគូ និងពន្យល់អំពីអ្វីជាផលប្រយោជន៍ឬការលំបាកដែលអាចកើតមាន ។

## ជំហានទី ២ ប្រភេទនៃភាពជាដៃគូ

សកម្មភាពសំខាន់បន្ទាប់ គឺការសម្រេចចិត្តឱ្យបានច្បាស់ថា តើដៃគូប្រភេទណាដែលក្រុមប្រឹក្សាកំពង់ត្រូវការ ។ មានមធ្យោបាយជាច្រើនសម្រាប់ក្រុមប្រឹក្សាអាចធ្វើការជាមួយដៃគូ៖

> **ការសម្របសម្រួល** : ការសម្របសម្រួលកើតឡើងនៅពេលណាដែលក្រុមប្រឹក្សា និងដៃគូរបស់ខ្លួនធ្វើការដោយឡែកពីគ្នា ប៉ុន្តែចាំបាច់ត្រូវការសម្របសម្រួលសកម្មភាព ដើម្បីជៀសវាងការធ្វើការត្រួតគ្នា ។ នៅពេលដែលក្រុមប្រឹក្សាមួយធ្វើការសម្របសម្រួល សកម្មភាពចាំបាច់មួយដៃគូដែលមានគោលដៅដូចគ្នា គឺអាចចែករំលែកធនធានទៅឱ្យគ្នាទៅវិញទៅមក ធ្វើការប្រើប្រាស់នូវ ធនធានដែលមានតិចតួចកាន់តែប្រសើរឡើងនិងសហគមន៍មូលដ្ឋានទទួលបានផលប្រយោជន៍កាន់តែប្រសើរឡើង ។

**ការពិគ្រោះយោបល់** : ដៃគូប្រភេទនេះច្រើនតែ ប្រព្រឹត្តទៅតាមរយៈការសួរជាសំនួរ ស្តាប់ការបកស្រាយ និងសិក្សាពីប្រជាពលរដ្ឋរស់នៅក្នុង និងអ្នកនៅក្រៅឃុំ សង្កាត់ ការពិគ្រោះយោបល់កើតឡើងនៅពេលក្រុមប្រឹក្សាត្រូវការព័ត៌មាន ជំនាញ បច្ចេកទេស ចំណេះដឹង បទពិសោធន៍គំនិត និងយោបល់នានា ដើម្បីយកមកធ្វើការសម្រេចចិត្តលើអ្វីមួយ ។ ដៃគូអាចជួយដល់ក្រុមប្រឹក្សាឃុំសង្កាត់បានច្រើនក្នុងការធ្វើការសម្រេចចិត្តឱ្យបានល្អប្រសើរ ដែលផ្តល់ផលប្រយោជន៍ដល់សហគមន៍ ។

**កិច្ចសហការ:** កិច្ចសហការកើតឡើងនៅពេលក្រុមប្រឹក្សាឃុំ សង្កាត់ និងដៃគូរបស់ខ្លួនធ្វើការរួមគ្នាដើម្បីសម្រេចគោលដៅរួម ។កិច្ចសហការអាចជោគជ័យបាននៅពេលដៃគូទាំងអស់ធ្វើការយ៉ាងជិតស្និតជាមួយគ្នាដែលកិច្ចសហការនេះ និងផ្តល់មកវិញនូវផលចំណេញយ៉ាងច្រើន ។ ដើម្បីសម្រេចបានជោគជ័យនូវកិច្ចសហការក្នុងភាពជាដៃគូប្រភេទនេះគឺត្រូវរួមបញ្ចូលទាំងការពិគ្រោះយោបល់ ។

## ជំហានទី ៣ ការជ្រើសរើសដៃគូ

ការជ្រើសរើសដៃគូគួរតែធ្វើឡើងដោយមានការចូលរួមពីសមាជិកពាក់ពន្ធ័ទាំងអស់នៃក្រុមប្រឹក្សា និងក្រុមផ្សេងៗទៀតដែលចាប់អារម្មណ៍លើគម្រោង ។ មុននិងក្រុមប្រឹក្សាជ្រើសរើសដៃគូណាមួយមកធ្វើការជាមួយនោះជាដំបូងត្រូវកំណត់នូវតម្រូវការរបស់ខ្លួនឱ្យបានច្បាស់លាស់ជាមុនសិន និងស្វែងយល់ថាតើដៃគូនោះអាចជួយបំពេញនូវតម្រូវការដែលបានរកឃើញនោះដែរឬទេ? ។ ការជ្រើសរើសនេះក្រុមប្រឹក្សាឃុំសង្កាត់ត្រូវគិតអំពី:

### ✍ អ្នកណាខ្លះអាចជាដៃគូ?

- *ជាការល្អត្រូវរៀបចំបញ្ជីឈ្មោះដៃគូទាំងនោះព្រោះជួនកាលមានតែអង្គការ មួយគត់នៅក្នុងបញ្ជីហើយជួនកាលមានអង្គការច្រើន ។*

### ✍ តើដៃគូដែលសមស្របមានលក្ខណៈដូចម្តេចខ្លះ ?

- ✓ តើចំណេះដឹងនិងបទពិសោធន៍របស់គេជាអ្វីខ្លះ?
- ✓ តើដៃគូមានទីតាំងនៅកន្លែងណា?
- ✓ តើដៃគូអាចចាប់ផ្តើមបាននៅពេលណា?
- ✓ តើដៃគូយល់ដឹងពីបញ្ហានានានៅក្នុងតំបន់អ្នកដែរឬទេ?
- ✓ តើដៃគូធ្លាប់អនុវត្តគម្រោងស្រដៀងគ្នានេះពីមុនដែរឬទេ?
- ✓ តើយើងត្រូវចំណាយថវិកាប៉ុន្មានដើម្បីធ្វើការជាមួយដៃគូ?

### ✍ បើធ្វើការជាមួយដៃគូទាំងនោះ តើអាចទទួលបានផលប្រយោជន៍អ្វីខ្លះ ?

- ផលប្រយោជន៍ពីដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាល គឺខុសគ្នាពីផលប្រយោជន៍ដែលបានមកពីសមាគមមូលដ្ឋាន

**ជំហានទី៤ ការជ្រើសរើសក្រុមការងារ**

បន្ទាប់ពីក្រុមប្រឹក្សាជ្រើសរើសដៃគូបានមកត្រូវជ្រើសរើសអ្នកធ្វើការក្នុងក្រុមការងារភាពជាដៃគូ មិនមែនចាំបាច់ត្រូវតែឱ្យសមាជិកក្រុមប្រឹក្សាទាំងអស់ធ្វើការក្នុងភាពជាដៃគូនោះទេ ហើយក្រុមការងារនោះក៏មិនគួធំពេកដែរ ។ ក្រុមការងារអាចធ្វើរបាយការណ៍ដល់សមាជិកក្រុមប្រឹក្សាផ្សេងទៀត ។ វាជារឿងសំខាន់ណាស់ដែលត្រូវជ្រើសរើសមនុស្សដែលមានជំនាញ និងសមត្ថភាពត្រឹមត្រូវ ហើយអ្នកទាំងនោះគួតែ៖

| **ការប្តេជ្ញាចិត្ត** | **ជំនាញ** | **ពេលវេលា** |
|---|---|---|
| មានការប្តេជ្ញាចិត្ត ដើម្បីជោគជ័យ | មានជំនាញពិតប្រាកដ ដែលអាចជួយដល់ដៃគូ | មានពេលវេលាគ្រប់គ្រាន់ សម្រាប់ធ្វើការ |

**ជំហានទី៥ ចែករំលែកការរំពឹងទុក**

ឥឡូវនេះជាពេលដែលត្រូវចាប់ផ្តើមកសាងភាពជាដៃគូ ហើយនេះជាជំហានដំបូងដែលអ្នកត្រូវធ្វើសេចក្តីសម្រេចចិត្តជាមួយដៃគូរបស់អ្នក ។ សកម្មភាពដំបូងយើងត្រូវធ្វើការប្រជុំគ្នាជាមួយដៃគូរបស់អ្នក ដើម្បីពិភាក្សាជាដៃគូ ។ នៅពេលដែលភាគីទាំងពីរបានយល់ព្រមគ្នា អ្នកអាចចាប់ផ្តើមចែករំលែកនូវការរំពឹងទុកអំពីភាពជាដៃគូ ។ ដំណាក់កាលនេះសំខាន់ណាស់ព្រោះថា អ្នកត្រូវគិតឱ្យបានច្បាស់លាស់ពីក្តីសង្ឃឹម ដែលអ្នករំពឹងថា និងទទួលបានពីដៃគូរបស់អ្នក តើអ្នកសង្ឃឹមថាបានអ្វី? អ្នកក៏ត្រូវស្តាប់ការរំពឹងទុកពីដៃគូរបស់អ្នកវិញដែរ ។ តាមរយៈការបង្ហាញពីទស្សនៈឱ្យគ្នាទៅវិញទៅមកនេះ លោកអ្នក អាចនឹងកំណត់បាននូវសេចក្តីរំពឹងទុកនានាដែលអ្នកនិងដៃគូរបស់អ្នកចង់បានរួមគ្នា ។

**ជំហានទី ៦ ការព្រមព្រៀងលើគោលការណ៍**

ជំហាននេះគឺ ការព្រមព្រៀងលើគោលការណ៍នានាដែលណែនាំពីភាពជាដៃគូរបស់លោកអ្នក រួមទាំងការកំណត់រកល័ក្ខខ័ណ្ឌរួមសម្រាប់ដៃគូ ។ អ្នកគួពិចារណាលើគោលការណ៍មួយចំនួនដូចជា៖

→ ការគោរពគ្នាទៅវិញទៅមកគ្រប់ពេលវេលា

→ មានភាពស្មោះត្រង់

→ សម្របសម្រួលគ្នានៅពេលចាំបាច់

→ រីករាយនិងទទួលយកនូវគំនិតយោបល់ពីគ្នាទៅវិញទៅមក

→ មានការចូលរួមពីគ្នាទៅវិញទៅមក

**ជាឧទាហរណ៍:** បើអ្នកយល់ព្រមថា ជួបគ្នានៅពេលណាមួយ ថ្ងៃណាមួយជាក់លាក់ អ្នកត្រូវតែចូលរួមតាមការព្រមព្រៀងនោះ។ មានន័យថាអ្នកត្រៀមខ្លួនជាស្រេច ដើម្បីចូលរួមក្នុងការប្រជុំនោះ ឬអាចជាសកម្មភាពផ្សេងទៀតដែលអ្នករៀបចំជាមួយដៃគូរបស់អ្នក។

**ជំហានទី ៧ កំណត់គោលដៅ**

ការកំនត់គោលដៅសម្រាប់ភាពជាដៃគូ គឺជាសកម្មភាពសំខាន់បំផុតក្នុងការកសាងភាពជាដៃគូ។ នេះជាការព្រមព្រៀងដែលភាពជាដៃគូត្រូវសម្រេចបាន។ ពេលដែលលោកអ្នកពិភាក្សាជាមួយដៃគូពីគោលដៅរួម លោកអ្នកនឹងអាចឃើញថា គោលដៅនោះអាចទូលំទូលាយពេក ឬអាចមានមហិច្ឆតាពេក ។ ដូច្នេះមុននឹងលោកអ្នកយល់ព្រមជាចុងក្រោយជាមួយដៃគូ លោកអ្នកត្រូវប្រាកដក្នុងចិត្តថាគោលដៅនោះច្បាស់លាស់និងអាចសម្រេចជោគជ័យបាន។

ឧទាហរណ៍: មួយចំនួនដែលបង្ហាញពីគោលដៅនៃភាពជាដៃគូរវាងក្រុមប្រឹក្សា និងសង្គមស៊ីវិល។

- ប៉ាន់ប្រមាណពីតម្រូវការនៅក្នុងភូមិ ដែលមានការចូលរួមសម្រាប់សកម្មភាពទៅអនាគតរបស់ក្រុមប្រឹក្សាឃុំសង្កាត់។
- ចែករំលែកព័តិមានពីគម្រោង និងកម្មវិធីអភិវឌ្ឍឃុំ សង្កាត់
- សហការលើគម្រោង និងកម្មវិធីអភិវឌ្ឍជាក់លាក់ណាមួយ
- កសាងសមត្ថភាពក្រុមប្រឹក្សា
- ការបែងចែកយ៉ាងទូលំទូលាយពីព័តិមាន និងការសម្រេចចិត្តរបស់ក្រុមប្រឹក្សា
- ការរៀបចំ និងការបង្កើនការចូលរួមឱ្យបានច្រើននៅក្នុងវេទិកាសាធារណៈ
- កំណត់រក និងដោះស្រាយបញ្ហាសង្គម និងសណ្តាប់ធ្នាប់សាធារណៈសំខាន់ៗក្នុងឃុំ សង្កាត់
- ចាត់ចែងឱ្យមានការចូលរួមពីស្ត្រី និងជនជាតិភាគតិចក្នុងសកម្មភាពឃុំ សង្កាត់
- ពង្រឹងតម្លាភាព និងគណនេយ្យភាពនៃសកម្មភាពរបស់ក្រុមប្រឹក្សា
- ត្រួតពិនិត្យការអនុវត្តរបស់ក្រុមប្រឹក្សាដែលជំរុញដល់ការរីកចំរើនក្នុងការងារឃុំ សង្កាត់
- ត្រួតពិនិត្យកិច្ចសន្យារវាងក្រុមប្រឹក្សា និងផ្នែកឯកជន និងគម្រោងកសាងហេដ្ឋារចនាសម្ព័ន្ធ

**ជំហានទី ៨ ការធ្វើផែនការសកម្មភាព**

ពេលដែលដៃគូព្រមព្រៀងលើអ្វីដែលត្រូវធ្វើរួមគ្នាហើយនោះ ជំហានបន្ទាប់ទៀតគឺការសម្រេចចិត្ត ថាតើគេត្រូវធ្វើកិច្ចការនោះដោយរបៀបណា?

ផែនការសកម្មភាពគួតែរៀបចំជាមួយគ្នា និងបង្ហាញពីគោលដៅនៃភាពជាដៃគូ ថា តើគោលដៅនោះសម្រេចបានដោយរបៀបណា នៅពេលណា និងដោយអ្នកណា? ផែនការសកម្មភាពត្រូវមានៈ

- ✓ *គោលដៅច្បាស់លាស់*
- ✓ *បញ្ជីសកម្មភាព ដែលបង្ហាញពីកិច្ចការដែលត្រូវអនុវត្តដើម្បីសម្រេចគោលដៅ*
- ✓ *អ្នកទទួលខុសត្រូវ និងដឹកនាំសកម្មភាពទាំងនោះ*
- ✓ *ដំណាក់កាលអនុវត្តលើសកម្មភាពនីមួយៗ*
- ✓ *តារាងពេលវេលាសម្រាប់សកម្មភាពនីមួយៗ ថាត្រូវចាប់ផ្តើមនៅពេលណាហើយ បញ្ចប់នៅពេលណា?*
- ✓ *ធនធានដែលត្រូវការសម្រាប់សកម្មភាពនីមួយៗ និងអ្នកដែលជួយផ្គត់ផ្គង់ធនធានទាំងនោះ*
- ✓ *មធ្យោបាយវាស់វែងដើម្បីឱ្យដឹងថាយើងសម្រេចបានដល់គោលដៅដែរឬទេ ?*

## ជំហានទី ៩ ការគៀរគរធនធាន

ជំហានចុងក្រោយមុននិងចាប់ផ្តើមអនុវត្តការងារ គឺការកៀរគរធនធាន ។ ពេលដែលអ្នកបានបញ្ចប់ផែនការសកម្មភាពរបស់អ្នក អ្នកនឹងដឹងថា ធនធានអ្វីខ្លះដែលត្រូវការជាចាំបាច់ដើម្បីធ្វើឱ្យគោលដៅរបស់អ្នកអាចសម្រេចបាន។

ធនធានចាំបាច់សម្រាប់ភាពជាដៃគូអាស្រ័យទៅលើប្រភេទដៃគូដែលអ្នកបានបង្កើតឡើង និងសកម្មភាពនានាដែលបានដាក់បញ្ចូលពេលធ្វើផែនការជាមួយដៃគូរបស់អ្នក។ ជួនកាលធនធានហិរញ្ញវត្ថុ និងសម្ភារៈត្រូវការជាចាំបាច់ហើយជួនកាលទៀតសកម្មភាពនោះត្រូវការតែពេលវេលា និងកិច្ចខិតខំប្រឹងប្រែង ឬធនធានបរិច្ចាគ ឬត្រូវការចូលរួមដោយអ្នកស្ម័គ្រចិត្តពីសមាជិកសហគមន៍តែប៉ុណ្ណោះ ។

ជាការសំខាន់ណាស់ ដែលអ្នកត្រូវពិភាក្សាពីធនធានដែលត្រូវការជាមួយដៃគូមុននឹងអនុវត្តសកម្មភាព។ លោកអ្នកត្រូវដឹងពីធនធានដែលអ្នកនឹងផ្តល់ទៅឱ្យដៃគូហើយ និងធនធានដែលដៃគូ និងផ្តល់ឱ្យអ្នកវិញ ដើម្បីជៀសវាងកុំឱ្យមានជម្លោះ និងការយល់ច្រឡំគ្នាទៅថ្ងៃក្រោយ ។

### ធនធានដែលត្រូវការសម្រាប់សកម្មភាពខុសៗគ្នារួមមានៈ

- ✍ ពេលវេលាធ្វើការលើគម្រោង
- ✍ កិច្ចខំប្រឹងប្រែងដើម្បីបញ្ចប់គម្រោង
- ✍ សម្ភារចាំបាច់សម្រាប់អនុវត្តសកម្មភាព *ឧទាហរណ៍ដូចជា ឥដ្ឋសម្រាប់សាងសងបន្ទប់ថ្មីមួយជាដើម*
- ✍ មធ្យោបាយធ្វើដំណើរ និងដឹកជញ្ជូនសម្ភារៈ
- ✍ ការចំណាយផ្នែករដ្ឋបាល *ដូចជាសម្ភារៈការិយាល័យ ថតចម្លងនិងបោះ ពុម្ពឯកសារ*
- ✍ ម្ហូបអាហារនិងការស្នាក់អាស្រ័យ
  ពិសេសនៅពេលដែលសកម្មភាពរបស់អ្នកត្រូវអនុវត្តនៅឆ្ងាយពីផ្ទះ

- ថវិកាសម្រាប់ទិញធនធាននានាដែលមិនអាចទទួលបានពីការបរិច្ចាគ

## ជំហានទី ១០ អនុវត្តសកម្មភាព

បន្ទាប់ពីមានការព្រមព្រៀងជាមួយដៃគូអ្នកលើគោលដៅ និងរបៀបដែលអាចសម្រេចជោគជ័យបានរួចមក អ្នកអាចចាប់ផ្តើមអនុវត្តសកម្មភាពបានហើយ ។ ដើម្បីសម្រេចគោលដៅដែលបានព្រមព្រៀងគ្នានោះ ផែនការសកម្មភាពរបស់លោកអ្នកគួមានលក្ខណៈដូចខាងក្រោមនេះ៖

- **ប្តេជ្ញាអនុវត្ត** : ប្តេជ្ញាអនុវត្តផែនការសកម្មភាពរបស់លោកអ្នកឱ្យបានចប់ចុងចប់ដើម ។
- **ផ្តោតលើការទទួលខុសត្រូវ** : គ្រប់អ្នកពាក់ព័ន្ធក្នុងផែនការសកម្មភាពត្រូវបំពេញតួនាទី និងការទទួលខុសត្រូវក្នុងភាពជាដៃគូ ។
- **ទំនាក់ទំនង** : ចាប់តាំងពីពេលចាប់ផ្តើមអនុវត្តផែនការសកម្មភាព ការទំនាក់ទំនងត្រូវធ្វើឱ្យបានញឹកញាប់ជាមួយដៃគូរបស់ខ្លួន ព្រោះថាការទំនាក់ទំនងស្អិតរមួតនេះនិងអាចដោះស្រាយបញ្ហា និងជំរុញឱ្យមានការពង្រឹងការប្តេជ្ញាចិត្តចំពោះភាពជាដៃគូផ្សេងទៀតផង ។
- **មិនត្រូវព្រងើយកន្តើយ ឬ គេចវេសចំពោះជម្លោះដែលកើតឡើង** : ការមិនឯកភាពគ្នាក៏អាចកើតមានដែរ ទោះបីជាភាពជាដៃគូមានភាពរឹងមាំបំផុតក៏ដោយ ។ ជាការសំខាន់ ណាស់នៅពេលដែលមានបញ្ហាខ្វែងគំនិតគ្នា ឬមានជម្លោះអ្វីកើតឡើងជាមួយដៃគូបញ្ហានោះត្រូវបានយកមកពិភាក្សា និងដោះស្រាយឱ្យបានឆាប់រហ័ស បើពុំនោះទេវារិតតែរីកធំឡើងៗ ហើយនឹងអាចធ្វើឱ្យមានការពិបាកក្នុងការដោះស្រាយ ។

## ជំហានទី ១១ ការវាយតម្លៃ

គ្រប់សកម្មភាពនៃភាពជាដៃគូត្រូវធ្វើការត្រួតពិនិត្យ និងវាយតម្លៃ ។ ធ្វើដូច្នេះយើងអាចរៀនសូត្រនូវអ្វីដែលយើងធ្វើទៅបានល្អ និងអ្វីដែលត្រូវកែតម្រូវ ។ ការរៀនសូត្រទាំងនោះមានប្រយោជន៍ដល់ការធ្វើផែនការ និងការអនុវត្តផែនការបានល្អនាពេលអនាគត ។

- **ការត្រួតពិនិត្យ** : ការប្រមូលព័ត៌មានដើម្បីវាស់វែងពីភាពជោគជ័យនៃសកម្មភាពការងារនោះហៅថា "ការត្រួតពិនិត្យ" ។ ព័ត៌មានដែលយើងត្រូវប្រមូលនោះគួមាននៅក្នុងផែនការសកម្មភាព ប្រសិនបើយើងធ្វើការត្រួតពិនិត្យជាទៀងទាត់អាចឱ្យយើងដឹងថា តើសកម្មភាពទាំងនោះអាចជួយយើងឱ្យសម្រេចគោលដៅរបស់យើងដែរឬទេ? ។ ការត្រួតពិនិត្យអាចជួយឱ្យក្រុមប្រឹក្សាមានគណនេយ្យភាពលើការធ្វើអ្វីដែលបាននិយាយ និងអ្វីដែលត្រូវសម្រេចបាន ។ ប្រសិនបើយើងកំពង់អនុវត្តកម្មវិធីមួយដែលកម្មវិធីនោះមានគោលបណងបង្កើនការចូលរួមរបស់ស្ត្រីក្នុងរដ្ឋបាលមូលដ្ឋាន ពេលនោះយើងពិនិត្យលើចំនួនស្ត្រីដែលចូលរួមក្នុងអង្គប្រជុំនានារបស់ក្រុមប្រឹក្សា ។ ម្យ៉ាងវិញទៀត បើភាពជាដៃគូ

របស់យើងទាក់ទងដល់ការនេសាទខុសច្បាប់ យើងអាចត្រួតពិនិត្យលើចំនួនជនល្មើសដែលត្រូវបានចាប់ខ្លួននិងឧបករណ៍ល្មើសច្បាប់ដែលរឹបអូសបានមក ឬថាតើសមាជិកសហគមន៍បានចូលរួមនៅក្នុងកិច្ចប្រជុំពិភាក្សាពីបញ្ហា ដែលបានចែងក្នុងផែនការដែរឬទេ?

- **ការវាយតម្លៃ** : ក្រុមប្រឹក្សាគួតែវិភាគព័ត៌មាន ដែលបានប្រមូលក្នុងដំណើរការត្រួតពិនិត្យនៅ ក្នុងពេលណាមួយនៃការធ្វើការក្នុងភាពជាដៃគូ ។ ការវិភាគនេះហៅថា “ការវាយតម្លៃ” ។ ការ វាយតម្លៃអាចជួយឱ្យក្រុមប្រឹក្សារៀនសូត្រអំពីសកម្មភាពណាដែលធ្វើបានល្អ ហើយសកម្មភាពណាដែលត្រូវធ្វើការកែតម្រូវ ។ យើងគួរពិនិត្យមើលថាយើងប្រើប្រាស់ធនធានរបស់យើងមានប្រសិទ្ធភាពកំរិតណាហើយបានសម្រេចអ្វីខ្លះ? ក្រុមប្រឹក្សាគួរវាយតម្លៃសកម្មភាពការងារនៅក្នុងអំឡុងពេលដំណើរការភាពជាដៃគូដើម្បីសម្រេចថាតើត្រូវផ្លាស់ប្តូរផែនការសកម្មភាពដែរឬទេ? ប្រសិនបើសកម្មភាពណាមួយមិនដំណើរការនោះអ្នកគួតែធ្វើការផ្លាស់ប្តូរ ។ ក្រុមប្រឹក្សាអាចធ្វើការវាយតម្លៃសកម្មភាពការងារនៅពេលដែលគម្រោងបានបញ្ចប់សព្វគ្រប់ ។ ការវាយតម្លៃចុងក្រោយនេះអាចជួយដល់ក្រុមប្រឹក្សាក្នុងការធ្វើផែនការសកម្មភាពបន្ទាប់ទៀត ប្រសិនបើគោលដៅមិនបានសម្រេចដូចការគ្រោងទុក ។ បទពិសោធន៍ ដែលបានមកពីការវាយតម្លៃនេះនឹងជួយដល់ការកែលម្អគម្រោង និងភាពជាដៃគូទៅអនាគត ។

## ៨. សេចក្តីសន្និដ្ឋាន

ភាពជាដៃគូមានសារះសំខាន់ណាស់ក្នុងការធ្វើឱ្យរដ្ឋបាលមូលដ្ឋានទទួលបានជោគជ័យ និងជួយដល់ការអភិវឌ្ឍមូលដ្ឋាន ។ ដោយហេតុថា ក្រុមប្រឹក្សា នៅកម្ពុជាមិនទាន់មានជំនាញ និងធនធានគ្រប់គ្រាន់សម្រាប់អនុវត្តការងារតែឯកឯងបាន ទើបការបង្កើតភាពជាដៃគូជាមួយអង្គការនានា និងសហគមន៍មូលដ្ឋានអាចធ្វើឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាចទទួលបាននូវធនធានច្រើនបង្កើនភាពជាដៃគូ ធ្វើឱ្យប្រសើរឡើងនូវសេវាសាធារណៈ ទទួលបានអភិបាលកិច្ចល្អ មានការសម្របសម្រួលសកម្មភាពល្អប្រសើរ និងធ្វើឱ្យការអនុវត្តគម្រោងអាចបញ្ចប់បានឆាប់រហ័ស ។

--- ចប់ ---